# មាតិកា

## ជំពូក១៖ ស្ថានភាពរួម


១- សេចក្តីសង្ខេប ៖ ........ 1

២- សេចក្តីផ្តើម ........ 4

៣- គោលដៅ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ........ 5

៣.១-យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល (Rectangular Strategy) ........ 5

៣.២- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០០៩-២០១៣ ........ 6

៣.៣- ផែនការសកម្មភាព សម្រាប់អនុវត្តគោលនយោបាយ ជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករ ........ 7

៣.៤- យុទ្ធសាស្ត្រសម្រាប់វិស័យកសិកម្ម និងទឹក ........ 9

៤- កសិកម្មក្នុងកំណើនសេដ្ឋកិច្ចជាតិ ........ 10

៤.១-វិស័យកសិកម្មក្នុងការកាត់បន្ថយភាពក្រីក្រ ........ 10

៤.២-កំណើនផលិតផលកសិកម្មឆ្នាំ ២០១១២ ........ 11

៤.៣-ការវិវឌ្ឍនៃផលិតកម្មកសិកម្មរយៈពេល ៥ឆ្នាំ ........ 14


## ជំពូក២៖ លទ្ធផលនិងទិសដៅ


៥-លទ្ធផលឆ្នាំ២០១២-២០១៣និងទិសដៅឆ្នាំ២០១៣-២០១៤ ........ 26

៥.១-ផលិតកម្មដំណាំស្រូវនិងដំណាំផ្សេងៗ (ឧបសម្ព័ន្ធទី១-៨) ........ 26

៥.២. ការងារកសិកម្ម ........ 27

៥.២.១. លទ្ធផល ........ 27

៥.២.២. វាយតម្លៃនិងសន្និដ្ឋាន ........ 33

៥.២.៣. វិធានការ ........ 33

៥.៣- ការងារស្រាវជ្រាវបច្ចេកទេសកសិកម្ម ........ 34

៥.៣-១. លទ្ធផល ........ 34

៥.៣-២. វាយតម្លៃនិងសំណើ ........ 38

៥.៣-៣. វិធានការ ........ 38

៥.៤-ផលិតកម្មនិងបសុព្យាបាល (ឧបសម្ព័ន្ធទី៩-១១) ........ 39

៥.៤.១-លទ្ធផល ........ 39

៥.៤.២-វាយតម្លៃនិងសន្និដ្ឋាន ........ 52

៥.៤.៣-វិធានការ ........ 53

៥.៥- ផលិតផលដំណាំកៅស៊ូ (ឧបសម្ព័ន្ធទី១២-១៣) ........ 53

៥.៥.១-លទ្ធផល ........ 53

៥.៥.២- វាយតម្លៃនិងសន្និដ្ឋាន 56
៥.៥.៣-វិធានការ 56
៥.៦- លទ្ធផលការងារក្រុកម្ម 57
៥.៦.១-លទ្ធផល 57
៥.៦.២. វាយតម្លៃនិងសន្និដ្ឋាន 62
៥.៦.៣. វិធានការ 62
៥.៧- ការងារជលផល ( ឧបសម្ព័ន្ធទី ១៤) 63
៥.៧.១- លទ្ធផល 63
៥.៧.២. វាយតម្លៃនិងសន្និដ្ឋាន 65
៥.៧.៣. វិធានការ 66
៥.៨- ការងារសេវាកម្មនិងការគាំទ្រ 66
៥.៨.១-ការងារគោលនយោបាយផែនការនិងវិនិយោគ 66
៥.៨.២-ការងារសហប្រតិបត្តិការអន្តរជាតិ 72
៥.៨.៣-ការងារកិច្ចការរដ្ឋបាល 74
៥.៨.៤-ការងារនីតិកម្មកសិកម្ម 75
៥.៨.៥-ការងារអធិការកិច្ចនិងសវនកម្មផ្ទៃក្នុង 77
៥.៨.៦- ការងារកសិ-ឧស្សាហកម្ម 80
៥.៨.៧- ការងារយេនឌ័រ 80
៥.៩- ធនធានមនុស្សនិងថវិកា 81
៥.៩.១ ការងារបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស 81
៥.៩.២- ការអភិវឌ្ឍន៍ធនធានមនុស្សនៅតាមគ្រឹះស្ថានអប់រំ 83
៥.៩.៣- ការងារគណនេយ្យ-ហិរញ្ញវត្ថុ 90
៥.១០- កម្មវិធី និងគម្រោងជំនួយដោយដៃគូអភិវឌ្ឍន៍ 96

## ជំពូក៣៖ វាយតម្លៃនិងសន្និដ្ឋាន

៦-វាយតម្លៃរួម 105
៧-ទិសដៅរួម 107
៨. ការវាយតម្លៃនិងសន្និដ្ឋាន 114

# ជំពូក ១
# ស្ថានភាពរួម

## ១- សេចក្តីសង្ខេប ៖

ឆ្នាំ២០១២ គឺជាឆ្នាំទី៥ នៃការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ របស់រាជរដ្ឋាភិបាលក្រោមការដឹកនាំប្រកបដោយភាពឈ្លាសវៃ មុតមាំ និងគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។**

មកទល់ពេលនេះ ការងារបង្កបង្កើនផលរដូវវស្សានិងរដូវប្រាំង ត្រូវបានបញ្ចប់ការដាំដុះជាស្ថាពរ និងជាការឈានដល់ពេលកំណត់ដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រារព្ធធ្វើសន្និបាតបូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឆ្នាំ២០១២-២០១៣ និងលើកទិសដៅសម្រាប់អនុវត្តឆ្នាំ២០១៣-២០១៤ ដើម្បីឆ្លុះបញ្ចាំងឱ្យឃើញអំពីសមិទ្ធផលដែលសម្រេចបានជាវិជ្ជមាន ក៏ដូចជាការប្រមូលផ្តុំនូវមតិយោបល់ ទស្សនៈទៅលើបញ្ហាប្រឈមទាំងឡាយ និងការវិភាគចែករំលែកលើបទពិសោធន៍ល្អៗ ជាពិសេសការផ្តល់អនុសាសន៍គន្លឹះដ៏មានតម្លៃរបស់**សម្តេចនាយករដ្ឋមន្ត្រី** ដើម្បីជាត្រីវិស័យក្នុងការរៀបចំជាចក្ខុវិស័យ ជាយុទ្ធសាស្ត្រ និងលើកទិសដៅអនុវត្តបន្តនៅឆ្នាំបន្ទាប់ ឱ្យមានលក្ខណៈប្រទាក់ក្រឡាគ្នា ទៅនឹងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ របស់រាជរដ្ឋាភិបាលកម្ពុជា។

នារយៈពេលមួយឆ្នាំកន្លងមកនេះ បើទោះបីជាបានជួបប្រទះនូវរាំងស្ងួតកង្វះខាតទឹកនៅពាក់កណ្តាលរដូវវស្សាបានអូសបន្លាយចាប់ពីចុងខែមិថុនារហូតដល់សប្តាហ៍ទី២នៃខែកញ្ញាឆ្នាំ២០១២ នៅតាមបណ្តាខេត្តមួយចំនួនដូចជា ខេត្តបាត់ដំបង កំពង់ចាម កំពង់ឆ្នាំង កំពង់ស្ពឺ កំពត កណ្តាល ក្រចេះ មណ្ឌលគិរី រាជធានីភ្នំពេញ ព្រៃវែង ពោធិសាត់ សៀមរាប ស្វាយរៀង តាកែវ និងឧត្តរមានជ័យ។ ហើយកង្វះខាតទឹកបានកើតមានម្តងទៀត នៅចុងរដូវវស្សាក្នុងសប្តាហ៍ទី៣នៃខែវិច្ឆិកា នៅស្រុកកោះញែក ខេត្តមណ្ឌលគិរី។ ទន្ទឹមនឹងនោះបណ្តាខេត្តដែលជួបនឹងទឹកភ្លៀងដូចជាខេត្ត បន្ទាយមានជ័យ កំពង់ធំ ព្រះវិហារ ពោធិ៍សាត់ សៀមរាប និងស្វាយរៀង។ ព្រមទាំងភាពស្ថិតនៅក្រោមឥទ្ធិពលបន្សល់ពីវិបត្តហិរញ្ញវត្ថុនិងសេដ្ឋកិច្ចពិភពលោក ដែលនៅមិនទាន់មានភាពប្រាកដប្រជា តែក្រោមការខិតខំប្រឹងប្រែងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមការណែនាំនិងតម្រង់ទិស ក៏ដូចជាវិធានការឆ្លើយតបយ៉ាងមានប្រសិទ្ធភាពរបស់រាជរដ្ឋាភិបាល និងដោយមានការចូលរួមដ៏សកម្មពីគ្រប់ក្រសួងស្ថាប័ន អាជ្ញាធរមូលដ្ឋាន កងកម្លាំងប្រដាប់អាវុធ និងប្រជាកសិករទូទាំងប្រទេស ព្រមទាំងការរួមចំណែកពីដៃគូអភិវឌ្ឍន៍ បានធ្វើឱ្យផលិតកម្មកសិកម្ម នៅតែមានការកើនឡើងគួរឱ្យកត់សម្គាល់។ ជាក់ស្តែងស្រូវរដូវវស្សាឆ្នាំ២០១២នេះ ពិតមែនតែមានភាពមិនប្រក្រតីនៃគ្រោះធម្មជាតិ ក៏ស្ថានភាពផលិតកម្មកសិកម្ម ជារួមមានកម្រិតល្អទូទាំងប្រទេស។ យើងបានដាំដុះស្រូវរដូវវស្សាលើផ្ទៃដីសរុប **២,៥១លានហត** ដែលមានទិន្នផលជាមធ្យមចំនួន **២,៨៧២ត/ហត** ដោយទទួលបរិមាណផលសរុបប្រមាណ ៧,១៤លានតោន និងស្រូវរដូវប្រាំងឆ្នាំ២០១២-២០១៣ លើផ្ទៃដីប្រមាណ**៤៩៦.០០០ហត** ដែលមានទិន្នផលជាមធ្យម**៤,៣៥ត/ហត** ដោយទទួលបានបរិមាណផលសរុបចំនួន **២,១៥៤លាន**តោន។ សរុបទាំងរដូវវស្សានិងរដូវប្រាំង យើងអនុវត្តបានលើផ្ទៃដីសរុប**៣,០០៧លានហត** ដោយទទួលបរិមាណផលសរុបប្រមាណ **៩,២៩លានតោនស្រូវ** និងទិន្នផលមធ្យមប្រចាំឆ្នាំ **៣,១១៧ត/ហត**។ ដូច្នេះតុល្យភាពស្បៀងនៅសល់ប្រមាណ**៣លានតោនអង្ករ** គិតជាស្រូវជាង **៤,៧លានតោន** លើសឆ្នាំមុន ៣៩១.០០០តោនស្រូវ និងខ្ពស់ជាងមធ្យមភាគ១០ឆ្នាំកន្លងមកប្រមាណ១,២លានតោនអង្ករ ដែលនេះជាជោគជ័យមួយធំណាស់។ ការពិសោធន៍ស្រាវជ្រាវដំណាំ ការស្វែងរកបច្ចេកទេសសមស្រប ដើម្បីយកទៅផ្សព្វផ្សាយជូនប្រជាកសិករប្រើប្រាស់ក្នុងការធ្វើប្រពលវប្បកម្មដំណាំកំពុងត្រូវបានដំណើរការយ៉ាងផុសផុល ពិសេសការបានអនុវត្តការងារពិសោធន៍ស្រាវជ្រាវលើដំណាំស្រូវយ៉ាងសកម្មនៅតាមកសិដ្ឋានស្ថានីយ៍ មណ្ឌលអភិវឌ្ឍកសិកម្ម និងស្រែកសិករ មានជាអាទិ៍ ការពិសោធន៍ពាក់ព័ន្ធនឹងប្រសិទ្ធិភាពនៃការប្រើប្រាស់ជី ការពិសោធន៍ប្រៀបធៀបពូជ ការពិសោធន៍បន្សាំពូជ និងការពិសោធន៍អំពីវិធីសាស្ត្រដាំដុះដំណាំផ្សេងៗទៀត។

ការធ្វើបង្ហាញទិវាស្រែ និងការរៀបចំទស្សនៈកិច្ចសិក្សា ដោយមានកសិករចូលរួមត្រូវបានអនុវត្តយ៉ាងសកម្ម។

ផ្លែផ្កាដែលលេចចេញពីការសម្រួចសកម្មភាពរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទទន និងក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការងារអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការជំរុញផលិតកម្មស្រូវនិងនាំចេញអង្ករ បាននឹងកំពុងរីកចម្រើនគួរឲ្យកត់សម្គាល់។

ចំពោះដំណាំរួមផ្សំនិងដំណាំឧស្សាហកម្មសំខាន់ៗ ក៏មានការកើនឡើងលើសឆ្នាំមុន។ ជារួមឈានមកដល់ពេលបច្ចុប្បន្នការងារបង្កបង្កើនផលដំណាំឆ្នាំ២០១២-២០១៣នេះ ទទួលបានផលយ៉ាងល្អ។

ផ្នែកផលិតកម្មស្រូវដូចបានរៀបរាប់ខាងលើ នៅឆ្នាំ២០១២-២០១៣នេះ កម្ពុជាមានអតិរេកជាង៤,**៧លានតោនស្រូវ** ត្រូវជាប្រមាណ**៣លានតោនអង្ករ** សម្រាប់បម្រើឲ្យការនាំចេញ។ ជាការកត់សម្គាល់ការនាំចេញអង្ករកម្ពុជាកំពុងស្ថិតនៅលើនិន្នាការកើនឡើងជាលំដាប់ ដោយនៅឆ្នាំ២០១២ អង្ករកម្ពុជាប្រមាណ២០ម៉ឺនតោន ត្រូវបាននាំចេញទៅកាន់៥៧ប្រទេស ក្នុងខណៈដែលត្រឹមត្រីមាសទី១ឆ្នាំ២០១៣ អង្ករកម្ពុជាត្រូវបាននាំចេញ៩៥ពាន់តោនរួចទៅហើយ។

ដោយឡែកផលិតកម្មសត្វនៅកម្ពុជាជាពិសេស គោ ក្របី និងបក្សីមានការវិវត្តន៍គួរកត់សម្គាល់ ដោយធ្វើការប្រៀបធៀបផលិតកម្មសត្វពីឆ្នាំ២០០៨ ដល់ឆ្នាំ២០១២ ឃើញថាផលិតកម្មគោថយចុះប្រមាណ ០,៨៦% ក្របីថយចុះ ៤,៧៦%។ ការថយចុះនេះគឺ បណ្តាលមកពីមួយផ្នែកធំ ដោយសារការប្រើប្រាស់គ្រឿងយន្តក្នុងផលិតកម្មកសិកម្មជំនួសឲ្យការប្រើប្រាស់កម្លាំងគោ ក្របី (នៅឆ្នាំ២០១២ ការភ្ជួររាស់ដោយគោ ក្របីមានចំនួន១.១១៧.៣៤៣ហត ស្មើនឹង៣៥,៤៩% នៅខណៈដែលការភ្ជួររាស់ដោយត្រាក់ទ័រ-គោយន្តមានចំនួន២.០៣០.៩០១ហត ស្មើនឹង៦៤.៥១%)។ ការចិញ្ចឹមបក្សីពីឆ្នាំ២០០៨ ដល់ ២០១២ មានការកើនឡើងយ៉ាងខ្លាំងរហូតដល់ ៣៦% គឺពី ១៦,៩២លានក្បាល ដល់ ២៣លានក្បាល។

ចំពោះដំណាំអចិន្ត្រៃយ៍ដូចជា កៅស៊ូ ស្វាយចន្ទី ដំណាំឈើហូបផ្លែផ្សេងៗ និងចំការ។ល។ កំពុងមានការរីកចម្រើនជាបន្តបន្ទាប់ជាលក្ខណៈគ្រួសារ និងជាលក្ខណៈវិនិយោគខ្នាតតូច មធ្យម និងធំ។ គួរកត់សម្គាល់ថា មកដល់ឆ្នាំ២០១២ ផ្ទៃដីដាំដុះកៅស៊ូទូទាំងប្រទេសមានចំនួន ២៨០.៣៥៥ហត គឺកើនឡើង ៣១,៥% ប្រៀបធៀបទៅនឹងឆ្នាំ២០១១ ក្នុងនោះ ការអភិវឌ្ឍវិស័យកៅស៊ូគ្រួសារ មានការវិវឌ្ឍន៍តាមសន្ទុះមួយគួរឱ្យចាប់អារម្មណ៍។

វិស័យព្រៃឈើកំពុងតែត្រូវធានាឱ្យមាននិរន្តរភាពសម្រាប់ការគ្រប់គ្រងធនធានព្រៃឈើ និងការប្រើប្រាស់ធនធានព្រៃឈើដល់ប្រជាជនក្រីក្រ តាមរយៈកំណែទម្រង់ព្រៃឈើ។ រយៈពេលប្រាំមកទល់នឹងឆ្នាំ២០១២នេះ សកម្មភាពដាំឈើជាចំការសម្រេចបានសរុបចំនួន ៨០.៦៩៣ហត ក្នុងនោះ រដ្ឋបាលព្រៃឈើដាំបានចំនួន ៣.៨៣៣ហត ក្រុមហ៊ុនវិនិយោគឯកជនដាំដុះបានចំនួន ៧០.០៩៨ហត គ្រួសារឯកជនខ្នាតតូចដាំបានចំនួន ៦.១២០ហត។ ទន្ទឹមនឹងនោះ សហគមន៍ព្រៃឈើសរុបចំនួន ៤៥៣ សហគមន៍ត្រូវបានបង្កើតឡើង ហើយគ្រប់គ្រងលើផ្ទៃដីសរុបចំនួន ៣៩៩.៨៨០ហត។

ចំណែកឯវិស័យជលផល ការធ្វើអាជីវកម្មនេសាទទឹកសាបបានកើនឡើង ៩% គឺពី ៤៤៥ពាន់តោននៅឆ្នាំ២០១១ ដល់ ៥០៩ពាន់តោននៅឆ្នាំ២០១២ ហើយអាជីវកម្មនេសាទសមុទ្រសម្រេចបាន ៩៩ពាន់តោន កើនលើសឆ្នាំមុន ៨,១%។ ការអភិវឌ្ឍវារីវប្បកម្ម ដូចជាការចិញ្ចឹមត្រី បង្គា ការភ្ញាស់កូនត្រីពូជ ក្រពើ សម្រេចបាន ៧៤ពាន់តោន កើនបាន២,៨% និងសហគមន៍នេសាទមានចំនួន ៥១៦សហគមន៍ ដែលបានចុះបញ្ជីការធ្វើអាជីវកម្មនេសាទចំនួន៣២៨សហគមន៍រួចហើយ។

ជាការកត់សម្គាល់កំណែទម្រង់ជលផល ដែលមានចរិកជាការធ្វើបដិវត្តក្រោមការដឹកនាំដ៏មោះមុតប្រកបដោយបញ្ញាញាណដ៏ខ្ពង់ខ្ពស់របស់ ***សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា*** លើស្មារតីគិតគូរផលប្រយោជន៍ប្រជាពលរដ្ឋជាធំ បានរំលាយចោលនូវឡូតិ៍នេសាទទាំងអស់ ប្រគល់ជូនប្រជាពលរដ្ឋអាស្រ័យផលនិងគ្រប់គ្រងក្រៅពីទុកតំបន់មួយផ្នែកតូចសម្រាប់ជាតំបន់អភិរក្ស។ កំណែទម្រង់នេះ រួមចំណែកយ៉ាងសំខាន់ដល់ការលើកស្ទួយជីវភាពប្រជាពលរដ្ឋជនបទនិងរួមចំណែកយ៉ាងសំខាន់ដល់ការកាត់បន្ថយអតិថរណា។

ការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ និងច្បាប់ស្តីពីជលផល កំពុងត្រូវបានយកចិត្តទុកដាក់ និងកាត់បន្ថយឱ្យបានជាអតិបរមានូវគ្រប់រូបភាពនៃបទល្មើសផ្សេងៗ ក្រោមកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរមូលដ្ឋាននិងស្ថាប័នមាន

សមត្ថកិច្ចពាក់ព័ន្ធ។

ទន្ទឹមនឹងអនុវិស័យខាងលើ (ផលិតកម្មដំណាំស្រូវ ផលិតកម្ម និងបសុព្យាបាល ផលិតកម្មដំណាំកៅស៊ូ រុក្ខកម្ម ជលផល) ផ្នែកសេវាកម្ម និងការគាំទ្រផ្សេងៗ ក៏បានសម្រេចនូវលទ្ធផលការងារតាមផ្នែកនីមួយៗបានល្អប្រសើរ ស្របតាមគោលការណ៍ និងទិសដៅរបស់រាជរដ្ឋាភិបាល ដូចជាការងារវិនិយោគសាធារណៈ ការរៀបចំគម្រោងសម្រាប់អភិវឌ្ឍន៍វិស័យកសិកម្ម ការងារវិនិយោគផ្នែកឯកជនលើវិស័យកសិកម្មមានការកើនឡើង ការងារស្រាវជ្រាវនិងផ្សព្វផ្សាយបច្ចេកទេសកសិកម្មកាន់តែទូលំទូលាយ កិច្ចការសហប្រតិបត្តិការអន្តរជាតិកាន់តែល្អប្រសើរឡើង និងការរៀបចំលិខិតបទដ្ឋានច្បាប់ លិខិតបទដ្ឋានក្រោមច្បាប់ ដែលពាក់ព័ន្ធនឹងវិស័យកសិកម្ម ត្រូវបានធ្វើកាន់តែច្រើនផងដែរ។

តាមការរៀបរាប់ខាងលើ យើងអាចវាយតម្លៃបានថា បរិមាណផលិតកម្មស្រូវមានការកើនឡើង បើប្រៀបធៀបនឹងឆ្នាំកន្លងមក ជារួមការងារបង្កបង្កើនផលកសិកម្មពីមួយឆ្នាំទៅមួយឆ្នាំកំពុងវិវឌ្ឍន៍ល្អ និងមានការចាប់អារម្មណ៍ខ្ពស់ពីប្រជាកសិកររបស់យើង។

ជារួមសមិទ្ធផល ដែលសម្រេចបានដូចក្នុងរបាយការណ៍លំអិតនេះ គឺជាផ្លែផ្កានៃកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន ដៃគូអភិវឌ្ឍន៍នានា និងការចូលរួមយ៉ាងសស្រាក់សស្រាំរបស់ប្រជាពលរដ្ឋផងដែរ។

ជាសន្និដ្ឋាន កសិកម្មកម្ពុជាសម្រេចបាននូវលទ្ធផលល្អប្រសើរ ដោយសារការដាក់ចេញ និងអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់នូវគោលនយោបាយ និងយុទ្ធសាស្ត្រ ជាពិសេសយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំប្រកបដោយភាពឈ្លាសវៃ និងម៉ឺងម៉ាត់បំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**។

## ២- សេចក្តីផ្តើម

ប្រទេសកម្ពុជាគឺជាប្រទេសដែលមានខឿនសេដ្ឋកិច្ចជាតិ ពឹងផ្អែកមួយភាគធំលើវិស័យកសិកម្មនៅឡើយ ហើយមានប្រជាពលរដ្ឋប្រមាណ៨០%រស់នៅជនបទ ហើយដែលក្នុងនោះភាគច្រើនលើសលុប ប្រកបរបរកសិកម្មសម្រាប់ចិញ្ចឹមជីវិត។ ក្នុងលក្ខខណ្ឌនៃដំណើរការវិវឌ្ឍន៍សេដ្ឋកិច្ចសង្គមបែបនេះ រាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងចាត់ទុកថាកសិកម្ម គឺជាវិស័យមួយដែលមានអាទិភាពខ្ពស់នៅក្នុងរបៀបវារៈនៃការអភិវឌ្ឍប្រទេសជាតិ។

ដោយយោងលើសារៈសំខាន់នៃវិស័យនេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញ និងអនុវត្តជាបន្តបន្ទាប់នូវយុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍន៍ជាតិ ដោយផ្តោតទៅលើការលើកស្ទួយវិស័យកសិកម្មនិងជនបទ ការកាត់បន្ថយភាពក្រីក្រឱ្យបានក្នុងកម្រិតមួយសមស្រប (ជាង១%ក្នុងមួយឆ្នាំ) តាមរយៈការបង្កើនផលិតភាពកសិកម្មធានានូវសន្តិសុខស្បៀង បង្កើតការងារ និងបង្កើនចំណូលប្រចាំគ្រួសារកសិករ ហើយដែលថ្មីៗកន្លងមកនេះ វិស័យនេះអាចធានាបាននូវអតិរេកនៃផលិតផលកសិកម្មបម្រើឱ្យការនាំចេញទៀតផង។ យើងបានពិនិត្យឃើញថា កិច្ចខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្លាទាំងនេះ បានឆ្លុះបញ្ចាំងតាមរយៈការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០០៩-២០១៣ ដែលត្រូវបានរៀបចំឡើង និងឆ្លើយតបនូវទិសដៅគោលនយោបាយយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា ពិសេសយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ នៃរាជរដ្ឋាភិបាលកម្ពុជា។

ជាការពិតឆ្នាំ២០១២ គឺជាឆ្នាំទី៥ នៃការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ របស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់នីតិកាលទី៤នៃរដ្ឋសភា ក្រោមការដឹកនាំដ៏ឈ្លាសវៃមោះមុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលក្នុងនោះការលើកស្ទួយវិស័យកសិកម្មគឺជាមុំមួយដ៏សំខាន់ សម្រាប់កំណើនសេដ្ឋកិច្ចជាតិ។ ការលើកកម្ពស់ផលិតភាព និងពិពិធកម្មកសិកម្ម ការកែទម្រង់ដីធ្លីនិងបោសសំអាតមីន ការកែទម្រង់វិស័យ ជលផល និងការកែទម្រង់វិស័យព្រៃឈើ គឺជាមុខព្រួញស្នូលដើម្បីចូលរួមជំរុញសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា។

ដោយមានការជួយឧបត្ថម្ភគាំទ្រគ្រប់បែបយ៉ាងពីរាជរដ្ឋាភិបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ និងដៃគូអភិវឌ្ឍន៍នានា គួបផ្សំនឹងការខិតខំ និងការផ្លាស់ប្តូរទម្លាប់របស់ប្រជាកសិករផង បានជំរុញឱ្យដំណើរការផលិតកម្មកសិកម្មទទួលបានជោគជ័យ និងជំនះដោះស្រាយបាននូវការលំបាកផ្សេងៗ ដែលរួមមានកត្តាអវិជ្ជមាននៃធម្មជាតិ ពិសេសគ្រោះកង្វះទឹកនារដូវវស្សាឆ្នាំ២០១២ ដែលបានប៉ះពាល់បំផ្លិចបំផ្លាញផលដំណាំស្រូវនិងដំណាំផ្សេងៗប្រមាណជាង៣ម៉ឺនហត រួមនឹងមានភាពជំនន់ទឹកភ្លៀងនៅតំបន់មួយចំនួនទៀត។ ស្ថិតក្នុងបរិបទនេះ វិស័យកសិកម្មសម្រេចបានកំណើនដល់៤,៣%នាឆ្នាំ២០១២ ដោយកើនលើសឆ្នាំ២០១១ ដែលអត្រាកំណើនមានចំនួន១% និងសង្ឃឹមថាវិស័យនេះអាចនឹងទទួលបានកំណើនក្នុងឆ្នាំ២០១៣ និងក្នុងរយៈពេលមធ្យមខាងមុខ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានខិតខំជំរុញផលិតកម្មកសិកម្មលើគ្រប់មុខព្រួញ ជាពិសេសការបង្កបង្កើនផលដំណាំជាយុទ្ធសាស្ត្រជាអាទិ៍ ដំណាំស្រូវ កៅស៊ូ និងដំណាំរួមផ្សំ ការចិញ្ចឹមសត្វ និងវារីវប្បកម្ម ដែលអាចឆ្លើយតបបានទៅនឹងតម្រូវការស្បៀងក្នុងស្រុក និងនៅសល់ស្បៀងសម្រាប់នាំចេញជាក់ស្តែង កម្ពុជាអាចនៅសល់ស្រូវជាង៤,៧លានតោន សម្រាប់ប្រើប្រាស់ក្នុងឧស្សាហកម្មអាហារក្នុងស្រុកនិងការនាំចេញ។ ទន្ទឹមនឹងការកែទម្រង់ផ្តាច់ព្រ័ត្រវិស័យជលផលដែលដឹកនាំប្រកបដោយគតិបណ្ឌិតមុតស្រួចរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានរួមចំណែកយ៉ាងសំខាន់ដល់ការកាត់បន្ថយកម្រិតអតិផរណានៅកម្ពុជា។

ស្ថិតក្នុងបរិយាកាសអំណោយផលនេះ ប្រជាពលរដ្ឋគ្រប់តំបន់និងទីប្រជុំជន បានខិតខំប្រកបមុខរបរយ៉ាងមមាញឹកប្រកបដោយលក្ខណៈប្រកួតប្រជែង ក្នុងបរិបទនៃពាណិជ្ជូបនីយកម្មកសិកម្ម ដែលធ្វើឱ្យវិស័យកសិកម្មកាន់តែមានសភាពសកម្ម និងមានសារៈសំខាន់ក្នុងជីវភាពសង្គម ក៏ដូចជាការគាំទ្រសេដ្ឋកិច្ចជាតិ ទន្ទឹមនឹងរាជរដ្ឋាភិបាលបាននិងកំពុងបង្កើនផ្តោតការយកចិត្តទុកដាក់ និងវិនិយោគកាន់តែខ្លាំងក្លាលើវិស័យកសិកម្មនេះ ដែលជាបុរេលក្ខខណ្ឌផ្តល់ការលើកទឹកចិត្ត និងទាក់ទាញការដាក់ទុនវិនិយោគកាន់តែធំឡើងជាលំដាប់ពីវិស័យឯកជន ជាតិ និងអន្តរជាតិ។

ជារួមផ្នែកផលិតកម្មកសិកម្មអាចវាយតម្លៃបានថាទទួលបានជោគជ័យ និងលទ្ធផលល្អប្រសើរ ពិសេសលើបរិមាណផលិតផលស្រូវបានកើនប្រមាណ ៥,៨៣% លើសឆ្នាំមុន ទន្ទឹមនឹងការកែទម្រង់លើវិស័យព្រៃឈើ និងជលផល បាន ដំណើរការទៅមុខប្រកបដោយលទ្ធផលជាទីមោទនៈ គួបផ្សំនឹងការផ្តល់សេវាកម្មគាំទ្រ និងការផ្សព្វផ្សាយផ្ទេរបច្ចេកវិទ្យា មានសភាពកាន់តែសកម្ម ចូលជ្រៅដល់មជ្ឈដ្ឋានប្រជាកសិករ។ ទោះជាយ៉ាងណាក្តី ការរីកចំរើនក្នុងវិស័យកសិកម្ម ក៏មិនអាចកាត់ផ្តាច់បានពីការរួមចំណែកឧបត្ថម្ភពីបណ្តាដៃគូអភិវឌ្ឍន៍របស់កម្ពុជាបានដែរ ជាពិសេសការផ្តល់ជំនួយបច្ចេកទេស និងហិរញ្ញប្បទានដ៏ច្រើនសន្ធឹកសន្ធាប់ដើម្បីចូលរួមជំរុញវិស័យនេះ។

ក្រោយពីរាជរដ្ឋាភិបាលដាក់ចេញនូវគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករឆ្នាំ២០១២ បានកត់សម្គាល់នូវកំណើនការនាំចេញអង្ករកម្ពុជាជាផ្លូវការក្នុងបរិមាណប្រមាណ២០ម៉ឺនតោនទៅកាន់បណ្តាប្រទេសចំនួន ៥៧ ហើយនិន្នាការនេះកាន់តែហក់ឡើងនៅត្រីមាសទី១ឆ្នាំ២០១៣ ជាមួយនឹងបរិមាណនៃការចេញនាំអង្ករកម្ពុជាជាង៩៥.០០០តោន។ នេះជាការឆ្លុះបញ្ចាំងនូវការខិតខំរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ រាជរដ្ឋាភិបាល ក្នុងការសម្រេចសកម្មភាពអនុវត្តគោលនយោបាយទៅតាមចក្ខុវិស័យប្រក្បត្យរបស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា។ សកម្មភាពដើម្បីអនុវត្តគោលនយោបាយនេះ ហើយគ្រប់អង្គភាពដែលពាក់ព័ន្ធក្នុងផលិតកម្មស្រូវបានខិតខំអនុវត្ត គួបផ្សំនឹងការចូលរួមចំណែកទាំងផ្នែកបច្ចេកទេស និងធនធានថវិកា សម្រាប់អនុវត្តការងារនេះឱ្យសម្រេចបានលទ្ធផល តាមការគ្រោងទុក។ ក្រៅពីអង្ករ កៅស៊ូ ដំឡូងមី និងពោត បានឈរក្នុងលំដាប់នៃការនាំចេញ ដែលអាចសន្និដ្ឋានបានថាផលិតផលកសិកម្មសម្រាប់ការនាំចេញមានបីមុខសំខាន់កំពុងលេចធ្លោនាពេលបច្ចុប្បន្ននេះ។

ជាការសន្និដ្ឋាន វិស័យកសិកម្មបច្ចុប្បន្ននេះ មានការអភិវឌ្ឍប្រកបដោយមោទនភាព ជាពិសេសផលិតកម្មកសិកម្មកម្ពុជានៅតែបន្តឈានចូលដល់ដំណាក់កាលល្អបំផុត ក្នុងប្រវត្តិសាស្ត្ររបស់ព្រះរាជាណាចក្រកម្ពុជា។

## ៣- គោលដៅ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

### ៣.១-យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល (Rectangular Strategy)

យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២នៃរាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏ឆ្លាសវៃរបស់ ***សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា*** បានកំណត់ការលើកកម្ពស់វិស័យកសិកម្ម សម្រាប់ជំរុញកំណើនសេដ្ឋកិច្ច និងពន្លឿនការកាត់បន្ថយភាពក្រីក្រ ដោយផ្តោតសំខាន់ទៅលើការលើកកម្ពស់ផលិតភាព និងពិពិធភាវូបនីយកម្មកសិកម្ម កំណែទម្រង់ដីធ្លី កំណែទម្រង់ជលផល និងកំណែទម្រង់ព្រៃឈើ។

ចតុកោណយុទ្ធសាស្ត្រទាំងបួនសម្រាប់ជំរុញកំណើនសេដ្ឋកិច្ចគឺ÷ ១-ការលើស្ទួយវិស័យកសិកម្ម ២-ការអភិវឌ្ឍផ្នែកឯកជននិងការងារ ៣-ការបន្តស្តារនិងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ៤-ការកសាងសមត្ថភាពនិងអភិវឌ្ឍន៍ធនធានមនុស្ស។

ការលើកស្ទួយវិស័យកសិកម្មរួមមាន: (ទី១)-ការលើកកម្ពស់ផលិតភាពនិងពិពិធកម្មកសិកម្ម (ទី២)-កំណែទម្រង់ដីធ្លី និងការបោសសំអាតមីន (ទី៣)- កំណែទម្រង់ជលផល និង (ទី៤)-កំណែទម្រង់ព្រៃឈើ។

គោលនយោបាយកសិកម្មរបស់រាជរដ្ឋាភិបាល គឺសំដៅលើកកម្ពស់វិស័យកសិកម្ម ឱ្យក្លាយទៅជាផ្នែកនាំមុខមួយដែលអាចផ្តល់ចលករបន្ថែមដល់កំណើនសេដ្ឋកិច្ច និងអាចចូលរួមវិភាគទានយ៉ាងសំខាន់ដល់ការកាត់បន្ថយភាពក្រីក្រ។ នៅក្នុងទិសដៅនេះ រាជរដ្ឋាភិបាលកម្ពុជា នឹងបង្កើនការប្រើប្រាស់ធនធានក្នុងស្រុករួមជាមួយធនធានថវិកា និងជំនួយបច្ចេកទេសពីដៃគូអភិវឌ្ឍន៍នានា សម្រាប់អនុវត្តពហុវប្បកម្ម និងប្រពលវប្បកម្មកសិកម្ម ដោយដោះស្រាយជាកញ្ចប់នូវបញ្ហាបច្ចេកទេសកសិកម្ម ហេដ្ឋារចនាសម្ព័ន្ធជនបទដូចជា ផ្លូវថ្នល់ ធារាសាស្ត្រ និងអគ្គិសនី ព្រមទាំងឥណទានទីផ្សារ និងការកែច្នៃកសិផលជាពិសេសការកែច្នៃសម្រាប់ការនាំចេញ ដើម្បីធានាបាននូវនិរន្តរភាពនៃកំណើនសេដ្ឋកិច្ច បង្កើតការងារ និងបង្កើនប្រាក់ចំណូលនៅជនបទ ព្រមទាំងធានាសន្តិសុខស្បៀងសម្រាប់ប្រជាជនទូទៅ ហើយធ្វើឱ្យប្រសើរឡើងនូវអាហារូបត្ថម្ភ និងបង្កើនការនាំចេញផលិតផលកសិកម្ម។

### ៣.២- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០០៩-២០១៣

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០០៩-២០១៣ ត្រូវបានរៀបចំឡើងដោយឆ្លុះបញ្ចាំង និងឆ្លើយតបនូវទិសដៅយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា ពិសេសយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២នៃរាជរដ្ឋាភិបាលកម្ពុជា។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០០៩-២០១៣ ក៏បានរៀបចំធ្វើឱ្យមានសង្គតិភាព រវាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ សំដៅចូលរួមជំរុញកំណើនសេដ្ឋកិច្ចជាតិ និងពន្លឿនការកាត់បន្ថយភាពក្រីក្រតាមរយៈការលើកកម្ពស់និងជំរុញការអភិវឌ្ឍកសិកម្ម។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០០៩-២០១៣ បានកំណត់ចក្ខុវិស័យដើម្បីធានា "ភាពមានស្បៀងគ្រប់គ្រាន់ និងប្រកបដោយសុវត្ថិភាពសម្រាប់ប្រជាពលរដ្ឋគ្រប់រូប រួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ ដោយជំរុញការរីកលូតលាស់សេដ្ឋកិច្ចកសិកម្ម រួមនឹងការគ្រប់គ្រង និងអភិរក្សធនធានធម្មជាតិប្រកបដោយនិរន្តរភាព"។

ដើម្បីសម្រេចបាននូវទស្សនវិស័យនេះ សកម្មភាពគាំទ្រជាច្រើនត្រូវបានផ្តល់ រួមជាមួយនូវធាតុចូលសំខាន់ៗ សំដៅជំរុញដល់ការលូតលាស់សេដ្ឋកិច្ច ដូចជាការផ្តល់សេវាកម្មមានគុណភាពខ្ពស់ ដែលនាំដល់ការផ្គត់ផ្គង់ស្បៀងប្រកបដោយសុវត្ថិភាព បង្កើនផលិតភាពកសិកម្មនិងតម្លៃបន្ថែម ដោយផ្អែកទៅលើមូលដ្ឋាននិរន្តរភាព និងប្រសិទ្ធភាពតម្លៃចំពោះវិស័យ ដែលពឹងផ្អែកលើផលិតកម្មកសិកម្ម នេសាទ និងរុក្ខាប្រមាញ់។

ទិសដៅគោលនយោបាយរួមត្រូវបានកំណត់សំដៅ "**<u>លើកកម្ពស់ផលិតភាព ពិពិធភាវូបនីយកម្ម និងពាណិជ្ជកម្មកសិកម្ម ដើម្បីកាត់បន្ថយភាពក្រីក្រនិងជំរុញកំណើនសេដ្ឋកិច្ច ដោយយកចិត្តទុកដាក់ខ្ពស់លើការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព</u>**"។

ដើម្បីសម្រេចបានគោលដៅជាយុទ្ធសាស្ត្រចំបងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏ដូចជាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានកំណត់នូវទិសដៅគោលនយោបាយជាយុទ្ធសាស្ត្រតាមអនុវិស័យដូចខាងក្រោម ÷

**ទិសដៅគោលនយោបាយទី-១÷ ធានាសន្តិសុខស្បៀង បង្កើនផលិតភាព និងពិពិធកម្មកសិកម្ម**

**ទិសដៅគោលនយោបាយទី-២÷ ពង្រីកទីផ្សារសម្រាប់ផលិតផលកសិកម្ម**

**ទិសដៅគោលនយោបាយទី-៣÷ ក្របខ័ណ្ឌនៃការអភិវឌ្ឍនស្ថាប័ននិងបញ្ញត្តិច្បាប់**

**ទិសដៅគោលនយោបាយទី-៤÷ កំណែទម្រង់ជលផល**

**ទិសដៅគោលនយោបាយទី-៥÷ កំណែទម្រង់ព្រៃឈើ**

**<u>គោលបំណងគោលនយោបាយ</u>**៖ (Policy Objectives)

*ទី-១÷ បង្កើនផលិតភាពនិងពិពិធកម្មកសិកម្ម ដោយធានាឱ្យបាននូវកំណើនផលិតកម្មគ្រប់មុខដំណាំក្នុងកម្រិតប្រមាណជា ១០% ផលិតកម្មសត្វ ៣% ក្នុងមួយឆ្នាំ លើមូលដ្ឋាននៃការបង្កើនការស្រាវជ្រាវនិងផ្សព្វផ្សាយកសិកម្មទូលាយជាងមុន និងការទប់ស្កាត់ជំងឺឆ្លងសត្វកាន់តែមានប្រសិទ្ធភាព។*

*ទី-២÷ ធានារក្សាឱ្យបាននូវផ្ទៃដែននេសាទសម្រាប់សហគមន៍នេសាទ បង្កើនការការពារធនធានជលផល ការទប់ស្កាត់បទល្មើសនេសាទ ពិសេសតំបន់ជុំវិញបឹងទន្លេសាប និងការជំរុញវារីវប្បកម្មក្នុងកំរិត ១៥% ក្នុងមួយឆ្នាំ រួមនឹងការពង្រឹងសមត្ថភាពសហគមន៍នេសាទឱ្យកាន់តែប្រសើរឡើង ។*

*ទី-៣÷ រក្សាបាននូវផ្ទៃដីគ្របដណ្តប់ដោយព្រៃឈើ ៦០% នៅឆ្នាំ២០១៥ ដោយត្រូវបង្កើនការការពារធនធានព្រៃឈើ ពិសេសការទប់ស្កាត់បង្ក្រាបបទល្មើសព្រៃឈើ សត្វព្រៃ ការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ ជំរុញការដាំឈើឡើងវិញឱ្យបានខ្លាំងក្លា និងបង្កើនសមត្ថភាពសហគមន៍ព្រៃឈើ លើមូលដ្ឋាននិរន្តរភាព និងប្រសិទ្ធភាពនៃការគ្រប់គ្រង។*

ដើម្បីសម្រេចបានគោលដៅនៃយុទ្ធសាស្ត្រទាំងប្រាំ និងគោលបំណងគោលនយោបាយខាងលើ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំកម្មវិធីអាទិភាពសំខាន់ៗចំនួនប្រាំ ដែលជាផ្នែកមួយនៃកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ សំដៅ

ពង្រឹងការអនុវត្តថវិកាតាមកម្មវិធី ដោយរួមបញ្ចូលនូវប្រភពធនធានថវិកាខាងក្រៅផងដែរ។ កម្មវិធីទាំងនោះរួមមាន ៖

**កម្មវិធីទី ១ ÷ បង្កើនផលិតភាពនិងពិពិធកម្មកសិកម្ម**

**កម្មវិធីទី ២ ÷ ជំរុញការចូលទីផ្សារ នៃផលិតផលកសិកម្ម**

**កម្មវិធីទី ៣ ÷ ពង្រឹងស្ថាប័ន ក្របខ័ណ្ឌច្បាប់និងអភិវឌ្ឍន៍ធនធានមនុស្ស**

**កម្មវិធីទី ៤ ÷ ការគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព**

**កម្មវិធីទី ៥ ÷ ការគ្រប់គ្រងធនធានព្រៃឈើនិងសត្វព្រៃ ប្រកបដោយនិរន្តរភាព**

### ៣.៣- ផែនការសកម្មភាព សម្រាប់អនុវត្តគោលនយោបាយ ជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករ

ឯកសារគោលនយោបាយស្តីពីការជំរុញផលិតកម្មដំណាំស្រូវនិងការនាំចេញអង្ករ ត្រូវបានប្រកាសដាក់ឱ្យអនុវត្តកាលពីថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១០ កន្លងទៅនេះ ដោយ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ហើយដែលគ្រប់ភាគីដែលពាក់ព័ន្ធក្នុងកិច្ចការនេះ ត្រូវតែរៀបចំផែនការសកម្មភាពសម្រាប់អនុវត្តជាក់ស្តែងប្រកបដោយប្រសិទ្ធភាព ដើម្បីសម្រេចបាននូវទិសដៅធ្វើយ៉ាងណាឱ្យកម្ពុជាមានផលិតផលស្រូវ ដែលផលិតលើសប្រមាណជាង ៤លានតោន និងមានលទ្ធភាពនាំចេញអង្ករជាផ្លូវការជាង ១លានតោន នៅឆ្នាំ២០១៥ ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំនូវផែនការសកម្មភាពលម្អិតរបស់ខ្លួន សំដៅឆ្លើយតបនិងសម្រេចបាននូវចំណុចទិសដៅគោលនយោបាយដែលបានកំណត់នេះ។ ឯកសារគោលនយោបាយស្តីពី ការជំរុញផលិតកម្មដំណាំស្រូវនិងការនាំចេញអង្ករ បានកំណត់ច្បាស់នូវចំណុចវិធានការគោលនយោបាយសំខាន់ៗ ទៅតាមដំណាក់កាលនីមួយៗគឺៈ (ទី១) វិធានការគោលនយោបាយដែលពាក់ព័ន្ធនឹងផលិតកម្ម (ទី២) ពាក់ព័ន្ធនឹងការប្រមូលទិញនិងការកែច្នៃ (ទី៣) ពាក់ព័ន្ធនឹងប្រព័ន្ធសម្រួលការនាំចេញ និង (ទី៤) គឺវិធានការគោលនយោបាយដែលពាក់ព័ន្ធនឹងការស្វែងរកទីផ្សារ។

ដើម្បីឆ្លើយតបបាននូវទិសដៅគោលនយោបាយ ដែលបានដាក់ឱ្យអនុវត្តនេះ "ការបង្កើនផលិតភាព ពិសេសប្រពលវប្បកម្មដំណាំស្រូវនិងពិពិធភាវូបនីយកម្ម" គឺជាចំណុចគន្លឹះ ដែលនឹងត្រូវយកចិត្តទុកដាក់និងត្រូវផ្តោតទៅ លើការបង្កើនសេវាកម្មនិងអន្តរាគមន៍នានា ដើម្បីជួយដល់ការបង្កើនផលិតផលស្រូវ ការផ្ទេរបច្ចេកទេសសមស្របដល់កសិករ ការបង្កើនការស្រាវជ្រាវនិងអភិវឌ្ឍពូជស្រូវដែលស្របនឹងលក្ខណៈដី កត្តាអាកាសធាតុ និងពិសេសការកំណត់ប្រភេទពូជសំខាន់ៗ ស្របតាមតម្រូវការទីផ្សារចង់បាន។ល។ ម្យ៉ាងទៀត ការសម្របសម្រួលនិងគាំទ្រវិស័យឯកជនក្នុងការបង្កើនសមត្ថភាពម៉ាស៊ីនកែច្នៃ តម្រូវតាមស្តង់ដារទីផ្សារអន្តរជាតិ គឺជាការចាំបាច់ និងត្រូវតែគាំទ្រឱ្យបានខ្លាំងក្លា។

ការប្រមូលផ្តុំផលិតកម្ម ក៏ជាចំណុចគ្រឹះមួយសំខាន់ផងដែរ ពោលគឺសំដៅសម្រួលដល់ការផ្គត់ផ្គង់ និងប្រមូលទិញជាលក្ខណៈទ្រង់ទ្រាយធំតាមរយៈ "សហគមន៍កសិកម្ម ឬសហករណ៍កសិកម្ម" ។ ដូចនេះ ទាមទារឱ្យមានការប្រមូលផ្តុំផលិតកម្មជាចាំបាច់ ហើយសហគមន៍កសិកម្មគឺជាមជ្ឈមណ្ឌលផលិតនិងផ្គត់ផ្គង់ដ៏សំខាន់នាពេលអនាគត។

ក្នុងន័យនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានតម្រង់ទិសនៃការធ្វើអន្តរាគមន៍ទៅរកការពង្រឹងសមត្ថភាពរបស់សហគមន៍កសិកម្ម ដើម្បីផលិតក្នុងទ្រង់ទ្រាយធំនាពេលខាងមុខ។ ម្យ៉ាងវិញទៀត ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏បានយកចិត្តទុកដាក់ខ្លាំងក្លាដល់ការគាំទ្រផ្នែកឯកជន ពិសេសបណ្តាក្រុមហ៊ុនដែលចូលរួមក្នុងការធ្វើផលិតកម្មកសិកម្មនៅកម្ពុជា ។

ការផ្សារភ្ជាប់រវាងក្រុមអ្នកផលិត និងអ្នកប្រមូលទិញ តាមយន្តការ «ផលិតកម្មកសិកម្មតាម កិច្ចសន្យា» គឺជាចំណុចយុទ្ធសាស្រ្តដ៏សំខាន់ ក្នុងការសម្រេចបាននូវទិសដៅគោលនយោបាយនេះ។ ម្យ៉ាងវិញទៀត ការផ្តល់ព័ត៌មានអំពីទីផ្សារស្រូវអង្ករ ក៏ជាមធ្យោបាយដ៏សំខាន់មួយដើម្បីឱ្យកសិករ ពាណិជ្ជករ មានទំនាក់ទំនងគ្នាក្នុងពាណិជ្ជកម្មកសិកម្មនេះ។ លើសពីនេះទៀតនោះ ការសម្រួលពាណិជ្ជកម្ម និងការនាំចេញតាមរយៈសកម្មភាពនានា ដែលពាក់ព័ន្ធនឹងការសម្រួលបែបបទលិខិតបទដ្ឋានក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺជាវិធានការចាំបាច់និងត្រូវពង្រឹងបន្ថែមទៀត។

ផ្អែកលើសារសំខាន់នេះនិងភាពចាំបាច់នៃឯកសារគោលនយោបាយនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានខិតខំរៀបចំនូវផែនការសកម្មភាពរបស់ខ្លួនដោយបានលម្អិតនូវអ្វីដែលជាសកម្មភាព និងភារកិច្ចត្រូវអនុវត្ត និងបានដាក់

ចុះជាសកម្មភាពជាក់ស្តែងនានាដល់អង្គភាពជំនាញដែលពាក់ព័ន្ធ ដើម្បីរួមគ្នាអនុវត្តវិធានការគោលនយោបាយនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ អនុវត្តនូវបណ្តាសកម្មភាពធំៗមួយចំនួន ដូចជា÷

(ទី-១) **វិធានការពាក់ពន្ធ័នឹងផលិតកម្មស្រូវ:**

មកទល់នឹងពេលនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ បានកំណត់រួចហើយនូវប្រភេទពូជស្រូវសំខាន់ៗ ចំនួន ១០ ប្រភេទ សម្រាប់ជំរុញផលិតកម្ម រួមមាន÷

- ពូជស្រូវស្រាលមិនប្រកាន់រដូវចំនួន ៣ ពូជ: ពូជសែនពិដោរ ពូជជលសារ និង ពូជ IR66
- ពូជស្រូវកណ្តាលចំនួន ៤ ពូជ: ពូជផ្ការំដួល ពូជផ្ការំដេង ពូជផ្ការមៀត និងពូជផ្កាច័ន្ទសែនស
- ពូជស្រូវធ្ងន់ចំនួន ៣ ពូជ: ពូជរាំងជ័យ ពូជខា៤ និង ពូជខា៦ ។

ការផ្សព្វផ្សាយពូជទាំង១០ប្រភេទនេះ ត្រូវបានជំរុញឱ្យផលិតយ៉ាងខ្លាំងក្លា។

ក្រសួងបានធ្វើការសម្រួលនីតិវិធីនៃការនាំចូលពូជស្រូវ ជី ធាតុចូលកសិកម្មផ្សេងៗទៀត ជាមួយនឹងច្បាប់ស្តីពីថ្នាំកសិកម្មនិងជីកសិកម្ម ក៏ត្រូវបានអនុវត្ត។ ក្រសួងបានពង្រឹងនិងពង្រីកសមត្ថភាព CARDI ស្ថានីយ៍ពិសោធន៍ មណ្ឌលអភិវឌ្ឍន៍កសិកម្ម ក៏ដូចជាការពិនិត្យឡើងវិញនូវក្របខ័ណ្ឌនៃសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ពង្រីករចនាសម្ព័ន្ធផ្សព្វផ្សាយកសិកម្ម រៀបចំគម្រោងផែនការដើម្បីគាំទ្រការរៀបចំរចនាសម្ព័ន្ធ និងពង្រឹងតួនាទីរបស់អង្គការកសិករ ពិសេសការលើកកម្ពស់សមត្ថភាពរបស់កសិករនិងសហគមន៍កសិកម្មក្នុងការខ្ចីនិងការប្រើប្រាស់ឱ្យមានប្រសិទ្ធភាពនូវឥណទានពីស្ថាប័នហិរញ្ញវត្ថុផ្សេងៗ។ ច្បាប់ស្តីពីសហគមន៍កសិកម្មត្រូវបានរៀបចំរួចរាល់ និងបានដាក់ឆ្លងការពិភាក្សាអន្តរក្រសួង ហើយបានទទួលការអនុម័តពីគណៈរដ្ឋមន្ត្រីកាលពីថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ រួចហើយ។

ការរៀបចំធ្វើចំណាត់ថ្នាក់តំបន់ប្រើប្រាស់ដីកំពុងត្រូវបានគិតគូរ និងស្វះស្វែងរកធនធានដើម្បីអនុវត្ត និងផ្សព្វផ្សាយឱ្យបានទូលាយ។ ច្បាប់ស្តីពី ការគ្រប់គ្រងនិងប្រើប្រាស់ដីកសិកម្ម កំពុងដំណើរការរៀបចំកសាងយ៉ាងសកម្ម។ អនុក្រឹត្យស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យាត្រូវបានអនុម័ត និងកំពុងរៀបចំអនុវត្ត។ ការរៀបចំធ្វើជំរឿនកសិកម្ម កំពុងអនុវត្តដោយបានសហការជាមួយក្រសួងផែនការ ក្រោមជំនួយបច្ចេកទេសពីដៃគូអភិវឌ្ឍន៍។

(ទី-២) **វិធានការពាក់ពន្ធ័នឹងការប្រមូលទិញនិងការកែច្នៃស្រូវ:** ក្រសួងបានយកចិត្តទុកដាក់ដល់ការពង្រឹងសហគមន៍កសិកម្ម ដោយបានផ្តោតលើសកម្មភាព÷ ផ្តល់វគ្គបណ្តុះបណ្តាលបច្ចេកទេស ការផ្សារភ្ជាប់ទីផ្សារកសិផល ពង្រឹងសមត្ថភាពគ្រប់គ្រង និងកសាងពង្រឹងហេដ្ឋារចនាសម្ព័ន្ធរូបវន្តដល់សហគមន៍កសិកម្ម។ ជាក់ស្តែង មកដល់ខែធ្នូ ឆ្នាំ២០១២នេះ មានសហគមន៍កសិកម្មសរុបចំនួន៣៧៥សហគមន៍ត្រូវបានបង្កើតឡើង និងកំពុងពង្រឹងសមត្ថភាពគ្រប់គ្រង។

(ទី-៣) **វិធានការពាក់ពន្ធ័នឹងប្រពន្ធ័សម្រួលការនាំចេញអង្ករ:** ក្រសួងបានរៀបចំចងក្រងនិងផ្សព្វផ្សាយឯកសារស្តីពីនីតិវិធីនៃការនាំចេញទំនិញជាកម្មវត្ថុការត្រួតពិនិត្យភូតគាមអនាម័យ ស្វែងរកធនធានដើម្បីសិក្សាពីសមាសភាពចង្រៃលើអង្ករនៅក្នុងប្រទេសកម្ពុជា រៀបចំបញ្ជីឈ្មោះសមាសភាពចង្រៃ ដើម្បីឆ្លើយតបការតម្រូវរបស់ភាគីពាក់ព័ន្ធ រៀបចំចងក្រងនិងផ្សព្វផ្សាយអត្ថបទបច្ចេកទេសស្តីពីសមាសភាពចង្រៃលើអង្ករ រៀបចំតំបន់គ្មានសមាសភាពចង្រៃ សម្រាប់ផលិតកម្មដំណាំស្រូវ ដើម្បីនាំចេញទៅតាមតម្រូវការរបស់ប្រទេសនាំចូល ដោយផ្អែកលើស្តង់ដារអន្តរជាតិស្តីពីវិធានភូតគាមអនាម័យ ខិតខំពង្រឹងសមត្ថភាពបច្ចេកទេស ដើម្បីជំរុញការអនុវត្តការងារធ្វូបទកម្ម ហើយច្បាប់ស្តីពីការការពារដំណាំនិងភូតគាមអនាម័យកំពុងត្រូវបានរៀបចំ។ ក្រសួងបានចាត់មន្ត្រីជំនាញជាន់ខ្ពស់ ដើម្បីប្រចាំការនៅច្រកចេញចូល តែសម្រាប់ធ្វើសេវាបំពេញបែបបទនាំអង្ករនូវក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ ក្រសួងបានរួមសហការជាមួយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដើម្បីកំណត់ស្តង់ដារគុណភាពអង្ករកម្ពុជាឲ្យស្របតាមស្តង់ដារអន្តរជាតិ ។

(ទី-៤) **វិធានការស្វែងរកទីផ្សារ:** ក្រសួងបានផ្សព្វផ្សាយព័ត៌មានតម្លៃស្រូវអង្ករក្នុងស្រុក និងទីផ្សារអន្តរជាតិ តាមវិទ្យុ ទូរស្សន៍ សារជាអក្សរ ព្រឹត្តិបត្រ គេហទំព័រព័ត៌មានទីផ្សារកសិកម្ម ធ្វើអង្កេតអំពីលំហូរពាណិជ្ជកម្ម និងចរាចរស្រូវ-អង្ករ និងវិភាគអំពីស្ថានការទីផ្សារតំបន់ និងអន្តរជាតិ ។

ការនាំចេញអង្ករផ្លូវការរបស់កម្ពុជាមាននិន្នាការវិវឌ្ឍគួរឱ្យកត់សម្គាល់ ។ នាឆ្នាំ២០០៧ ការនាំចេញអង្ករឆ្លងកាត់

ប្រតិវេទគយមានត្រឹមតែ៤.០០០តោន និងបានកើនខ្លាំងចាប់ពីមានការអនុវត្តគោលនយោបាយជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករកាលពីឆ្នាំ២០១០។ អង្ករនាំចេញផ្លូវការបានកើនពី៥១,៣ពាន់តោននាឆ្នាំ២០១០រហូតដល់១៩២,៦ពាន់តោននាឆ្នាំ២០១២នេះ។ ប៉ុន្តែទោះជាយ៉ាងនេះក្តី ការនាំចេញអង្ករផ្លូវការនៅទាបជាងសូចនាករកំណត់ ក្នុងឯកសារគោលនយោបាយនៅឡើយ (ឆ្នាំ២០១២ គ្រោងសម្រេចឱ្យបាន ២៥០ពាន់តោន) ដែលកិច្ចការនេះទាមទារឱ្យមានការខិតខំបន្ថែមទៀតដើម្បីសម្រេចបានដល់គោលដៅកំណត់។




*ប្រភព÷ អគ្គនាយកដ្ឋានគយនិងរដ្ឋាករ ២០១២*

សហព័ន្ធអ្នកនាំអង្ករចេញកម្ពុជាត្រូវបានបង្កើត និងប្រកាសទទួលស្គាល់នាខែកក្កដា ឆ្នាំ២០១២។ សហព័ន្ធនេះគឺជាដៃគូរបស់រាជរដ្ឋាភិបាលក្នុងការជំរុញការនាំចេញអង្ករកម្ពុជា និងបានដាក់នៅក្នុងក្រុមការងារទី៩ ស្តីពីក្រុមការងារផ្នែកស្រូវអង្ករនៃវេទិការាជរដ្ឋាភិបាល ផ្នែកឯកជន។ កម្ពុជាមានភាពអនុគ្រោះពន្ធគយសម្រាប់ទីផ្សារនៅអឺរ៉ុប ដែលកត្តានេះបានធ្វើឱ្យកម្ពុជាមានឧត្តមភាពប្រៀបធៀបផ្នែកតម្លៃបើធៀបនឹងប្រទេសជិតខាង ក៏ប៉ុន្តែទីផ្សារសហគមន៍អឺរ៉ុប បានរឹតបន្តឹងផ្នែកស្តង់ដារអង្ករ អនាម័យនិងភូតគាមអនាម័យ (SPS) និងអង្ករដែលប្រើពូជ GMO។ ដូចនេះ ដើម្បីមានលទ្ធភាពនាំចូលទៅទីផ្សារអឺរ៉ុប កម្ពុជាត្រូវបំពេញលក្ខខណ្ឌឱ្យបានត្រឹមត្រូវនិងមានការធានាច្បាស់លាស់។

កង្វះខាតទុនសម្រាប់ប្រមូលទិញស្រូវនៅរដូវប្រមូលផលគឺជាបញ្ហាមួយគួរកត់សម្គាល់ ដែលកត្តានេះបានធ្វើឱ្យស្រូវកម្ពុជាហូរចេញទៅក្រៅ ជាពិសេសទៅវៀតណាមនិងថៃ។ បើតាមការគណនានិងប៉ាន់ស្មាន កម្ពុជានឹងត្រូវការទុនប្រមាណ ១២០០លានដុល្លារអាមេរិក សម្រាប់ប្រមូលទិញស្រូវដែលផលិតលើសពីតម្រូវការសម្រាប់កែច្នៃនាំចេញ ប៉ុន្តែប្រភពទុនដែលមាននៅកម្ពុជាមានប្រមាណ៣០០លានដុល្លារអាមេរិកតែប៉ុណ្ណោះ។ ការខ្ចីទុនពីធនាគារក៏មានការលំបាកដោយសារខ្វះទ្រព្យបញ្ចាំឬធានា ហើយចំនួននៅមានកម្រិតទាប ដែលកិច្ចការនេះនឹងត្រូវពិភាក្សាដើម្បីស្វែងរកដំណោះស្រាយ។

## ៣.៤- យុទ្ធសាស្ត្រសម្រាប់វិស័យកសិកម្ម និងទឹក

យុទ្ធសាស្ត្រសម្រាប់វិស័យកសិកម្មនិងទឹក មានទស្សនៈវិស័យ “ធានាឱ្យមានស្បៀងនិងទឹកគ្រប់គ្រាន់ មានសុវត្ថិភាពសម្រាប់ប្រជាពលរដ្ឋគ្រប់រូបភាពក្រីក្រត្រូវបានកាត់បន្ថយ រួមចំណែកក្នុងការលូតលាស់សេដ្ឋកិច្ចជាតិ (បង្កើនផលិតផលសរុបក្នុងស្រុកសម្រាប់ប្រជាជនម្នាក់ៗ) និងធានាឱ្យបាននូវចីរភាពធនធានធម្មជាតិ ”។

រាជរដ្ឋាភិបាលកម្ពុជា បានរៀបចំយន្តការដើម្បីគៀងគរជំនួយនិងធនធានសំរាប់អនុវត្ត ជាពិសេសអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម និងយុទ្ធសាស្ត្រសម្រាប់វិស័យកសិកម្មនិងទឹក តាមរយៈយន្តការសហប្រតិបត្តិការទ្វេភាគី ពហុភាគី ជំនួយអភិវឌ្ឍន៍ផ្លូវការ និងយន្តការក្រុមការងារបច្ចេកទេសនានា។ ទស្សនវិស័យទិសដៅនិងកម្មវិធីរបស់យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មនិងយុទ្ធសាស្ត្រសម្រាប់វិស័យកសិកម្មនិងទឹកនេះ គឺសមស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទីពីររបស់រាជរដ្ឋាភិបាលកម្ពុជា និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម២០០៩-២០១៣ ហើយក៏ស្របតាមដំណើរការវិវឌ្ឍ និងនិន្នាការប្រកួតប្រជែងនៅលើទីផ្សារនៅក្នុងតំបន់ និងលើសកលលោក និងតាមតម្រូវការសេដ្ឋកិច្ចទីផ្សារសេរី។ ប្រការទាំងអស់នេះហើយ ដែលធ្វើឱ្យដៃគូអភិវឌ្ឍន៍នានាមានការចូលរួមយ៉ាងពេញទំហឹងក្នុងការកសាងយុទ្ធសាស្ត្រនេះ បាន

ផ្តល់ជំនួយទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុសម្រាប់គាំទ្រសកម្មភាពទាំងឡាយ ដែលមានចែងក្នុងយុទ្ធសាស្ត្រសម្រាប់វិស័យកសិកម្មនិងទឹកនេះ។

ផ្អែកលើទស្សនវិស័យរយៈពេលវែង យុទ្ធសាស្ត្រនេះមានគោលដៅរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ ធានាបាននូវសន្តិសុខស្បៀង និងការលូតលាស់សេដ្ឋកិច្ច តាមរយៈការបង្កើននូវផលិតភាពនិងពិពិធកម្មកសិកម្ម បង្កើនការអភិវឌ្ឍនិងគ្រប់គ្រងធនធានទឹក។ ដើម្បីសម្រេចបាននូវគោលដៅនេះ យុទ្ធសាស្ត្របានកំណត់នូវកម្មវិធីសំខាន់ចំនួន៥គឺៈ ទី(១) កម្មវិធីគាំទ្រដល់ការពង្រឹងសមត្ថភាពនិងគ្រប់គ្រងស្ថាប័នសម្រាប់វិស័យកសិកម្មនិងទឹកៈ ទី(២) កម្មវិធីគាំទ្រសន្តិសុខស្បៀង ទី(៣) កម្មវិធីគាំទ្រកសិកម្មនិងកសិពាណិជ្ជកម្ម ទី(៤) កម្មវិធីគ្រប់គ្រងធនធានទឹក ការស្រោចស្រពនិងដីធ្លី ទី(៥) កម្មវិធីស្រាវជ្រាវអប់រំនិងផ្សព្វផ្សាយសម្រាប់កសិកម្មនិងធនធានទឹក។

ដោយផ្អែកលើទិសដៅនេះ ក្រុមការងារបច្ចេកទេសកសិកម្មនិងទឹក ដែលមានក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងធនធានទឹកនិងឧតុនិយមនាំមុខ និងដោយមានការសម្របសម្រួលគាំទ្រពីដៃគូអភិវឌ្ឍន៍ បានកំណត់រៀបចំកម្មវិធីទាំង៥រួចជាស្ថាពរ។ ក្រុមការងារបច្ចេកទេសកសិកម្មនិងទឹក ដោយមានការជួយឧបត្ថម្ភគាំទ្រពីដៃគូអភិវឌ្ឍន៍ បានពិនិត្យនិងរៀបចំធ្វើសុខុដុមនីយកម្មកម្មវិធីទាំង៥នេះ ក្នុងគោលបំណងដើម្បីកំណត់អាទិភាពកម្មវិធីទាំងអស់ឱ្យមានលក្ខណៈស្របគ្នាទាក់ទងគ្នានិងតាមលំដាប់។ ជាលទ្ធផលការធ្វើសុខុដុមនីយកម្មកម្មវិធីនេះកំណត់បាននូវផ្នែក (Component) ចំនួន ០៦ ដែលរួមមានផ្នែកទី១: គោលនយោបាយ និងបទប្បញ្ញត្តិ ផ្នែកទី២: ការកសាងសមត្ថភាព ស្ថាប័ននិងការអភិវឌ្ឍ ធនធានមនុស្ស ផ្នែកទី៣: ការស្រាវជ្រាវនិងការអប់រំ ផ្នែកទី៤: សន្តិសុខស្បៀង ផ្នែកទី៥: ការគ្រប់គ្រងធនធានទឹកនិងដីកសិកម្ម និងផ្នែកទី៦: កសិពាណិជ្ជកម្មនិងទីផ្សារ។ ផ្នែកទាំង៦នៃកម្មវិធីនេះ គ្រោងនឹងប្រើប្រាស់ថវិកាសរុបប្រមាណ ៥០១ លានដុល្លារអាមេរិក សម្រាប់អនុវត្តរយៈពេល០៤ឆ្នាំ។

## ៤- កសិកម្មក្នុងកំណើនសេដ្ឋកិច្ចជាតិ

វិស័យកសិកម្មមានសារៈសំខាន់បំផុតក្នុងការចូលរួមចំណែកជំរុញកំណើនសេដ្ឋកិច្ចជាតិ ព្រោះវិស័យនេះអាចផ្តល់នូវប្រភពស្បៀងអាហារ សម្រាប់ជីវភាពប្រចាំថ្ងៃរបស់មនុស្សគ្រប់រូប ជាប្រភពផ្គត់ផ្គង់វត្ថុធាតុដើមចម្បងសម្រាប់ការអភិវឌ្ឍផ្នែកកសិឧស្សាហកម្មនិងជាប្រភពចំណូលជាតិសំខាន់ ដែលទទួលបានពីការធ្វើផលិតកម្ម និងការនាំចេញផលិតផលកសិកម្មចូលទៅក្នុងទីផ្សារអន្តជាតិ។ នេះគឺជាចំណុចគន្លឹះចំបងបំផុតដែលអាចបញ្ជាក់បានថា វិស័យកសិកម្មមានតួនាទីក្នុងការជំរុញការរីកលូតលាស់ផ្នែកសេដ្ឋកិច្ច។

តម្រូវការផលិតផលកសិកម្មសម្រាប់អាស៊ីមានការកើនឡើងយ៉ាងឆាប់រហ័ស។ ការកើនឡើងនេះ គឺធ្វើឱ្យកើនឡើងតម្លៃចំណីអាហារ និងការព្រួយបារម្ភចំពោះសុវត្ថិភាពស្បៀងដែលកំពុងបន្តកើតមាន។ តម្លៃវត្ថុធាតុដើមសម្រាប់ការប្រើប្រាស់ក្នុងវិស័យឧស្សាហកម្ម ដូចជាជ័រកៅស៊ូ រំពឹងថានឹងកើនឡើង ស្របគ្នានឹងនិន្នាការកើនឡើងនៃតម្លៃប្រេងផងដែរ។ ស្ថានភាពសេដ្ឋកិច្ចដែលប្រែប្រួល និងស្ថានភាពនៃការផ្គត់ផ្គង់ចំណីអាហារ អាចបង្កើនតម្រូវការផលិតផលកសិកម្ម។ ដោយគិតគូរពីកត្តាទាំងអស់នេះ វិស័យកសិកម្មត្រូវបានព្យាករណ៍ថានឹងរក្សាបានការអនុវត្តល្អប្រសើរក្នុងឆ្នាំ២០១៤ និងក្នុងរយៈពេលមធ្យមខាងមុខ។ ការនាំចេញផលិតផលកសិកម្ម ពិសេសការនាំចេញអង្ករ ត្រូវបានវាយតម្លៃថាមានការកើនឡើងដោយសាររាជរដ្ឋាភិបាលបានផ្តល់អាទិភាពខ្ពស់ដល់វិស័យនេះ ។

## ៤.១-វិស័យកសិកម្មក្នុងការកាត់បន្ថយភាពក្រីក្រ

វិស័យកសិកម្មមិនត្រឹមតែបានចូលរួមចំណែក ឱ្យមានកំណើនសេដ្ឋកិច្ចប៉ុណ្ណោះទេ គឺថែមទាំងបានចូលរួមចំណែកដ៏សំខាន់ក្នុងកិច្ចការសង្គម ក៏ដូចជាការចូលរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជាផងដែរ។ ពោលគឺវិស័យកសិកម្មអាចដោះស្រាយបាននូវការងារធ្វើរបស់ប្រជាជនរហូតដល់ប្រមាណជិត៧០% និងអាចចូលរួមមួយចំណែកធំដល់ការកាត់បន្ថយភាពក្រីក្រ តាមរយៈការធ្វើផលិតកម្មកសិកម្មនេះ។

ការខិតខំប្រឹងប្រែងកន្លងមករបស់រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការជំរុញការអភិវឌ្ឍវិស័យកសិកម្ម បានរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា ជាក់ស្តែងភាពក្រីក្របានថយចុះ

ពីកម្រិត៤៧% នៅឆ្នាំ១៩៩៤មកត្រឹម៣៤,៧% នៅឆ្នាំ២០០៤ អាត្រានៃភាពក្រីក្រនេះបានថយចុះមកនៅ៣០,១% នៅឆ្នាំ២០០៧ ហើយតាមការប៉ាន់ស្មានកន្លងមកនេះ បានបង្ហាញថាអាត្រានេះបានថយមកត្រឹមតែ២៦,១%នាឆ្នាំ២០១០។ ដូចនេះ យើងអាចវាយតម្លៃបានថា ជាមធ្យមភាគភាពក្រីក្របានថយចុះជាង ១% ក្នុងមួយឆ្នាំៗ។

សន្តិភាព ការបង្រួបបង្រួមជាតិ និងស្ថេរភាពសង្គមគឺជាកត្តាគន្លឹះសម្រាប់ការកសាងប្រទេស ពិសេសការអភិវឌ្ឍវិស័យកសិកម្មនេះ។ គោលនយោបាយគាំទ្រដល់ការរីកលូតលាស់នៃវិស័យកសិកម្ម ក៏ជាកត្តាជំរុញមួយទៀតយ៉ាងសំខាន់ក្នុងការអភិវឌ្ឍវិស័យនេះ ដែលធ្វើឱ្យសហគមន៍ផ្តល់ជំនួយនានា យកចិត្តទុកដាក់ជួយគាំទ្រយ៉ាងខ្លាំងក្លា។ រាជរដ្ឋាភិបាលកម្ពុជាបានជំរុញការអនុវត្តពហុវប្បកម្ម និងប្រពលវប្បកម្ម ដើម្បីធានាឱ្យបាននូវនិរន្តភាពនៃកំណើនសេដ្ឋកិច្ច បង្កើតការងារ និងបង្កើនប្រាក់ចំណូលនៅជនបទ ធានាសន្តិសុខស្បៀងសម្រាប់ប្រជាពលរដ្ឋទូទៅ។ ម្យ៉ាងវិញទៀត សក្តានុពលភាពសម្រាប់ការអភិវឌ្ឍវិស័យកសិកម្មដូចជា កត្តាដីកសិកម្មដែលអាចពង្រីកផលិតកម្មកសិកម្ម លទ្ធភាពបង្កើនទិន្នផលដំណាំ ប្រភពធនធានទឹកនិងការស្រោចស្រព កម្លាំងពលកម្មកសិកម្ម។ល។ នឹងអាចរុញការរីកលូតលាស់ សេដ្ឋកិច្ចជនបទ និងអាចធ្វើឱ្យមានការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនបន្ថែមទៀត។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានយកចិត្តទុកដាក់ជំរុញផលិតភាពកសិកម្ម ដោយខិតខំពង្រឹងថែមទៀតនូវប្រសិទ្ធភាពសេវាកម្មគាំទ្រដូចជាៈ ការងារស្រាវជ្រាវនិងផ្សព្វផ្សាយកសិកម្ម ការអភិវឌ្ឍនូវទីផ្សារកសិកម្មនិងបទដ្ឋានគតិយុត្តនានា ក៏បានកែលម្អបំពេញបន្ថែមនិងកសាងថ្មី ដែលបានជួយឱ្យការងារដឹកនាំអនុវត្តសកម្មភាពនានា មានលក្ខណៈប្រសើរនិងមានប្រសិទ្ធភាព ។

## ៤.២-កំណើនផលិតផលកសិកម្មឆ្នាំ ២០១១២

### ៤.២.១- ការចូលរួមចំណែករបស់វិស័យសេដ្ឋកិច្ចសំខាន់ៗក្នុង GDP ឆ្នាំ ២០១២ (Constant Price)




__*ប្រភពទិន្នន័យ:*__ តួលេខប៉ាន់ស្មានរបស់ក្រសួងផែនការខែមីនា ឆ្នាំ២០១៣

វិស័យកសិកម្មបានចូលរួមចំណែកប្រហែល២៧,៥%នៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ២០១២នេះ។ ដោយឡែកវិស័យឧស្សាហកម្មបានរួមចំណែកប្រមាណ៣១,១% និងវិស័យសេវាកម្មប្រហែល៤១,៤%។ ការកើនឬថយចុះនូវចំណែកនៃការចូលរួមរបស់វិស័យកសិកម្ម គឺអាស្រ័យទៅនឹងការរីកលូតលាស់នៃផ្នែកពីរសំខាន់ផ្សេងទៀតក្នុងវិស័យសេដ្ឋកិច្ច (វិស័យឧស្សាហកម្ម សំណង់ និងវិស័យសេវាកម្ម) ដែលជាការកត់សម្គាល់នាពេលកន្លងមក ការចូលរួមចំណែករបស់វិស័យកសិកម្មបានកើនឡើងពី២៨%-២៩% ក្នុងចន្លោះឆ្នាំ២០០៩-២០១០ ដោយសារតែវិស័យឧស្សាហកម្ម សំណង់ និងវិស័យសេវាកម្មមានសភាពទ្រឹងនិងមានសន្ទុះថយចុះ (ឥទ្ធិពលនៃវិបត្តិសេដ្ឋកិច្ចពិភពលោក)។ ប៉ុន្តែចាប់ពីឆ្នាំ២០១០ ដល់ឆ្នាំ២០១២ វិស័យឧស្សាហកម្ម និងវិស័យសេវាកម្មមានសន្ទុះរីកលូតលាស់ឡើងវិញជាបណ្តើរៗ។

### ៤.២.២-ការចូលរួមចំណែកជា % ផ្នែកកសិកម្មក្នុង GDP ចាប់ពីឆ្នាំ ២០០២-២០១២




គួរកត់សម្គាល់ដែរថា ការចូលរួមចំណែកជា%នៃផ្នែកកសិកម្មក្នុង GDP (គិតតាមថ្លៃស្ថេរឆ្នាំ២០០០) ជារួមមាននិន្នាកាថយចុះពី៣១,៥%នាឆ្នាំ២០០២ មកនៅត្រឹម២៦,៧% នៅឆ្នាំ២០០៧ និងកើនឡើងវិញប្រមាណពី២៦,៨%នៅឆ្នាំ២០០៨ ដល់២៩% នៅឆ្នាំ២០១០។ សភាពការណ៍នេះ បានបង្ហាញអំពីភាពប្រកួតប្រជែងរីកចំរើនរួមនៃវិស័យសេដ្ឋកិច្ចទាំងបីរបស់កម្ពុជា ហើយក្នុងនោះវិស័យកសិកម្មនៅតែបន្តរីកចម្រើនទាំងបរិមាណនិងគុណភាព។ ឆ្នាំ២០១១កន្លងទៅនេះ ការចូលរួមចំណែករបស់កសិកម្មក្នុង GDP មានចំនួន២៨,៤% និងនៅឆ្នាំ២០១២នេះ មានប្រហែល២៧,៥% (តាមការប៉ាន់ស្មានជំហ៊ានដំបូងរបស់វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ)។

### ៤.២.៣-តម្លៃបន្ថែមសរុប (GVA) ផ្នែកកសិកម្មចាប់ពីឆ្នាំ ២០០៣-២០១២




ការធ្លាក់ចុះនូវចំណែក (%) របស់វិស័យកសិកម្មក្នុង GDP រយៈពេល៦ឆ្នាំកន្លងមក (២០០២-២០០៧) មិនមែនមានន័យថាផលិតកម្មកសិកម្មធ្លាក់ចុះនោះទេ។ ផ្ទុយទៅវិញ តម្លៃបន្ថែមសរុបនៃផលិតផលកសិកម្ម (Gross Value Added-GVA) បានកើនឡើងពី៥.១០៨ពាន់លានរៀលនៅឆ្នាំ២០០២ រហូតដល់៧.១៧៤ពាន់លានរៀលនៅឆ្នាំ២០០៧ (កើនប្រហែលជាង៤០%) និងបានបន្តកើនថែមទៀតដល់៨.៩៣៥ពាន់លានរៀលឆ្នាំ២០១២នេះ (តម្លៃគិតតាមថ្លៃថេរឆ្នាំ២០០០)។

### ៤.២.៤-កំណើន ( %) នៃវិស័យកសិកម្មចាប់ពីឆ្នាំ ១៩៩៩-២០១២




ជារួមកំណើន (%) នៃវិស័យកសិកម្ម មានការកើនឡើងជាមធ្យមប្រចាំឆ្នាំប្រមាណជាពី៣ទៅ៥% (២០០៧-២០១២) កំណើនមានការប្រែប្រួលយ៉ាងខ្លាំងពីមួយឆ្នាំទៅមួយឆ្នាំដូចដែលបានបង្ហាញតាមក្រាហ្វិកខាងលើ ហើយការប្រែប្រួលនេះ មានពាក់ព័ន្ធទៅនឹងស្ថានភាពអាកាសធាតុនៃឆ្នាំនីមួយៗ។ ដូចនេះ វិស័យកសិកម្មគឺពឹងផ្អែកច្រើននៅឡើយលើកត្តាធម្មជាតិដែលជះឥទ្ធិពលដល់ផលិតកម្មកសិកម្ម។

នៅឆ្នាំ២០១២ កំណើននៃវិស័យកសិកម្មបានកើនឡើងវិញ ដែលតាមការប៉ាន់ស្មានគឺមានចំនួនប្រមាណជា ៤,៣%។ នាឆ្នាំ២០០៣ វិស័យកសិកម្មកើនក្នុងរង្វង់ប្រហែល១០,៥% និងនៅឆ្នាំ២០០៥ កើនខ្លាំងរហូតដល់១៥,៧% (អាស្រ័យដោយភាពអនុគ្រោះខ្លាំងពីធម្មជាតិ ពិសេសកត្តាទឹកភ្លៀង និងមិនមានបញ្ហាសត្វល្អិតបំផ្លាញ)។ នៅឆ្នាំ២០០៦ វិស័យកសិកម្មបានកើនប្រមាណ៥,៥% និងឆ្នាំ២០០៩ មានកំណើនប្រហែល៥,៤% និងឆ្នាំ២០១០ កំណើនមានត្រឹមតែ ៤%។ ដោយឡែកឆ្នាំ២០១១ កំណើនបានធ្លាក់ចុះប្រហែលជាង៣,៣% ដែលនេះគឺជាឥទ្ធិពលនៃគ្រោះទឹកជំនន់នៅរដូវវស្សាឆ្នាំ២០១១កន្លងទៅ។ គួរកត់សម្គាល់ដែរថា នៅឆ្នាំ២០០០ ២០០២ និង២០០៤ កំណើនផ្នែកកសិកម្មជាចំនួនអវិជ្ជមាននេះ គឺអាស្រ័យដោយការជួបប្រទះធ្ងន់ធ្ងរពីកត្តាធម្មជាតិ ដែលរួមមាន ទឹកជំនន់ រាំងស្ងួត និងការបំផ្លាញដំណាំដោយសត្វចង្រៃ។

### ៤.២.៥-សមាសភាគនៃអនុវិស័យក្នុងវិស័យកសិកម្មឆ្នាំ២០១២




ពិនិត្យជារួមយើងសង្កេតឃើញថា នៅក្នុងវិស័យកសិកម្មទាំងមូល សមាសភាគចូលរួមចំណែកគិតជា (%) របស់ផលិតកម្មដំណាំគ្រប់ប្រភេទនាឆ្នាំ២០១២ មានចំនួនជាងពាក់កណ្ដាល ពោលគឺកើនដល់៥៤,៨%នៃផលិតផលសរុបរបស់

វិស័យកសិកម្ម។ ផលិតកម្មនេសាទ បានចូលរួមចំណែកច្រើនបន្ទាប់ពីដំណាំ គឺមានប្រមាណ២៥,៤% ផលិតកម្មសត្វ បានចូលរួម១៤,១% និងអាជីវកម្មព្រៃឈើមានត្រឹមតែ៥,៧%ប៉ុណ្ណោះ។

ផលិតកម្មដំណាំ ពិសេសស្រូវនៅតែជាមុខដំណាំសំខាន់សម្រាប់ការរកចំណូលរបស់កសិករ។ មុខរបរអាជីវកម្មបន្ទាប់ គឺអាចសន្និដ្ឋានថាអាជីវកម្មនេសាទ (មានសមាសភាគប្រមាណ ២៥-២៧%) និងផលិតកម្មសត្វមានការចូលរួមតិចជាងអាជីវកម្មនេសាទ (១២,៨-១៥,៥% ក្នុងកំឡុងពេល៥ឆ្នាំកន្លងទៅនេះ ២០០៨-២០១២)។ ដោយឡែក អាជីវកម្មព្រៃឈើមាននិន្នាការថយចុះជាបន្តបន្ទាប់ (សមាសភាគចូលរួមក្នុងវិស័យកសិកម្មមានត្រឹមតែប្រមាណ៥,៧% នាឆ្នាំ២០១២)។

### ៤.២.៦-សមាសភាគនៃអនុវិស័យក្នុងវិស័យកសិកម្ម




ការបង្ហាញតាមក្រាហ្វិកឃើញថា ផ្នែកដំណាំមានការកើនឡើងយ៉ាងខ្លាំង ដែលសមាសភាគរបស់ផ្នែកនេះមានចំនួន៥២,២% នៅឆ្នាំ២០០៧ និងមាននិន្នាការកើនឡើងដល់៥៤% នៅឆ្នាំ២០១១ និងកើនឡើងរហូតដល់៥៤,៨%នៅឆ្នាំ២០១២។ សមាសភាគនៃផ្នែកផលិតកម្មដំណាំនេះបានកើនប្រហែល៤,៩% បើប្រៀបធៀបនឹងឆ្នាំ២០០៧។ ចំពោះ សមាសភាគផ្នែកជលផលមានការប្រែប្រួលពី២៤,៨%នៅឆ្នាំ២០០៧ (ផ្នែកនេះបានទទួលរងនូវកត្តាជះឥទ្ធិពលទឹកទន្លេ) កើនរហូតដល់២៥,៤%នាឆ្នាំ២០១២។ ដោយឡែកសមាសភាគចូលរួមផ្នែកអាជីវកម្មព្រៃឈើ មានការថយចុះជាបន្តបន្ទាប់បើធៀបនិងឆ្នាំ២០០៧ ពី៧,៣%មកត្រឹមតែ៦%នៅឆ្នាំ២០១១ និង៥,៧%នៅឆ្នាំ២០១២។ រីឯសមាសភាគផ្នែកផលិតកម្មសត្វមានការប្រែប្រួលនិងថយចុះ បើធៀបរយៈពេលឆ្នាំ៥កន្លងទៅនេះ (១៥,៥%ឆ្នាំ២០០៨ ថយមកត្រឹម១២,៨%ឆ្នាំ២០១០ ១៥% ឆ្នាំ២០១១ និង១៤,១%ឆ្នាំ២០១២)។

## ៤.៣-ការវិវឌ្ឍនៃផលិតកម្មកសិកម្មរយៈពេល ៥ ឆ្នាំ

### ៤.៣.១-ការវិវឌ្ឍផលិតកម្មដំណាំស្រូវ

ផលិតកម្មស្រូវ នៅតែជាផលិតកម្មចម្បងមួយសម្រាប់ទ្រទ្រង់ជីវភាពប្រជាជននៅជនបទស្ទើរតែទាំងអស់ នៅក្នុងប្រទេសកម្ពុជា។ ក្នុងរយៈពេលកន្លងមកនេះ ក្រោមការខិតខំប្រឹងប្រែងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមការណែនាំនិងតម្រង់ទិសរបស់រាជរដ្ឋាភិបាល ដោយមានការចូលរួមដ៏សកម្មពីគ្រប់ក្រសួងស្ថាប័ន អាជ្ញាធរមូលដ្ឋាន និងប្រជាកសិករទូទាំងប្រទេស ព្រមទាំងការរួមចំណែកពីដៃគូអភិវឌ្ឍន៍ បានធ្វើឱ្យផលិតកម្មកសិកម្មមានការវិវឌ្ឍន៍រីក ចម្រើនឡើងគួរឱ្យកត់សម្គាល់។

ជាក់ស្តែងផលិតកម្មស្រូវប្រចាំឆ្នាំ២០១២នេះ ពិតមែនតែមានភាពមិនប្រក្រតីនៃបាតុភូតធម្មជាតិ ក៏ស្ថានភាពផលិត កម្មកសិកម្មជារួមមានកម្រិតល្អប្រសើរទូទាំងប្រទេស។ ផលិតកម្មដំណាំស្រូវអនុវត្តបានសរុបប្រមាណ**៣**លានហត ផ្ទៃដីអាចប្រមូលផលបានមានចំនួន**២,៩៨**លានហត និងទិន្នផលមធ្យមប្រចាំឆ្នាំទទួលបានចំនួន**៣,១១៧ត/ហត**។ ផ្ទៃដីចំនួន ៣៦.០៦៧ ហត ត្រូវបានទទួលរងដោយគ្រោះធម្មជាតិនាឆ្នាំ២០១២កន្លងទៅនេះ ពិសេសគ្រោះទឹកជំនន់ទឹកភ្លៀង រាំងស្ងួត និងសត្វល្អិត

បំផ្លាញ។ តែទោះជាយ៉ាងណាក្តី កម្ពុជាអាចទទួលបានបរិមាណផលស្រូវជាង**៩,២៩**លានតោន និងអាចសល់ស្បៀងជាអង្ករប្រមាណ**៣លានតោន** (បរិមាណស្បៀងសល់គិតជាស្រូវនៅសល់ប្រមាណជាង**៤,៧**លានតោន)។

ក្នុងអំឡុងរយៈពេល៥ឆ្នាំ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបញ្ចេញពូជស្រូវថ្មីៗចំនួន ០៣ពូជបន្ថែមទៀតគឺ ផ្ការមៀត ផ្ការំដេង និងផ្កាច័ន្ទសែនសរ។ គួរកត់សម្គាល់ថា រាជរដ្ឋាភិបាលកម្ពុជាបានកំណត់យកឆ្នាំ២០១៥ ជាឆ្នាំគោល ដើម្បីជំរុញការផលិតស្រូវលើសឱ្យបានច្រើនជាង៤លានតោន និងគិតជាបរិមាណអង្ករសម្រាប់នាំចេញជាផ្លូវការត្រូវសម្រេចឱ្យបានយ៉ាងតិច១លានតោន (ចំណុចទី៧នៃឯកសារគោលនយោបាយ) និងតាមការកំណត់សូចនាករអតិរេកស្រូវសម្រាប់ឆ្នាំ២០១២ ត្រូវសម្រេចឲ្យបាន៣,៨លានតោនស្រូវ ប៉ុន្តែអតិរេកស្រូវសម្រេចបានមានរហូតដល់៤,៧លានតោននាឆ្នាំ២០១២ គឺលើសផែនការកំណត់។ នេះជាជោគជ័យមួយគួរជាទីមោទន៍ៈបំផុត សម្រាប់កម្ពុជាក្នុងការជំរុញផលិតកម្មដំណាំស្រូវ។

**តារាង÷ ប្រៀបធៀបកំណើនដំណាំស្រូវប្រចាំឆ្នាំ២០០៨-២០១២**

| **បរិយាយ** | ២០០៨ | ២០០៩ | ២០១០ | ២០១១ | ២០១២ | ប្រៀបធៀប កើន/ថយ ២០១២/២០១១ |
|---|---|---|---|---|---|---|
| ផ្ទៃដីដាំដុះ (ហត) | 2,615,741 | 2,719,080 | 2,795,892 | 2,968,529 | 3,007,545 | **1.31%** |
| ផ្ទៃដីប្រមូលផល (ហត) | 2,613,363 | 2,674,603 | 2,777,323 | 2,766,617 | 2,980,297 | **7.72%** |
| ទិន្នផល (តោន/ហត) | 2.746 | 2.836 | 2.970 | 3.173 | 3.117 | **-1.76%** |
| បរិមាណផល (តោន) | 7,175,473 | 7,585,870 | 8,249,452 | 8,779,365 | 9,290,940 | **5.83%** |
| ***បរិមាណអង្ករសល់ (mt)*** | ***2,025,033*** | ***2,244,598*** | ***2,516,752*** | ***2,780,328*** | ***3,031,017*** | **9.02%** |
| ***គិតជាស្រូវសល់ (mt)*** | ***3,164,114*** | ***3,507,185*** | ***3,932,425*** | ***4,344,263*** | ***4,735,964*** | **9.02%** |

**ក្រាហ្វិកទី ១ ÷ បង្ហាញសមាសភាគចូលរួមនៃផ្ទៃដីដាំដុះស្រូវវស្សាតាមប្រភេទឆ្នាំ២០១២**




ជារួមពីមួយឆ្នាំទៅមួយឆ្នាំ ទាំងផ្ទៃដីអនុវត្ត ផ្ទៃដីប្រមូលផល និងបរិមាណផល មានការរីកចម្រើនឡើងជាលំដាប់ សមិទ្ធផលទទួលបានទាំងនេះ ក៏ដោយមានការគាំទ្រពីរាជរដ្ឋាភិបាល ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ជាពិសេសគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការជំរុញផលិតកម្មស្រូវនិងនាំចេញអង្ករ បានជួយធ្វើឱ្យវិស័យកសិកម្មមានដំណើរការល្អគួរលាស់ទាំងការងារ

គ្រប់គ្រងទាំងបច្ចេកទេសដាំដុះ ដោយបានបង្កើនការអប់រំណែនាំដល់ប្រជាកសិករឱ្យកែប្រែទន្លាប់ចាស់ បង្កើនចំណេះដឹងក្នុងផលិតកម្ម និងបច្ចេកទេសកែច្នៃផលិតផលកាន់តែប្រសើរឡើង។

កសិករបានបង្កើនផ្ទៃដីដាំដុះប្រភេទស្រូវកណ្ដាល ដែលមានប្រមាណ៤៧% (ប្រជាកសិករទទួលយកនូវបច្ចេកទេសសម្រាប់ដាំដុះប្រភេទស្រូវនេះច្រើន) ប្រភេទស្រូវស្រាលមានប្រមាណ២៧% និងស្រូវធ្ងន់មានប្រហែល២១%។ ដោយឡែកស្រូវចំការ និងស្រូវឡើងទឹកមានសមាសភាគតិចតួច (ស្រូវចំការ២% និងស្រូវឡើងទឹក៣%)។

**ក្រាហ្វិកទី ២ ÷ បង្ហាញការវិវត្តន៍នៃផ្ទៃដីដាំដុះនិងផ្ទៃដីប្រមូលផលចាប់ពីឆ្នាំ២០០៣-២០១២ (រយៈពេល ១០ ឆ្នាំ)**




ផលិតកម្មស្រូវរដូវវស្សាមានចំណែកប្រមាណជាង៨៤% នៃផ្ទៃដីផលិតកម្មស្រូវទូទាំងប្រទេស។ ប្រទេសកម្ពុជាទទួលរងនូវគ្រោះទឹកជំនន់ទឹកភ្លៀងនិងរាំងស្ងួតនៅតាមបណ្ដារាជធានីខេត្តចំនួន១២ក្នុងទូទាំងប្រទេស បានធ្វើឱ្យផ្ទៃដីប្រមូលផលថយចុះ ប៉ុន្តែបរិមាណស្រូវនៅតែបន្តកើនឡើង។ ផ្ទៃដីដាំដុះស្រូវរដូវវស្សាឆ្នាំ២០១២ សម្រេចបានប្រមាណ**២,៥១**លានហាត ដែលមានទិន្នផលជាមធ្យមចំនួន**២,៨៧**ត/ហាត ដោយទទួលបរិមាណផលសរុបប្រមាណជាង**៧,១៤**លានតោន និងស្រូវរដូវប្រាំង២០១២-២០១៣ សម្រេចបានលើផ្ទៃដីដាំដុះជាង**០,៤៩៥**លានហិកតា ទទួលបានទិន្នផលជាមធ្យម**៤,៣៥**ត/ហាត ដោយ ទទួលបានបរិមាណផលសរុបជាង**២,១៥**លានតោន។

**តារាង÷បង្ហាញពីផលិតកម្មដំណាំស្រូវវស្សានិងប្រាំងឆ្នាំ២០១២-២០១៣**

| **កំរិតកំណត់** | **ឯកត្តា** | **រដូវវស្សា** | **រដូវប្រាំង** | **សរុប** |
|---|---|---|---|---|
| ផែនការដាំដុះ | ហត | 2,369,730 | 366,561 | **2,736,291** |
| ផ្ទៃដីអនុវត្ត | ហត | 2,512,038 | 495,507 | **3,007,545** |
| ផ្ទៃដីខូចខាត | ហត | 36,025 | 42 | **36,067** |
| ផ្ទៃដីស្តារបាន | ហត | 8,819 | - | **8,819** |
| ផ្ទៃដីប្រមូលផល | ហត | 2,484,832 | 495,465 | **2,980,297** |
| ទិន្នផលមធ្យម | ត/ហត | 2.872 | 4.349 | **3.117** |
| បរិមាណផល | តោន | 7,136,139 | 2,154,801 | **9,290,940** |

**ក្រាហ្វិកទី ៣ ÷ បង្ហាញការវិវត្តន៍នៃបរិមាណផលស្រូវប្រចាំឆ្នាំ២០០៣-២០១២**




ក្នុងរយៈពេល១០ឆ្នាំចុងក្រោយពីឆ្នាំ២០០៣ដល់ឆ្នាំ២០១២ យើងពិនិត្យឃើញថា បរិមាណផលស្រូវសរុប ប្រចាំឆ្នាំក៏ដូចជាបរិមាណផលស្រូវរដូវវស្សា និងស្រូវរដូវប្រាំងមានការកើនឡើងជាលំដាប់ ទោះបីផ្នែកនេះបានជួបប្រទះ នូវគ្រោះធម្មជាតិដូចជា: ទឹកជំនន់ រាំងស្ងួត និងសត្វល្អិតបំផ្លាញខ្លះៗក៏ដោយ។ នៅឆ្នាំ២០១២នេះ បរិមាណផលសរុបកើនឡើងជាងឆ្នាំ២០១១ប្រមាណ៥១២.៨៩៦តោន ស្មើនឹង៥,៨% ដោយសារការខិតខំស្តារឡើងវិញនូវផ្ទៃដីដែលបានខូចខាត និងម្យ៉ាងទៀតគឺអាស្រ័យដោយប្រជាកសិករមានភាពរីកចម្រើនក្នុងការគ្រប់គ្រងស្រែចំការ ការផ្លាស់ប្តូរបច្ចេកទេស និងការផ្លាស់ប្តូរពូជដែលមានទិន្នផលខ្ពស់។

### ក្រាហ្វិកទី ៤ ÷ បង្ហាញអំពីកំណើនផលិតកម្មស្រូវពីឆ្នាំ ២០០៨-២០១២




កំណើននៃផលិតកម្មដំណាំស្រូវមានការប្រែប្រួលតាមឆ្នាំនីមួយៗ អាស្រ័យដោយលក្ខខណ្ឌនិងភាពអនុគ្រោះនៃកត្តាទឹកនិងសមត្ថភាពទប់ទល់ស្តារពីការខូចខាត។ ទន្ទឹមនឹងនោះ បើប្រៀបធៀបទៅនឹងឆ្នាំ២០១១ ផ្ទៃដីអនុវត្តដាំដុះបានកើនប្រហែល ១,១% តែផ្ទៃដីប្រមូលផលកើន៧,៥% និងបរិមាណផលកើន៥,៨%។ ជារួមផលិតផលស្រូវបានកើនឡើងធៀបនឹងឆ្នាំកន្លងមកដែលទាំងអស់នេះ គឺដោយមានការគាំទ្រពីរាជរដ្ឋាភិបាលកម្ពុជា ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរថ្នាក់ក្រោមជាតិ បានជំរុញឱ្យវិស័យកសិកម្មមានដំណើរការល្អគួរសមទាំងបរិមាណនិងគុណភាព ពិសេសការគ្រប់គ្រងទាំងផ្នែកបច្ចេកទេស ដាំដុះ និងការកែច្នៃផលិតផលកាន់តែប្រសើរឡើង។

### ៤.៣.២- ការអភិវឌ្ឍន៍ដំណាំកសិកម្ម ៤ មុខពីឆ្នាំ២០០៤-២០១២

ក្រាហ្វិកទី ៥ ÷ បង្ហាញអំពីផ្ទៃដីដំណាំ ៤ មុខ ឆ្នាំ ២០០៤-២០១២ (ពោត ដំឡូងមី សណ្តែកបាយ និងសណ្តែកសៀង)




តារាង: **ផ្ទៃដីដាំដុះដំណាំរដូវសំខាន់ៗ៤មុខ÷** (ឯកតា: គិតជាហត)

| *មុខដំណាំ* | *2003* | *2004* | *2005* | *2006* | *2007* | *2008* | *2009* | *2010* | *2011* | *2012* |
|---|---|---|---|---|---|---|---|---|---|---|
| **ពោត** | 93,362 | 91,203 | 90,732 | 108,836 | 142,391 | 163,106 | 206,058 | 213,622 | 174,257 | 216,330 |
| **ដំឡូងមី** | 25,740 | 22,749 | 30,032 | 97,918 | 108,122 | 179,945 | 160,326 | 206,226 | 391,714 | 361,854 |
| **សណ្តែកបាយ** | 44,940 | 39,089 | 60,570 | 85,140 | 65,261 | 45,605 | 49,599 | 69,206 | 68,111 | 66,850 |
| **សណ្តែកសៀង** | 53,064 | 84,886 | 118,760 | 75,053 | 76,981 | 74,413 | 96,388 | 103,198 | 70,584 | 71,337 |
| **សរុបដំណាំ៤មុខ** | **217,106** | **237,927** | **300,094** | **366,947** | **392,755** | **463,069** | **512,371** | **592,252** | **704,666** | **716,370** |

ជារួមផ្ទៃដីដាំដុះដំណាំរដូវ មានការប្រែប្រួលចុះឡើងទៅតាមប្រភេទដំណាំនីមួយៗ ហើយក៏អាស្រ័យទៅតាមឥទ្ធិពលនៃកត្តាថ្លៃនិងទីផ្សារ។ ផ្ទៃដីដាំដុះដំណាំសំខាន់ៗ (ពោត ដំឡូងមី សណ្តែកបាយ សណ្តែកសៀង) មាននិន្នាការកើនឡើងគួរឱ្យកត់សម្គាល់ គឺកើនឡើងបានពី ៧០៤.៦៦០ហត(ឆ្នាំ២០១១) ដល់ ៧១៦.៣៧០ហត(ឆ្នាំ២០១២) ពោលគឺកើនប្រហែល ១,៦៦%។

ផ្ទៃដីដាំដុះដំណាំរួមផ្សំនិងដំណាំឧស្សាហកម្មសរុបទូទាំងប្រទេសសម្រាប់ឆ្នាំ២០១២ សម្រេចដាំដុះបានលើផ្ទៃដីប្រមាណ ៩១២.៨៨០ហត កើនលើសឆ្នាំមុន៦,៥% (ឆ្នាំ២០១១សម្រេចបាន៨៥៦.៧៧៧ហត) និងបរិមាណផលសរុបនៃដំណាំរួមផ្សំនិងដំណាំឧស្សាហកម្មប្រចាំឆ្នាំក៏មានការកើនឡើងដែរ គឺបានកើនពី៩,៩៣លានតោននាឆ្នាំ២០១១ ដល់១០,៨៥លាន តោននាឆ្នាំ២០១២ (កើនប្រមាណ៩,២៦%) ព្រមទាំងបានបញ្ចេញពូជសណ្តែកបាយថ្មីៗចំនួន០៣ពូជគឺ CMB1 CMB2 និង CMB3។ ទន្ទឹមនឹងនោះ ផ្ទៃដីដាំដុះដំណាំអចិន្ត្រៃយ៍ អនុវត្តបានសរុបចំនួន ១៩៣.៧៥១ហត កើនលើសឆ្នាំមុន១៧,៥% (ឆ្នាំ២០១១មានតែ១៦៤.៨៤០ហត)។ ដូចនេះ ផ្ទៃដីដាំដុះដំណាំទូទាំងប្រទេសសម្រេចបាន ៤,៣៩លានហត (ផ្ទៃដីដាំដុះដំណាំស្រូវចំនួនជាង៣លានហត ផ្ទៃដីដាំដុះដំណាំរួមផ្សំនិងដំណាំ ឧស្សាហកម្មចំនួន០,៩១លានហត ផ្ទៃដីដាំដុះដំណាំអចិន្ត្រៃយ៍ចំនួន០,១៩លានហត និងកៅស៊ូ០,២៨លានហត)។

**តារាង: ផ្ទៃដីដាំដុះដំណាំគ្រប់ប្រភេទឆ្នាំ២០១២ (ហត)**

| ផ្ទៃដីដំណាំគ្រប់ប្រភេទ | ឆ្នាំ២០១២ | សេចក្តីផ្សេងៗ |
|---|---|---|
| ផ្ទៃដីដំណាំស្រូវ | 3,007,545 | ស្រូវវស្សានិងប្រាំង |
| ផ្ទៃដីដំណាំរួមផ្សំនិងដំណាំឧស្សាហកម្ម | 912,883 | ពោត ដំឡូងឈើ ដំឡូងជ្វា បន្លែ ស |
| ផ្ទៃដីដំណាំអចិន្ត្រៃយ៍ | 193,751 | ស្វាយចន្ទី ចេក ដូងប្រេង ដូង មៀន |
| ផ្ទៃដីដំណាំកៅស៊ូ | 280,355 | |
| **សរុបរួម** | 4,394,338 | |

## ៤.៣.៣- ការវិវឌ្ឍវិស័យផលិតកម្មនិងបសុព្យាបាលសត្វ

**ក្រាហ្វិកទី ៦ ÷ បង្ហាញអំពីការវិវត្តន៍សត្វនៅកម្ពុជាពីឆ្នាំ២០០៨-២០១២**




ជារួមផលិតកម្មសត្វជាលក្ខណៈគ្រួសារនៅកម្ពុជា ជាពិសេស គោ ក្របី និងបក្សីមានការវិវឌ្ឍគួរកត់សម្គាល់ទាំងចំនួនសត្វទាំងបែប ផែនផលិតកម្ម ដោយផលិតកម្មនេះ អាចធានាការផ្គត់ផ្គង់សេចក្ដីត្រូវការក្នុងស្រុក និងកន្លងមកគោ ក្របីមួយចំនួនត្រូវបាននាំចេញទៅបរទេស។ ដោយធ្វើការប្រៀបធៀបផលិតកម្មសត្វរយៈពេល៥ឆ្នាំ (២០០៨-២០១២) ឃើញថាផលិតកម្មគោបានថយចុះចំនួន២,៣៤%។ ដោយឡែក បើប្រៀបធៀបនឹងឆ្នាំ២០១១ ការចិញ្ចឹមគោបានថយចុះពី៣,៤លានក្បាល មកត្រឹម៣,៣៨លានក្បាល ថយចុះប្រមាណ០,៨៦% រីឯក្របីសរុបមានចំនួនជាង៦៥៧ពាន់ក្បាល ថយចុះ៤,៧៦% និងជ្រូកចិញ្ចឹមបានជាង២,២លានក្បាល កើនប្រមាណ៥,២១%។ ការថយចុះចំពោះសត្វគោក្របីនេះ គឺមូលហេតុបណ្ដាលមកពីជម្ងឺឆ្លងសត្វ (ពិសេសជំងឺសារទឹក ជំងឺអុតក្ដាម និងជំងឺជ្រូកត្រចៀកខៀវ) ចលនាពាណិជ្ជកម្មសត្វនាំចូលនាំចេញមិនផ្លូវការ។ល។ ជាពិសេសប្រជាកសិករភាគច្រើនប្រើប្រាស់ត្រាក់ទ័រនិងគោយន្ត និងបានបោះបង់ចោលការចិញ្ចឹមគោក្របី។

**ក្រាហ្វិកទី ៧ ÷ បង្ហាញអំពីបម្រែបម្រួលស្ថិតិសត្វស្លាប (មាន់ទា) នៅកម្ពុជាពីឆ្នាំ២០០៨-២០១២**




ការចិញ្ចឹមសត្វស្លាប (មាន់ ទា) ជាលក្ខណៈគ្រួសារពីឆ្នាំ២០០៨ដល់២០១២ មានការកើនឡើងយ៉ាងខ្លាំងរហូតដល់៣៦% គឺពីជាង១៦,៩២លានក្បាលឆ្នាំ២០០៨ ដល់ជាង២៣លានក្បាលឆ្នាំ២០១២។ ជាមួយនោះ ឆ្នាំ២០១២ សត្វស្លាបមានការកើនឡើងចំនួន៤,៨២% បើប្រៀបធៀបនឹងឆ្នាំ២០១១ នេះបញ្ជាក់ឱ្យឃើញថា ប្រជាកសិករយល់ដឹងជាបណ្ដើរៗ នូវបច្ចេកទេសចិញ្ចឹមសត្វតាមគោលការណ៍ជីវសុវត្ថិភាព និងការយល់ដឹងពីវិធានការទប់ស្កាត់ជំងឺឆ្លង។ ជាពិសេសការផ្សព្វផ្សាយទូលំទូលាយក្នុងជួរកសិករ ដែលជាលទ្ធផលចំនួនសត្វស្លាប មានការកើនឡើង និងធានាបាននូវការផ្គត់ផ្គង់សាច់ ស៊ុត នៅក្នុងប្រទេស និងកសិកដ្ឋានផលិតកម្មមានលក្ខណៈស្របច្បាប់ជាបណ្ដើរៗដែរ។ គួរកត់សម្គាល់ថា មានករណីជម្ងឺកើតសត្វស្លាប

កើតមាននៅតំបន់មួយចំនួន ប៉ុន្តែត្រូវបានការពារបានយ៉ាងមានប្រសិទ្ធភាព។ ទន្ទឹមនោះ ពាក់ព័ន្ធនឹងការងារផលិតកម្ម និងបសុព្យាបាលនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានដាក់ចុះនូវវិធានការមួយចំនួន ដើម្បីជំរុញការចិញ្ចឹមសត្វស្លាបទាំងកម្រិតគ្រួសារ និងកម្រិតកសិដ្ឋាន ក៏ដូចជាបានលើកទឹកចិត្តវិនិយោគលើការចិញ្ចឹមមាន់សាច់ និងស៊ុត។

ជារួមការចិញ្ចឹមសត្វមាននិន្នាការរីកចម្រើនតាមបែបគ្រួសារនិងបែបពាណិជ្ជកម្មគួរឲ្យកត់សម្គាល់ បើធៀបនឹងឆ្នាំមុន លើកលែងការចិញ្ចឹមគោក្របី។ ប៉ុន្តែចំពោះការកែលម្អពូជសត្វ គឺកំពុងតែឈានឆ្ពោះទៅមុខជាបណ្តើរផងដែរ ព្រោះប្រជាកសិករភាគច្រើន កាន់តែមានការយល់ដឹងពីការជ្រើសរើសពូជសត្វជាកត្តាសំខាន់ ដែលផ្តល់ទិន្នផលខ្ពស់ ការលូតលាស់ឆាប់រហ័សធន់នឹងជំងឺ និងផ្តល់ប្រាក់ចំណូលគ្រួសារបានឆាប់ទៀតផង។ ចំណែកឯចំណីសត្វ និងដំណាំចំណីសត្វ ប្រជាកសិករ មានការចូលរួមយ៉ាងសកម្ម និងយល់ដឹងខ្ពស់លើការប្រើប្រាស់ចំណីសត្វ និងចំណីផ្សំស្រេចក្នុងស្រុកយ៉ាងផុសផុល។

### ៤.៣.៤- ការអភិវឌ្ឍវិស័យកៅស៊ូ

កៅស៊ូធម្មជាតិគឺជាប្រភេទដំណាំឧស្សាហកម្មរយៈពេលវែងមួយយ៉ាងសំខាន់ ដែលបានផ្តល់ផលប្រយោជន៍ដល់សេដ្ឋកិច្ចជាតិ ដល់សង្គម ដល់អ្នកដាំ និងដែលបានចូលរួមចំណែកយ៉ាងសកម្មនៅក្នុងការការពារបរិស្ថានធម្មជាតិប្រកបដោយចីរភាព។

នៅឆ្នាំ២០១២ ផ្ទៃដីដាំដុះកៅស៊ូនៅកម្ពុជាបានកើនដល់ចំនួន២៨០.៣៥៥ហត គឺកើនឡើង៣១,៥% បើប្រៀបធៀបទៅនឹងឆ្នាំ២០១១ ដែលមានផ្ទៃដីដាំកៅស៊ូចំនួន២១៣.១០៤ហតហត ក្នុងនោះ ផ្ទៃដីចម្ការកៅស៊ូកសិឧស្សាហកម្មមានស្រាប់ចំនួន៥៤.២០៩ហត ក្រុមហ៊ុនវិនិយោគលើដីសម្បទានសេដ្ឋកិច្ចបានដាំដុះចំនួន១១៨.៤៤៩ហត និងផ្ទៃដីកៅស៊ូគ្រួសារមានចំនួន១០៧.៦៩៦ ហត។

**ស្ថិតិផ្ទៃដីចម្ការកៅស៊ូឆ្នាំ២០១២**

| ប្រភេទចម្ការកៅស៊ូ | ផ្ទៃដី (គិតជាហត) | | | | សមាមាត្រ |
|---|---|---|---|---|---|
| | សម្បទាន | ចៀរជ័រ | ថែទាំ | សរុប | % |
| កៅស៊ូកសិឧស្សាហកម្ម | ៧៣.៩០៦ | ២៤.០៦២ | ៣០.១៤៦ | ៥៤.២០៩ | ១៩,៣៤ |
| កៅស៊ូកសិឧស្សាហកម្ម | ៥៤៤.៧៩១ | - | ១១៨.៤៤៩ | ១១៨.៤៤៩ | ៤២,២៥ |
| កៅស៊ូគ្រួសារ | - | ៣១.២៩៨ | ៧៦.៣៩៨ | ១០៧.៦៩៦ | ៣៨,៤១ |
| **សរុប** | **៦១៨.៦៩៨** | **៥៥.៣៦១** | **២២៤.៩៩៤** | **២៨០.៣៥៥** | **១០០%** |

**ក្រាហ្វិកទី ៨: ផ្ទៃដីដាំដុះកៅស៊ូតាមប្រភេទឆ្នាំ២០១២**



សន្ទុះនៃការដាំដុះកៅស៊ូនៅកម្ពុជាមានការកើនឡើងជាលំដាប់ អាស្រ័យដោយសារតម្លៃកៅស៊ូបានឡើងខ្ពស់ គួបផ្សំស្ថានភាពនយោបាយសន្តិសុខល្អប្រសើរ សក្តានុពលនៃដីសមស្រប និងគោលនយោបាយសេរីភាវូបនីយកម្ម លើការលក់ដូរផលិតផលកៅស៊ូគ្រួសារក្នុងស្រុក ជាពិសេសមានការចូលរួមពីផ្នែកឯកជន ដែលបានធ្វើវិនិយោគលើសម្បទានដីសេដ្ឋកិច្ច និងផ្នែកកៅស៊ូគ្រួសារ ដោយបានធ្វើឲ្យផ្ទៃដីដាំដុះកៅស៊ូកើនឡើងគួរជាទីមោទនៈ។ ដោយឡែក ចំពោះចម្ការកៅស៊ូកសិឧស្សាហកម្មមានស្រាប់ ពុំមានការកើនឡើងផ្ទៃដីដាំដុះថ្មីគួរឲ្យកត់សម្គាល់ទេ គឺធ្វើការដាំដុះតែលើផ្ទៃដីកៅស៊ូចាស់ កាប់និងដាំឡើងវិញតែប៉ុណ្ណោះ។

**ក្រាហ្វិកទី ៩ ៖ ការវិវឌ្ឍនៅក្នុងការដាំដុះកៅស៊ូឆ្នាំ២០០៨-២០១២**




## ៤.៣.៤- ការវិវឌ្ឍវិស័យរុក្ខកម្ម

ឆ្នាំ២០១២នេះ កម្ពុជាត្រូវប្រឈមបញ្ហាលេចធ្លោសំខាន់ៗមួយចំនួនក្នុងវិស័យព្រៃឈើ ដូចជាបញ្ហាប្រែប្រួលអាកាសធាតុ ការកាត់បន្ថយការបញ្ចេញឧស្ម័នពីការបាត់បង់ព្រៃឈើ និងការរេចរឹលព្រៃឈើ (REDD) យន្តការអភិវឌ្ឍស្អាត (CDM) កម្មវិធីព្រៃឈើជាតិ (NFP)។ ចំពោះបញ្ហាប្រែប្រួលអាកាសធាតុ កាត់បន្ថយការបញ្ចេញឧស្ម័នពីការបាត់បង់ព្រៃឈើ និងការរេចរឹលព្រៃឈើ យន្តការអភិវឌ្ឍស្អាត កំពុងស្ថិតក្នុងដំណើរការចរចាជាអន្តរជាតិ និងកំពុងដំណើរការរៀបចំអនុវត្តជាបណ្តើរៗនៅកម្ពុជា ដូចជាការអនុវត្តគម្រោងកាត់បន្ថយការសាយភាយឧស្ម័នផ្ទះកញ្ចក់ តាមរយៈការកាត់បន្ថយឧស្ម័នកាបូនិចពីការបាត់បង់ព្រៃឈើ និងការរេចរឹលព្រៃឈើនៅតាមបណ្តាខេត្តមួយចំនួនដូចជា ខេត្តរតនគិរី ស្ទឹងត្រែង ក្រចេះ កំពង់ធំ សៀមរាប...។ល។

ដើម្បីបង្កើនកិច្ចសហការគ្រប់គ្រងវិស័យព្រៃឈើ សហគមន៍ព្រៃឈើចំនួន០៧កន្លែង មានផ្ទៃដីសរុបចំនួន៥.៨៤៧ហតក្នុងខណ្ឌរដ្ឋបាលព្រៃឈើកំពង់ចាម ព្រះសីហនុ ស្ទឹងត្រែង ក្រចេះ និងកោះកុង ត្រូវបានអនុម័តពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១២ និងបានចូលរួមចុះកិច្ចព្រមព្រៀងព្រៃសហគមន៍ចំនួន២៤កន្លែង លើផ្ទៃដី១១.៤៩៨ហតក្នុងនោះខេត្តតាកែវចំនួន០៤កន្លែងលើផ្ទៃដីចំនួន១.៨៤៣ហតខេត្តកំពតចំនួន០៤កន្លែងលើផ្ទៃដីចំនួន១.៩៣៦ហត ខេត្តកំពង់ធំចំនួន០៥កន្លែងលើផ្ទៃដីចំនួន២.៩៨ហតខេត្តស្ទឹងត្រែងចំនួន០២កន្លែងលើផ្ទៃដីចំនួន១.៣៧០ហតខេត្តក្រចេះចំនួន០២កន្លែងលើផ្ទៃដីចំនួន៣៥ហតខេត្តស្វាយរៀងចំនួន០២កន្លែងលើផ្ទៃដីចំនួន៥០៤ហត និងខេត្តបាត់ដំបងចំនួន០៥កន្លែងលើផ្ទៃដី២១៣០ហត។

បន្ថែមលើនេះទៀត រដ្ឋបាលព្រៃឈើបានសហការជាមួយមន្ត្រីមូលដ្ឋាន បោះបង្គោលព្រំព្រៃសហគមន៍នៅខេត្តស្វាយរៀង កំពត សៀមរាប កំពង់ធំ ពោធិ៍សាត់ និងខេត្តបាត់ដំបង សរុបព្រៃសហគមន៍ចំនួន២៨កន្លែង ស្មើនឹង ១.៦២៤បង្គោល និងបានសម្របសម្រួលដំឡើងប្រព័ន្ធគ្រប់គ្រងទិន្នន័យសហគមន៍ព្រៃឈើ នៅខណ្ឌរដ្ឋបាលព្រៃឈើកំពត និងសៀមរាប។

# ក្រាហ្វិកទី ១០៖ បង្ហាញអំពីសហគមន៍ព្រៃឈើពីឆ្នាំ២០០៧-២០១២




ដើម្បីបង្កើនគម្របព្រៃឈើលើផ្ទៃដីព្រៃរេចរឹល និងស្តារព្រៃឈើឡើងវិញ ក្នុងឆ្នាំ២០១២នេះ រដ្ឋបាលព្រៃឈើបានសម្រេច ដាំដុះជាចម្ការព្រៃឈើបានចំនួន៤៨៨ហតនៅស្ថានីយផ្សព្វផ្សាយនិងស្តារព្រៃឈើចំនួន០៣ស្ថានីយ៍ ដាំជួសចម្ការឈើចាស់ឆ្នាំ២០១១លើផ្ទៃដីចំនួន៤.៦៦៥ហតត្រូវបានយកចិត្តទុកដាក់ធ្វើការថែទាំ និងធ្វើអនាម័យចម្ការឈើចាស់ក្នុងនោះមានការត្រីមែក ភ្ជួរសម្អាតផ្លូវភ្លើង និងភ្ជួរចន្លោះជួរដើមឈើ ដោយប្រើប្រាស់ថវិការដ្ឋ។ ចំពោះគោលបំណងបង្កើនគម្របព្រៃឈើលើផ្ទៃដីព្រៃរេចរឹលនិងស្តារព្រៃឈើឡើងវិញ ក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ចចំនួន៦៣ក្រុមហ៊ុនបានទទួលគោលការណ៍អនុវត្តសកម្មភាពឈូសឆាយដាំដំណាំកៅស៊ូ និងដំណាំឈើព្រៃលើផ្ទៃដី២៦.០១៨ហត និងបានដាំដុះលើផ្ទៃដីចំនួន១៣.៤០០,៤០ហតនិងដាំឈើជាលក្ខណៈគ្រួសារសម្រេចបានចំនួន២.៧៩៣ហត។

ក្នុងរយៈពេល៥ឆ្នាំ២០០៨-២០១២ លទ្ធផលនៃការងារដាំឈើទទួលបានសរុបចំនួន៨០.៦៩៣ហត ក្នុងនោះដាំដោយរដ្ឋបាលព្រៃឈើចំនួន៣.៨៣៨ហត កងយោធពលខេមរភូមិន្ទចំនួន៣០០ហត បុគ្គលជាលក្ខណៈគ្រួសារចំនួន៦.១២០ហត រុក្ខទិវាចំនួន៣៣៦,៧៣ហត និងក្រុមហ៊ុនឯកជនចំនួន៧០.០៩៨ហត។

តារាង៖ ការដាំឈើរយៈពេល៥ឆ្នាំ២០០៨-២០១២ (គិតជាហត)

| ល.រ | ឆ្នាំដាំដុះ (ហត) | រដ្ឋបាលព្រៃឈើ (ហត) | កងទ័ព (ហត) | គ្រួសារ (ហត) | រុក្ខទិវា (ហត) | ក្រុមហ៊ុនឯកជន (ហត) | សរុប (ហត) |
|---|---|---|---|---|---|---|---|
| 1 | 2008 | 900 | 200 | 1,654 | 50.65 | 7,436 | **10,240.65** |
| 2 | 2009 | 1,000 | 0 | 385 | 69.00 | 17,924 | **19,378** |
| 3 | 2010 | 920 | 100 | 973.50 | 66.00 | 27,748 | **29,807.50** |
| 4 | 2011 | 530 | 0 | 314.50 | 67.50 | 3,590 | **4,502** |
| 5 | 2012 | 488 | 0 | 2,793 | 83.58 | 13,400 | **16,765** |
| **សរុប** | | **3,838** | **300** | **6,120** | **336.73** | **70,098** | **80,692.73** |

ក្រាហ្វិកទី ១១៖បង្ហាញអំពីការដាំដុះឈើពីឆ្នាំ២០០៨-២០១២




## ៤.៣.៦- ការអភិវឌ្ឍវិស័យជលផល

នៅក្នុងឆ្នាំ២០១២នេះ រដ្ឋបាលជលផលបានបំពេញភារកិច្ចយ៉ាងសកម្ម ដោយសម្រេចបានលទ្ធផលគ្រប់ផ្នែកលើវិស័យជលផល ក្នុងនោះមានការពង្រឹងសហគមន៍នេសាទ ការបង្កើតស្រះជម្រកត្រី ការអភិវឌ្ឍន៍វារីវប្បកម្ម ការសិក្សាស្រាវជ្រាវ ការផ្សព្វផ្សាយ ការអភិរក្ស ការបង្ក្រាបបទល្មើសនេសាទ និងរៀបចំលិខិតបទដ្ឋានក្រោមច្បាប់ជាដើម។ល។ ដោយឡែកចំពោះលិខិតបទដ្ឋានច្បាប់និងលិខិតបទដ្ឋានបច្ចេកទេសមួយចំនួនទៀត ដែលបានរៀបចំកន្លងមកត្រូវបានពិនិត្យកែសម្រួលនិងអនុម័តដើម្បីដាក់ឱ្យប្រើប្រាស់ធានាដល់ការគ្រប់គ្រងវិស័យជលផលប្រកបដោយប្រសិទ្ធភាព។ ជាមួយគ្នានេះដែរ រដ្ឋបាលជលផលក៏បានសហការជាមួយដៃគូអភិវឌ្ឍន៍នានា ជំរុញការរៀបចំផ្សព្វផ្សាយលិខិតបទដ្ឋានច្បាប់ ពង្រឹងសហគមន៍នេសាទ និងបង្កើនសមត្ថភាពមន្ត្រី ផ្សព្វផ្សាយវារីវប្បកម្មនិងការអភិរក្ស ដែលទាក់ទងដល់ការគ្រប់គ្រងវិស័យជលផល។

ជាមួយការរីកចំរើននេះដែរក្នុងឱកាសប្រារព្ធទិវាមច្ឆជាតិ១ កក្កដា **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** តែងតែបានផ្តល់អនុសាសន៍ដ៏ថ្លៃថ្លាពាក់ព័ន្ធនឹងការគ្រប់គ្រងនិងអភិវឌ្ឍន៍ វិស័យជលផលដែលទាក់ទងដល់ការបង្ក្រាបបទល្មើស ការបង្កើតកន្លែងអភិរក្សធនធានជលផល ការរៀបចំនិងពង្រឹងសហគមន៍នេសាទ ជំរុញការអភិវឌ្ឍន៍វារីវប្បកម្ម ការថែរក្សាការពារព្រៃលិចទឹកនិងព្រៃកោងកាងជាដើម។ល។

ក្នុងការកែទម្រង់ស៊ីជម្រៅវិស័យជលផលដំណាក់កាលទី២ រាជរដ្ឋាភិបាលបានសម្រេចលុបឡូត៍នេសាទទាំងអស់ទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាលក្ខណៈគ្រួសារ និងធ្វើជាកន្លែងអភិរក្សជលផល។ ជាក់ស្តែងសមិទ្ធផលធំៗ ដែលទទួលបានក្នុងឆ្នាំ២០១២នេះ មានដូចខាងក្រោម÷

- **អាជីវកម្មនេសាទទឹកសាប៖** នេសាទទឹកសាបឆ្នាំ២០១២ អនុវត្តបាន៥០៩.០០០តោន ស្មើនឹង ១១០,៦៥% កើនលើសឆ្នាំមុន ៦៤.០០០តោន និងមានកំណើនប្រមាណ៣៩%រយៈពេល៥ឆ្នាំ (ឆ្នាំ២០០៨-២០១២)
- **អាជីវកម្មនេសាទសមុទ្រ៖** ការធ្វើអាជីវកម្មនេសាទសមុទ្រឆ្នាំ២០១២ អនុវត្តបាន៩៩.០០០តោន ស្មើនឹង១១០% កើនលើសឆ្នាំមុន៨.០០០តោន និងមានកំណើនប្រមាណ៨,១%រយៈពេល៥ឆ្នាំ (ឆ្នាំ២០០៨-២០១២)។
- **ការអភិវឌ្ឍវារីវប្បកម្ម៖** ការចិញ្ចឹមត្រី បង្កាឆ្នាំ២០១២ អនុវត្តបាន៧៤.០០០តោន ស្មើនឹង៨៧% នៃផែនការ ៨៥.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាកើនឡើង២.០០០តោន ជាមួយគ្នានេះដែរ ការចិញ្ចឹមក្រពើ អនុវត្តបាន២០០.០០០ក្បាល ស្មើនឹង១០០% នៃផែនការ២០០.០០០ក្បាល ប្រៀបធៀបរយៈពេលដូចគ្នាថយចុះ ៣.០០០ក្បាល និងភ្ញាស់កូនត្រីពូជទូ

ទាំប្រទេសអនុវត្តបាន១៤០.០០០.០០០កូន ដែលមានកន្លែងភ្ញាស់ត្រី ចំនួន២៩៦កន្លែង ក្នុងនោះមាន២៨៣កន្លែងជារបស់កសិករ តាមរយៈការផ្តល់បច្ចេកទេសពីរដ្ឋបាលជលផល និងបានបង្កើតសហគមន៍ស្រះជម្រកត្រីបានចំនួន៧៣៨កន្លែង ដែលនៅក្នុងខេត្តកំពង់ស្ពឺច្រើនជាងគេចំនួន១៧៣កន្លែង។ ជាមួយគ្នានោះ កន្លែងដែលបានរៀបចំហើយធ្វើឲ្យផលត្រីតាមវាល ស្រែកើនពី៤ទៅ៦ដងជាមធ្យម ។

- ក្នុងការអនុវត្តវិធានការកែទម្រង់ស៊ីជម្រៅវិស័យជលផលរហូតដល់សព្វថ្ងៃនេះ ឡូត៍នេសាទដែលបានលុបទាំងអស់ត្រូវរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាលក្ខណៈគ្រួសារ និងធ្វើជាកន្លែងអភិរក្សជលផល និងបានរៀបចំបង្កើតសហគមន៍នេសាទសរុបបានចំនួន៥១៦សហគមន៍ ដែលបានចុះបញ្ជីជាផ្លូវការបានចំនួន៣២៨សហគមន៍រួចហើយ។
- ចំណូលវិស័យជលផលៈ ក្នុងឆ្នាំ២០១២អនុវត្តបាន **៤.១៤៦.៤៥៧.៥៧៥រៀល**។

**ក្រាហ្វិកៈ បង្ហាញអំពីផលនេសាទទឹកសាប សមុទ្រ និងវារីវប្បកម្មរយៈពេល៥ឆ្នាំ**




ទន្ទឹមនឹងសមិទ្ធិផលខាងលើ រដ្ឋបាលជលផលក៏បានសហការជាមួយដៃគូអភិវឌ្ឍនិងប្រទេសផ្តល់ជំនួយនានា ជំរុញការរៀបចំផ្សព្វផ្សាយច្បាប់ពង្រឹងសមត្ថភាពមន្ត្រី ពង្រឹងសហគមន៍នេសាទ ផ្សព្វផ្សាយពង្រីកវារីវប្បកម្ម និងការអភិរក្ស ដែលទាក់ទងដល់ការគ្រប់គ្រងវិស័យជលផល ដើម្បីអភិរក្សនិងអភិវឌ្ឍន៍វិស័យជលផលប្រកបដោយនិរន្តរភាព។

ម្យ៉ាងវិញទៀត រដ្ឋបាលជលផលបានជំរុញបង្កើនការទំនាក់ទំនងល្អជាមួយអាជ្ញាធរដែនដី ស្ថាប័នពាក់ព័ន្ធនិងអង្គការនានា ដើម្បីគាំទ្រដល់ការរៀបចំគ្រប់គ្រងនិងការអភិវឌ្ឍន៍សហគមន៍នេសាទ និងសហគមន៍ស្រះជម្រកត្រី បង្កើនដល់ការលើកស្ទួយក្នុងវិស័យជលផលឲ្យកាន់តែមានការរីកចម្រើន និងបានជួយដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅជនបទឲ្យកាន់តែមានភាពវិវឌ្ឍឈានឡើងជាលំដាប់នាពេលកន្លងមក។ ពិសេសការខិតខំអនុវត្តអនុសាសន៍របស់***សម្តេចនាយករដ្ឋមន្ត្រី “ធ្វើឲ្យទីណាមានទឹក ទីនោះមានត្រីឡើងវិញ”*** បានធ្វើឲ្យវិស័យជលផលមានការរីកចម្រើនគួរជាទីមោទនៈ និងបន្តរអនុវត្តបទបញ្ជារបស់រាជរដ្ឋាភិបាលក្នុងការលុបបំបាត់បទល្មើសនេសាទ ជាពិសេសក្នុងតំបន់បឹងទន្លេសាប។

ក្នុងទិសដៅជំរុញការងារគ្រប់គ្រងវិស័យជលផលឲ្យកាន់តែមានភាពប្រសើរជាងមុន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងត្រូវផ្តោតជាសំខាន់លើការអនុវត្តតាមគោលការណ៍មួយចំនួនរួមមាន÷ បន្តសហការជាមួយក្រសួង ពាក់ព័ន្ធ និងអាជ្ញាធរដែនដី ដើម្បីទប់ស្កាត់ឲ្យទាន់ពេលវេលានូវការកាប់បំផ្លាញព្រៃលិចទឹកនៅតំបន់ហាមឃាត់ ដូចជា នៅជុំវិញបឹងទន្លេសាបនិងព្រៃកោងកាងតំបន់សមុទ្រ ហើយនឹងមានវិធានការជាក់ស្តែងជាយុទ្ធសាស្ត្រ ដើម្បីទប់ស្កាត់ ឲ្យបានជាដាច់ខាតនូវការរំលោភយកដីព្រៃលិចទឹកនិងព្រៃកោងកាងធ្វើជាដីកម្មសិទ្ធិ។

ភារកិច្ចសំខាន់ និងបន្ទាន់ចំពោះមុខគឺចុះរៀបចំបោះបង្គោលព្រំប្រទល់កន្លែងអភិរក្ស និងកន្លែងនេសាទគ្រួសារឲ្យបានច្បាស់លាស់ ដោយសហការជាមួយក្រសួងស្ថាប័ននិងរដ្ឋបាលជលផលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ព្រមទាំងពង្រឹង

សកម្មភាពគ្រប់គ្រងកន្លែងអភិរក្សជលផលដោយប្រសិទ្ធភាព។ បន្តយកចិត្តទុកដាក់ជំរុញការអភិវឌ្ឍន៍វារីវប្បកម្មគ្រប់ប្រភេទ ដូចជា ចិញ្ចឹមត្រីក្នុងស្រះ ក្នុងស្រែនិងក្នុងបែរទៅតាមស្ថានភាពជាក់ស្តែង ជាពិសេសតំបន់ដែលខ្វះទឹកខ្វះខាត ត្រីដោយលើកទឹកចិត្តនិងជំរុញការចិញ្ចឹមត្រីខ្នាតតូចជាលក្ខណៈគ្រួសារ ព្រមទាំងទាក់ទាញអ្នកវិនិយោគិនឲ្យចូលរួមវិនិយោគក្នុងវិស័យវារីវប្បកម្មឲ្យបានខ្លាំងក្លា ដើម្បីជួយអភិវឌ្ឍន៍ផ្នែកវារីវប្បកម្មឲ្យបានកាន់តែខ្លាំងក្លា។

ទន្ទឹមនឹងនេះ រដ្ឋបាលជលផលថ្នាក់មូលដ្ឋាននឹងបង្កើនសកម្មភាពត្រួតពិនិត្យនិងបង្ក្រាបបទល្មើសជលផល គ្រប់រូបភាពតាមបណ្តាខេត្ត និងការពារឲ្យកាន់តែខ្លាំងក្លា ជាពិសេសបទល្មើសអាគុយឆក់ត្រីនិងស្បៃមុង។

# ជំពូក ២
# លទ្ធផលនិងទិសដៅ

## ៥-លទ្ធផលឆ្នាំ២០១២-២០១៣និងទិសដៅឆ្នាំ២០១៣-២០១៤

### ៥.១- ផលិតកម្មដំណាំស្រូវនិងដំណាំផ្សេងៗ (ឧបសម្ព័ន្ធទី១-៨)

ជារួមឆ្នាំ២០១២នេះ សភាពការណ៍អាកាសធាតុទូទាំងប្រទេស ពិសេសស្ថានភាពទឹកភ្លៀងបានចាប់ផ្តើមធ្លាក់ពីដើមរដូវវស្សា។ ទោះយ៉ាងណា កង្វះខាតទឹកនៅកណ្តាលរដូវវស្សា បានអូសបន្លាយមានរយៈពេលវែង ចាប់ពីចុងខែមិថុនារហូតដល់សប្តាហ៍ទី២នៃខែកញ្ញាឆ្នាំ២០១២ និងមានជំនន់ទឹកភ្លៀងចាប់ពីសប្តាហ៍ទី៣នៃខែកញ្ញា រហូតដល់ដើមសប្តាហ៍ទី១នៃខែវិច្ឆិកា ឆ្នាំ២០១២។ម្ព័ន្ធទី ១)

បណ្តាខេត្តដែលជួបនឹងកង្វះខាតទឹកដូចជាមាន÷ បាត់ដំបង កំពង់ចាម កំពង់ឆ្នាំង កំពង់ស្ពឺ កំពត កណ្តាល ក្រចេះ មណ្ឌលគីរី រាជធានីភ្នំពេញ ព្រៃវែង ពោធិសាត់ សៀមរាប ស្វាយរៀង តាកែវ និងឧត្តរមានជ័យ។ ហើយកង្វះខាតទឹកបានកើតមានម្តងទៀត នៅចុងរដូវវស្សាក្នុងសប្តាហ៍ទី៣នៃខែវិច្ឆិកា នៅស្រុកកោះញែក ខេត្តមណ្ឌលគីរី។

បណ្តាខេត្តដែលជួបនឹងទឹកភ្លៀងដូចជាមាន÷ បន្ទាយមានជ័យ កំពង់ធំ ព្រះវិហារ ពោធិ៍សាត់ សៀមរាប និង ស្វាយរៀង

ម្យ៉ាងទៀត ដោយសារកម្ពស់ទឹកទន្លេទាប (ទឹកមិនធំ) នាំឲ្យខកខានការងារដាំដុះស្រូវ (ស្រូវធ្ងន់ ដោយបារម្ភណ៍នឹងទឹកជំនន់ និងស្រូវប្រដេញទឹក ដោយទឹកឡើងមិនដល់)។ ស្ថានភាពវិវត្តន៍នៃអាកាសធាតុនេះបានបណ្តាលឲ្យប៉ះពាល់ដល់ទំហំផ្ទៃដីបង្កបង្កើនផល ការលូតលាស់របស់ដំណាំស្រូវ និងបង្កការខូចខាតដល់ដំណាំស្រូវវស្សាមួយចំនួន។

ឆ្នាំ២០១២នេះ ទោះបីជួបប្រទះកង្វះខាតទឹកនិងជំនន់ទឹកភ្លៀងលើផលិតផលដំណាំក៏ដោយ ក៏យើងខិតខំយ៉ាងសកម្មយកអស់កម្លាំងកាយចិត្តជំរុញការងារផលិតកម្មទទួលបានជោគជ័យគួរជាទីមោទនៈ។

**ក-ដំណាំស្រូវ ៖**

-ផ្ទៃដីអនុវត្តសរុបទូទាំងឆ្នាំ**៣.០០៧.៥៤៥ហត**លើសឆ្នាំមុន៣០.០១៦ហត ក្នុងនោះ រដូវវស្សាអនុវត្តបានចំនួន **២.៥១២.០៣៨ហត** លើសឆ្នាំមុនចំនួន ១៥.៤៦៩ហត និងរដូវប្រាំងសរុបចំនួន**៤៩៥.៥០៧ហត** លើសឆ្នាំមុន២៣.៥៤៧ ហត

-ផ្ទៃដីខូចខាតសរុបចំនួន**៣៦.០៦៧ហត** ក្នុងនោះ ផ្ទៃដីដំណាំស្រូវរដូវវស្សា **៣៦.០២៥ហត** តែស្តារបានវិញ**៨.៨១៩ហត** រីឯដំណាំស្រូវរដូវប្រាំងទទួលរងការខូចខាតចំនួន **៤២ហត**។

-ផ្ទៃដីប្រមូលផលសរុប**២.៩៨០.២៩៧ហត** លើសឆ្នាំមុន ២១៣.៦៨០ហត ក្នុងនោះរដូវវស្សា **២.៤៨៤.៨៣២ហត** លើសឆ្នាំមុនចំនួន១៩០.០៤៨ហត និងរដូវប្រាំងសរុបចំនួន**៤៩៥.៤៦៥ហត** លើសឆ្នាំមុនចំនួន២៣.៦៣២ហត

-ទិន្នផលមធ្យមប្រចាំឆ្នាំ**៣,១១៧ត/ហត**តិចជាងឆ្នាំមុន០,០៥៦ត/ហត ក្នុងនោះរដូវវស្សា**២,៨៧២ត/ហត** (តិចជាងឆ្នាំមុន ០,០៤៨ត/ហត) និងរដូវប្រាំង**៤,៣៨៩ត/ហត** (តិចជាងឆ្នាំមុន០,០៥៧ត/ហត)

-បរិមាណផលទទួលបានសរុប**៩.២៩០.៩៤០តោន** លើសឆ្នាំមុន៥១១.៥៧៥តោន ក្នុងនោះ រដូវវស្សា ៧.១៣៦.១៣៩តោន លើសឆ្នាំមុន៤៣៥.៧០០តោន និងរដូវប្រាំងឆ្នាំ២០១២-២០១៣ចំនួន២.១៥៤.៨០១តោនលើសឆ្នាំមុនចំនួន៧៥.៨៧៥តោន

-តុល្យភាពស្បៀងសល់**៣.០៣៦.០១៧តោន**អង្ករគិតជាស្រូវ**៤.៧៣៥.៩៦៤តោន**លើសឆ្នាំមុនចំនួន៣៩១.៧០១តោន។

**ខ-ដំណាំកសិកម្មរួមផ្សំ**

***ខ.១- ដំណាំរួមផ្សំ÷***

ដំណាំរួមផ្សំអនុវត្តបានសរុប ៧៣១.៩៥៧ហត កើនលើសឆ្នាំមុន ៦៤.៥១៤ហត និងបរិមាណផលសរុប ៩.០៩៩.៣៩០តោន តិចជាងឆ្នាំមុន ១៧៤.៥៣៣តោន ដោយសារការថយនៃផលិតកម្មដំណាំដំឡូងឈើ ដែលផ្ទៃដីតិចជាងឆ្នាំមុនចំនួន៤២០.១៤២ហត។

*ខ.២- ដំណាំឧស្សាហកម្ម÷*

ដំណាំឧស្សាកម្មអនុវត្តបានសរុប ១៨០.៩២៦ហត លើសឆ្នាំមុន ២០.១៩២ហត និងបរិមាណផលសរុប ១.៧៥៩.៥៥៩ តោន កើនលើសឆ្នាំមុន ១.១០៦.៧៣៩ តោន។

ពិនិត្យជារួមលទ្ធផលដំណាំកសិកម្មបានអភិវឌ្ឍដ៏ល្អប្រសើរ នូវសមិទ្ធផលនៃវិស័យកសិកម្មមានការរីកចម្រើនដូចពេលនេះ ពិសេសដំណាំស្រូវបានកើនឡើងលើសផែនការដែលបានគ្រោងទុក។

## ៥.២. ការងារកសិកម្ម

### ៥.២.១. លទ្ធផល

វិស័យកសិកម្មមានបេសកកម្មដឹកនាំគ្រប់គ្រង និងធ្វើសកម្មភាពជំរុញការអភិវឌ្ឍវិស័យផលិតកម្មដំណាំកសិកម្ម ដើម្បីចូលរួមចំណែក(១) ធានាបាននូវសន្តិសុខស្បៀងសម្រាប់ប្រជាពលរដ្ឋ(២) គ្រប់គ្រង និងត្រួតពិនិត្យគុណភាព និងសុវត្ថិភាពផលិតផល(៣) ជំរុញកំណើនផលិតភាពកសិកម្មតាមរយៈពិពិធកម្មកសិកម្ម(៤) កាត់បន្ថយភាពក្រីក្រតាមរយៈបង្កើនចំណូលដល់កសិករដោយតម្លៃបន្ថែមលើកសិផល និង(៥) ធានាទីផ្សារកសិផល។

តួនាទីនិងភារកិច្ចស្នូលរបស់អគ្គនាយកដ្ឋានកសិកម្មផ្តោតលើការងារស្រាវជ្រាវនិងអភិវឌ្ឍ និងផ្ទេរបច្ចេកវិទ្យាពាក់ព័ន្ធនឹង (១) ការគ្រប់គ្រងធនធានដីកសិកម្ម (២) ការអភិវឌ្ឍដំណាំកសិកម្មគ្រប់ប្រភេទ (៣) ការការពារដំណាំ អនាម័យនិងភូតគាមអនាម័យ (៤) ការប្រើប្រាស់គ្រឿងយន្តកសិកម្ម (៥) ការផ្សព្វផ្សាយកសិកម្ម និង (៦) ការត្រួតពិនិត្យគុណភាពនៅមន្ទីរពិសោធន៍ ។

ក្នុងឆ្នាំ២០១២នេះ ដោយមានការគាំទ្រទាំងផ្នែកស្មារតី សម្ភារៈថវិកា និងការតម្រង់ទិសពីថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ កិច្ចចូលរួមសហការនិងការគាំពារពីដៃគូរអភិវឌ្ឍនានា ការចូលរួមសហការស្អិតរម្មួតពីសំណាក់អាជ្ញាធរមូលដ្ឋានគ្រប់ជាន់ថ្នាក់ និងជាពិសេសការចូលរួមរបស់ប្រជាកសិករ អគ្គនាយកដ្ឋានកសិកម្មសម្រេចបាននូវលទ្ធផលពាក់ព័ន្ធនឹងភារកិច្ចស្នូលខាងលើគួរជាទីមោទនៈដូចខាងក្រោម÷

#### ក. ការងារពិសោធន៍ស្រាវជ្រាវ

ក្នុងឆ្នាំ២០១២នេះ ការងារពិសោធន៍ស្រាវជ្រាវក៏ត្រូវបានជំរុញអនុវត្តខ្លាំងក្លាផងដែរ។ ជាក់ស្តែងដំណើរការកសិកម្មបានធ្វើការពិសោធន៍ស្រាវជ្រាវចំនួន២៦១ពិសោធន៍ រួមមាន÷ ពិសោធន៍ពាក់ព័ន្ធនឹងលើដំណាំស្រូវមាន៤៧ពិសោធន៍ ពិសោធន៍ស្រាវជ្រាវនិងអភិរក្ស ជម្រើស និងបន្សុទ្ធពូជដំណាំបន្លែ ឈើហូបផ្លែ និងរុក្ខជាតិលម្អចំនួន៧ពូជ ពិសោធន៍ស្តីពីការជ្រើសរើសពូជដំណាំ និងបច្ចេកទេសដាំដុះដំណាំឧស្សាហកម្មចំនួន១៣ពិសោធន៍ពិសោធន៍ស្រាវជាវនិងជំរុញការប្រើប្រាស់ថ្នាំកសិកម្មផ្សំពីរុក្ខជាតិមាន៨៤ពិសោធន៍ ពិសោធន៍ស្តីពីសត្វល្អិតចង្រៃលើដំណាំស្រូវនិងបន្លែ សិក្សាអង្កេតវិធានការកំចាត់រុយចោះផ្លែស្វាយមាន១០០ពិសោធន៍ ពិសោធន៍ស្រាវជ្រាវស្តីពីការផលិត និងសាកពិសោធន៍គ្រឿងយន្តកសិកម្ម និងឧបករណ៍កសិកម្មនៅកម្ពុជាចំនួន១០ពិសោធន៍។ ដោយឡែកពាក់ព័ន្ធនឹងការគ្រប់គ្រងនិងប្រើប្រាស់ដីកសិកម្ម ផ្នែកកសិកម្មបានសិក្សានិងវាយតម្លៃការប្រើប្រាស់ដីកសិកម្មនៅខេត្តកំពង់ឆ្នាំងសិក្សាបឋមនិងកំណត់តំបន់ដាំដុះ តាមគោលការណ៍ភូមិ១ផលិតផល១ចំនួន១ស្រុក (ស្រុកចំការលើ) ការសិក្សាកំណត់តំបន់ដាំដុះដំណាំឧស្សា-ហកម្មនៅខេត្តកែបសិក្សានិងវាយតម្លៃស្ថានភាពដំណាំហូបផ្លែចំនួន៣ខេត្ត(សៀមរាបកំពង់ធំព្រះវិហារ) និងចុះសិក្សាវាយតម្លៃក្បេត្របរិស្ថានឃុំចំនួន៥១ឃុំ។

#### ខ. ការផលិតនិងផ្សព្វផ្សាយពូជដំណាំ

ដោយសារកម្ពុជាមានសក្តានុពលខ្លាំងក្នុងការផលិតស្រូវ រាជរដ្ឋាភិបាលកម្ពុជាបានកំណត់ចក្ខុវិស័យវែងឆ្ងាយ ដូចមានចែងច្បាស់ក្នុងឯកសារគោលនយោបាយស្តីពី ការជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករដែលត្រូវបានប្រកាសដាក់ឱ្យអនុវត្តកាលពីថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១០ ដោយប្រមុខរាជរដ្ឋាភិបាលកម្ពុជាគឺសំដៅប្រែក្លាយកម្ពុជាឱ្យទៅជាប្រទេស នាំចេញអង្ករមួយដ៏សំខាន់ក្នុងតំបន់នាពេលខាងមុខ។ រាជរដ្ឋាភិបាលកម្ពុជាបានកំណត់យកឆ្នាំ២០១៥ ជាឆ្នាំគោលដៅដើម្បីសម្រេចធ្វើយ៉ាងហោចណាស់ឱ្យអតិរេកស្រូវមានជាង៤លានតោន ហើយដែលអាចកែច្នៃជាអង្ករនាំចេញជាផ្លូវការយ៉ាងតិចជាង១លានតោន និងធ្វើ យ៉ាងណាឱ្យអង្ករ កម្ពុជាត្រូវបានគេទទួលស្គាល់ជាអន្តរជាតិ។

ពូជត្រូវបានគេទទួលស្គាល់ថា ជាកត្តាគន្លឹះមួយដ៏សំខាន់កំណត់គុណភាពនិងផលិតភាពផលិតកម្ម ចូលរួមសម្រេចបាននូវទិសដៅគោលនយោបាយទាំងអស់ខាងលើ។ ក្នុងន័យនេះ វិស័យកសិកម្មបានផ្តល់អាទិភាពខ្ពស់ក្នុងការបង្កើនល្បឿនការងារស្រាវជ្រាវនិងផលិតពូជស្រូវដែលមានគុណភាពសុទ្ធល្អ ពិសេសពូជស្រូវទាំង១០ប្រភេទដែលរាជរដ្ឋាភិបាលបានកំណត់ ដើម្បីផ្សព្វផ្សាយជូនប្រជាកសិករប្រើប្រាស់។

ក្នុងឆ្នាំ២០១២ ផលិតកម្មពូជស្រូវសំខាន់ៗរួមមាន ពូជIR៦៦ ពូជផលសារ ពូជផ្កាវិជ្ជូល ពូជរាំងជ័យ ពូជខា៤ សម្រេចបានបរិមាណសរុប១.៤២៦,៨តោន ក្នុងនោះ ៨២៥តោនផលិតដោយប្រើប្រាស់ថវិកាអំណោយរបស់សម្តេចអគ្គ**មហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ១០១,៨តោន ផលិតដោយប្រើប្រាស់ថវិកាតាមកម្មវិធីរបស់រាជរដ្ឋាភិបាល និងចំនួន៥០០តោនផលិតដោយប្រើប្រាស់ថវិកាគម្រោងឧបត្ថម្ភស្បៀងបន្ទាន់។

## គ. ការផ្សព្វផ្សាយបច្ចេកទេសកសិកម្មនិងពង្រឹងសហគមន៍កសិកម្ម

បានធ្វើការផ្សព្វផ្សាយបច្ចេកទេសកសិកម្មដល់ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម ក្រុមប្រឹក្សាឃុំ និងកសិករគំរូចំនួន ៤២.៣៣៦នាក់ តាមរយៈការអនុវត្តបង្ហាញ ការបណ្តុះបណ្តាល ទិវាស្រែ ទស្សនៈកិច្ចសិក្សា ការរៀបចំសន្និបាតកសិករទូទាំងប្រទេសក្នុងការជ្រើសរើសកសិករឆ្នើម និងបោះពុម្ពផ្សព្វផ្សាយឯកសារបច្ចេកទេស និងបណ្តុះបណ្តាលកសិករតាមមូលដ្ឋាននានារួមមាន÷

- បច្ចេកទេសផលិតកម្មពូជស្រូវចំនួន១០.១៨២នាក់
- ការប្រើប្រាស់ជីគីមីលាយជីធម្មជាតិចំនួន៩៥៥នាក់
- ការសន្សំនិងប្រើប្រាស់ជីកំប៉ុស្តចំនួន៣.៣០០នាក់
- បច្ចេកទេសថែរក្សា ជួសជុល និងប្រើប្រាស់គ្រឿងយន្តកសិកម្មនិងឧបករណ៍កសិកម្មចំនួន៥០០នាក់
- សុវត្ថិភាពក្នុងការប្រើប្រាស់ថ្នាំពុលកសិកម្មចំនួន១.២៦០នាក់
- ការអនុវត្តកសិកម្មល្អចំនួន១.៤៧០នាក់ ការរៀបចំផែនការក្នុងការងារផលិតកម្មកសិកម្មចំនួន២.១០០នាក់
- វិធានការកំចាត់សត្វល្អិតចង្រៃលើដំណាំបន្លែចំនួន១.៣៣០នាក់
- បច្ចេកទេសដាំដុះដំណាំឧស្សាហកម្មចំនួន៦៧០នាក់
- បច្ចេកទេសដាំដុះសាកវប្បកម្មនិងដំណាំរួមផ្សំចំនួន៣៨៧៥នាក់
- បច្ចេកទេសធ្វើផ្សិតចំបើងនិងផ្សិតអំបោះចំនួន៧០០នាក់
- ការគ្រប់គ្រង ការធ្វើផែនការជំនួញ និងការកត់ត្រាបញ្ជីគណនេយ្យនៅក្នុងសហគមន៍កសិកម្មចំនួន១.០៥០នាក់
- គោលគំនិតក្នុងការចងក្រងនិងដឹកនាំសហគមន៍ចំនួន៨២៣នាក់

**ការផ្សព្វផ្សាយបច្ចេកទេសតាមប្រព័ន្ធផ្សព្វផ្សាយសាធារណៈ**រួមមាន÷ ការចាក់ផ្សាយអំពីបច្ចេកទេសកសិកម្មតាមរយៈទូរទស្សន៍ជាតិបានចំនួន៥២អត្ថបទ តាមវិទ្យុចំនួន៥២អត្ថបទ ទិវាចុះស្រែចំនួន១៤អត្ថបទ និងបានរៀបចំនាទីស្វែងយល់ពីកសិកម្មចំនួន១២ដង។

**លើសពីនេះក៏**បានផលិតនិងចែកចាយឯកសារបច្ចេកទេសកសិកម្មបានចំនួន២២.៣០០ច្បាប់រួមមាន÷ ទស្សនាវដ្តីកសិកម្មចំនួន៥.២០០ច្បាប់និងទស្សនាវដ្តីសមិទ្ធផលកសិកម្មចំនួន២.៦០០ច្បាប់ និងកូនសៀវភៅបច្ចេកទេស៥.០០០ច្បាប់ ប៉ូស្ទ័រ៥.០០០ច្បាប់ និងបច្ចេកទេសដាំដុះបន្លែចំនួន៤.៥០០ច្បាប់។

ការពង្រឹងនិងចងក្រងសហគមន៍កសិកម្មបានក៏ជាអាទិភាពការងារ ដែលបាននិងកំពុងជំរុញយ៉ាងសស្រាក់សស្រាំផងដែរចូលរួមជាដៃគូអភិវឌ្ឍវិស័យកសិកម្មជាមួយផ្នែកឯកជន។ ក្នុងឆ្នាំ២០១២ សហគមន៍កសិកម្មចំនួន១០២សហគមន៍ត្រូវបានចុះបញ្ជី ដែលមកទល់បច្ចុប្បន្នសហគមន៍កសិកម្មទូទាំងប្រទេសសរុបមានចំនួន៣៧៥សហគមន៍។ សហគមន៍ កសិកម្មក៏ត្រូវបានផ្តល់ឱកាសចូលរួមក្នុងសកម្មភាពផ្សេងៗមួយចំនួនដូចជា÷ ពិព័រណ៍ផលិតផលកសិកម្មបានចំនួន៨លើកទាំងនៅក្នុងស្រុកនិងក្រៅស្រុក (ប្រទេសចិននិងឥណ្ឌា) និងទិវាបណ្តាញកសិកម្មនិងការពិព័រណ៍ផលិតផល និងសម្ភារកសិកម្មដែលត្រូវបានរៀបចំនៅខេត្តតាកែវ កំពត និងខេត្តកំពង់ធំ ដើម្បីឱ្យកសិករនិងសហគមន៍កសិកម្មទទួលបាននូវព័ត៌មានចាំបាច់នានានិង ជំរុញឱ្យមានការឈានចូលទីផ្សារនូវផលិតផលរបស់ប្រជាកសិករ បង្កើតបណ្តាញកសិធុរកិច្ច (កសិ

ពាណិជ្ជកម្ម) និងទំនាក់ទំនងទីផ្សាររវាងកសិករ សហគមន៍កសិកម្ម សហគ្រាសផលិតកម្ម និងការកែច្នៃកសិផលខ្នាតតូច និងមធ្យម ក្រុមហ៊ុនឯកជន និងអ្នកផ្តល់សេវាកសិកម្មនានា ជួយលើកកម្ពស់ផលិតផលកសិកម្ម និងតម្លៃផលិតផលក្នុងស្រុក ធ្វើឱ្យផលិតផលក្នុងស្រុកមានការនិយម បានតម្លៃសមស្របដល់អ្នកផលិតនិងជំរុញការផលិតបានកាន់តែច្រើន និងកាត់បន្ថយការនាំចូល និងជួយបង្កើនការងារឱ្យប្រជាជនកាន់តែច្រើន។

នៅឆ្នាំ២០១២ មានកសិករគំរូ១៦៨នាក់ត្រូវបានជ្រើសរើស ឱ្យចូលរួមក្នុងសន្និបាតកសិករទូទាំងប្រទេស លើកទី៣ ដោយជ្រើសរើសកសិករជ័យលាភីក្នុងប្រព័ន្ធផលិតកម្មកសិកម្ម បានចំនួន៣៥នាក់ លើប្រធានបទប្រពលវប្បកម្មដំណាំស្រូវ៥នាក់ ប្រព័ន្ធកសិកម្មចំរុះ៥នាក់ ការចិញ្ចឹមសត្វ៥នាក់ វារីវប្បកម្ម៥នាក់ ការកែឆ្នៃផលិតផលកសិកម្ម ៥នាក់ ការកែឆ្នៃគ្រឿងយន្តកសិកម្មចំនួន៥នាក់និងសហគមន៍ព្រៃឈើចំនួន៥នាក់។ ក្នុងឆ្នាំ២០១២កសិករទទួលជ័យលាភីសរុបចំនួន៩០នាក់ក្នុងនោះមាន÷ប្រធានបទប្រពលវប្បកម្មដំណាំស្រូវ១៥នាក់ ប្រព័ន្ធកសិកម្មចំរុះ១០នាក់ ការចិញ្ចឹមសត្វ១៥នាក់វារីវប្បកម្ម១៥នាក់ការកែឆ្នៃផលិតផលកសិកម្ម១៥នាក់ការកែឆ្នៃគ្រឿងយន្តកសិកម្មចំនួន១៥នាក់ និងសហគមន៍ព្រៃឈើចំនួន៥នាក់។ កសិករជ័យលាភីលេខមួយចំនួន៧នាក់ ក្នុងមានស្ត្រី១នាក់ ជាជនជាតិភាគតិចស្រុកថ្មបាំងខេត្តកោះកុងត្រូវបានបញ្ជូលឱ្យទៅចូលរួមទស្សនៈកិច្ចសិក្សា នៅសាធារណៈរដ្ឋកូរ៉េរយៈពេលពីរសប្តាហ៍ និងបានបញ្ជូនកសិករជ័យលាភី២នាក់ និងមន្ត្រីផ្សព្វផ្សាយកសិកម្ម១នាក់ទៅទស្សនៈកិច្ចសិក្សា នៅប្រទេសឥណ្ឌា។

## ឃ. ការងារគ្រឿងយន្តកសិកម្ម ឆ្នាំ២០១២

គ្រឿងយន្តកសិកម្មចូលរួមចំណែកយ៉ាងសំខាន់ នៅក្នុងដំណើរការប្រពលវប្បកម្មឆ្ពោះទៅបង្កើនផលិតភាព គុណភាពកសិកម្ម និងកាត់បន្ថយការបាត់បង់។ នាពេលបច្ចុប្បន្ននេះ ប្រទេសកម្ពុជានិយមការប្រើប្រាស់គ្រឿងយន្តកសិកម្ម កំពុងមានការកើនឡើងគួរឱ្យកត់សម្គាល់ ដែលជាបច្ច័យមួយបង្ហាញអំពី ដំណើរការវិវត្តនៃយន្តូបនីយកម្មក្នុងវិស័យកសិកម្មកម្ពុជា។ ជាក់ស្តែងលទ្ធផលភ្ជួររាស់ទូទាំងប្រទេសសម្រេចបានប្រមាណ ៣.៦៤៣.៧៥១ហិកតា រួមមាន÷

- រដូវវស្សាចំនួន៣.១៤៨.២២៤ហត ក្នុងនោះ ភ្ជួរដោយគ្រឿងយន្តកសិកម្មបានចំនួន២.០៣០.៩០១ហត និងភ្ជួរដោយគោក្របីចំនួន១.១១៧.៣៤៣ហត
- រដូវប្រាំងឆ្នាំ២០១២-២០១៣ចំនួន៤៨៨.០១៤ហត ក្នុងនោះ ភ្ជួរដោយគ្រឿងយន្តកសិកម្មចំនួន៤៨៧.៩៨១ហតនិងភ្ជួរដោយគោក្របីចំនួន៧.៥២៦ហត។ លទ្ធផលរដូវប្រាំងភ្ជួរដោយគ្រឿងយន្តកសិកម្ម បើប្រៀបធៀបរយៈពេលដូចគ្នាកើនបានចំនួន១៩៣.៨១១ហតស្មើនឹង១៣៧,៦៦%។

### *ឃ.១- ស្ថានភាពគ្រឿងយន្តកសិកម្ម ÷*

ក្នុងឆ្នាំ២០១២នេះ ស្ថិតិគ្រឿងយន្តកសិកម្មសរុបបានបង្ហាញថា នៅទូទាំងប្រទេសកម្ពុជាមានដូចខាងក្រោម÷

-ត្រាក់ទ័រចំនួន៨៧៩៧គ្រឿងគោយន្ត១២៧៨០២គ្រឿង

-ម៉ាស៊ីនបូមទឹក២២៧៤១៩គ្រឿង

-ម៉ាស៊ីនច្រូត៤៧២២គ្រឿង

-ម៉ាស៊ីនបោក១៥៣២០គ្រឿង

-ម៉ាស៊ីនសំងួត៩២គ្រឿង

-ម៉ាស៊ីនកិនស្រូវ៥៣៩៣៣គ្រឿង

-ស្ថិតិឧបករណ៍បំពាក់ត្រាក់ទ័រមាន នង្គ័ល៦.០៤៥គ្រឿង រនាស់៣.៨០៨គ្រឿង រ៉ឺម៉ក៣២៤៦គ្រឿង អង្កប់វាយដី១.១២៥គ្រឿង

-ស្ថិតិឧបករណ៍បំពាក់គោយន្តមាននង្គ័ល៨៤៩៤២គ្រឿង រនាស់៨១២០០គ្រឿង រ៉ឺម៉ក៧៧១៧៩គ្រឿងនិងអង្កប់៤១៧គ្រឿង

-ស្ថិតិឧបករណ៍កសិកម្មមានឧបករណ៍ដាំស្រូវ២៩គ្រឿងនិងឧបករណ៍ជ្រួយដីសម្អាតស្មៅ៥៩គ្រឿង។

### ឃ.២. ស្ថិតិទីតាំងផលិត លក់ចែកចាយគ្រឿងយន្តនិងឧបករណ៍កសិកម្ម៖

-រោងជាងដំដែកមានចំនួន១៩៨៤កន្លែង

- រោងជាងផលិតកែច្នៃ និងជួសជុលគ្រឿងយន្តនិងឧបករណ៍កសិកម្មមានចំនួន១២៩កន្លែង

- កន្លែងលក់គ្រឿងយន្តកសិកម្មនិងឧបករណ៍កសិកម្ម មានចំនួន៣០១កន្លែង។

### ឃ.៣. ការងារអន្តរាគមន៍

-បានចុះអន្តរាគមន៍បូមទឹកសង្គ្រោះស្រូវនៅស្រុកកំពង់ស្វាយខេត្តកំពង់ធំស្រុកបន្ទាយមាសស្រុកអង្គរជ័យស្រុកឈូកខេត្តកំពតនិងនៅស្រុកកោះញែកខេត្តមណ្ឌលគិរី

-បានចុះអន្តរាគមន៍ភ្ជួររាស់ដោយគ្រឿងយន្តកសិកម្ម ជូនកសិករក្រីក្រស្ត្រីមេម៉ាយនិងយោធិនពិការនៅឃុំរំចេក ស្រុកព្រះស្ដេចឃុំព្រែកខ្លោងស្រុកពោធិរៀងនិងស្រុកស្វាយអន្ទរខេត្តព្រៃវែងនៅឃុំត្រពាំងឫស្សី ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ និងខេត្តកំពង់ស្ពឺ

-បានចុះអន្តរាគមន៍បូមទឹកសង្គ្រោះស្រូវរាំងស្ងួតដូចជាខេត្តកំពត កំពង់ធំ និងមណ្ឌលគិរី និងចុះកៀរពង្រាបដីស្រែ ដោយប្រព័ន្ធឡាហ្សែរចំនួន៣០ហតនិងបានចូលរួមបង្ហាញការអូសដាំដោយឧបករណ៍ អូសដាំ (Drum Seeder) ព្រមទាំងពិនិត្យទីតាំងដីដែលត្រូវអន្តរាគមន៍ជីកប្រឡាយមួយខ្សែប្រវែង៤២៥ម៉ែត្រនៅ ស្រុកអង្គរជ័យខេត្តកំពត

-បានពិសោធន៍ឧបករណ៍កៀរពង្រាបដី ដោយប្រព័ន្ធឡាហ៊្សែរដោយសហការជាមួយអង្គការ IRRI នៅខេត្តបាត់ដំបងនិងខេត្តពោធិសាត់

-បានចុះលើកភ្លឺស្រែបង្ហាញនៅភូមិកំបោរឃុំលៀបស្រុកព្រះនេត្រព្រះខេត្តបន្ទាយមានជ័យបានប្រវែង៣.៩២០ម

-បានអន្តរាគមន៍ភ្ជួររាស់ជូនកសិករក្រីក្រស្ត្រីមេម៉ាយយោធិនពិការនិងកសិករខ្វះកម្លាំងពលកម្មនៅខេត្តបន្ទាយមានជ័យ

-បានសាកពិសោធន៍ដាំស្រូវ ដោយប្រើឧបករណ៍អូសដាំជាជួរ (Drum Seeder)និងស្ទង់ស្រូវលក្ខណៈប.វ.ស ពិនិត្យស្រែពិសោធន៍ដែលប្រើជីវធ្យូងគុនតាន់និងច្រូតកាត់ប្រមូលផលស្រូវនិងបានកំណត់ទីតាំងសាងសង់ឃ្លាំងដាក់ស្រូវនៅមជ្ឈមណ្ឌលវិស្វកម្មកសិកម្មក្បាលពោធិ។

## ង. ការជំរុញការនាំចេញកសិផល

ក្នុងឆ្នាំ២០១២នេះ បានធ្វើការត្រួតពិនិត្យភូតគាមអនាម័យ និងផ្តល់វិញ្ញាបនប័ត្រភូតគាមអនាម័យសរុបបានចំនួន ៧.៥៥៧ច្បាប់ សម្រួលការនាំចេញផលិតផលកសិកម្មចំនួន ២៥មុខ ទំនិញទៅកាន់ទីផ្សារបរទេស មានបរិមាណសរុបចំនួន ៦៨០.៤៥៧តោន កើនលើសឆ្នាំ២០១១ ចំនួន១៩៣.១៣០តោន ឬស្មើនឹង៣៩,៦%។



ការនាំចេញអង្ករឆ្លងកាត់ការត្រួតពិនិត្យភូតគាមអនាម័យក្នុងឆ្នាំ២០១២ សម្រេចបានចំនួន២០៥.៧១៧តោន កើនលើសឆ្នាំ២០១១ ចំនួន១,៩% អង្ករ ដែលបាននាំចេញមានចំនួន១០ប្រភេទរួមមាន÷ អង្ករចំរុះ (white rice) ១០២.២២៤តោន (៤៩,៦៩%) អង្ករផ្កាម្លិះ៦៥.២៨១តោន (៣១,៧៣%) អង្ករនាងម្លិះ ២០.៦០៥តោន (១០%) អង្ករសូម៉ាលី៩.២៧៥តោន (៤,៥%) អង្ករផ្កាខ្ញី ២.៩៧៨តោន (១,៤៤%) អង្ករសែនក្រអូប១.៦៤៩តោន (០,៨%) និងអង្ករនាងខុន នាងមិញ ផ្ការំដួល និងរំចេកសរុបចំនួន ៣.៧០៥តោន (១,៨%) ។

តារាងទី១. បរិមាណអង្ករនាំចេញតាមប្រភេទអង្ករឆ្នាំ២០១២ (តួលេខអង្ករបានត្រួតពិនិត្យភូតគាមអនាម័យសម្រាប់នាំចេញ)

| ល.រ | ប្រភេទអង្ករ | បរិមាណ (តោន) | % |
|---|---|---|---|
| ១ | អង្ករចំរុះ | ១០២.២២៤ | ៤៩,៦៩ |
| ២ | អង្ករផ្កាម្លិះ | ៦៥.២៨១ | ៣១,៧៣ |
| ៣ | អង្ករនាងម្លិះ | ២០.៦០៥ | ១០ |
| ៤ | អង្ករសូម៉ាលី | ៩.២៧៥ | ៤,៥០ |
| ៥ | អង្ករផ្កាខ្ញី | ២.៩៧៨ | ១,៤៤ |
| ៦ | អង្ករសែនក្រអូប | ១.៦៤៩ | ០,៨០ |
| ៧ | អង្ករនាងខុន នាងមិញ ផ្ការំដួល និងរំចេក | ៣.៧០៥ | ១,៨០ |
| **សរុប** | | **២០៥.៧១៧** | **១០០** |

អង្ករទាំងនេះបាននាំចេញទៅចំនួន៥៧ប្រទេស ដែលភាគច្រើនជាប្រទេសក្នុងសហគមន៍អឺរ៉ុបមានមានការបញ្ជាទិញច្រើនជាងគេ។ ក្រៅពីនេះមានការបញ្ជាទិញពីប្រទេសផ្សេងៗផងដែររួមមាន÷ ម៉ាឡេស៊ី សឹង្ហបូរី ហុងកុង អាមេរិក ញ៉ូវហ្សេឡិន វៀតណាម អូស្ត្រាលី ចិន កុងហ្គូ កូម៉ូរូស តូហ្គូ ហ្គាណា អង់ហ្គោឡា កូរ៉េ កាម៉េរូន អេស្វូនៀ ហ្វីលីពីន ម៉ូរីទីណា ម៉ាដាហ្គាស្កា France Guiana Lietuva និង Guyana។ ដោយឡែកចំនួនប្រទេសនាំចូលមានការកើនឡើងច្រើនមានចំនួន៥៧ប្រទេសបើធៀបនឹងឆ្នាំ២០១១មានតែ៤៨ប្រទេស។ រីឯអ្នកនាំចេញក៏មានការកើនឡើងដែរនៅក្នុងឆ្នាំ២០១២នេះ មានចំនួន៦៨ក្រុមហ៊ុននាំចេញ។ ចំណែកឯការនាំចេញអង្ករទៅកាន់ប្រទេសចិននៅក្នុងឆ្នាំ២០១២នេះ មានការកើនឡើងច្រើនក្នុងបរិមាណ៦១៨១តោន ជាពិសេសនៅក្នុងខែធ្នូនេះ បើធៀបនឹងឆ្នាំ២០១១មានតែ៤៨តោនប៉ុណ្ណោះ នេះជាក្តីសង្ឃឹមមួយដែលការនាំចេញអង្ករនៅឆ្នាំក្រោយមានការកើនឡើង។

ការនាំចេញផលិតផលដំឡូងមីសម្រេចបាន២២៥ ៦៨១តោន ក្នុងនោះ÷ ម្សៅដំឡូងមីមានចំនួន៤៨ ៨៧៤តោន ចំណិតដំឡូងមីមានចំនួន១២៦ ២៧៦តោន និងដំឡូងមីស្រស់ចំនួន៥០ ៥៤០តោន ត្រូវបាននាំចេញទៅកាន់ប្រទេសវៀតណាម និងថៃ។ ដោយឡែកការនាំចេញមិនទាន់មានកំណើនគួរឱ្យកត់សម្គាល់នៅឡើយ ប៉ុន្តែក្នុងការជំរុញអនុវត្តពិធីសារជាមួយប្រទេសចិនស្តីពីការនាំចេញចំណិតដំឡូងមីក្រៀមទៅប្រទេសចិននេះ ក្នុងឆ្នាំ២០១២កន្លងមកនេះ អគ្គនាយកដ្ឋានកសិកម្មបានពិនិត្យនិងវាយតម្លៃ និងស្នើសុំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទជូនដំណឹងស្តីពីការចុះបញ្ជីក្រុមហ៊ុននាំចេញចំណិតដំឡូងមីក្រៀមទៅកាន់អគ្គរដ្ឋបាលត្រួតពិនិត្យគុណភាព អធិការកិច្ច និងចត្តាឡីស័កប្រទេសចិន (AQSIQ) បានចំនួន១៥ក្រុមហ៊ុន។

## ច. ការងាររៀបចំលិខិតបទដ្ឋានគតិយុត្ត

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រៀបចំនូវសេចក្តីព្រាងច្បាប់ចំនួន០៣រួមមាន÷ សេចក្តីព្រាងច្បាប់ស្តីពីសហគមន៍កសិកម្ម សេចក្តីព្រាងច្បាប់ស្តីពីការការពារដំណាំនិងភូតគាមអនាម័យ និងសេចក្តីព្រាងច្បាប់ស្តីពីការប្រើប្រាស់និងគ្រប់គ្រងដីកសិកម្ម។ លទ្ធផលសម្រេចបានជាទីមោទនៈក្នុងឆ្នាំ២០១២នេះគឺសេចក្តីព្រាងច្បាប់ស្តីពីសហករណ៍កសិកម្មត្រូវបានរាជរដ្ឋាភិបាលកម្ពុជាពិនិត្យនិងអនុម័តបញ្ជូនទៅកាន់រដ្ឋសភាជាតិ ដើម្បីអនុម័តរួចហើយ។ដោយឡែកសេចក្តីព្រាងច្បាប់ពីរផ្សេងទៀតកំពុងស្ថិតក្នុងដំណាក់កាលរៀបចំផ្ទៃក្នុងនៅឡើយ។

ក្រៅពីការរៀបចំសេចក្តីព្រាងច្បាប់ខាងលើ អគ្គនាយកដ្ឋានកសិកម្មក៏បានខិតខំរៀបចំនូវឯកសារគតិយុត្តសំខាន់ៗមួយចំនួនទៀតរួមមាន÷

-សេចក្តីព្រាងអនុក្រឹត្យស្តីពី "ការគ្រប់គ្រងរោងជាងផលិត កែច្នៃ ដំឡើង និងរោងជាងជួសជុលគ្រឿងយន្ត កសិកម្ម និងឧបករណ៍កសិកម្ម" ដោយបានឆ្លងការប្រជុំអចិន្ត្រៃយ៍ក្រសួងរួចហើយ ហើយកំពុងបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រី

-បានរៀបចំប្រកាសស្តីពី "បទបញ្ជាផ្ទៃក្នុងគំរូរបស់បុរេសហគមន៍អភិវឌ្ឍកសិកម្ម"

-បានរៀបចំប្រកាសស្តីពី "បញ្ជីឈ្មោះសមាសភាពចង្រៃភូតគាមអនាម័យ និងបង្កគ្រោះថ្នាក់ដែលត្រូវហាមឃាត់ចូលព្រះរាជាណាចក្រកម្ពុជា"

-ប្រកាសស្តីពី "នីតិវិធីនៃការត្រួតពិនិត្យភូតគាមអនាម័យ"

-ប្រកាសស្តីពី "ការដាក់ឲ្យប្រើប្រាស់នូវវិធាននៃការអនុវត្តកសិកម្មល្អ ក្នុងការងារផលិតកម្មផ្លែឈើ និងបន្លែស្រស់"

-បានរៀបចំសេចក្តីព្រាងប្រកាសរួមស្តីពី "សោហ៊ុយសេវាកម្មត្រួតពិនិត្យភូតគាមអនាម័យ និងការកំចាត់សមាសភាពចង្រៃ"

## ឆ. ការងារសហប្រតិបត្តិការ

ការងារសហប្រតិបត្តិការអន្តរជាតិត្រូវបានជំរុញជាមួយនឹងគោលបំណងសំខាន់គៀងគរថវិកាបន្ថែម។ ជាក់ស្តែងក្នុងឆ្នាំ ២០១២ មានដៃគូជាតិនិងអន្តរជាតិចូលរួមទ្រទ្រង់សកម្មភាពអភិវឌ្ឍវិស័យកសិកម្មតាមរយៈគម្រោងមួយចំនួនដូចខាងក្រោម÷

(១) គម្រោងអភិវឌ្ឍធារាសាស្ត្រនិងបង្កើនផលិតភាពកសិកម្ម (RIAPIP) ដែលប្រើប្រាស់ថវិកាបង្វិលសង IMF

(២) គម្រោងកាត់បន្ថយភាពក្រីក្រនិងអភិវឌ្ឍកសិករខ្នាតតូចជុំវិញតំបន់ទន្លេសាប (TS-PRSDP) ទ្រទ្រង់ថវិកាដោយរាជរដ្ឋាភិបាលកម្ពុជានិង ADB

(៣) គម្រោងអភិវឌ្ឍជនបទទំនាបបឹងទន្លេសាប (TS-RDP) ទ្រទ្រង់ថវិកាដោយ ADB

(៤) គម្រោងជំនួយស្បៀងបន្ទាន់ (EFAP) ទ្រទ្រង់ថវិកាដោយ ADB

(៥) គម្រោងអភិវឌ្ឍន៍កសិកម្មនិងជំរុញកំណើនសេដ្ឋកិច្ច (PADEE) ឧបត្ថម្ភថវិកាដោយ IFAD

(៦) គម្រោងលើកកំពស់ផលិតភាពកសិកម្ម (APPP) គាំទ្រថវិកាដោយ JICA

(៧) គម្រោងស្រាវជ្រាវដំណាំស្រូវគាំទ្រថវិកាដោយ SEARICE និង ACIAR

(៧) គម្រោងពិពិធកម្មកសិកម្មកម្ពុជា (PADAC) ដែលជំរុញការស្រាវជ្រាវបច្ចេកទេសដំណាំគម្របដី DMC ហើយទ្រទ្រង់ថវិកាដោយ AFD

(៨) គម្រោងស្តីពីការកែលំអសន្តិសុខស្បៀងនិងទីផ្សារសម្រាប់កសិករខ្នាតតូច (MALIS) ទ្រទ្រង់ថវិកាដោយ EU និង FAO។ល។

## ជ. បញ្ហាប្រឈម

-ហេដ្ឋារចនាសម្ព័ន្ធរូបវន្តនៅតាមកសិដ្ឋាន ស្ថានីយ៍ពិសោធន៍ និងមណ្ឌលអភិវឌ្ឍកសិកម្មនូវមានការខ្វះខាត (ប្រព័ន្ធស្រោចស្រោចស្រព អគារបណ្តុះបណ្តាល ផ្លូវថ្នល់...) ខ្វះឧបករណ៍ សម្ភារៈ និងមធ្យោបាយផលិតកម្ម នៅតាមកសិដ្ឋាន ស្ថានីយ៍ពិសោធន៍ និងមណ្ឌលអភិវឌ្ឍកសិកម្ម

-ការរក្សាពូជដំណាំបានជួបប្រទះបញ្ហាប្រឈម ដោយសារឃ្លាំងទុកដាក់មិនបានសមស្របតាមបទដ្ឋានបច្ចេកទេស ដែលធ្វើឲ្យមានបញ្ហាប្រឈមនៅតាមមូលដ្ឋានខ្លះៗក្នុងពេលកន្លងមក

-ថវិកាសំរាប់ការងារស្រាវជ្រាវ និងអភិវឌ្ឍវិស័យកសិកម្មនៅមានកម្រិត ពិសេសការងារអនុវត្តសកម្មភាពសម្រាប់គោលនយោបាយជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ

-ខ្វះធនធាន (ធនធានមនុស្សនិងធនធានសម្ភារៈ) ទាំងនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន

-ខ្វះការវិនិយោគពីវិស័យឯកជនពាក់ព័ន្ធនឹងវិស័យកសិកម្ម

-ចំណាកស្រុករបស់ប្រជាជនកំពុងក្លាយជាបញ្ហាចោទមួយសម្រាប់ការអភិវឌ្ឍវិស័យកសិកម្ម

-ចំណេះដឹងកសិករនៅមូលដ្ឋាននៅមានកម្រិត ធ្វើឲ្យមានការលំបាកក្នុងការបញ្ជ្រាបបច្ចេកទេសកសិកម្មថ្មី និងងាយរងគ្រោះពីការឆបោកឈ្មួញទុច្ចរិត។

### ៥.២.២. វាយតម្លៃនិងសន្និដ្ឋាន

ក្នុងឆ្នាំ២០១២នៃអាណត្តិទី៤ នៃរាជរដ្ឋាភិបាលកម្ពុជាដឹកនាំដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា** ធ្វើការវាយតម្លៃនិងសន្និដ្ឋានដោយមោទនភាពថា ទោះបីស្ថិតនៅក្នុងដំណាក់កាលពឹងផ្អែកលើធម្មជាតិ និងជាញឹកញាប់បានទទួលរងការគម្រាមកំហែងពីគ្រោះមហន្តរាយធម្មជាតិជាបន្តបន្ទាប់ក្តីវិស័យកសិកម្មកម្ពុជាបាននិងកំពុងមានការផ្លាស់ប្តូរជាវិជ្ជមានប្រកបដោយក្តីសង្ឃឹមថា កសិកម្មពិតជានឹងក្លាយជាឆ្អឹងខ្នងយ៉ាងរឹងមាំសម្រាប់ការពន្លឿននិងការពង្រីកមូលដ្ឋានអភិវឌ្ឍវិស័យសេដ្ឋកិច្ចកម្ពុជា បន្តចូលចូលរួមចំណែកកាត់បន្ថយភាពក្រីក្រប្រកបដោយភាពស្វាហាប់និងចីរភាព។

និយាយជារួមវិស័យកសិកម្មកម្ពុជាកំពុងតែមានការវិវត្តប្រកប ដោយអត្ថន័យទាំងបរិមាណនិងគុណភាព។ ប្រជាកសិករកាន់តែមានសមត្ថភាពធានាបាននូវភាពម្ចាស់ការនៅក្នុងដំណើរការផលិតកម្ម ដោយសារការខិតខំរបស់រាជរដ្ឋាភិបាលដែលបាននិងកំពុងធ្វើឱ្យមានការរីកចម្រើនជាបណ្តើរៗនូវមូលដ្ឋានបម្រើឲ្យផលិតកម្ម និងពាណិជ្ជកម្ម កសិកម្ម ពិសេសការរីកចម្រើនខាងប្រព័ន្ធធារាសាស្ត្រយន្តូបនីយកម្មកសិកម្មពូជដំណាំមានគុណភាព បច្ចេកទេសដាំដុះនិងថែទាំដំណាំថ្មីៗនិងយន្តការសម្របសម្រួល ទីផ្សារផលិតផលកសិកម្ម។ល។ ព្រមជាមួយគ្នានេះ ប្រជាកសិករក៏កំពុងតែមានការកែប្រែទម្លាប់និងផ្នត់គំនិតជាបណ្តើរៗ ក្នុងការចាប់យកទៅអនុវត្តនូវបច្ចេកទេសប្រពលវប្បកម្មនិងពិពិធកម្មដំណាំត្រឹមត្រូវស្របតាមបទដ្ឋានបច្ចេកទេស។ កំណើនផលិតកម្មកសិកម្មទាំងផ្ទៃដីដាំដុះ បរិមាណផល ទិន្នផល ពិសេសកំណើននៃការនាំចេញផលិតផលកសិកម្មទៅកាន់ទីផ្សារបរទេសពិតជាសក្ខីកម្មមិនអាចប្រកែកបានស្តីពី ការរីកចម្រើន នៅក្នុងវិស័យកសិកម្មប្រកបដោយអត្ថន័យ។

ទាំងអស់នេះជាផ្លែផ្កាកើតចេញពីការបំពេញការងារមិនចេះនឿយហត់ និងប្រកបដោយស្មារតីទទួលខុសត្រូវនិងការលះបង់ខ្ពស់របស់ថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃវិស័យកសិកម្មនិងអ្នកពាក់ព័ន្ធគ្រប់ជាន់ថ្នាក់ ក្រោមការជួយឧបត្ថម្ភគាំទ្រទាំងស្មារតី សម្ភារៈ ថវិកានិងការដឹកនាំចង្អុលបង្ហាញប្រកបដោយប្រសិទ្ធភាពរបស់ថ្នាក់ដឹកនាំ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទគ្រប់ជាន់ថ្នាក់ ពិសេស**ឯកឧត្តមបណ្ឌិត ចាន់ សារុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

### ៥.២.៣. វិធានការ

ក្នុងគោលបំណងដើម្បីឈានទៅសម្រេចបានសមិទ្ធផលធំៗបន្ថែមទៀតសម្រាប់អនុវិស័យផលិតកម្មដំណាំការងារសំខាន់ដែលត្រូវបន្តជំរុញអនុវត្តនាឆ្នាំ២០១៣ក៏ដូចជាបណ្តាឆ្នាំបន្តបន្ទាប់ទៀតខាងមុខនេះរួមមាន÷

-បន្តជំរុញការលើកកំពស់ផលិតភាព និងពិពិធភាវូបនីយកម្មកសិកម្ម តាមរយៈការពង្រឹង និងកសាងហេដ្ឋារចនាសម្ព័ន្ធនៅតាមកសិដ្ឋាន ស្ថានីយ៍ពិសោធន៍កសិកម្ម និងមជ្ឈមណ្ឌលអភិវឌ្ឍន៍កសិកម្ម ដើម្បីបម្រើឱ្យការងារពិសោធន៍ស្រាវជ្រាវ អភិវឌ្ឍ និងផ្ទេរបច្ចេកវិទ្យាទំនើបសមស្រប លើគ្រប់មុខជំនាញពាក់ព័ន្ធនឹងការអភិវឌ្ឍផលិតកម្មដំណាំទៅដល់ស្រទាប់ប្រជាកសិករនិងផលិតករគ្រប់កំរិតនាំទៅដល់ការបង្កើនទិន្នផលនិងគុណភាពផលិតផល ឆ្លើយតបទៅនឹងសេចក្តីត្រូវទីផ្សារក្នុងស្រុកនិងក្រៅស្រុក។

-បន្តពង្រឹងសេវាអប់រំផ្សព្វផ្សាយបច្ចេកទេសជូនដល់ប្រជាកសិករឱ្យបានកាន់តែទូលំទូលាយ និងស៊ីជម្រៅថែមទៀត ដើម្បីពង្រីកការទទួលយកទៅអនុវត្តនូវបច្ចេកទេសសមស្របសម្រាប់ការដាំដុះ ការគ្រប់គ្រងជីជាតិដី ការការពារដំណាំ ការប្រើប្រាស់និងថែទាំគ្រឿងយន្តនិងឧបករណ៍កសិកម្ម ការប្រមូលផលទុកដាក់និងកែច្នៃក្រោយពេលប្រមូលផលប្រកបដោយប្រសិទ្ធភាព តាមរយៈការបើកសាលារៀនស្រែកសិករ ការបើកវគ្គបណ្តុះបណ្តាលរយៈពេលខ្លី ការដំណើរការស្រែបង្ហាញ ការផ្លាស់ប្តូរទស្សនកិច្ចសិក្សា ការផ្សព្វផ្សាយតាមប្រព័ន្ធព័ត៌មានមហាជន និងការដំណើរការសន្និបាតកសិករ។ល។លើសពីនេះទៀតត្រូវខិតខំបង្ហិតសេវាផ្សព្វផ្សាយកសិកម្មឱ្យបានកាន់តែជិតកសិករតាមរយៈការបណ្តុះបណ្តាលភ្នាក់ងារផ្សព្វផ្សាយកសិកម្មភូមិ-ឃុំការរៀបចំបង្កើតឱ្យមានជាមណ្ឌលកសិកម្មឃុំសង្កាត់និងដាក់មន្ត្រីជំនាញ បំពាក់មធ្យោបាយ និងបរិក្ខារ និងបង្កើតមណ្ឌលព័ត៌មានកសិកម្មតាមខេត្ត ស្រុក និងមូលដ្ឋានឃុំសង្កាត់។

-បន្តកិច្ចខិតខំជំរុញការចងក្រងនិងព្រងឹងសហគមន៍កសិកម្មតាមរយៈការកសាងសមត្ថភាពដឹកនាំគ្រប់គ្រងជំនាញក្នុងការធ្វើផែនការ ដំណើរការមុខរបរ ការធ្វើជំនួញ និងទីផ្សារ និងសេវាកម្មពាក់ព័ន្ធនឹងខ្សែចង្វាក់ផលិតកម្ម

កសិកម្ម ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការអភិវឌ្ឍកសិកម្មមានលក្ខណៈប្រមូលផ្តុំក្នុងភាពជាដៃគូរជាមួយផ្នែកឯកជន ក្រោមក្របខ័ណ្ឌផលិតកម្មកសិកម្មតាមកិច្ចសន្យាដើម្បីទទួលបានទាំងបច្ចេកវិទ្យាថ្មី និងឥណទានគ្រប់គ្រាន់ ធានាបាន ស្ថេរភាពនៃការផ្គត់ផ្គង់ផលិតផលទៅកាន់ទីផ្សារទាំងបរិមាណនិងគុណភាពនិងជាពិសេស ដើម្បីព្រងឹងអំណាចតថ្លៃរបស់ កសិករនៅក្នុងខ្សែសង្វាក់ផលិតកម្ម។

## ៥.៣- ការងារស្រាវជ្រាវបច្ចេកទេសកសិកម្ម

ក្នុងឆ្នាំ២០១២នេះ វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា មានមន្ត្រី-និយោជិតសរុបចំនួន១៥៥នាក់ (មន្ត្រីរាជការចំនួន៤៨នាក់) ក្នុងនោះមាននារីចំនួន៤៨នាក់។ វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជាបានបន្តការខិតខំប្រឹងប្រែងអនុវត្តយ៉ាងសស្រាក់សស្រាំលើការងារស្រាវជ្រាវនិងអភិវឌ្ឍន៍បច្ចេកវិទ្យាសម្រាប់ (១)ការអភិវឌ្ឍន៍ពូជដំណាំកសិកម្ម(២)ការគ្រប់គ្រងជីជាតិដីនិងសារធាតុចិញ្ចឹម (៣)ការអភិវឌ្ឍន៍បច្ចេកទេសដាំដុះនិងប្រព័ន្ធកសិកម្ម (៤)ការការពារដំណាំពីការបំផ្លាញរបស់កត្តាចង្រៃផ្សេងៗមានដូចជាសត្វល្អិតចង្រៃស្មៅនិងជំងឺ (៥)ការអភិវឌ្ឍន៍បច្ចេកទេសមុននិងក្រោយពេលប្រមូលផល (៦)ការវិភាគសេដ្ឋកិច្ចសង្គមពាក់ព័ន្ធវិស័យកសិកម្មនិង(៧)ការបណ្តុះបណ្តាលនិងការផ្សព្វផ្សាយចំណេះដឹងបច្ចេកទេសនិងព័ត៌មានកសិកម្ម។ ទន្ទឹមនឹងនេះបានប្រារព្ធសិក្ខាសាលាថ្នាក់ជាតិរយៈពេលពីរថ្ងៃចាប់ពីថ្ងៃទី៦-៧ ខែវិច្ឆិកា ឆ្នាំ២០១២អំពី ផលិតកម្មដំណាំដំឡូងមីនិងការប្រើប្រាស់ប្រកបដោយនិរន្តរភាព ដើម្បីកាត់បន្ថយភាពក្រីក្រនៅជនបទក្នុងប្រទេសកម្ពុជាក្រោមអធិបតីភាពរបស់ ឯកឧត្តមបណ្ឌិតច័ន្ទសារុនរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

### ៥.៣-១. លទ្ធផល

សមិទ្ធផលការងារស្រាវជ្រាវ បណ្តុះបណ្តាលនិងផ្សព្វផ្សាយរបស់វិទ្យាស្ថានចែកចេញជា៦ផ្នែកធំៗ ដែលសរុបទាំងអស់មានចំនួន៣១ចំណុចដូចខាងក្រោម÷

### ក. ការងារអភិរក្ស

**-ពូជដំណាំ:**បន្តការអភិរក្សពូជដំណាំដែលមាននៅក្នុងធនាគារពូជ នៅក្នុងផ្ទះសំណាញ់និងនៅក្នុងចម្ការ។

ទន្ទឹមនឹងនេះដែរ បានធ្វើយុវកម្មលើដំណាំចំនួន២ប្រភេទរួមមានស្រូវចំនួន១០០០បញ្ជីក និងសំណាកនិងដំឡូងមីចំនួន២៨សំណាកព្រមទាំងបានចុះប្រមូលបន្ថែមនូវពូជដំណាំបចំនួន១០ប្រភេទ ដែលក្នុងនោះមានស្រូវចំនួន១៨៥សំណាកនិងដំណាំដទៃទៀតចំនួន៦៦សំណាក។ គិតជារួមត្រឹមដំណាច់ឆ្នាំ២០១២នេះ វិទ្យាស្ថានបានប្រមូលនិងអភិរក្សលើដំណាំចំនួន៣០ប្រភេទ ហើយដែលបន្ទាប់ពីធ្វើយុវកម្មរួច ការអភិរក្សសរុបទាំងអស់មានចំនួន៣៤១១បញ្ជីកនិងសំណាកស្រូវ និង៩០៣សំណាកដំណាំដទៃទៀត។

**-សម្ងហកម្មសត្វល្អិត:**បានបន្តថែរក្សានិងធ្វើការប្រមូលសត្វល្អិតបន្ថែមលើដំណាំស្រូវចំនួន៩ប្រភេទ (មមាចខៀវ មមាចត្នោត មមាចខ្នងតូច ដង្កូវស៊ីរូងដើមក្បាលខ្មៅ ចៃស្រូវ ដង្កូវរុយ ទ្រីបជញ្ជក់ស្លឹក ខ្យងស្រូវពណ៌មាសនិងដង្កូវមូរស្លឹក) លើដំណាំពោតចំនួន៣ប្រភេទ (ចៃពោត ដង្កូវស៊ីរូងផ្លែពោតនិងដង្កូវស៊ីរូងដើមពោត) លើដំណាំសណ្តែកបាយ ចំនួន១០ប្រភេទ (ដង្កូវផែនទី ដង្កូវស៊ីរូងគ្រាប់សណ្តែក ដង្កូវស៊ីរូងផ្លែនិងគ្រាប់សណ្តែក ដង្កូវរុយ ដង្កូវមូរស្លឹក ទ្រីបផ្កា ចៃសណ្តែក ស្រឹងបៃតង ស្រឹងម្ទូលនិងអណ្តើកមាសស៊ីស្លឹក) លើដំណាំប៉េងប៉ោះចំនួន៤ប្រភេទ (ដង្កូវស៊ីរូងផ្លែ ដង្កូវផែនទីដង្កូវហ្វូងតូចនិងចៃពណ៌ខ្មៅ) លើដំណាំម្ទេសចំនួន៥ប្រភេទ (ដង្កូវស៊ីរូងផ្លែ ដង្កូវផែនទី ចៃពណ៌ខ្មៅ រុយចោះផ្លែនិងទ្រីបស្លឹក) និងលើដំណាំស្វាយចំនួន៦ប្រភេទ (ដង្កូវស៊ីរូងដើមនិងឫស រុយចោះផ្លែ ស្កុលស្វាយ ដង្កូវស៊ីរូងមែក និងចៃស្វាយពណ៌ខ្មៅ)។

### ខ. ការអភិវឌ្ឍន៍និងជ្រើសរើសពូជដំណាំ

-បានធ្វើការបង្កាត់និងបង្កាត់ត្រឡប់ពូជស្រូវចំនួន៥០បង្កាត់និងដាំវិយោគកម្មចំនួន១២៣ប្រជាករ ដើម្បីអភិវឌ្ឍពូជស្រូវឲ្យមានភាពធន់ទ្រាំនឹងការរាំងស្ងួត ធន់ទ្រាំនឹងការលិចទឹកធន់ទ្រាំនឹងអាកាសធាតុក្តៅ ធន់ទ្រាំនឹងការដួលដើម ធន់ទ្រាំនឹងដីប្រៃ ធន់ទ្រាំនឹងមមាចត្នោត ព្រមទាំងអភិវឌ្ឍពូជស្រូវមានគុណភាពល្អសម្រាប់ស្រូវវស្សានិងប្រាំង។

-បានធ្វើពិសោធន៍ជ្រើសរើសស្រឡាយស្រូវនិងដំណាំផ្សេងៗទៀតចំនួន៥៣ប្រភេទពិសោធន៍ ក្នុងនោះពិសោធន៍គ្មានសារនិងពិសោធន៍មានសារសរុបចំនួន៩០ពិសោធន៍ពិសោធន៍បន្សាំពូជលើស្រែកសិករមានចំនួន៨៥ពិសោធន៍ និងស្រែ

បង្ហាញមានចំនួន៨៩ស្រែបង្ហាញដែលមានពូជនិងស្រឡាយចូលរួមសរុបចំនួន៩៧៩។បានបន្តសិក្សាវាយតម្លៃពូជស្រូវនាងគំ តាមវិធីសាស្ត្រជម្រើសឯកត្តៈ។

-បានរៀបចំសំណាកជីវសាស្ត្រពូជស្រូវនិងពូជពោតបានចំនួន៨ពូជបន្ថែមទៀត ក្នុងគោលបំណងបង្ហាញនូវលក្ខណៈជីវសាស្ត្ររបស់ដំណាំដោយអាចថែរក្សាទុកបានរយៈពេលពី៤ទៅ៥ឆ្នាំ។ ទន្ទឹមនឹងនេះ បានចុះយកសំណាកស្រូវវារនៅខេត្តកំពង់ធំបានចំនួន០២សំណាកនិងស្រង៉ែ០១សំណាកដែលក្នុងនោះសំណាកស្រូវព្រះពាយក្រហម (ឬបឹងកក់ក្រហម) មានកម្ពស់៥,៣៥ម៉ែត្រនិងសំណាកស្រូវព្រះពាយស (ឬបឹងកក់ស) មានកម្ពស់៤,២៥ម៉ែត្រ។ សំណាកទាំង៣នេះបានរៀបចំដាក់តាំងនៅអគាររដ្ឋបាលនៃវិទ្យាស្ថាន។

## គ. ការបង្កើនផលិតភាពដំណាំ

-លទ្ធផលស្រែបង្ហាញចំនួន២៦កន្លែងនៅខេត្តព្រះវិហារ ស្ទឹងត្រែងនិងមណ្ឌលគិរីបានបង្ហាញថា ១).ការប្រើប្រាស់ពូជស្រូវជំរុញដោយរាជរដ្ឋាភិបាល (ផ្ការំដួល ផ្ការមៀត ផ្កាច័ន្ទសែនសរ និងសែនពិដោរ) ទិន្នផលស្រូវដាំដុះតាមទម្លាប់កសិករកើនពី២,៧៧ត/ហតទៅ៣,២៧ត/ហត និងផ្តល់ប្រាក់ចំណេញដុល២,២លានរៀល (ទម្លាប់កសិករបានតែ១,៦៦លានរៀល) និង២).ការប្រើប្រាស់បង្កុំបច្ចេកទេសបង្កើនផលិតភាពដំណាំស្រូវបានកើនរហូតដល់៤,១៨ត/ហត និងផ្តល់ប្រាក់ចំណេញដុលរហូតដល់២,៦៨លានរៀលដូចបង្ហាញក្នុងក្រាហ្វិកខាងក្រោម។




-តាមរយៈលទ្ធផលពិសោធន៍រយៈពេលវែងនៅក្នុងវិទ្យាស្ថានបានបង្ហាញថាការប្រើប្រាស់ជី NPK តាមការណែនាំរបស់វិទ្យាស្ថានរួមផ្សំជាមួយជីលាមកគោ៥តោន/ហត ពូជស្រូវសែនពិដោរនៅតែរក្សាបានទិន្នផលខ្ពស់ក្នុងរយៈពេល១២ដំណាំ លើក្រុមដីប្រទះឡាងដែលទិន្នផលប្រែប្រួលពី៥តោន/ហតទៅ៥,៤តោន/ហត។

-ការប្រើប្រាស់ផ្ទាំងគម្រូពណ៌ស្លឹកសម្រាប់បាចអាសូត (N) បំប៉នក្នុងការប្រើប្រាស់ជីតាមកម្រិតណែនាំបានបង្កើនទិន្នផលស្រូវរហូតដល់៣,៤តោន/ហត គឺស្មើនឹង៦២% ខ្ពស់ជាងការប្រើប្រាស់ជីតាមទម្លាប់កសិករ(២,១តោន/ហត)។

-ការដុះលូតលាស់របស់ដំណាំសណ្តែកបាយមានការឆ្លើយតបខ្លាំងទៅនឹងការដាក់ជីផូស្វ័រ (P) និងប៉ូតាស្យូម (K) ប៉ុន្តែមិនសូវឆ្លើយតបទៅនឹងការដាក់ជីអាសូត(N) ទេ។

-ថ្នាំ Cyperan 10 EC មានប្រសិទ្ធភាពក្នុងការកម្ចាត់ដង្កូវផែនទីប៉េងប៉ោះនិងសណ្តែកបាយ ស្រឹងបៃតងនិងស្រឹងសណ្តែកបាយ ចំណែកឯថ្នាំ BIOBIT 32B FC មានប្រសិទ្ធភាពខ្ពស់ក្នុងការកម្ចាត់នូវចៃ រុយនិងដង្កូវស៊ីរូងផ្លែសណ្តែកបាយព្រមទាំងដង្កូវស៊ីរូងផ្លែប៉េងប៉ោះ។

-ការពន្លិចទឹកស្រូវនៅដំណាក់កាលសំណាបឬលូតលាស់ដំបូង (ពេលស្រូវនៅទាប) ឲ្យលិចពាក់កណ្តាលស្លឹក មិនត្រឹមតែធ្វើឲ្យមមាចឆ្មោតមិនអាចជញ្ជក់រុក្ខរសបានទេ ថែមទាំងអាចកាត់បន្ថយចំនួនកូនញាស់របស់វាបានទៀតផង។ លទ្ធផលនៃការពិសោធន៍នៅផ្ទះកញ្ចក់ចំនួន០២លើកបានបញ្ជាក់ដូចគ្នាថា ចំនួនកូនមមាចឆ្មោតដែលញាស់មានការថយចុះជាអិចស្ប៉ូណង់ស្យែលជាមួយរយៈពេលពន្លិចទឹក ហើយចំនួននេះបានធ្លាក់ចុះពីជាង៧០០ពីមិនពន្លិចទឹក មកប្រហែល៣០បន្ទាប់ពីពន្លិចទឹករយៈពេល០៧ថ្ងៃ ដូចមានបង្ហាញក្នុងក្រាហ្វិចខាងក្រោម។



រយៈពេលពន្លិចទឹក (ថ្ងៃ)

-លទ្ធផលបឋមបានបង្ហាញថា ការដាំគ្រាប់ស្រូវស្ងួតដោយឧបករណ៍ដាំបំពាក់ជាមួយគោយន្តនិងត្រាក់ទ័រក្នុងជម្រៅពី២ ៣សង់ទីម៉ែត្រផ្តល់ផលស្រូវ៣,៣៨៥/ហតដូចគ្នា គឺច្រើនជាងការព្រោះគ្រាប់ស្រូវស្ងួតរួចរាស់លប់ប្រមាណ៤៥% ដោយសារការដាំគ្រាប់ស្រូវស្ងួតដោយឧបករណ៍ដាំធ្វើឱ្យគ្រាប់ស្រូវដុះលឿននិងដុះបានប្រហែល៩០% ដែលច្រើនជាងការព្រោះដោយដៃរួចរាស់លប់ប្រមាណ៣០%និងមានបរិមាណស្មៅទាប។

## ឃ. ពិពិធកម្មនិងការអង្កេត

-លទ្ធផលនៃការធ្វើស្រែបង្ហាញចំនួន២៩កន្លែងនៅខេត្តតាកែវ កំពតនិងកំពង់ធំលើការដាំដុះដំណាំសណ្តែកបាយបន្ទាប់ពីប្រមូលផលស្រូវវស្សាលើដីល្បាយខ្សាច់បានឱ្យឃើញថា ដោយការប្រើប្រាស់បច្ចេកទេសរបស់វិទ្យាស្ថានទិន្នផលដំណាំសណ្តែកបាយទទួលបានជាមធ្យម៥៦១គីឡូក្រាម/ហត ប៉ុន្តែចំពោះកសិករដែលអនុវត្តតាមបច្ចេកទេសបានល្អទទួលបានរហូតដល់១០៦០គីឡូក្រាម/ហត ដែលសមាមាត្រទៅនឹងប្រាក់ចំណេញដុលចំនួន២,៩លានរៀល។

-លទ្ធផលនៃការអង្កេតជាមួយកសិករចំនួន១៨០គ្រួសារនៅក្នុងស្រុកកោះអណ្តែត អង្គរបុរីនិងគីរីវង់ បានបង្ហាញថា មានគ្រួសារកសិករចំនួន១៨% ធ្វើស្រូវ០៣ដង/ឆ្នាំ ៥៨% ធ្វើស្រូវ០២ដង/ឆ្នាំ និង២៤% ធ្វើស្រូវតែម្តង/ឆ្នាំ។

## ង. មន្ទីរពិសោធន៍

**-មន្ទីរពិសោធន៍ជីវបច្ចេកវិទ្យា:** បានរៀបចំបំពាក់បំពេញនូវឧបករណ៍និងសារធាតុវិភាគសម្រាប់ធ្វើការកំណត់ពន្ធុដោយប្រើសារធាតុសម្គាល់ជាចំនួន (Marker Assisted Selection) បានបណ្តុះបណ្តាលដល់មន្ត្រីជំនាញពីដំណើរការអនុវត្តការងារនិងបានសាកល្បងដំណើរការវិធីសាស្ត្រ។

**-មន្ទីរពិសោធន៍គុណភាពអង្ករ:** បានរៀបចំបំពាក់បំពេញនូវឧបករណ៍និងសារធាតុវិភាគនិងសាកល្បងដំណើរការ។ ទន្ទឹមនឹងនេះដែរបានធ្វើការវិភាគគុណភាពអង្ករលើសីតុណ្ហភាពចម្អិនបានចំនួន៧០សំណាក និងវិភាគអាមីឡូសបាន៤១សំណាកធៀបជាមួយមន្ទីរពិសោធន៍អ៊ីរី (IRRI) ទទួលបានលទ្ធផលដូចគ្នា។

**-មន្ទីរពិសោធន៍ជាលិកាវប្បកម្មដំណាំ:** បាននឹងកំពុងដំណើរការលើដំណាំមួយចំនួនរួមមានដំណាំចេក និងពពួកផ្កាអ័រគីដេ លីលី Chrysanthemum Gladiolus និងដំបងយក្ស។

**-មន្ទីរពិសោធន៍វិភាគដីនិងទឹក:** បានវិភាគសំណាកដីលើប៉ារ៉ាម៉ែត្រសំខាន់ៗដូចជា pH ភាពចម្លងអគ្គិសនី (EC) អាសូត (N) ផូស្វ័រ (P) កាបូនសរីរាង្គ (Organic C) អាម៉ូនីញ៉ូម ($NH^{+4}$) នីត្រាត ($NO^{-3}$) និងទឹកក្នុងដី (Soil water content) សរុបចំនួន៩៨៣សំណាក ព្រមទាំងបានវិភាគសំណាកទឹកលើប៉ារ៉ាម៉ែត្រសំខាន់ៗដូចជា pH ភាពចម្លងអគ្គិសនី (EC) អាលុយមីញ៉ូម (Al) និងដែក (Fe) បានចំនួន១៣៤សំណាក។

**-មន្ទីរពិសោធន៍រុក្ខរោគសាស្ត្រ:** បានធ្វើការបណ្តុះរកភ្នាក់ងារបង្ករោគ ដែលប្រមូលបាននៅក្នុងវិទ្យាស្ថានលើដំណាំសណ្តែកបាយ (៣ប្រភេទ) ប៉េងប៉ោះ (៤ប្រភេទ) ពោត (២ប្រភេទ) ចេក (២ប្រភេទ) ស្វាយ (១ប្រភេទ)។

**-មន្ទីរពិសោធន៍តំណជាតិសាស្ត្រ:** បានប្រមូលស្មៅលើដំណាំស្រូវចំនួន១៣ប្រភេទ ដើម្បីអភិរក្សទុកសម្រាប់ការងារសិក្សាស្រាវជ្រាវ។

## ច. ការផ្សព្វផ្សាយ បណ្តុះបណ្តាលនិងសហប្រតិបត្តិការ

**-តាមរយៈកិច្ចប្រជុំក្រៅប្រទេស:** បានធ្វើបង្ហាញនូវលទ្ធផលស្រាវជ្រាវរបស់វិទ្យាស្ថានទៅដល់អ្នកវិទ្យាសាស្ត្រពាក់ព័ន្ធបានចំនួន១៥លើក។

**-តាមរយៈអត្ថបទវិទ្យាសាស្ត្រ:** បានសរសេរអត្ថបទវិទ្យាសាស្ត្រអំពី លទ្ធផលការងារស្រាវជ្រាវ និងបោះពុម្ពតាមរយៈទស្សនាវដ្ដីវិទ្យាសាស្ត្របានចំនួន១អត្ថបទ(Shu Fukai and Makara Ouk (2012).Increased productivity of rainfed lowland rice croppingsystems of the Mekong region. Crop and Pasture Science, 2012, 63, 944-973)។

**-តាមរយៈការបោះពុម្ពនិងចែកចាយ:** បានបោះពុម្ពរបាយការណ៍ប្រចាំឆ្នាំ២០១០ និង២០១១របស់វិទ្យាស្ថានសរុបចំនួន១២០០ច្បាប់ ទស្សនាវដ្ដីកសិកម្មកម្ពុជា (CJA) ចំនួន៧០០ច្បាប់ព្រឹត្តិប័ត្រព័ត៌មានកសិករសរុបចំនួន១៨៥០០ច្បាប់និងសៀវភៅស្នោចង្រៃនៃដំណាំស្រូវនៅអាស៊ីជាភាសាខ្មែរចំនួន១៥០០ច្បាប់។ បានធ្វើការបែងចែកសៀវភៅស្ដីពីពូជស្រូវ និងបច្ចេកទេសដាំដុះការគ្រប់គ្រងជីជាតិដីកម្រងឯកសារអំពី ក្បេត្របរិស្ថានដំណាំស្រូវក្នុងប្រទេសកម្ពុជាការកំណត់ក្រុមដីស្រែលក្ខណៈសំខាន់ៗរបស់ពូជស្រូវចំនួន១០ពូជ វិធីសាស្ត្រសម្រិតសម្រាំងគ្រាប់ពូជស្រូវតាមបែបកសិករ និងបង្គិបច្ចេកទេសបង្កើនផលិតភាពដំណាំស្រូវសរុបចំនួន៤៦០០ច្បាប់ ព្រមទាំងបដាស្ដីពីការប្រើប្រាស់ជីនិងប្រហ្វីលក្រុមដីសំខាន់ៗចំនួន២៨៥ផ្ទាំង និងបានបែងចែកព្រឹត្តិប័ត្រព័ត៌មានកសិករសរុបចំនួន១៨១០០ច្បាប់ ជូនថ្នាក់ដឹកនាំក្រសួង ក្រុមប្រឹក្សាភិបាលអង្គភាពក្រោមឱវាទក្រសួង មន្ទីរកសិកម្មរាជធានី ខេត្ត ការិយាល័យកសិកម្មស្រុកនិងអ្នកពាក់ព័ន្ធជាពិសេសដល់កសិករ។

**-តាមរយៈគេហទំព័រ www.cardi.org.kh និងwww.crkb.org.kh:** ក្នុងរយៈពេលមួយឆ្នាំនេះមានអ្នកបើកស្រាវជ្រាវរកព័ត៌មានបច្ចេកទេសកសិកម្មរបស់វិទ្យាស្ថានសរុបចំនួន ១០៩៤៥០នាក់ ហើយគិតជាមធ្យមមានប្រមាណ៣០៤នាក់/ថ្ងៃ (កើនលើសឆ្នាំ២០១១ចំនួន៥៥នាក់/ថ្ងៃ) ដែលក្នុងនោះ ក្នុងប្រទេសកម្ពុជាចំនួន ៦១% សហរដ្ឋអាមេរិកចំនួន ១៣% អូស្ត្រាលី ចំនួន១០% ជប៉ុនចំនួន៦% និងប្រទេសផ្សេងៗទៀត(១០១ប្រទេស) ចំនួន១០%។

**-តាមរយៈទិវាស្រែបង្ហាញនិងបណ្ដុះបណ្ដាលកសិករ:** បានធ្វើទិវាស្រែបង្ហាញចំនួន៧កន្លែង ដែលមានមន្ត្រីបច្ចេកទេសមន្ត្រីផ្សព្វផ្សាយនិងកសិករចូលរួមចំនួន៣២៩នាក់ និងវគ្គបណ្ដុះបណ្ដាលកសិករចំនួន៦វគ្គ ដែលមានអ្នកចូលរួមចំនួន១៣២នាក់។ បានចែកពូជស្រូវក្នុងចំណោមពូជស្រូវ១០ពូជក្នុងមួយគ្រួសារចំនួន៥គីឡូក្រាមជូនដល់កសិករចំនួន១២២គ្រួសារ ដែលក្នុងនោះនៅខេត្តស្ទឹងត្រែងចំនួន៥១គ្រួសារ ខេត្តមណ្ឌលគីរីចំនួន៤៣គ្រួសារនិងខេត្តព្រះវិហារចំនួន២៨គ្រួសារតាមលក្ខខណ្ឌដាំដុះរបស់កសិករនីមួយៗ។

**-តាមរយៈការចូលរួមជាវាគ្មិនក្នុងកម្មវិធីវិទ្យុនិងទូរទស្សន៍:** បានចូលរួមជាវាគ្មិនក្នុងកម្មវិធីសន្ទនាមតិ "ជីវិតយើង សង្គមយើង" លើប្រធានបទស្ដីពី វិធីបន្សុទ្ធពូជស្រូវ និងស្ដីពីការប្រើប្រាស់ដីសើមបន្ទាប់ពីប្រមូលផលស្រូវវស្សាចំនួន២លើក និងចូលរួមជាជាគណៈអធិបតីនិងភ្ញៀវកិត្តិយសក្នុងវេទិកាស្វែងយល់កសិកម្មលើប្រធានបទសហគមន៍ព្រៃឈើនិងការប្រែប្រួលអាកាសធាតុនៅស្ថានីយ៍ទូរទស្សន៍ជាតិកម្ពុជាសរុបចំនួន២លើក ចូលរួមជាវាគ្មិនកិត្តិយសក្នុងកម្មវិធីនាទីវេទិកា អ្នកស្ដាប់នៅវិទ្យុអាស៊ីសេរីចំនួន១លើក ចូលរួមផ្ដល់បទសម្ភាសន៍ជាមួយវិទ្យុ ABC ស្ដីពី ការស្រាវជ្រាវដំណាំស្រូវប្រឈមនឹងការប្រែប្រួលអាកាសធាតុនិងស្ដីពីប្រភេទដី និងការគ្រប់គ្រងដីសម្រាប់ដំណាំកសិកម្មកម្ពុជាសរុបចំនួន២លើក ផ្ដល់បទសម្ភាសន៍ពាក់ព័ន្ធវេទិកាដំណាំបន្លែនៅស្ថានីយ៍ទូរទស្សន៍CTN ចំនួន០១លើក។

**-តាមរយៈសារណា:** បានទទួលនិស្សិតចំនួន១៧នាក់ ដែលក្នុងនោះ៦នាក់មកពីសាលាជាតិកសិកម្មព្រែកលៀបនិង ១១នាក់មកពីសាកលវិទ្យាល័យភូមិន្ទកសិកម្ម ធ្វើពិសោធន៍និងដឹកនាំសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រកសិកម្ម។

**-ការងារបណ្ដុះបណ្ដាល:** បានបើកវគ្គបណ្ដុះបណ្ដាល សិក្ខាសាលានិងសន្និបាតចំនួន១០វគ្គ ដែលមានអ្នកចូលរួមសរុបចំនួន៥៥៧នាក់។ បានចូលរួមវគ្គបណ្ដុះបណ្ដាល សិក្ខាសាលានិងសន្និបាតក្នុងប្រទេសចំនួន១១លើកដែលមានថ្នាក់ដឹកនាំនិងមន្ត្រីវិទ្យាស្ថានទៅចូលរួមសរុបចំនួន៣៨នាក់និងក្រៅប្រទេសចំនួន៣០លើក ដែលមានថ្នាក់ដឹកនាំនិងមន្ត្រីវិទ្យាស្ថានចូលរួមចំនួន៣៨នាក់និងថ្នាក់ក្រោយឧត្តមសិក្សា(បរិញ្ញាបត្រជាន់ខ្ពស់និងបណ្ឌិត) ក្រៅប្រទេសចំនួន៨នាក់។

**-ការងារសហប្រតិបត្តិការ:** បានធ្វើកិច្ចសហប្រតិបត្តិការជាមួយ ACIAR, IRRI, RDA, KOICA, KOPIA, CIAT, Nippon Foundation, INIBAP, FAO, Development Alternatives Incorporation (DAI), IAS, IDE Cambodia, University of Tokyo និង YAAS បានល្អគួរជាប់ខ្លួន។

- បានចូលរួមបង្រៀនថ្នាក់បរិញ្ញាបត្រនៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម និងសមាជិកនៃ "ក្រុមជំនាញថ្នាក់ជាតិសរសេរសេចក្តីព្រាងគោលនយោបាយជាតិ វិទ្យាសាស្ត្របច្ចេកវិទ្យានិងនវានុវត្តន៍ (NCOST)" ដើម្បីប្រជុំរៀបចំសេចក្តីព្រាងគោលនយោបាយជាតិស្តីពីវិទ្យាសាស្ត្របច្ចេកវិទ្យានិងនវានុវត្តន៍បានចំនួន៥លើក។

### ៥.៣-២. វាយតម្លៃនិងសំណើ

ក្នុងឆ្នាំ២០១២នេះថ្នាក់ដឹកនាំនិងមន្ត្រី-និយោជិតទាំងអស់ បានខិតខំប្រឹងប្រែងដឹកនាំនិងបំពេញភារកិច្ច ដើម្បីកសាងនិងអភិវឌ្ឍន៍វិទ្យាស្ថានដោយស្មារតីយកចិត្តទុកដាក់និងទទួលខុសត្រូវខ្ពស់ស្របតាមវិធានការដែលបានលើកឡើងក្នុងឆ្នាំ២០១១។ សមិទ្ធផលសំខាន់ៗមានជាអាទិ៍ (១)វិទ្យាស្ថានបានធ្វើពិសោធន៍ចំនួន១២៣ប្រភេទដែលមានចំនួនពិសោធន៍សរុប៥៥៨កន្លែង និងបានធ្វើអង្កេតចំនួន៧ប្រភេទមានចំនួន១១៣០កម្រងសំណួរ និងបានពិភាក្សាជាក្រុមចំនួន១៥លើកមានអ្នកចូលរួមសរុប២៥០នាក់ (២)បានប្រារព្ធទិវាស្រែបង្ហាញចំនួន៧កន្លែងមានអ្នកចូលរួមចំនួន៣២៩នាក់និងបានបណ្តុះបណ្តាលកសិករចំនួន៩វគ្គមានអ្នកចូលរួមចំនួន១៣២នាក់ រួមទាំងមន្ត្រីបច្ចេកទេសនិងមន្ត្រីផ្សព្វផ្សាយខេត្ត (៣)បានបោះពុម្ពទស្សនាវដ្តីកសិកម្មកម្ពុជា (CJA) ចំនួន៧០០ច្បាប់និងសៀវភៅស្នោចង្រៃនៃដំណាំស្រូវជាភាសាខ្មែរបានចំនួន១៥០០០ច្បាប់ ព្រមទាំងបានធ្វើការបែងចែកសៀវភៅឯកសារនានារបស់វិទ្យាស្ថានចំនួន៤៦០០ច្បាប់ បដាស្តីពីការប្រើប្រាស់ជីនិងប្រូហ្វីលក្រុមដីសំខាន់ៗចំនួន២៤៥ផ្ទាំងនិងព្រឹត្តិប័ត្រព័ត៌មានកសិករចំនួន១៨១០០ច្បាប់ជូនថ្នាក់ដឹកនាំក្រសួង ក្រុមប្រឹក្សាភិបាល អង្គភាពក្រោមឱវាទក្រសួង មន្ទីរកសិកម្មរាជធានី ខេត្ត ការិយាល័យកសិកម្មស្រុកនិងអ្នកពាក់ព័ន្ធជាពិសេសដល់កសិករដើម្បីចូលរួមអនុវត្តចក្ខុកោណរបស់រាជរដ្ឋាភិបាល ជាពិសេសគោលនយោបាយជំរុញផលិតកម្មដំណាំស្រូវនិងការនាំចេញអង្ករ (៤)បានបង្កើតនិងជ្រើសរើសបាននូវស្រឡាយ ស្រូវមួយចំនួនដែលចាំបាច់សម្រាប់ធ្វើពិសោធន៍បន្ត និង (៥)បញ្ជាក់នូវបច្ចេកទេសបង្កើនផលិតភាពដំណាំមួយចំនួនដូចមានរៀបរាប់ខាងលើ។

ទន្ទឹមនឹងកិច្ចខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំនិងមន្ត្រី-និយោជិតទាំងអស់ព្រមទាំងដើម្បីឆ្លើយតបទៅនឹងយុទ្ធសាស្ត្រចតុកោណនិងគោលនយោបាយជំរុញផលិតកម្មដំណាំស្រូវនិងការនាំចេញអង្កររបស់រាជរដ្ឋាភិបាលក៏ដូចជា ផែនការយុទ្ធសាស្ត្ររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ វិទ្យាស្ថានមានសំណូមពរសំខាន់ៗចំនួន០៣គឺ (១)សំណើឲ្យបន្តការបង្កើនថវិការាជរដ្ឋាភិបាលសម្រាប់វិស័យស្រាវជ្រាវ និងបន្តជំរុញឲ្យប្រទេសផ្តល់ជំនួយពង្រឹងស្ថាប័នស្រាវជ្រាវជាតិបន្ថែមទៀតជាពិសេសផ្នែកហិរញ្ញវត្ថុ និងធនធានមនុស្សសម្រាប់ការងារគ្រប់គ្រងប្រតិបត្តិការរបស់វិទ្យាស្ថាន (២)សំណើជួយគាំទ្រដល់បច្ចេកទេសអភិវឌ្ឍន៍ដោយវិទ្យាស្ថាននិងប្រើប្រាស់ដោយប្រុងប្រយ័ត្ននូវបច្ចេកទេសបរទេសជាពិសេសពូជដំណាំនិង (៣)សំណើសុំផ្តល់នូវធនធានមនុស្សប្រកបដោយគុណភាពបន្ថែមទៀត ដោយសារមន្ត្រីវិទ្យាស្ថានមួយចំនួនបានចូលនិវត្តន៍ជាបន្តបន្ទាប់។

ទន្ទឹមនឹងនោះដែរ វិទ្យាស្ថាននៅជួបប្រទះការលំបាកចំនួន០២ធំៗ ដែលទោះបីជាថ្នាក់ដឹកនាំ និងជាពិសេស **ឯកឧត្តមរដ្ឋមន្ត្រី**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានជួយធ្វើអន្តរាគមន៍ជាបន្តបន្ទាប់ទៅស្ថាប័នទទួលខុសត្រូវក៏ដោយ ក៏បញ្ហាទាំងនេះនៅតែជាបញ្ហាប្រឈមដដែលពីព្រោះជាបញ្ហាផែនការយូរអង្វែងរបស់រាជធានីភ្នំពេញ។ បញ្ហាទាំង០២នោះគឺ ១)ប្រព័ន្ធទឹកស្អាតមិនទាន់មកដល់ និង២)ភ្លើងអគ្គិសនីនៅតែបន្តដាច់ជាប្រចាំជារៀងរាល់ថ្ងៃ ដែលបញ្ហាទាំង០២នេះបង្កឲ្យមានការលំបាកក្នុងដំណើរការមន្ទីរពិសោធន៍និងជាពិសេសបណ្តាលឲ្យឆាប់ខូចឧបករណ៍វិភាគ ព្រមទាំងបរិមាណប្រេងប្រើប្រាស់ច្រើន។

### ៥.៣-៣. វិធានការ

ពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តការជាមួយដៃគូអភិវឌ្ឍន៍ អង្គភាពស្រាវជ្រាវជាតិនិងអន្តរជាតិ មន្ទីរកសិកម្មរាជធានី ខេត្ត អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកនិងក្រៅស្រុកនានា ដើម្បី (១)បន្តអភិវឌ្ឍពូជដំណាំកសិកម្ម ដែលមានសក្តានុពលទិន្នផលខ្ពស់ហើយប្រកបដោយគុណភាពល្អប្រពៃធន់ទ្រាំទៅនឹងទឹកជំនន់ គ្រោះរាំងស្ងួត ជាតិប្រៃនិងកំដៅពូជស្រូវអាយុកាលខ្លីជាង១០០ថ្ងៃនិងបន្តធ្វើការស្រាវជ្រាវ ដោយប្រើវិធីសាស្ត្ររួមគ្នាប្រកបដោយសុវត្ថិភាពនិងមាននិរន្តរភាពដើម្បីជួយកសិករក្នុងការការពារការបាត់បង់ទិន្នផលដំណាំនិងប្រាក់ចំណេញ (២)បន្តស្រាវជ្រាវនិងអភិវឌ្ឍបច្ចេកទេសនៃប្រព័ន្ធគ្រប់គ្រងជីជាតិដី សារធាតុចិញ្ចឹមប្រកបដោយលក្ខណៈសេដ្ឋកិច្ចនិងនិរន្តរភាពខ្ពស់ ដើម្បីជួយប្រជាកសិករក្នុង

ការបង្កើននិងធ្វើឱ្យមានស្ថេរភាពទិន្នផលដំណាំនៅក្នុងប្រព័ន្ធកសិកម្មនៃតំបន់ទំនាប តំបន់ស្រោចស្រពនិងតំបន់ខ្ពង់រាប តាមរយៈការធ្វើឱ្យកាន់តែប្រសើរឡើងនូវចំណេះដឹងលើផ្នែកគ្រប់គ្រងដីនិងសារធាតុចិញ្ចឹមរបស់ដំណាំ (៣)បន្តសិក្សារកលទ្ធភាពបង្កើនផលិតភាពនិងពិពិធកម្មដំណាំកសិកម្មក្នុងប្រព័ន្ធកសិកម្ម នៃតំបន់ទំនាបនិងតំបន់ខ្ពង់រាប នៃប្រព័ន្ធផលិតកម្មដំណាំកសិកម្ម (៤)បន្តស្រាវជ្រាវដើម្បីអភិវឌ្ឍន៍សមត្ថភាពវិភាគក្នុងមន្ទីរពិសោធន៍ផ្នែកវិភាគដី ទឹក រុក្ខជាតិ ជីធី រុក្ខវិទ្យា និងជាលិកាវប្បកម្ម (៥)បន្តពង្រឹងនិងជំរុញការផ្សព្វផ្សាយបច្ចេកវិទ្យាទៅដល់កសិករនិងអ្នកពាក់ព័ន្ធនានាតាមរយៈការបោះពុម្ពផ្សាយគេហទំព័រ កាសែត វិទ្យុនិងទូរទស្សន៍ (៦) លើកកម្ពស់សមត្ថភាពរបស់មន្ត្រី និយោជិតតាមរយៈវគ្គបណ្តុះបណ្តាល សិក្ខាសាលា ទស្សនកិច្ចសិក្សានិងកិច្ចប្រជុំផ្សេងៗ ទាំងក្នុងប្រទេសនិងក្រៅប្រទេស និង (៧)ប្រើប្រាស់អគ្គិសនីដោយសន្សំសំចៃ។

## ៥.៤- ផលិតកម្មនិងបសុព្យាបាល (ឧបសម្ព័ន្ធទី៩-១១)

ការងារផលិតកម្មសត្វ និងសុខភាពសត្វ ជាវិស័យមួយយ៉ាងសំខាន់ ក្នុងការចូលរួមចំណែកអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២របស់រាជរដ្ឋាភិបាលកម្ពុជា ជាពិសេសបាននិងកំពុងបន្តបំពេញការអនុវត្តការងារ និងភារកិច្ចរបស់ខ្លួន យ៉ាងមមាញឹកបំផុត និងធ្វើឱ្យសម្រេចសមិទ្ធផលយ៉ាងធំធេងជាបន្តបន្ទាប់ប្រកបដោយជោគជ័យយ៉ាងត្រចះត្រចង់។

វិស័យនេះ បានបង្កើតការងារ និងបង្កើនប្រាក់ចំណូលជូនប្រជាកសិករនៅតាមជនបទ ចូលរួមចំណែកកាត់បន្ថយភាពក្រីក្រ និងកំណើនជីវភាពគ្រួសារឱ្យមានភាពធូរធា និងសេដ្ឋកិច្ចរុងរឿង ស្របតាមគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល។ វិស័យផលិតកម្មសត្វ និងសុខភាពសត្វ បានរួមចំណែកប្រមាណ ១៥%នៃផលិតផលសុបរបស់វិស័យកសិកម្ម ។ ដើម្បីសម្រេចគោលដៅ និងគោលបំណងខាងលើ វិស័យនេះបានចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគោលនយោបាយ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាលកម្ពុជា ដោយបន្តការគាំទ្រ និងពង្រឹងសន្តិសុខស្បៀង ផ្តល់អាហាររូបត្ថម្ភគ្រប់គ្រាន់ និងសុវត្ថិភាពម្ហូបអាហារសម្រាប់តម្រូវការក្នុងស្រុក និងការនាំចេញ។ ក្នុងឆ្នាំ២០១២កន្លងទៅនេះ ក៏ដូចជារយៈពេលឆ្នាំបន្តបន្ទាប់ទៀត សកម្មភាពជាច្រើនត្រូវបានអនុវត្តនៅក្នុងរាជធានី ខេត្តទាំង២៤ ដោយមានការសម្របសម្រួល និងសហការជាមួយអង្គភាពជំនាញ មន្ទីរកសិកម្មរាជធានី ខេត្ត គម្រោងកម្មវិធីនានា ព្រមទាំងជាមួយភ្នាក់ងារប្រតិបត្តិមួយចំនួននៅតាមមូលដ្ឋាន អង្គការក្រៅរដ្ឋាភិបាល បណ្តាប្រទេសជាមិត្ត អាជ្ញាធរមូលដ្ឋាន និងផ្នែកឯកជន សំដៅជួយក្នុងការអភិវឌ្ឍន៍លើការងារផលិតកម្ម និងសុខភាពសត្វនេះយ៉ាងសកម្មបំផុត។

ជារួមវិស័យផលិតកម្មនិងបសុព្យាបាល នៅជួបប្រទះបញ្ហាប្រឈមមួយចំនួន ដូចជាជំងឺឆ្លងរាលដាលសត្វ គោក្របីខ្វះខាតចំណីអាហារ ការយល់ដឹងរបស់កសិករលើបច្ចេកទេស និងការផ្សព្វផ្សាយបច្ចេកទេសនៅមានកម្រិត ថ្លៃដើមផលិតកម្មខ្ពស់ និងវិនិយោគទុនលើវិស័យចិញ្ចឹមសត្វនៅមានសន្ទុះយឺត។ល។

នៅក្នុងឆ្នាំ២០១២កន្លងទៅនេះ ជំងឺឆ្លងសត្វ នៅជាបញ្ហាប្រឈមសំខាន់បំផុត ដែលវិស័យផលិតកម្មនិងបសុព្យាបាលបាននិងកំពុងយកចិត្តទុកដាក់ខ្ពស់បំផុត ក្នុងការប្រយុទ្ធប្រឆាំង ជាពិសេសជំងឺផ្តាសាយបក្សីលើបក្សី ដែលបានផ្ទុះឡើងចំនួន០១ករណី នៅខេត្តកំពង់ស្ពឺ និងផ្តាសាយបក្សីលើមនុស្ស ចំនួន០៣ ករណី នៅខេត្តកំពង់ស្ពឺ កំពង់ឆ្នាំង និងបន្ទាយមានជ័យ ។ បន្ថែមលើសពីនេះ ស្ថានភាពជំងឺដទៃផ្សេងទៀតរួមមាន ជំងឺជ្រូកត្រចៀកខៀវ ជំងឺសារទឹក និងជំងឺអុតក្តាម គឺមានការផ្ទុះរាលដាលនៅតំបន់មួយចំនួន ដែលបង្កឱ្យមានការប៉ះពាល់ដល់ផលិតកម្មសត្វ។

លទ្ធផលដែលសម្រេចបានទាំងនេះ ក៏ដោយសារមានការគាំទ្រពីសំណាក់រាជរដ្ឋាភិបាល ជាពិសេសក្រោមការដឹកនាំរបស់ថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងដោយមានការខិតខំប្រឹងប្រែងយក ចិត្តទុកដាក់ពីមន្ត្រីនាយកដ្ឋានផលិតកម្ម និងបសុព្យាបាល មន្ទីរកសិកម្មខេត្ត ការិយាល័យផលិតកម្ម និងបសុព្យាបាលរាជធានី ខេត្ត ភ្នាក់ងារសុខភាពសត្វភូមិ ប្រជាកសិករម្ចាស់សត្វ ជាពិសេសម្ចាស់ជំនួយពីអង្គការជាតិ និងអន្តរជាតិនានា ។

### ៥.៤.១-លទ្ធផល

#### ក- គោលដៅនិងយុទ្ធសាស្ត្រសំខាន់ៗ

នៅក្នុងឆ្នាំ២០១២នេះ អនុវិស័យផលិតកម្ម និងបសុពេទ្យបាល បានកំណត់គោលដៅគោលនយោបាយ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ ដើម្បីបង្កើននូវផលិតភាពសត្វ ដោយធានាបាននូវកំលាំងអូសទាញ ការពារ និងទប់ស្កាត់ជំងឺឆ្លងសត្វ សុខភាពសាធារណៈ ម្ហូបអាហារ និងការនាំចេញសត្វ និងផលិតផលមានដើមកំណើតពីសត្វ ដើម្បីប្តូរជារូបិយប័ណ្ណសម្រាប់ជាចំណូលគ្រួសារ និងសេដ្ឋកិច្ចជាតិ ក្នុងការអនុវត្តការងារលើអនុវិស័យនេះ ប្រកបដោយប្រសិទ្ធភាព ស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យរយៈពេលខ្លី មធ្យម និងវែងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០០៩-២០១៣ នៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា។ គម្រោងសកម្មភាពកម្មវិធីជាអទិភាពសម្រាប់ការអនុវត្តឱ្យស្របតាមគោលនយោបាយជាតិរួមមាន÷

- កសាងច្បាប់និងអភិវឌ្ឍធនធានមនុស្ស
- ការកាត់បន្ថយអត្រាសត្វឈឺនិងងាប់ តាមរយៈការត្រួតពិនិត្យជំងឺសត្វ
- ការធ្វើឱ្យប្រសើរឡើងនូវសុវត្ថិភាពម្ហូបអាហារមានប្រភពពីសត្វនិងសុខភាពសាធារណៈ ពិសេសការទប់ស្កាត់ជំងឺឆ្លងពីសត្វទៅមនុស្ស
- ជំរុញធ្វើឱ្យប្រសើរឡើងនូវផលិតកម្មចំណីសត្វនិងធ្វើឱ្យប្រសើរឡើងនូវពូជសត្វ
- ជំរុញការគ្រប់គ្រងកាកសំណល់សត្វ តាមរយៈការសាងសង់ឡជីវឧស្ម័ន
- ជំរុញការកែទម្លាប់ការចិញ្ចឹមសត្វរបស់កសិករបែបយថាផលនិងការចិញ្ចឹមសត្វ សម្រាប់ផ្គត់ផ្គង់គ្រួសារទៅជាការចិញ្ចឹមសត្វតាមបច្ចេកទេស ទៅជាបែបពាណិជ្ជកម្ម ដោយមានជីវសុវត្ថិភាព
- បង្កើននិងពង្រឹងការស្រាវជ្រាវ និងផ្សព្វផ្សាយលើការងារផលិតកម្មសត្វនិងសុខភាពសត្វ
- ជំរុញឱ្យប្រសើរឡើងនូវឥណទានក្នុងការសាងសង់ឡជីវឧស្ម័ននិងការចិញ្ចឹមសត្វ
- លើកទឹកចិត្តការវិនិយោគលើការចិញ្ចឹមសត្វ សេវាកម្មសុខភាពសត្វ និងធ្វើឱ្យប្រសើរឡើងនូវទីផ្សារសត្វ និងផលិតផលមានដើមកំណើតពីសត្វ

## ខ. សកម្មភាពនិងលទ្ធផលសម្រេចបានឆ្នាំ២០១២

### ខ.១. លទ្ធផលសំខាន់ៗឆ្នាំ២០១២

ការអនុវត្តការងារអនុវិស័យនេះ ក្នុងរយៈមួយឆ្នាំកន្លងទៅនេះ ទទួលបានលទ្ធផលសំខាន់ៗ ដូចខាងក្រោម÷

-ស្ថិតិសត្វ បានកត់សំគាល់ថា គោ ក្របីសរុប **៤.០៨៣.៣៧៣** ក្បាល ថយចុះចំនួន **១,៥៤%** ក្នុងនោះ គោសរុបចំនួន **៣.៣៨១.៣៩៨** ក្បាល ថយចុះ **0,៨៩** % និងក្របីសរុបចំនួន **៦៩៧.០១២** ក្បាល ថយចុះ **៥,១៥** % ធៀបឆ្នាំ២០១១ ។ សត្វស្លាប កើន **៥,៩៣%** និងជ្រូក កើនឡើងចុះ **៨,៨៨** % ធៀបទៅនឹងឆ្នាំ២០១១។

-តាមការវិភាគពីស្ទួចនាករនៃសត្វគ្រប់ប្រភេទ បានសន្និដ្ឋានថា មានការកើនឡើងដល់ ៣១,៤ លានក្បាល ដែលស្មើនឹង៤.៨៨% ធៀបនឹងចំណុចដៅ ២៨,៥លានក្បាល។

-ស្ថានីយ មានជ្រូកពូជសរុបចំនួន **១៧៩** ក្បាល ក្នុងនោះមេពូជមានចំនួន **១៦១** ក្បាល និងបាពូជមានចំនួន**១៨** ក្បាល។ ឆ្នាំ២០១១ ស្ថានីយ ផលិតបានកូនជ្រូកពូជចំនួន **៨៥១** ក្បាល ដែលបានលក់ចែកចាយជូនកសិករសម្រាប់ធ្វើពូជក្នុងតម្លៃគោលនយោបាយរដ្ឋ។ កសិករពីខេត្តចំនួន **១២** រួមមាន ខេត្តកណ្តាល ព្រះវិហារ តាកែវ ព្រះសីហនុ សៀមរាប ព្រៃវែង តាកែវ កំពង់ចាម រាជធានីភ្នំពេញ ពោធិសាត់ កំពត និងរតនៈគីរី បានទទួលទិញជ្រូកពូជពីស្ថានីយ ដើម្បីចិញ្ចឹមផ្សព្វផ្សាយពូជបន្ត

-ស្ថានីយមានចំនួនគោសរុប **២២៦** ក្បាល ក្នុងនោះមានគោពូជកំផែងសែន ចំនួន **៣៦** ក្បាល ជាអំណោយដ៏ថ្លៃថ្លារបស់**ឯកឧត្តមបណ្ឌិត ច័ន្ទ សារុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ស្ថានីយមិនគ្រាន់តែជាកន្លែងចិញ្ចឹមគោពូជប៉ុណ្ណោះទេ ប៉ុន្តែក៏ជាកន្លែងដាំ និងផ្សព្វផ្សាយដំណាំចំណីសត្វផងដែរ។ ឆ្នាំ២០១២ ស្ថានីយបានចែកពូជស្មៅឃីងក្រាស ហ្គីណេ ម៉ារ៉ាន់ឌូ មុលឡាតូ ប៉ាស្ពាឡូម និងស៊ីម្លងដល់បណ្តាខេត្តមួយចំនួន ហើយស្ថានីយក៏បានផ្សព្វផ្សាយពូជគោទៅតាមបណ្តាខេត្តដូចជា ខេត្តសៀមរាប ខេត្តកំពត និងខេត្តបាត់ដំបង

-ការកែលំអរពូជសត្វនិងការដាំដំណាំចំណីសត្វ កំពុងតែមានការរីកចម្រើនល្អប្រសើរ និងពង្រីកការផ្សព្វផ្សាយពូជសត្វ និងពូជស្មៅជាបន្តទៅតំបន់ផ្សេងៗ ទូទាំងប្រទេសយ៉ាងផុសផុល

-គម្រោងសាងសង់ឡជីវឧស្ម័នថ្នាក់ជាតិ÷ ចាប់ពីឆ្នាំ ២០០៦ ដល់ឆ្នាំ ២០១២ ការកសាងឡជីវឧស្ម័ន បានអនុវត្តក្នុងខេត្តចំនួន១៤ សរុបមានចំនួន១៩.១៧៣ ឡ ដែលក្នុងនោះ នៅឆ្នាំ ២០១២ ឡជីឧស្ម័ន បានសាងសង់ចំនួន ៤.២០១ ឡ

-ព័ត៌មានទីផ្សារសត្វនិងផលិតផលសត្វ មានតួនាទីយ៉ាងសំខាន់ ដើម្បីផ្សព្វផ្សាយពីតំលៃសត្វ និងផលិតផលសត្វដល់ប្រជាកសិករនៅតាមមូលដ្ឋាន សម្រាប់ជាមូលដ្ឋានក្នុងការលក់ដូរសត្វរបស់កសិករ

-ការអភិវឌ្ឍន៍ការចិញ្ចឹមសត្វនៅតាមមូលដ្ឋាននៃរាជធានី ខេត្ត នៅទូទាំងប្រទេស ដោយមានការសហការជាមួយអង្គការជាដៃគូ និងផ្នែកឯកជន គឺមានការអនុវត្តបានល្អប្រសើរជាងឆ្នាំមុនៗ

-ជំងឺអុតក្តាម សារទឹក បូសខ្យល់ ជំងឺផ្តាសាយបក្សី និងជំងឺផ្សេងៗទៀត គឺត្រូវបានចាត់ទុកថា ជាជំងឺឆ្លងដ៏សំខាន់ដែលនៅតែបន្តការបង្កនូវភាពស្មុគ្រស្មាញ បំផ្លិចបំផ្លាញ និងគ្រោះមហន្តរាយដល់អាយុជីវិតមនុស្ស សត្វ

-ជំងឺផ្តាសាយបក្សី គឺនៅជាបញ្ហាចំបង ហើយនាឆ្នាំ២០១២ ជំងឺផ្តាសាយបក្សីលើបក្សី បានផ្ទុះឡើងចំនួន០១ករណីនៅខេត្តកំពង់ស្ពឺ និងផ្តាសាយបក្សីលើមនុស្ស ចំនួន០៣ករណី នៅខេត្តកំពង់ឆ្នាំង កំពង់ស្ពឺ និងបន្ទាយមានជ័យ។ បន្ថែមលើសពីនេះ ស្ថានភាពជំងឺដទៃផ្សេងទៀតរួមមាន ជំងឺជ្រូកត្រចៀកខៀវ ជំងឺសារទឹក និងជំងឺអុតក្តាម គឺមានការផ្ទុះរាលដាលនៅតំបន់មួយចំនួន ដែលបង្កឲ្យមានការប៉ះពាល់ដល់ផលិតកម្មសត្វ

-ជាលទ្ធផលនៅទូទាំងប្រទេសសត្វបានទទួលការចាក់ថ្នាំការពាររួមមាន÷ សារទឹកគោក្របីបានចំនួន១.១៦០.៧៣១ក្បាល អុតក្តាមគោក្របីបានចំនួន៥៦.៨០៤ក្បាល បូសខ្យល់ចំនួន១២.៧៧១ក្បាល សារទឹកជ្រូកចំនួន១៥១.៨៣១ក្បាល ប៉េស្តជ្រូកចំនួន២១៦.៣៨៩ក្បាល សាល់ម៉ូជ្រូកចំនួន១៤០.០៤០ក្បាល អុតក្តាមជ្រូកចំនួន២៥.០៦០ក្បាល អូហ្យេស្គីជ្រូកចំនួន២០.១៦១ក្បាល រាគកូនជ្រូកចំនួន២៧.២៤៥ក្បាល កញ្ជ្រឹលជ្រូកចំនួន១៤.៣២៩ក្បាល ញីវកាសបក្សីចំនួន១.៥១០.៥៤៩ ក្បាល អាសន្នរោគមាន់ចំនួន១.៤០៨.៥៩៩ក្បាល អុតបក្សីចំនួន ១.១៣៤.៣២២ ក្បាល អាសន្នរោគទាចំនួន ១២៣.១៦៣ក្បាល ហ្គុមបូរ៉ូចំនួន ២២.១៤៩ ក្បាល និងប៉េស្តទាចំនួន១៨៨.៦១៧ក្បាល

-ការទប់ស្កាត់ជំងឺឆ្លងសត្វៈ បានពង្រឹងការត្រួតពិនិត្យចលនាសត្វ និងផលិតផលមានដើមកំណើតពីសត្វ ពង្រឹងការស្រាវជ្រាវ យកវត្ថុវិភាគ ធ្វើការផ្សព្វផ្សាយជាប្រចាំនូវផលប៉ះពាល់នៃជំងឺឆ្លង វិធានការការពារ និងជីវសុវត្ថិភាពក្នុងការចិញ្ចឹមសត្វនៅតាមផ្ទះ ក៏ដូចជានៅតាមកសិដ្ឋាន ចុះស្រាវជ្រាវ និងទប់ស្កាត់តាមគ្រប់ច្រកនាំចូល ពិសេសបណ្តាខេត្តតាមព្រំដែនរាយការណ៍ជាប្រចាំពីស្ថានភាពវិវត្តន៍នៃជំងឺឆ្លង និងលទ្ធផលនៃការអនុវត្តវិធានការទាំងឡាយ

-ការទប់ស្កាត់បទល្មើសៈ ការឃាត់ចាប់ និងដុតកំទេចចោលតាមវិធានបសុពេទ្យផលិតផលសត្វខុសច្បាប់នាំមកពីប្រទេសជិតខាង មានចំនួន ៧០ ករណី

-ត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វៈ ការនាំចេញសត្វគោ ក្របីក្នុងស្រុក គោឆ្លងកាត់ ការនាំចូលជ្រូក ព្រមទាំងបាននាំចេញ-ចូលសត្វ និងផលិតផលមានដើមកំណើតសត្វប្រភេទផ្សេងទៀត

-ភ្នាក់ងារសុខភាពសត្វភូមិសរុបមានចំនួន១៣.៤៣៤នាក់ ក្នុងនោះមានប្រុសចំនួន**១២.១៧៩**នាក់ និងស្រីចំនួន**១.២៥៥**នាក់ និងបានជ្រើសរើសភ្នាក់ងារសុខភាពសត្វភូមិចំនួន១.៤៤២នាក់ ដើម្បីបំពាក់បំប៉នជំនាញបច្ចេកទេសបន្ថែម

-សត្តឃាតដ្ឋានទាំងប្រភេទ “ក ”និង “ខ ” ដែលមានគោលការណ៍អនុញ្ញាតដោយអនុលោមតាមអនុក្រឹត្យលេខ ១០៨ អនក្រ.បក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៧ ស្តីពីការគ្រប់គ្រង សត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតផលសត្វ មានចំនួនសរុប**១១៦** កន្លែង ក្នុងនោះរួមមាន÷ រាជធានីភ្នំពេញ ១១កន្លែង កណ្តាល ២០កន្លែង កំពង់ឆ្នាំង ១០កន្លែង បន្ទាយមានជ័យ ១១កន្លែង បាត់ដំបង ១៣កន្លែង សៀមរាប ០៦កន្លែង ព្រះសីហនុ ០២កន្លែង ព្រៃវែង ០៣កន្លែង កំពង់ស្ពឺ ១០កន្លែង មណ្ឌលគីរី០២កន្លែង រតនៈគីរី ០២កន្លែង ស្ទឹងត្រែង ០១កន្លែង កំពត ០៤កន្លែង ក្រចេះ ០៥កន្លែង កោះកុង ០១កន្លែង ស្វាយរៀង ០៣កន្លែង កំពង់ធំ ០៥កន្លែង ពោធិសាត់ ០៦កន្លែង និងកែប ០១កន្លែង។ នៅក្នុងឆ្នាំ២០១២ សត្តឃាតដ្ឋានប្រភេទ " ខ " បង្កើតថ្មីមានចំនួន ២១កន្លែង រួមមាន÷ ខេត្តស្វាយរៀង ០៣កន្លែង

ខេត្តកំពង់ធំ ០៥កន្លែង ខេត្តបន្ទាយមានជ័យ ០២កន្លែង ខេត្តក្រចេះ ០៣កន្លែង ខេត្តកណ្តាល ០២ កន្លែង និងខេត្តពោធិ៍សាត់ ០៦កន្លែង។

-វត្ថុវិភាគ ដែលបានធ្វើវិភាគរកវត្តមានមេរោគបង្កជំងឺ មានចំនួនសរុប **២០.៦៧០** វត្ថុវិភាគ ក្នុងនោះប៉ារ៉ាស៊ីតសាស្ត្រចំនួន **៣.៥៥៨**បាក់តេរីសាស្ត្រចំនួន**៣.៧២១**លោហិតសាស្ត្រចំនួន **៣.៥៥៨**ស៊េរ៉ូមសាស្ត្រចំនួន **៩.៧៧៤** និងសរីរៈរោគសាស្ត្រ**៥៩** វត្ថុវិភាគ។ តាមការវិភាគនេះ វិទ្យាស្ថានជាតិ បានរកឃើញពពួកប៉ារ៉ាស៊ីត វីរុស (ផ្តាសាយ បក្សី ញូកាស អុតក្តាម ប៉េស្តជ្រូក ត្រចៀកខៀវ) និងបាក់តេរី (សារទឹក និងអ៊ីកូលី)

-អង្កេតតាមដាន និងស្រាវជ្រាវជំងឺសត្វ រួមមានសិក្សាស្រាវជ្រាវកន្លែងផ្ទុះជំងឺសារទឹក ជំងឺអុតក្តាម និងជំងឺប៉េស្តជ្រូក នៅតាមបណ្តារាជធានី ខេត្ត និងតាមដានឃ្លាំមើលពីស្ថានភាពជំងឺផ្តាសាយបក្សី នៅតាមបណ្តាភូមិនៅទូទាំងប្រទេស ដោយប្រើប្រាស់ភ្នាក់ងារសុខភាពសត្វភូមិ ព្រមទាំងនៅតាមទីផ្សារលក់បក្សីរស់រាជធានី ខេត្តផងដែរ

-ព័ត៌មានស្តីពីស្ថានភាពជំងឺសត្វនៅក្នុងប្រទេសកម្ពុជា ត្រូវបានរាយការណ៍ជាប្រចាំទៅប្រទេសអាស៊ាន និងអង្គការសុខភាពសត្វពិភពលោកតាមរយៈប្រព័ន្ធព័ត៌មានពីរ÷ (១)ប្រពន្ធ័ពត៌មានសុខភាពសត្វនៅក្នុងតំបន់អាស៊ាន (ARAHIS) និង(២) ប្រពន្ធ័ពត៌មានសុខភាពសត្វពិភពលោក (WAHIS)។តាមរយៈប្រព័ន្ធព័ត៌មានសុខភាពសត្វទាំងពីរនេះ នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល អាចទទួលបានមកវិញនូវព័ត៌មានស្តីពីស្ថានភាពជំងឺសត្វរបស់ប្រទេសក្នុងតំបន់ និងពីបណ្តាប្រទេសជាសមាជិកអង្គការសុខភាពសត្វពិភពលោក។ វិស័យផលិតកម្មនិងបសុព្យាបាល មានបណ្តាញទំនាក់ទំនងការងារនៅតាមបណ្តាភូមិ ស្រុក និងរាជធានី ខេត្ត ដែលរួមមានភ្នាក់ងារសុខភាពសត្វភូមិ មន្ត្រីការិយាល័យផលិតកម្មនិងបសុព្យាបាលស្រុក និងរាជធានី ខេត្ត ដើរតួនាទីសំខាន់ក្នុងការរាយការណ៍ពីស្ថានភាពជំងឺសត្វ និងមានអង្គការ និងក្រុមហ៊ុនឯកជនមួយចំនួនក៏បានចូលរួមក្នុងការរាយការណ៍ពីជំងឺសត្វផងដែរ មានបណ្តាញពត៌មានទាន់ហេតុការណ៍ចំនួនពីរខ្សែដែលមានលេខ ០១២ ២១៤ ៩៧០ និង ០១២ ៨៣៣ ៧៩៥ ឬ ១២៨៧ និង១២៨៩។

-កសាងច្បាប់ ប្រកាស និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗនៃផ្នែកផលិតកម្ម និងបសុព្យាបាល បានទទួលលទ្ធផលល្អគួរឱ្យកត់សំគាល់ ដូចជា ការកសាងលិខិតបទដ្ឋានគតិយុត្តនៃអនុក្រឹត្យលេខ១៦ និង១០៨ អនក្រ.បក បានបញ្ចប់សព្វគ្រប់ទាំងស្រុង។ ទន្ទឹមនឹងនោះ បានបញ្ចប់ប្រកាសលេខ ៣៦០ប្រក.កសកស្តីពីការគ្រប់គ្រងនិងការដាក់ឲ្យប្រើប្រើប្រាស់ស្លាកលេខសម្គាល់សត្វចតុប្បាទ ប្រកាសរួមលេខ ១០១៣សហវ.ប្រកស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងប្រកាសរួមលេខ ១០១៤សហវ.ប្រកស្តីពីការផ្តល់រង្វាន់លើកទឹកចិត្តជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ សេចក្តីព្រាងច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វបានប្រជុំពិភាក្សាចប់ជំនាញបច្ចេកទេសនៅទីស្តីការគណៈរដ្ឋមន្ត្រីដែលមានការចូលរួមពីក្រុមប្រឹក្សាអ្នកច្បាប់និងក្រុមប្រឹក្សាសេដ្ឋកិច្ចសង្គមកិច្ចនិងវប្បធម៌។ សេចក្តីព្រាងច្បាប់នេះមានចំនួន ២២ជំពូក ១២២មាត្រា ដោយមានសទ្ទានុក្រមដែលជាឧបសម្ព័ន្ធវាក្យស័ព្ទចំនួន ៣៦ ត្រូវបានប្រើក្នុងច្បាប់នេះ។សេចក្តីព្រាងច្បាប់ នេះនឹងត្រូវដាក់ប្រជុំពិភាក្សាអន្តរក្រសួងនៅទីស្តីការគណៈរដ្ឋមន្ត្រីនាពេលដ៏ខ្លីខាងមុខនេះ។

-ការផ្សព្វផ្សាយបច្ចេកទេស គឺកំពុងតែមានការចាប់អារម្មណ៍ និងមានការគាំទ្រពីគ្រប់ជំនាញ អង្គការជាតិ និងអន្តរជាតិ និងម្ចាស់ជំនួយជាច្រើន ហើយបាននឹងកំពុងតែអនុវត្តយ៉ាងសកម្ម នៅតាមមូលដ្ឋានរាជធានី ខេត្តទូទាំងប្រទេស។ ផ្នែកផលិតកម្មនិងបសុព្យាបាលបានយកចិត្តទុកដាក់ប្រើប្រាស់គ្រប់មធ្យោបាយទាំងអស់ តាមវិទ្យុ ទូរទស្ស ទស្សនាវដ្តីបទសម្ភាសន៍ ឯកសារបច្ចេកទេស ការតាំងពិព័ណ៌ ការផ្សព្វផ្សាយតាមប្រព័ន្ធអេឡិចត្រូនិក ការឃោសនាផ្សព្វផ្សាយនៅតាមមូលដ្ឋាន និងទស្សនកិច្ចសិក្សា។ល។ ដោយផ្តោតការយកចិត្តទុកដាក់ទៅលើបញ្ហាជាអទិភាពដូចជាបញ្ហាជំងឺឆ្លង អត្ថប្រយោជន៍នៃការចាក់ថ្នាំការពារជំងឺឆ្លងសត្វ បច្ចេកទេសចិញ្ចឹម ពូជនិងបច្ចេកទេសជ្រើសរើសពូជ បច្ចេកទេសបង្កាត់ពូជតាមបែបសិប្បនិមិត្ត បច្ចេកទេសដាំដំណាំចំណីសត្វ បច្ចេកទេសកែច្នៃចំណីសត្វ និងលិខិតបទដ្ឋានគតិយុតពាក់ព័ន្ធនឹងវិស័យផលិតកម្ម និងបសុព្យាបាល ។ល។

-សហការជាមួយដៃគូរអភិវឌ្ឍន៍មួយចំនួនដូចជាៈ OIE, SEAFMD, FAO, WHO, SLPP, WB, USDA, USAID, JICA, ACIAR, IPC និង SNV ។ល។

## ១.២. ការងារផលិតកម្មសត្វ

សមិទ្ធផលផ្នែកផលិតកម្មសត្វឆ្នាំ២០១២ មានការវិវត្តន៍ជាបន្តបន្ទាប់និងគួរឱ្យកត់សម្គាល់ដែលក្នុងនោះ÷

### *១.២.១. ស្ថានភាពរួមនៃការចិញ្ចឹមសត្វ*

**តារាងប្រៀបធៀបស្ថិតិសត្វ**

| ប្រភេទសត្វ | | ឆ្នាំ២០១១ (ក្បាល) | ឆ្នាំ២០១២(ក្បាល) | ការប្រៀបធៀប ២០១១- ២០១២ | |
|---|---|---|---|---|---|
| | | | | កើន/ថយ (ក្បាល) | %(%) |
| គោ | គ្រួសារ | 3,406,972 | 3,376,805 | -30,167 | 0.89 |
| | កសិដ្ឋាន | 4,770 | 4,593 | -177 | 3.71 |
| | សរុប | **3,411,742** | **3,381,398** | -30,344 | 0.89 |
| ក្របី | គ្រួសារ | 692,611 | 656,975 | -35,636 | 5.15 |
| | កសិដ្ឋាន | 84 | 37 | -47 | 55.95 |
| | សរុប | **692,695** | **657,012** | -35,683 | 5.15 |
| គោ+ ក្របី | គ្រួសារ | 4,096,801 | 4,033,780 | -63,021 | 1.54 |
| | កសិដ្ឋាន | 4,854 | 4,593 | -261 | 5.38 |
| | សរុប | **4,101,655** | **4,038,373** | -63,282 | 1.54 |
| កម្លាំងអូសទាញ | | **1,574,296** | **1,516,110** | -58,186 | 3.70 |
| ជ្រូក | គ្រួសារ | 2,099,332 | 2,208,611 | 109,279 | 5.21 |
| | កសិដ្ឋាន | 164,448 | 256,290 | 91,842 | 55.85 |
| | សរុប | **2,263,780** | **2,464,901** | 201,121 | 8.88 |
| បក្សី | គ្រួសារ | 22,036,755 | 23,348,430 | 1,311,675 | 5.95 |
| | កសិដ្ឋាន | 3,757,611 | 3,974,291 | 216,680 | 5.77 |
| | សរុប | **25,794,366** | **27,322,721** | 1,528,355 | 5.93 |
| សេះ | គ្រួសារ | 12,789 | 12,531 | -258 | 2.02 |
| | កសិដ្ឋាន | 43 | 137 | 94 | 218.60 |
| | សរុប | **12,832** | **12,668** | -164 | 1.28 |
| ចៀម | គ្រួសារ | 571 | 215 | -356 | 62.35 |
| | កសិដ្ឋាន | 403 | 41 | -362 | 89.83 |
| | សរុប | **974** | **256** | -718 | 73.72 |
| ពពែ | គ្រួសារ | 13,573 | 13,723 | 150 | 1.11 |
| | កសិដ្ឋាន | 2,525 | 1,728 | -797 | 31.56 |
| | សរុប | **16,098** | **15,451** | -647 | 4.02 |
| សរុបរួម | | **29,928,707** | **31,389,506** | **1,460,799** | **4.88** |

ឆ្នាំ២០១២ចំនួនគោក្របី មានការថយចុះប្រមាណ១,៥៤% ដោយឡែកជ្រូក និងបក្សីមានការកើនឡើង ៨,៨៨% និង ៥,៩៣% (ធៀបនឹងឆ្នាំ២០១១)។ តាមការវិភាគពីសូចនាករនៃសត្វគ្រប់ប្រភេទសរុបមានការកើនឡើងដល់៣១.៣៨៩.៥០៦ ក្បាល ដែលស្មើនឹង៤.៨៨% ធៀបនឹងចំណុចដៅ ២៨,៥លានក្បាល។

-ការថយចុះគោ ក្របី គឺបណ្ដាលមកពីកត្តាសំខាន់ៗមួយចំនួន រួមមានកំណើននៃការ ប្រើប្រាស់គ្រឿងយន្ត កសិកម្ម ការបម្រែបម្រួលអាកាសធាតុ ការកើនឡើងនៃផ្ទៃដីកសិកម្ម និងកំណើននៃតម្រូវការសាច់ជាម្ហូបអាហារក្នុងស្រុក និងទីផ្សារនាំចេញគោរស់ទៅប្រទេសជិតខាង

-ការចិញ្ចឹមជ្រូក មានការកើនឡើង ដោយសារមានតម្រូវការទីផ្សារខ្ពស់ ផ្ដល់នូវប្រាក់ចំណូល មានវដ្ដផលិតកម្មខ្លី និងការរីកចម្រើននៃបច្ចេកវិជ្ជាថ្មីៗ និងមានការចូលរួមពីផ្នែកឯកជន

-ការចិញ្ចឹមបក្សី ក៏នៅតែមានសន្ទុះកើនឡើងគួរឱ្យកត់សម្គាល់ ដោយសារការចិញ្ចឹមជាលក្ខណៈគ្រួសារមានការរីកចម្រើន ជាពិសេសសន្ទុះកើនឡើងនៃការវិនិយោគផ្នែកឯកជន និងមានកំណើនតម្រូវការទីផ្សារខ្ពស់។

### *៦.២.២ ស្ថានីយចិញ្ចឹមសត្វរដ្ឋ*

**<u>ស្ថានីយចិញ្ចឹមជ្រូកពូជបង្ហាញកម្ពុជា-ចិន</u>**

ស្ថានីយចិញ្ចឹមជ្រូកពូជបង្ហាញកម្ពុជា-ចិនផលិតកម្មនិងបសុព្យាបាល បានបង្កើតឡើងក្រោមកិច្ចសហប្រតិបត្តិការឧបត្ថម្ភគាំទ្ររបស់សាធារណៈរដ្ឋប្រជាមានិតចិននិងរាជរដ្ឋាភិបាលកម្ពុជា។ ចុងឆ្នាំ២០១២ ស្ថានីយ៍មានជ្រូកពូជសរុបចំនួន **១៧៩**ក្បាល ក្នុងនោះមេពូជមានចំនួន **១៦១**ក្បាល និងបាពូជមានចំនួន**១៨**ក្បាល។ ឆ្នាំ២០១២ ស្ថានីយផលិតបានកូនជ្រូកពូជចំនួន **៨៥១**ក្បាល ដែលបានលក់ចែកចាយជូនកសិករសម្រាប់ធ្វើពូជក្នុងតម្លៃគោលនយោបាយរដ្ឋ។ កសិករពីខេត្តចំនួន **១២** រួមមាន ខេត្តកណ្ដាល ព្រះវិហារ តាកែវ ព្រះសីហនុ សៀមរាប ព្រៃវែង តាកែវ កំពង់ចាម រាជធានីភ្នំពេញ ពោធិសាត់ កំពត និងរតនៈគីរី បានទទួលទិញជ្រូកពូជពីស្ថានីយ ដើម្បីចិញ្ចឹមផ្សព្វផ្សាយពូជបន្ត។

**<u>ស្ថានីយ៍ចិញ្ចឹមគោពូជភ្នំតាម៉ៅ</u>**

នាឆ្នាំ២០១២ ស្ថានីយមានចំនួនគោសរុប **២២៦** ក្បាល ក្នុងនោះមានគោពូជកំផែងសែន ចំនួន **៣៦** ក្បាល ជាអំណោយដ៏ថ្លៃថ្លារបស់**ឯកឧត្តម បណ្ឌិត ច័ន្ទ សារុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ស្ថានីយមិនគ្រាន់តែជាកន្លែងចិញ្ចឹមគោពូជប៉ុណ្ណោះទេ ប៉ុន្ដែក៏ជាកន្លែងដាំនិងផ្សព្វផ្សាយដំណាំចំណីសត្វផងដែរ។ ឆ្នាំ២០១២ ស្ថានីយ បានចែកពូជស្មៅឃីងក្រាស ហ្គីណេ ម៉ារ៉ាន់ឌូ មុលឡាតូ ប៉ាស្ពាឡូម និងស៊ីម្ពូងដល់បណ្ដាខេត្តមួយចំនួន ហើយស្ថានីយបានផ្សព្វផ្សាយពូជគោទៅតាមបណ្ដាខេត្តដូចជា ខេត្តសៀមរាប ខេត្តកំពត និងខេត្តបាត់ដំបង។

### *៦.២.៣ ការកែលម្អពូជសត្វ*

ការកែលំអពូជសត្វ បានអភិវឌ្ឍន៍ជាជំហានៗតាមគោលនយោបាយ និងយុទ្ធសាស្ត្រវិស័យផលិតកម្មនិងបសុព្យាបាល ដូចជា ការនាំចូលរូបធាតុសេនេទិកសត្វពូជសត្វ ការជ្រើសរើសពូជសត្វ ក្នុងស្រុក ដែលមានផលិតភាពខ្ពស់ ដើម្បីយកមកបង្កាត់និងផ្សព្វផ្សាយពូជទាំងក្នុងជួរកសិករ ក៏ដូចជាតាមបណ្ដាកសិដ្ឋានចិញ្ចឹមសត្វឯកជននៅក្នុងប្រទេសកម្ពុជា។ ពូជសត្វសំខាន់ៗ ដែលត្រូវបានយកមកបង្កាត់ និងផ្សព្វផ្សាយពូជ មានដូចជា÷

-ពូជកំផែងសែន និងពូជប្រាមាន់ នៅស្ថានីយចិញ្ចឹមគោពូជភ្នំតាម៉ៅ

-ការនាំចូលស្ពែមពូជគោស៊ីមប្រា និងសាន់តា ដែលត្រូវបានធ្វើការបង្កាត់សិប្បនិម្មិតជាមួយគោក្នុងស្រុកតាមបណ្ដាខេត្តមួយចំនួនដូចជា ខេត្តពោធិសាត់ បន្ទាយមានជ័យ បាត់ដំបង កំពង់ស្ពឺ កំពង់ឆ្នាំង សៀមរាប កណ្ដាល និងខេត្តតាកែវ ដែលបង្កាត់មេបានចំនួន ៥៩៦ ក្បាល និងផលិតកូនបានចំនួន ៤២៥ ក្បាល

-ស្ថានីយចិញ្ចឹមជ្រូកពូជបង្ហាញកម្ពុជា-ចិន ធ្វើការបង្កាត់ និងផ្សព្វផ្សាយពូជជ្រូក ឡែនដ្រេស យ៉កសៀ និងឌុយរ៉ុក និងខេត្តមួយចំនួន(ខេត្តតាកែវ កំពង់ស្ពឺ កំពង់ឆ្នាំង ពោធិ៍សាត់ កំពត បន្ទាយមានជ័យ ឧត្ដរមានជ័យ ព្រៃវែង កំពង់ចាម និងស្វាយរៀង) បានផ្សព្វផ្សាយពូជជ្រូក ដោយបង្កាត់តាមបែបសប្បនិមិត្ត បានចំនួនមេជ្រូក ៧.៩៨៨ ក្បាល និងកូនចំនួន ៣៣.១៧២ ក្បាល។

-ការបង្កាត់មាន់យកសាច់ ស៊ុត ពូជKI (ពូជមាន់ខ្មែរបង្កាត់ជាមួយអ៊ីសាប្រោន)នៅខេត្តសៀមរាប

-ការចិញ្ចឹមគោយកទឹកដោះ ក្រោមគម្រោងកិច្ចសហប្រតិបត្តិជប៉ុន(JLTA) អនុវត្តនៅរាជធានីភ្នំពេញនិងខេត្តកណ្ដាល

-ការផ្សព្វផ្សាយពូជតាមរយៈអង្គការ សម្បុរសជន ដូចជាការផ្ដល់ជ្រូក មេគោ មេក្របី មានទា ដល់កសិករតាមបណ្ដាខេត្តមួយចំនួន

-វិស័យឯកជនបាននឹងកំពុងបង្កាត់និងផ្សព្វផ្សាយលក់ពូជសត្វគ្រប់ប្រភេទ ដែលធ្វើឲ្យមានការផ្លាស់ប្តូរពូជសត្វគួរឲ្យកត់សម្គាល់។

**ក្រាហ្វិកបង្ហាញពីពីការបង្កាត់សប្បនិម្មិតគោនៅតាមបណ្តាខេត្តឆ្នាំ២០០៨-២០១២**




**ក្រាហ្វិកចំនួនកូនគោតាមរយៈការបង្កាត់សប្បនិម្មិតគោនៅតាមបណ្តាខេត្ត**




### ១.២.៤ការកែលំអចំណីសត្វ

អនុវិស័យផលិតកម្មនិងបសុព្យាបាល បាននឹងកំពុងជំរុញការដាំដំណាំចំណីសត្វ ផ្តល់ពូជ និងផ្សព្វផ្សាយពូជស្មៅ បច្ចេកទេសដាំដំណាំចំណីសត្វ ព្រមទាំងជំរុញការអនុវត្ត សាកល្បងពិសោធន៍ ផ្សព្វផ្សាយពីវិធីសាស្ត្រ និងបច្ចេកទេសកែច្នៃ និងផ្ទុំចំណីសត្វដល់ការិយាល័យផលិតកម្ម និងបសុព្យាបាលរាជធានី ខេត្ត និងកសិករតាមបណ្តាខេត្តនានានៅទូទាំងប្រទេស។

ពូជដំណាំចំណីសត្វ ដែលបានផ្សព្វផ្សាយដល់កសិករនាពេលបច្ចុប្បន្ន រួមមាន៖ Simung, Mulato, Paspalum, Stylo184, Marandu, Ruzi, Elephant grass, King grass កន្ទុំថេត ទ្រីចាន់ធារ៉ា ។ល។ បច្ចេកទេសកែច្នៃ និងផ្ទុំចំណីសត្វរួមមាន៖ ការធ្វើចំបើងផ្អាប់ជាមួយជីអ៊ុយរេ ផ្ទុកស្មៅ ស្ងួត ដំឡូងមីផ្អាប់។ល។

ខេត្តព្រៃវែងស្វាយរៀង សៀមរាប រតនៈគិរី ពោធិសាត់ តាកែវ មណ្ឌលគិរី កណ្តាល កំពត កំពង់ឆ្នាំង កំពង់ចាម បាត់ដំបង បន្ទាយមានជ័យ បាននឹងកំពុងដំណើរការដាំដំណាំចំណីសត្វទទួលបានជោគជ័យ និងបានអនុវត្តការកែច្នៃផ្ទុំចំណីសត្វ ព្រមទាំងផ្សព្វផ្សាយពូជ បច្ចេកទេសដាំដុះ បច្ចេកទេសកែច្នៃផ្ទុំ ដល់កសិករក្នុងខេត្តរបស់ខ្លួន និងខេត្តដទៃផ្សេងទៀត។

### ១.២.៥ ការអភិវឌ្ឍនកម្មវិធីឡជីវឧស្ម័ន

ចាប់ពីឆ្នាំ២០០៦ ដល់ឆ្នាំ២០១២ ការកសាងឡជីវឧស្ម័នបានអនុវត្តក្នុងខេត្តចំនួន ១៤ សរុបមានចំនួន១៩.១៧៣ឡ ដែលក្នុងនោះ នៅឆ្នាំ ២០១២ ឡជីឧស្ម័ន បានសាងសង់ចំនួ៤.២០១ ឡ ។

## តារាងចំនួនឡជីវឧស្ម័ននៅកម្ពុជាចាប់ពីឆ្នាំ២០០៦-២០១២

| ខេត្ត | ឡជីវឧស្ម័នដែលបានសាងសង់ | | | | | | | |
|---|---|---|---|---|---|---|---|---|
| | ២០០៦ | ២០០៧ | ២០០៨ | ២០០៩ | ២០១០ | ២០១១ | ២០១២ | សរុបរួម |
| កំពង់ចាម | ១១៣ | ២៥០ | ៤០០ | ៤៩៧ | ៤៨៤ | ៤៥០ | ៣៩៥ | **២.៥៨៩** |
| កណ្ដាល | ៨៧ | ៨១ | ១០០ | ១៣៣ | ២៨១ | ២២២ | ១៥២ | **១.០៥៦** |
| ស្វាយរៀង | ៦១ | ១៣៦ | ៣៣២ | ៥២៥ | ៥២២ | ៥៥២ | ៦៨៤ | **២.៨១២** |
| តាកែវ | ៣១ | ៤៥០ | ៦៨៦ | ៤០៥ | ៦១៩ | ៦៤០ | ៦៨៦ | **៣.៥១៧** |
| កំពង់ស្ពឺ | ៤ | ២៣២ | ២៨៩ | ២៣៥ | ៣៦២ | ៤៣៤ | ៤២០ | **១.៩៧៦** |
| កំពង់ឆ្នាំង | ០ | ០ | ១៥៥ | ១៩៨ | ១៦៨ | ២៣៨ | ១៨៧ | **៩៤៦** |
| កំពត | ០ | ១ | ៣៥៧ | ៣៧៧ | ៦៩៦ | ១.០៣៤ | ៧៩៤ | **៣.២៥៩** |
| ព្រៃវែង | ០ | ០ | ២១ | ២៤៦ | ៤៣៨ | ៦៥៣ | ៤២១ | **១.៧៧៩** |
| សៀមរាប | ០ | ០ | ០ | ០ | ៦៧ | ១០៧ | ១១២ | **២៨៦** |
| ពោធិ៍សាត់ | ០ | ០ | ០ | ០ | ៧៤ | ១១៦ | ១០៧ | **២៩៧** |
| បាត់ដំបង | ០ | ០ | ០ | ០ | ២២ | ៥៦ | ៣៦ | **១១៤** |
| កំពង់ធំ | ០ | ០ | ០ | ០ | ១១ | ២៦១ | ២០៧ | **៤៧៩** |
| កែប | ០ | ០ | ០ | ០ | ០ | ៦២ | ០ | **៦២** |
| ព្រះសីហនុ | ០ | ០ | ០ | ០ | ០ | ១ | ០ | **១** |
| **សរុប** | **២៩៦** | **១.១៥០** | **២.៣៤០** | **២.៦១៦** | **៣.៧៤៤** | **៤.៨២៦** | **៤.២០១** | **១៩.១៧៣** |

## ក្រាហ្វិកបង្ហាញចំនួនឡជីវឧស្ម័នដែលបានសាងសង់ចាប់ពីឆ្នាំ២០០៦ដល់២០១២




## តារាងបង្ហាញចំនួនឡជីវឧស្ម័នដែលបានសាងសង់ពីឆ្នាំ២០១២

| ល.រ | ខេត្ត | ឡដែលបាន សាងសង់ | ផែនការឆ្នាំ | %ឆ្នាំ |
|---|---|---|---|---|
| 1 | កំពង់ចាម | **395** | **426** | **93%** |
| 2 | កណ្ដាល | **152** | **251** | **61%** |
| 3 | ស្វាយរៀង | **684** | **715** | **96%** |
| 4 | តាកែវ | **686** | **603** | **114%** |
| 5 | កំពង់ស្ពឺ | **420** | **450** | **93%** |
| 6 | កំពង់ឆ្នាំង | **187** | **181** | **103%** |
| 7 | កំពត | **794** | **1078** | **74%** |
| 8 | ព្រៃវែង | **421** | **602** | **70%** |
| 9 | សៀមរាប | **112** | **179** | **63%** |
| 10 | ពោធិ៍សាត់ | **107** | **143** | **75%** |
| 11 | បាត់ដំបង | **36** | **107** | **34%** |
| 12 | កំពង់ធំ | **207** | **265** | **78%** |
| **សរុប** | | **4201** | **5000** | **84%** |

### ១.២.៦ ព័ត៌មានទីផ្សារសត្វនិងផលិតផលសត្វ

ព័ត៌មានទីផ្សារសត្វនិងផលិតផលសត្វ មានតួនាទីយ៉ាងសំខាន់ ដើម្បីផ្សព្វផ្សាយពីតម្លៃសត្វនិងផលិតផលសត្វ ដល់ប្រជាកសិករនៅតាមមូលដ្ឋាន សម្រាប់ជាមូលដ្ឋានក្នុងការលក់ដូរសត្វរបស់កសិករ។ នៅឆ្នាំ២០១២ អនុវិស័យនេះ បានបន្តការងារប្រមូលទិន្នន័យទីផ្សារសត្វ និងផលិតផលសត្វនៅតាមទីផ្សារមួយចំនួនក្នុងរាជធានី ខេត្ត។

**ក្រាហ្វិកបង្ហាញ** ទិន្នន័យតម្លៃសត្វនិងផលិតផលសត្វនៅឆ្នាំ ២០១២




### ១.២.៧ ការអភិវឌ្ឍន៍ការចិញ្ចឹមសត្វនៅតាមមូលដ្ឋានរបស់រាជធានី ខេត្ត

នៅឆ្នាំ២០១២នេះ ការអភិវឌ្ឍការចិញ្ចឹមសត្វនៅតាមមូលដ្ឋាននៃរាជធានី ខេត្តនៅទូទាំងប្រទេស ដោយមានការសហការជាមួយអង្គការជាដៃគូ និងផ្នែកឯកជន គឺមានការធ្លាក់ចុះបន្តិចដោយសារមានកត្តាជាច្រើន ដែលបង្កឱ្យមានបញ្ហាប្រឈមក្នុងកិច្ចដំណើរការការងារចិញ្ចឹមសត្វនេះ។ ប៉ុន្តែទោះជាយ៉ាងណាក្តី ក្រសួងបាននឹងកំពុងខិតខំប្រឹងប្រែងស្វែងរកគ្រប់មធ្យោបាយនិងវិធីសាស្ត្រសំខាន់ៗគ្រប់បែបយ៉ាង ដើម្បីដោះស្រាយរាល់បញ្ហាទាំងអស់នេះ ដោយមានការចុះណែនាំដល់អ្នកចិញ្ចឹមសត្វពីរបៀបចិញ្ចឹមសត្វ ការបង្កើតសហគមន៍ចិញ្ចឹមសត្វ ការផ្តល់ឥណទានសម្រាប់ចិញ្ចឹមសត្វនិងកម្មវិធីដទៃផ្សេងៗទៀត។

## គ. **ការងារសុខភាពសត្វ**

### គ.១ ស្ថានភាពជំងឺឆ្លងសត្វ

ជារៀងរាល់ឆ្នាំ ជំងឺឆ្លងសត្វច្រើនប្រភេទ បានបង្កឱ្យសត្វឈឺ និងងាប់ នឹងបណ្តាលឱ្យមានការខាតបង់សេដ្ឋកិច្ចគ្រួសារ និងសេដ្ឋកិច្ចជាតិផងដែរ។ មិនតែប៉ុណ្ណោះ ជួនពេលខ្លះ ជំងឺទាំងនេះក៏អាចឆ្លងរាលដាលដល់មនុស្សនិងបង្កឱ្យមានគ្រោះថ្នាក់ ដល់ជីវិតមនុស្សស្លាប់ថែមទៀតផង។ នៅឆ្នាំ២០១២ កន្លងទៅនេះ សភាពការណ៍នៃជំងឺឆ្លងសត្វ មានសភាពរាលដាលមិនសូវខ្លាំងក្លាគួរឱ្យកត់សម្គាល់ទេ ប៉ុន្តែតាមការសង្កេតជារួម ទិន្នន័យនៃស្ថានភាពជំងឺឆ្លងសំខាន់ៗ ដែលបង្កឱ្យមានមហន្តរាយដល់ជីវិតមនុស្សសត្វ និងសេដ្ឋកិច្ចគ្រួសារ ក៏ដូចជាសេដ្ឋកិច្ចជាតិរួមមាន ÷

**ជំងឺអុតក្តាម÷** មានការផ្ទុះឡើងចំនួន២៣កន្លែង ក្នុងនោះមាន០២កន្លែងនៅខេត្តកំពង់ចាម ខេត្តកណ្តាល០២កន្លែង បន្ទាយមានជ័យ០៣កន្លែង កំពង់ស្ពឺ០២កន្លែង កំពង់ឆ្នាំង០២កន្លែង តាកែវ១កន្លែង ស្វាយរៀង០៣កន្លែង ក្រចេះ០១កន្លែង រតនគីរី០១កន្លែង បាត់ដំបង០១កន្លែង សៀមរាប០២កន្លែង កែប០១កន្លែង មណ្ឌលគីរី០១កន្លែង និង០១កន្លែងនៅខេត្តកំពត។

**ជំងឺសារទឹក÷** មានការផ្ទុះឡើងចំនួនចំនួន៣៣កន្លែងគឺ÷ ដូចជាខេត្តកំពង់ស្ពឺ០១កន្លែង កណ្តាល០៦កន្លែង ព្រះវិហារ០១កន្លែង កោះកុង០១កន្លែង ពោធិ៍សាត់០១កន្លែង ក្រចេះ០៤កន្លែង បាត់ដំបង០២កន្លែង ស្ទឹងត្រែង០១កន្លែង កំពង់ចាម០២កន្លែង កំពង់ឆ្នាំង០២កន្លែង កំពង់ធំ០១កន្លែង រតនៈគីរី០១កន្លែង ឧត្តរមានជ័យ២កន្លែង ស្វាយរៀង០៨កន្លែង ។

**ជំងឺបូសខ្យល់÷** បានផ្ទុះឡើងចំនួន១១កន្លែង គឺនៅក្នុងខេត្តកំពង់ស្ពឺ០៣កន្លែង ក្រចេះ០២កន្លែង កំពង់ធំ០១កន្លែង មណ្ឌលគីរី០២កន្លែង កំពង់ឆ្នាំង០១កន្លែង រតនៈគីរី០១កន្លែង និងឧត្តរមានជ័យ២កន្លែង ។

**ជំងឺផ្តាសាយបក្សី÷** ក្នុងឆ្នាំ២០១២នេះ មានផ្ទុះជំងឺផ្តាសាយបក្សីលើបក្សីចំនួន០១កន្លែង (នៅភូមិព្រីង ឃុំទួលសាលា ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ) និងករណីជំងឺផ្តាសាយបក្សីលើមនុស្សចំនួន០៣នាក់(នៅភូមិរណាក់ ឃុំឈ្នួរមានជ័យ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យភូមិក្បាលកោះ ឃុំអំពិលទឹក ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង និងភូមិព្រីង ឃុំទួលសាលា ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ)។

## *គ.២ ការបង្ក្រាបបទល្មើស និងការទប់ស្កាត់ជំងឺឆ្លងសត្វ*

ផ្អែកលើវិធានបច្ចេកទេសនិងវិធានច្បាប់ បានទប់ស្កាត់និងបង្ក្រាបបទល្មើស ដែលទទួលបានលទ្ធផលដូចខាងក្រោម÷

**<u>នាយកដ្ឋានផលិតកម្មនិងបសុព្យាបាល÷</u>** បានត្រួតពិនិត្យចលនាសត្វ និងផលិតផលមានដើមកំណើតពីសត្វ ជាលទ្ធផលបានទទួលបានៈ ការត្រួតពិនិត្យចលនាសត្វនិងផលិតផលមានដើមកំណើតពីសត្វចំនួន ៣៤០ករណី ក្នុងនោះមានគោក្របី ១៦៦ករណី ជ្រូក ៨១ករណី មាន់ ១៦ករណី ស៊ុត៦១ករណីនិងបានបង្ក្រាបបទល្មើសដឹកជញ្ជូនសត្វនិងផលិតផលមានដើមកំណើតពីសត្វសរុបចំនួន១៦ករណី ក្នុងនោះមានគោក្របី ២២៥ក្បាលបក្សី២.៤៣៣ក្បាលស៊ុត ១២៣.៩៣០ គ្រាប់ និងបានដុតបំផ្លាញចោលនូវស៊ុតមាន់ចំនួន១.៩២០គ្រាប់ ហើយបានធ្វើការផាកពិន័យជា ទឹកប្រាក់ចំនួន ៤៤.៥០០.០០០៛០០។

**<u>ការិយាល័យផលិតកម្មនិងបសុព្យាបាលរាជធានី ខេត្ត</u>÷** បានត្រួតពិនិត្យចលនាសត្វ និងផលិតផលមានដើមកំណើតពីសត្វ ជាលទ្ធផលបានរកឃើញ និងបង្ក្រាបបទល្មើសដឹកជញ្ជូនសត្វ និងផលិតផលមានដើមកំណើតពីសត្វសរុបចំនួនករណី ក្នុងនោះមានគោក្របីចំនួន ៥៧ក្បាល បក្សីចំនួន ៤២.៦១២ក្បាល ស៊ុតមាន់ ទាចំនួន ៤៣.៦០០គ្រាប់ ផលិតផលខូចគុណភាពចំនួន ៦.៨៨៩គ.ក្រ បានដុតបំផ្លាញចំនួន០៩ករណី និងធ្វើការផកពិន័យជាទឹកប្រាក់ចំនួន២៤.៩៥០.០០០រៀល។

## *គ.៣ ការចាក់វ៉ាក់សាំងការពារជំងឺឆ្លងសត្វ*

ជាលទ្ធផល នៅទូទាំងប្រទេស សត្វបានទទួលការចាក់ថ្នាំការពារ រួមមាន÷ សារទឹកគោក្របីបានចំនួន ១.១៦០.៧៣២ ក្បាល អុតក្តាមគោក្របី បានចំនួន ៥៦.៨០៤ក្បាល បូសខ្យល់ ចំនួន ១២.៧៧១ក្បាល ចាក់វ៉ាកសាំងឆ្កែចំនួន ១.២៥៥ក្បាល សារទឹកជ្រូកចំនួន ១៥៧.៨៣១ក្បាល ប៉េស្តជ្រូកចំនួន ២១៦.៣៨៩ក្បាល សាល់ម៉ូជ្រូកចំនួន ១៤០.០៤០ក្បាល អុតក្តាមជ្រូកចំនួន ២៥.០៦០ក្បាល អូហ្យេស្គីជ្រូកចំនួន ២០.១៦១ក្បាល រាគកូនជ្រូកចំនួន ២៧.២៤៥ក្បាល កញ្រ្ជឹលជ្រូកចំនួន ១៤.៣២៩ក្បាល ជាតិដែកចំនួន ៧៨.៨០៩ ផ្លូវដង្ហើមចំនួន ៣.២៧៣ ញីវកាសបក្សីចំនួន ១.៥១០.៥៤៩ក្បាល អាសន្នរោគមាន់ចំនួន ១.៤០៨.៥៩៩ក្បាល អុតបក្សីចំនួន ១.១៣៤.៣២២ក្បាល អាសន្នរោគទាចំនួន ១២៣.១៦៣ក្បាល
ប៉េស្តទាចំនួន ១៨៨.៦១៧ក្បាល និងហ្គុមបូរូចំនួន ២២.១៤៩ក្បាល។

## *គ.៤ ការងារត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ*

នៅក្នុងឆ្នាំ២០១២ ការត្រួតពិនិត្យសត្វ និងផលិតមានដើមកំណើតពីសត្វ ដែលបាននាំចេញ នាំចូល និងនាំឆ្លងកាត់ព្រះរាជាណាចក្រកម្ពុជាមានដូចតទៅៈ **ការនាំចេញ÷** គោ-ក្របីក្នុងស្រុកចំនួន **៩.៣៨៤**ក្បាល កូនជ្រូកចំនួន ១៧.៩៧៥ ក្បាល ស្វាក្តាមចំនួន ៧.៧៥៦ក្បាល សាច់គោចំនួន ២៤.៣៣៣គ.ក្រ ចំណីឆ្កែចំនួន ៤១៣. ៨៧៦គ.ក្រ ស្បែកគោ ក្របីចំនួន ១.៦៦៧.០០០ គ.ក្រ និងរោមសត្វចំនួន ១.៧៨៥គ.ក្រ **ការនាំឆ្លងកាត់÷** សត្វគោពីប្រទេសថៃចំនួន ១០០.៣៥០ក្បាល និង **ការនាំចូល÷** ជ្រូកសរុបចំនួន**៣៧៤.៩៧៤**ក្បាល (ជ្រូកសាច់ចំនួន**៣៦២.៨២០**ក្បាល កូនជ្រូកពូជចំនួន៦.**០៩២**ក្បាល និងជ្រូកពូជមេបា ៥.៦៦២ក្បាល) កូនមាន់ពូជន **២៣២.៩០៧**ក្បាល **ស៊ុត**មាន់៣.៦៨១.០០គ្រាប់ សាច់គោ**១៥៥.៧២២**គ.ក្រ សាច់ចៀមចំនួន**២៥៧**គ.ក្រ សាច់ភ្លៅឆ្អិនចំនួន **១២០**គក្រ សាច់មាន់ទា**៧៦.៩៧៥**គ.ក្រ និងស្បែកគោផ្សំចំណីឆ្កែ**៥៧៧.៩៧០**គ.ក្រ សាច់មាន់/ទ្រូងមាន់ផ្សំចំណីឆ្កែ ២៤៧.៦៦៦គ.ក្រ។

## *គ.៥ ភ្នាក់ងារសុខភាពសត្វភូមិ*

ភ្នាក់ងារសុខភាពសត្វភូមិសរុបមានចំនួន **១៣.៤៣៤នាក់** ក្នុងនោះមានប្រុសចំនួន**១២.១៧៩**នាក់ និងស្រីចំនួន **១.២៥៥**នាក់ និងបានជ្រើរើសភ្នាក់ងារសុខភាពសត្វភូមិចំនួន១.៤៤២នាក់ ដើម្បីបំពាក់បំប៉នជំនាញបច្ចេកទេសបន្ថែម។

## ឃ. ការងារសុខភាពសាធារណៈ

ការងារសុខភាពសាធារណៈ ក៏ជាផ្នែកមួយដ៏សំខាន់នៃវិស័យផលិតកម្មនិងបសុពេទ្យបាល ដែលចូលរួមក្នុងការទប់ស្កាត់ជំងឺឆ្លងពីសត្វទៅសត្វ និងពីសត្វទៅមនុស្ស តាមរយៈការគ្រប់គ្រង និងការត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតសត្វនៅតាមសត្តឃាតដ្ឋាន និងកន្លែងតាំងលក់ ។

សត្តឃាតដ្ឋានទាំងប្រភេទ "ក" និង "ខ" ដែលមានគោលការណ៍អនុញ្ញាតដោយអនុលោមតាមអនុក្រឹត្យលេខ ១០៨អនក្រ.បក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៧ ស្តីពីការគ្រប់គ្រងសត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតផលសត្វមានចំនួនសរុប **១១៦ កន្លែង** ក្នុងនោះរួមមាន÷ រាជធានីភ្នំពេញ ១១កន្លែង កណ្តាល ២០កន្លែង កំពង់ឆ្នាំង ១០កន្លែង បន្ទាយមានជ័យ ១១កន្លែង បាត់ដំបង ១៣កន្លែង សៀមរាប ០៦កន្លែង ព្រះសីហនុ ០២កន្លែង ព្រៃវែង ០៣កន្លែង កំពង់ស្ពឺ ១០កន្លែង មណ្ឌលគីរី០២កន្លែង រតនៈគីរី ០២កន្លែង ស្ទឹងត្រែង ០១កន្លែង កំពត ០៤កន្លែង ក្រចេះ ០៥កន្លែង កោះកុង ០១កន្លែង ស្វាយរៀង ០៣កន្លែង កំពង់ធំ ០៥កន្លែង ពោធិសាត់ ០៦កន្លែង និងកែប ០១កន្លែង។ នៅក្នុងឆ្នាំ២០១២ សត្តឃាតដ្ឋានប្រភេទ" ខ" បង្កើតថ្មីមានចំនួន ២១កន្លែង រួមមាន÷ ខេត្តស្វាយរៀង ០៣កន្លែង ខេត្តកំពង់ធំ០៥កន្លែង ខេត្តបន្ទាយមានជ័យ ០២កន្លែង ខេត្តក្រចេះ ០៣កន្លែង ខេត្តកណ្តាល ០២ កន្លែង និងខេត្តពោធិ៍សាត់ ០៦កន្លែង។

ចំនួនសត្វពិឃាតនៅទទាំងប្រទេសឆ្នាំ២០១២ សរុបមាន÷ គោ ១១៣.៨៣១ក្បាល ក្របី២.៩៩៩ក្បាល និងជ្រូក ៧៥៣.២៩៦ក្បាល។

## ង. ការងារវិទ្យាស្ថានជាតិស្រាវស្រាវបសុពេទ្យបាល

វិទ្យាស្ថានជាតិស្រាវជ្រាវបសុពេទ្យបាល មានសមត្ថភាពគ្រប់គ្រាន់ក្នុងការធ្វើអង្កេតតាមដានឃ្លាំមើលសិក្សាស្រាវជ្រាវ វិភាគរកមេរោគ និងធ្វើរោគវិនិច្ឆ័យជំងឺសត្វ និងសម្រេចបាននូវលទ្ធផលប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលាក្នុងការឆ្លើយតបជាបន្ទាន់ នៅគ្រប់រូបភាពនិងស្ថានភាពទាន់ហេតុការណ៍នានានៃជំងឺសត្វ ដែលបង្កឡើងដោយមេរោគគ្រប់ប្រភេទ។ លទ្ធផលដែលទទួលបានមានដូចខាងក្រោម÷

-ផ្នែកសេរ៉ូមសាស្ត្រ/វីរុសសាស្ត្រ÷បានពិនិត្យ សិក្សាស្រាវជ្រាវ និងវិភាគរកមេរោគលើជំងឺសត្វមួយចំនួន រួមមានៈជំងឺផ្តាសាយបក្សី ញ៉ូវកាស មីកូប្លាស្មា ប៉េស្តជ្រូក ប្រ៊ុយសែលឡូស សាទឹក អុតក្តាម សាល់ម៉ូណែលឡូស ឆ្កែឆ្កួត ជ្រូកត្រចៀកខៀវ និងជំងឺស្វា (SRV STLV CHV)

-ផ្នែកបាក់តេរីសាស្ត្រ÷ បានពិនិត្យ សិក្សាស្រាវជ្រាវ និងវិភាគរកមេរោគលើជំងឺសត្វមួយចំនួនរួមមានៈ ជំងឺសាទឹក បូសខ្យល់ ឈាមខ្មៅ ស្តាហ្វីឡូកុកកូស ស្ត្រិបតូកុកកូស សាល់ម៉ូណែលឡូស អ៊ីកូលី ស៊ីយ៉ែលឡា និងវិភាគរកមេរោគក្នុងចំណីសត្វ ។ល។ និងជំងឺស្វា(Shigella Salmonella)

-ផ្នែកប៉ារ៉ាស៊ីត÷ បានពិនិត្យ សិក្សាស្រាវជ្រាវ និងវិភាគរកជំងឺបង្កដោយប៉ារ៉ាស៊ីតសត្វ

-ផ្នែកលោហិតសាស្ត្រ÷ បានពិនិត្យ សិក្សាស្រាវជ្រាវ និងវិភាគរកជំងឺលើសត្វជាច្រើនប្រភេទ

-ផ្នែកសរីរៈរោគសា÷ បានធ្វើការវះពិនិត្យប្រភេទសត្វតូច (ជ្រូក ចៀម ពពែ និងបក្សី) និងអ៊ីស្តូក្រាម (ការដាក់ពណ៌និងពិនិត្យនៅលើកញ្ចក់ឡាម) ដើម្បីសិក្សាស្រាវជ្រាវ និងវិភាគរកមេរោគលើជំងឺសត្វមួយចំនួន

-ផ្នែកអេពីដេមីសាស្ត្រ÷ តាមដានឃ្លាំមើលជំងឺសត្វ ស្រាវជ្រាវរកប្រភពជំងឺសត្វ អង្កេតស្រាវជ្រាវកន្លែងផ្ទុះជំងឺ គ្រប់គ្រងទិន្នន័យជំងឺសត្វ វិភាគទិន្នន័យនិងបកស្រាយលទ្ធផលនៃការអង្កេតស្រាវជ្រាវឬការសិក្សាជាដើម។

វិទ្យាស្ថានជាតិស្រាវជ្រាវបសុពេទ្យបាលដោយសហការជាមួយមន្ត្រីពាក់ព័ន្ធ បានចុះស្រាវជ្រាវអង្កេតតាមដានជំងឺសត្វសំខាន់ៗនៅទូទាំងប្រទេសរួមមាន ជំងឺសារទឹក អុតក្តាម បូសខ្យល់ ញូកាស បេស្តជ្រូក និងផ្តាសាយបក្សី។ល។ និងបានចុះយកវត្ថុវិភាគ ដើម្បីធ្វើរោគវិនិច្ឆ័យរកមេរោគបង្កជំងឺ។ ចំនួនវត្ថុវិភាគ ដែលបានធ្វើវិភាគរកវត្តមានមេរោគបង្កជំងឺ មានចំនួនសរុប

២០.៦៧០ វត្ថុវិភាគ ក្នុងនោះ ប៉ារ៉ាស៊ីតសាស្ត្រចំនួន ៣.៩៩៨ បាក់តេរីសាស្ត្រចំនួន៣.៧២១លោហិតសាស្ត្រចំនួន ៣.៩៩៨ សេរ៉ូមសាស្ត្រចំនួន ៩.៧៧៤ និងសរីរៈរោគសាស្ត្រ ៩៩វត្ថុវិភាគ។ តាមការវិភាគនេះ វិទ្យាស្ថានជាតិបានរកឃើញពពួកប៉ារ៉ាស៊ីត វីរុស (ផ្តាសាយបក្សី ញូកាស អុតក្តាម ប៉េស្តជ្រូក ត្រចៀកខៀវ) និងបាក់តេរី (សារទឹក និងអ៊ីកូលី)។

ព័ត៌មានស្តីពីស្ថានភាពជំងឺសត្វនៅក្នុប្រទេសកម្ពុជា ត្រូវបានរាយការណ៍ជាប្រចាំទៅប្រទេសអាស៊ាននិងអង្គការសុខភាពសត្វពិភពលោកតាមរយៈប្រព័ន្ធព័ត៌មានពីរ÷ (១) ប្រព័ន្ធពត៌មានសុខភាពសត្វ នៅក្នុងតំបន់អាស៊ាន (ARAHIS) និង(២) ប្រព័ន្ធព័ត៌មានសុខភាពសត្វពិភពលោក (WAHIS)។ តាមរយៈប្រព័ន្ធព័ត៌មានសុខភាពសត្វទាំងពីរនេះ អនុវិស័យទទួលបានមកវិញនូវព័ត៌មានស្តីពីស្ថានភាពជំងឺសត្វរបស់ប្រទេសក្នុងតំបន់ និងពីបណ្តាប្រទេសជាសមាជិកអង្គការសុខភាពសត្វពិភពលោក។ ចំពោះ ផលិតកម្មនិងបសុព្យាបាល មានបណ្តាញទំនាក់ទំនងការងារនៅតាមបណ្តាភូមិ ស្រុក និងរាជធានី ខេត្ត ដែលរួមមានភ្នាក់ងារសុខភាពសត្វភូមិ មន្ត្រីការិយាល័យផលិតកម្មនិងបសុព្យាបាលស្រុក និងរាជធានី ខេត្ត ដើរតួនាទីសំខាន់ក្នុងការរាយការណ៍ ពីស្ថានភាពជំងឺសត្វ និងមានអង្គការនិងក្រុមហ៊ុនឯកជនមួយចំនួនក៏បានចូលរួមក្នុងការរាយការណ៍ពីជំងឺសត្វផងដែរមានបណ្តាញពត៌មានទាន់ហេតុការណ៍ចំនួនពីរខ្សែដែលមានលេខ ០១២ ២១៤ ៩៧០ និង ០១២ ៨៣៣ ៧៩៥ ឬ ១២៨៧ និង១២៨៩។

ឆ្នាំ២០១២ ជំងឺផ្តាសាយបក្សីផ្ទុះឡើងលើបក្សីចំនួន១កន្លែង (ភូមិព្រីង ឃុំទួលសាលា ស្រុក បរសេដ្ឋ ខេត្តកំពង់ស្ពឺ) និងករណីជំងឺផ្តាសាយបក្សីលើមនុស្សមានចំនួន ០៣នាក់ (នៅភូមិរពាក់ ឃុំឈ្នួរមានជ័យ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ ភូមិក្បាលកោះ ឃុំអំពិលទឹក ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង និងភូមិព្រីង ឃុំទួលសាលា ស្រុក បរសេដ្ឋ ខេត្តកំពង់ស្ពឺ)។

**ក្រាហ្វិកបង្ហាញពីស្ថានភាពជំងឺផ្តាសាយបក្សី**




កសាងច្បាប់ ប្រកាស និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗនៃផ្នែកផលិតកម្ម និងបសុព្យាបាល បានទទួលលទ្ធផលល្អគួរឱ្យកត់សំគាល់ ដូចជា ការកសាងលិខិតបទដ្ឋានគតិយុត្តនៃអនុក្រឹត្យលេខ១៦ និង១០៨ អនក្រ.បក បានបញ្ចប់សព្វគ្រប់ទាំងស្រុង។ ទន្ទឹមនឹងនោះ បានបញ្ចប់ប្រកាសលេខ ៣៦០ប្រក.កសកស្តីពីការគ្រប់គ្រងនិងការដាក់ឱ្យប្រើប្រើប្រាស់ស្លាកលេខសម្គាល់សត្វចតុប្បាទ ប្រកាសរួមលេខ ១០១៣សហវ.ប្រកស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងប្រកាសរួមលេខ ១០១៤សហវ.ប្រកស្តីពីការផ្តល់រង្វាន់លើកទឹកចិត្តជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ សេចក្តីព្រាងច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វបានប្រជុំពិភាក្សាចប់ជំនាញបច្ចេកទេសនៅទីស្តីការគណៈរដ្ឋមន្ត្រី ដែលមានការចូលរួមពីក្រុមប្រឹក្សាអ្នកច្បាប់និងក្រុមប្រឹក្សាសេដ្ឋកិច្ចសង្គមកិច្ចនិងវប្បធម៌។ សេចក្តីព្រាងច្បាប់នេះមានចំនួន ២២ជំពូក ១២២មាត្រា ដោយមានសទ្ទានុក្រមដែលជាឧបសម្ព័ន្ធវាក្យស័ព្ទចំនួន ៣៦ ត្រូវបានប្រើក្នុងច្បាប់នេះ។ សេចក្តីព្រាងច្បាប់នេះ នឹងត្រូវដាក់ប្រជុំពិភាក្សាអន្តរក្រសួងនៅទីស្តីការ គណៈរដ្ឋមន្ត្រីនាពេលដ៏ខ្លីខាងមុខនេះ។ សេចក្តីព្រាងប្រកាសស្តីពី ការបង្កើតនិងការគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វ បានបញ្ជូនទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ការងារផ្សព្វផ្សាយបច្ចេកទេសផលិតកម្មនិងបសុព្យាបាល ជាផ្នែកមួយដ៏សំខាន់ក្នុងការចូលរួមអភិវឌ្ឍវិស័យផលិតកម្មនិងបសុព្យាបាល ជាមធ្យោបាយសម្រាប់ផ្ទេរចំណេះដឹងថ្មីៗតាមបែបវិទ្យាសាស្ត្រក្នុងការចិញ្ចឹមសត្វ វាគឺជាចលករដ៏សំខាន់ក្នុងការធ្វើឲ្យមានការផ្លាស់ប្តូរឥរិយាបទរបស់កសិករក្នុងការចិញ្ចឹមសត្វតាមបែបយថាផលទៅជាការចិញ្ចឹមតាមបែបបច្ចេកទេស ការចិញ្ចឹម

សត្វសម្រាប់តែតម្រូវការហូបចុកក្នុងគ្រួសារ ទៅជាការចិញ្ចឹមសម្រាប់ធ្វើពាណិជ្ជកម្ម។ ដោយយល់ឃើញពីសារៈសំខាន់នៃការងារផ្សព្វផ្សាយ និងបានយកចិត្តទុកដាក់ប្រើប្រាស់គ្រប់មធ្យោបាយទាំងអស់ តាមវិទ្យុ ទូរទស្ស ទស្សនាវដ្តី បទសម្ភាសន៍ ឯកសារបច្ចេកទេស ការតាំងពិព័ណ៌ ការផ្សព្វផ្សាយតាមប្រព័ន្ធអេឡិចត្រូនិក ការឃោសនាផ្សព្វផ្សាយនៅតាមមូលដ្ឋាន និងទស្សនកិច្ចសិក្សា។ល។ ដោយផ្តោតការយកចិត្តទុកដាក់ទៅលើបញ្ហាជាអទិភាពដូចជាបញ្ហាជំងឺឆ្លង អត្ថប្រយោជន៍នៃការចាក់ថ្នាំការពារជំងឺឆ្លងសត្វ បច្ចេកទេសចិញ្ចឹម ពូជនិងបច្ចេកទេសជ្រើសរើសពូជ បច្ចេកទេសបង្កាត់ពូជតាមបែបសិប្បនិមិត្ត បច្ចេកទេសដាំដំណាំចំណីសត្វ បច្ចេកទេសកែច្នៃចំណីសត្វ និងលិខិតបទដ្ឋានគតិយុតពាក់ព័ន្ធនឹងវិស័យ ផលិតកម្ម និងបសុព្យាបាល ។ល។

គម្រោងគាំទ្រដោយដៃគូអភិវឌ្ឍន៍ ÷ ដើម្បីធានាសុវត្ថិភាព និងការអភិវឌ្ឍន៍អនុវស័យផលិតកម្មសត្វ និងសុខភាពសត្វប្រកបដោយចីរភាព និងភាពរីកចម្រើន អនុវិស័យមានកិច្ចសហការយ៉ាងជិតស្និតជាមួយអង្គការជាតិ អង្គការអន្តរជាតិដៃគូអភិវឌ្ឍន៍ជាច្រើនផ្សេងទៀត និងផ្នែកឯកជននានា ដូចជា OIE, FAO, EU, JICA, WB, ACIAR, USAID, CP ដែលជាប្រភពធនធានយ៉ាងសំខាន់ ក្នុងការផ្តល់នូវការគាំទ្រទាំងផ្នែកបច្ចេកទេស និងថវិកា សម្រាប់ជួយដំណើរការនៃការអនុវត្តសកម្មភាពការងារក្នុងអនុវិស័យនេះ។

កិច្ចសហប្រតិបត្តិការទ្វេភាគី÷ មកទល់ពេលនេះ អនុវិស័យមានកិច្ចសហប្រតិបត្តិការទ្វេភាគីលើអនុវិស័យសុខភាពសត្វ និងផលិតកម្មសត្វជាមួយសាធារណៈរដ្ឋសង្គមនិយមវៀតណាម សាធារណៈរដ្ឋប្រជាមានិតចិន ថៃឡង់ដ៍ ជប៉ុន និងកូរ៉េក្រោមកិច្ចព្រមព្រៀង MOU។ ចំពោះកិច្ចសហប្រតិបត្តិការជាមួយភាគីវៀតណាម ជារៀងរាល់ឆ្នាំ ភាគីទាំងពីរមានការជួបប្រជុំគ្នា ដើម្បីជជែកពិភាក្សាគ្នាស្តីពីកិច្ចសហការលើសុខភាពសត្វនៃប្រទេសទាំងពីរ ដោះស្រាយរាល់ប្រឈម ការផ្លាស់ប្តូរបច្ចេកទេស ការផ្តល់ជំនួយជាសម្ភារបរិក្ខារ វគ្គបណ្តុះបណ្តាល និងទស្សនកិច្ចសិក្សា។ ចំពោះកិច្ចសហប្រតិបត្តិការជាមួយភាគីចិនក្រោមកិច្ចព្រមព្រៀង MOU ភាគីទាំងពីរ បានបង្កើតស្ថានីយចិញ្ចឹមជ្រូកពូជបង្ហាញកម្ពុជា ចិន ដោយមានការគាំទ្រទាំងបច្ចេកទេស ថវិកា និងពូជជ្រូក ដល់ភាគីកម្ពុជា។ ក្រៅពីនេះ ភាគីចិនមានការបន្តផ្តល់ជំនួយឡជីវឧស្ម័នចំនួនប្រមាណ ៣០០ឡ សម្រាប់ប្រជាកសិករកម្ពុជា នៅតាមជនបទ។ ចំពោះកិច្ចហសប្រតិបត្តិការទ្វេភាគីកម្ពុជា ជប៉ុន ភាគីទាំងពីរ បានផ្តោតលើការចិញ្ចឹមគោយកទឹកដោះនៅតាមសហគមន៍អ្នកចិញ្ចឹមសត្វ ដោយភាគីជប៉ុន បានផ្តល់ជំនួយផ្នែកបច្ចេកទេស ឧបករណ៍សម្ភារបរិក្ខារ និងថវិកាមួយចំនួន សម្រាប់គាំទ្រគម្រោងនេះ។ ចំពោះកិច្ចសហការជាមួយកូរ៉េ ភាគីទាំងពីរ បានសង្កត់លើការងារមន្ទីរពិសោធន៍ និងផ្នែកសុខភាពសត្វ ដោយផ្តល់នូវសម្ភារបរិក្ខារ និងផ្លាស់ប្តូរបទពិសោធន៍បច្ចេកទេសជំនាញតាមរយៈការផ្លាស់ប្តូរទស្សនកិច្ចសិក្សានៃមន្ត្រីជំនាញរវាងប្រទេសទាំងពីរ។

ការផ្គត់ផ្គង់និងបើកផ្តល់ថ្នាំការពារ សម្ភារបរិក្ខារបសុពេទ្យ និងសម្ភារផ្សេងទៀត÷ នាឆ្នាំ២០១២នេះ ផ្នែកផលិតកម្មនិងបសុព្យាបាល បានធ្វើការផ្គត់ផ្គង់សម្ភារបិក្ខារ និងប្រេងដល់ផ្នែកជំនាញ សម្រាប់កិច្ចដំណើការរបស់ខ្លួន និងចុះបំពេញការងារនៅតាមមូលដ្ឋាន។ ក្រៅពីនេះ បានធ្វើការបែងចែកថ្នាំការពារព្យាបាល និងសម្ភារបរិក្ខារបសុពេទ្យតាមបណ្តារាជធានី ខេត្ត និងស្ថានីយចិញ្ចឹមសត្វទាំងពីររួមមាន÷ វ៉ាក់សារទឹកចំនួន ១.៨៥៦.៥០០កម្រិត វ៉ាក់សាំងអុតក្តាមចំនួន ១៨.១៨០កម្រិត បូសខ្យល់ចំនួន ១៥.២០០កម្រិត វ៉ាក់សាំងផ្សេងៗ ៤.០០០ កម្រិត ស៊ីរាំង ១០ និង ២០ មម ចំនួន ៤៩៥ គ្រឿង ម្ជុលចំនួន ៥៤៣ ប្រអប់ដង្កៀបចំនួន ៩៣ គ្រឿង ទែម៉ូម៉ែតចំនួន ១៦៥ គ្រឿង ថ្នាំព្យាបាល ៣៩ មុខចំនួន ២.៨១០ ដប ប្លីមេទីឡែនចំនួន ៥៤ គ.ក្រ អាកុលចំនួន ២៩០ លីត្រ សំឡីចំនួន ១១៩ គក្រ អាវអៀមចំនួន ១១០ អាវ កាបូបពេទ្យសត្វចំនួន ១២២កាបូប និងធុងទឹកកកចំនួន ២៩ គ្រឿង ស្បែកជើងកវែង១២៥គូរ ស្រោមដៃ ១៤៩គូរម៉ាស់១២៣ប្រអប់ មួក និងអាវ៥.០០០កំប្លេ ម៉ាស៊ីនបាញ់រម្ងាប់មេរោគ២៥គ្រឿង ថ្នាំរម្ងាប់មេរោគ៣៨២លីត្រ និងខិតប័ណ្ណ និងផ្ទាំងរូបភាព៤៩.២០០សន្លឹក។

ការអង្កេតតាមដាននិងការវាយតម្លៃលើការងារពាក់ព័ន្ធ÷ អនុវិស័យនេះ បានចុះអនុវត្តត្រួតពិនិត្យ តាមដានលើការអនុវត្តគម្រោងតាមកម្មវិធី និងការប្រមូលចំណូល តាមរយៈរាជធានី ខេត្ត។ ក្រៅពីនេះ ជារៀងរាល់ឆ្នាំ តែងតែធ្វើការក្រើនរំលឹក និងចេញសេចក្តីណែនាំស្តីពីការប្រមូលចំណូលនេះ ជាហូរហែផងដែរ។

**៥.៤.២-វាយតម្លៃនិងសន្និដ្ឋាន**

វិស័យផលិតកម្មនិងបសុព្យាបាល កាន់តែមានសារៈសំខាន់ក្នុងវិស័យសេដ្ឋកិច្ចជាតិ និងមានតួនាទីសំខាន់ក្នុងការផ្គត់ផ្គង់សេចក្តីត្រូវការក្នុងស្រុក និងក្នុងតំបន់ ដូចជាការផ្តល់នូវកំលាំងអូសទាញផ្តល់សាច់ ស៊ុត វត្ថុធាតុដើម ចំណូលគ្រួសារ និងចំណូលសេដ្ឋកិច្ចជាតិ។

ឆ្នាំ២០១២ ផលិតកម្មគោ ក្របី មានការថយចុះចំនួន១.៥៤% ធៀបនឹងស្ថិតិសត្វឆ្នាំ ២០១១។ ការថយចុះគោ ក្របីគឺបណ្តាលមកពីកត្តាសំខាន់ៗមួយចំនួន រួមមានកំណើននៃការប្រើប្រាស់គ្រឿងយន្តកសិកម្ម ការបម្រែបម្រួលអាកាសធាតុការកើនឡើងនៃផ្ទៃដីកសិកម្ម និងកំណើននៃតម្រូវការសាច់ជាម្ហូបអាហារក្នុងស្រុក និងទីផ្សារនាំចេញគោរស់ទៅប្រទេសជិតខាង។ ប៉ុន្តែផ្ទុយទៅវិញ ជ្រូកបានកើនឡើងចំនួន៨.៨៥% និងចំនួនសត្វស្លាបមានការកើនឡើងចំនួន ៥.៩៣% បើធៀបនឹងស្ថិតិឆ្នាំ ២០១១។ តាមការវិភាគពីសូចនាកររនៃកើនសត្វគ្រប់ប្រភេទសរុប៣១.៣៨៩.៥០៦ក្បាលដែលស្មើនឹង៤.៨៥%។ មូលហេតុនៃការកើនឡើងនេះ គឺបណ្តាលមកពីមានកំណើនតម្រូវការទីផ្សារខ្ពស់ ផ្តល់នូវប្រាក់ចំណូល មានវដ្តផលិតកម្មខ្លី និងការរីកចម្រើននៃបច្ចេកវិជ្ជាថ្មីៗ និងការចិញ្ចឹមជាលក្ខណៈគ្រួសារមានការរីកចំរើន ជាពិសេសសន្ទុះកើនឡើងនៃការវិនិយោគផ្នែកឯកជន។ ការវិនិយោគក្នុងការផលិតចំណីសត្វ មានការរីកចម្រើនគួរឱ្យកត់សម្គាល់ ដោយសារមានការបង្កើតឡើងនូវរោងចក្រចំណីសត្វគ្រប់ប្រភេទពីសំណាក់វិនិយោគិនក្នុងស្រុក និងវិនិយោគិនពីបរទេស ដូចជាក្រុមហ៊ុន ស៊ី ភី ខេមបូឌា ក្រុមហ៊ុន អេស ស៊ី អេហ្វ ក្រុមហ៊ុនអេហ្គ្រីម៉ាស្ទ័រ ក្រុមហ៊ុនម៉ុង ឬទ្ធីគ្រុប ក្រុមហ៊ុន ហ្គ្រីនហ្វិត។ល។ សម្រាប់ផលិតចែកចាយក្នុងស្រុក និងក្រុមហ៊ុនជីហ្វៃផលិតចំណីសត្វសម្រាប់នាំចេញទៅក្រៅប្រទេស ។

ការកែលំអរពូជសត្វ មានការបន្តសកម្មភាពរបស់ខ្លួនខ្លាំងក្លា ដោយបានបង្កាត់ និងផ្សព្វផ្សាយពូជសត្វ ដូចជានៅស្ថានីយចិញ្ចឹមគោពូជភ្នំតាម៉ៅ ស្ថានីយចិញ្ចឹមជ្រូកពូជកម្ពុជា-ចិន និងមជ្ឈមណ្ឌលបង្កាត់ពូជគោសាន់តា និងស៊ីមប្រា ដោយសិប្បនិម្មិតនៅខេត្តពោធិសាត់ មជ្ឈមណ្ឌលបង្កាត់ជ្រូកពូជ ដោយសិប្បនិម្មិតនៅខេត្តតាកែវ និងការបង្កាត់ពូជមាន់ KI នៅខេត្តសៀមរាប ហើយផ្សព្វផ្សាយពូជបន្តដល់ខេត្តផ្សេៗទៀត។

ដំណាំចំណីសត្វ កាន់តែមានការពង្រីកសកម្មភាពរបស់ខ្លួនខ្លាំងក្លាផងដែរ នៅគ្រប់រាជធានី ខេត្តទូទាំងប្រទេស ដោយស្ថានីយចិញ្ចឹមគោពូជភ្នំតាម៉ៅ ជាកន្លែងផ្សព្វផ្សាយ ពូជស្មៅ និងចែកចាយពូជទៅតាមបណ្តាខេត្ត និងគម្រោង ACIAR គាំទ្រហិរញ្ញប្បទានដោយរដ្ឋាភិបាលអូស្ត្រាលី ជាពិសេសនៅមានស្រុកព្រៃឈរខេត្តកំពង់ចាម និងស្រុកត្រាំកក់ ខេត្តតាកែវ ប្រជាជនដាំស្មៅទទួលបានជោគជ័យ និងផ្សព្វផ្សាយដល់ខេត្តផ្សេងៗទៀត។ ក្រៅពីនេះ ក៏នៅមានការដាំស្មៅបង្ហាញនៅតាមខេត្ត ស្រុកមួយចំនួនទៀតផងដែរ។

ការគ្រប់គ្រងកាកសំណល់សត្វ តាមរយៈការសាងសង់ឡជីវឧស្ម័នសរុប ដែលបានសាងសង់ចាប់ពីឆ្នាំ ២០០៦ ដល់ឆ្នាំ ២០១២ គឺមានចំនួន **១៩.១៧៣ឡ** ដែលក្នុងនោះសម្រាប់ឆ្នាំ ២០១២ ឡជីឧស្ម័នមានចំនួន **៤.២០១ឡ** ។ នៅឆ្នាំ ២០១២ នេះ សភាពការណ៍ និងស្ថានភាពជំងឺសត្វ ពុំបានបង្កការឆ្លងរាលដាល និងប៉ះពាល់ខ្លាំងក្លាដល់ជីវិតមនុស្សសត្វអ្វីឡើយ។ នេះបញ្ជាក់ឲ្យឃើញថា នាយកដ្ឋានផ.ប និងការិយាល័យផ.ប បានរៀបចំផែនការគ្រប់គ្រងការត្រួតពិនិត្យបានគ្រប់ជ្រុងជ្រោយ និងចាត់វិធានបសុពេទ្យ ដើម្បីទប់ស្កាត់ជំងឺសត្វបានល្អប្រសើរ និងទាន់ពេលវេលា។

ការរៀបចំច្បាប់ លិខិតបទដ្ឋានគតិយុតនានាទាក់ទងវិស័យផលិតកម្ម និងបសុព្យាបាល បាននឹងកំពុងដំណើរការប្រកបដោផ្លែផ្កា ជាពិសេសបានបញ្ចប់សេចក្តីព្រៀងច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ ។

សមិទ្ធិផលទាំងអស់នេះ សម្រេចបានដោយសារមានការគាំទ្រពីរាជរដ្ឋាភិបាលពីថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាពិសេសពីសំណាក់**ឯកឧត្តមបណ្ឌិត ច័ន្ទ សារុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ការខិតខំប្រឹងប្រែងចូលរួមយ៉ាងសកម្មរបស់ថ្នាក់ដឹកនាំ មន្ត្រីរាជការរបស់នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល ព្រមទាំងមានការចូលរួមសហការយ៉ាងជិតស្និទ្ធជាមួយមន្ទីរកសិកម្មរាជធានី-ខេត្ត មន្ត្រីរាជការផលិតកម្ម និងបសុព្យាបាល រាជធានី-ខេត្ត ភ្នាក់ងារសុខភាពសត្វភូមិ និងដោយមានកិច្ចសហប្រតិបត្តិការ និងជំនួយឧបត្ថម្ភពីបណ្តាប្រទេសនានាក្នុងតំបន់ ភ្នាក់ងារផ្តល់ជំនួយអង្គការជាតិ អង្គការអន្តរជាតិនានា និងផ្នែកឯកជនជាដើម។

### ៥.៤.៣-វិធានការ

នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល មានទិសដៅច្បាស់លាស់ សម្រាប់អនុវត្តសកម្មភាពរបស់ខ្លួនក្នុងឆ្នាំ២០១៣ ដូចខាងក្រោម ÷

-បន្តពង្រឹង និងគ្រប់គ្រងអង្គភាព សម្រាប់អនុវត្តការងារវិស័យប្រកបដោយចីរភាព និងប្រសិទ្ធភាពខ្ពស់

-រៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យ ផែនការសកម្មភាព កម្មវិធីនិងគម្រោងសកម្មភាពអាទិភាពលើវិស័យផលិតកម្មសត្វ និងសុខភាពសត្វ

- រៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្តិ លើវិស័យផលិតកម្មសត្វ និងសុខភាពសត្វ

-បន្តនិងធ្វើឲ្យប្រសើរឡើងនូវកិច្ចសហប្រតិបត្តិការលើវិស័យផលិតកម្ម និងបសុព្យាបាល ជាមួយបណ្តាប្រទេសជាមិត្ត ដៃគូរអភិវឌ្ឍន៍ អង្គការជាតិ អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល ស្ថាប័នពាក់ពន្ធ័ និងកិច្ចសហការជាមួយផ្នែកឯកជន។

## ៥.៥- ផលិតផលដំណាំកៅស៊ូ (ឧបសម្ព័ន្ធទី១២-១៣)

កៅស៊ូជាដំណាំកសិ-ឧស្សាហកម្មរយៈពេលវែង ដែលបានបំពេញតួនាទីយ៉ាងសំខាន់ ជួយទ្រទ្រង់ដល់សង្គម-សេដ្ឋកិច្ចជាតិតាមរយៈនីហរ័ណកម្មផលិតផលជ័រនិងឈើកៅស៊ូ ដែលជាចំណែកមួយក្នុងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ បង្កើតការងារនៅជនបទ បង្កើនប្រាក់ចំណូល និងទប់ស្កាត់ធ្វើចំណាកស្រុករបស់កសិករ។ ម្យ៉ាងវិញទៀត ដំណាំកៅស៊ូក៏បានចូលរួមការពារបរិស្ថាន ដោយបង្កើតជាគម្របបៃតង រក្សាលំនឹងធម្មជាតិ និងការពារហួរច្រោះដី។

### ៥.៥.១-លទ្ធផល

នៅឆ្នាំ ២០១២ ចម្ការកៅស៊ូកសិ-ឧស្សាហកម្ម និងចម្ការកៅស៊ូគ្រួសារ ព្រមទាំង វិទ្យាស្ថាន ស្រាវជ្រាវកៅស៊ូកម្ពុជា បានដំណើរការអនុវត្តទៅតាមផែនការរៀងៗខ្លួន ក្នុងនោះ មុខព្រួញសំខាន់ៗរួមមានការធ្វើអាជីវកម្ម ផលិតកម្ម នីហរ័ណ កម្មការដាំដុះថ្មី និងការកាប់ដើមកៅស៊ូចាស់ៗនិងដាំកៅស៊ូឡើងវិញ ដោយទទួលបានលទ្ធផលដូចខាងក្រោមនេះ ÷

### ក- ការងារអាជីវកម្ម -ផលិតកម្មកៅស៊ូ

- ផ្ទៃដីចៀរជ័រ ៥៥.៣៦១ ហត ក្នុងនោះ ផ្ទៃដីចៀរជ័រកៅស៊ូគ្រួសារ ចំនួន ៣១.២៩៨ ហត
- ផលិតផលកៅស៊ូស្ងួត ៦៤.៥២៥តោន ក្នុងនោះ ផលិតផលកៅស៊ូគ្រួសារចំនួន ៣៥.៩៩៣តោន
- ការនាំចេញកៅស៊ូស្ងួត ៥៩.៩១៧តោន ក្នុងនោះ ផលិតផលកៅស៊ូគ្រួសារចំនួន ៣០.០០០តោន
- កូនកៅស៊ូកំពុងថែទាំសរុបចំនួន ២២៤.៩៩៤ហត ក្នុងនោះ កៅស៊ូកសិឧស្សាហកម្មសរុបចំនួន ១៤៨.៩៩៥ហត និង កៅស៊ូគ្រួសារចំនួន ៧៦.៣៩៨ហត។

**ក្រាហ្វិកបង្ហាញពីផលិតផល និងការនាំចេញកៅស៊ូឆ្នាំ ២០០៧-២០១២**




### ខ- ក្របខណ្ឌច្បាប់

ដោយទទួលបាននូវគម្រោងថវិកាតាមកម្មវិធី អគ្គនាយកដ្ឋានកៅស៊ូ បាននិងកំពុងរៀបចំសេចក្តី ព្រាងច្បាប់ស្តីពីកៅស៊ូ ដែលគ្រោងនឹងបញ្ចប់ក្នុងឆ្នាំ២០១២-២០១៣ នេះក្នុងកម្រិតក្រុមការងារតាក់តែងច្បាប់នៃអគ្គនាយកដ្ឋានកៅស៊ូ។

ជារួមវិស័យកៅស៊ូ បានកសាងយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍកៅស៊ូធម្មជាតិនៅកម្ពុជារយៈពេល១០ឆ្នាំ (២០១១-២០២០) បានអនុម័តរួចក្នុងឆ្នាំ២០១១ ធ្វើជាត្រីវិស័យសម្រាប់ការអនុវត្តមួយ ងដែរ។

## គ- ការងារស្រង់ស្ថិតិកៅស៊ូគ្រួសារ

ដោយទទួលបាននូវគម្រោងថវិកាតាមកម្មវិធី នៅឆ្នាំ២០១២ គឺជាឆ្នាំទី៣ ដែលអគ្គនាយកដ្ឋានកៅស៊ូ បាននិងកំពុងអនុវត្តគម្រោង ដោយនាយកដ្ឋានអភិវឌ្ឍន៍កៅស៊ូនៃកៅស៊ូ ដោយមានការសហការជាមួយមន្ទីរកសិកម្មខេត្តពាក់ព័ន្ធនិងអាជ្ញាធរមូលដ្ឋាន បានចុះស្រង់ស្ថិតិកៅស៊ូគ្រួសារ-ឯកជននៅលើខេត្តចំនួន១១ គឺខេត្តរតនគិរី ស្ទឹងត្រែង ក្រចេះ មណ្ឌលគិរី ពោធិសាត់ បន្ទាយមានជ័យ កំពត ព្រះសីហនុ កោះកុង ព្រៃវែង និងស្វាយរៀង។ ជារួមក្នុងរយៈពេលបីឆ្នាំនេះក្រុមការងារអនុវត្តគម្រោងអាទិភាព បានចុះស្រង់ស្ថិតិកៅស៊ូគ្រួសារនៅក្នុងខេត្តចំនួន១៨ ដែលមានផ្ទៃដីដាំដុះកៅស៊ូចំនួន១០៧.៦៩៦ហតស្មើនឹង២១.០៥៥គ្រួសារ។

## ឃ- ការចូលរួមសន្និសីទនិងសន្និបាតអន្តរជាតិ

ក្នុងឋានៈកម្ពុជាជាសមាជិកពេញសិទ្ធិ នៃសមាគមបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ (ANRPC) និងក្រុមប្រឹក្សាអភិវឌ្ឍន៍កៅស៊ូអន្តរជាតិ (IRRDB) អគ្គនាយកដ្ឋានកៅស៊ូ តែងបានចូលរួមប្រជុំសន្និសីទនៃអង្គការទាំងពីរនេះនៅប្រទេសឥណ្ឌូនេស៊ី និងប្រទេសឥណ្ឌា និងបានចូលរួមក្នុងកិច្ចប្រជុំលើកទី១២នៃក្រុមប្រឹក្សាកៅស៊ូត្រីភាគីអន្តរជាតិ (the 12th International Tripartite Rubber Council "ITRC") និងកិច្ចប្រជុំពិសេសថ្នាក់រដ្ឋមន្ត្រីស្តីពីកិច្ចសហប្រតិបត្តិការកៅស៊ូអន្តរជាតិ (The Special Ministerial Meeting on International Rubber Cooperation) នៅខេត្តភូកេត ប្រទេសថៃឡង់ ជាអ្នកសង្កេតការ ព្រមទាំងបានធ្វើការទំនាក់ទំនងជាប្រចាំជាក្រុមសិក្សាកៅស៊ូអន្តរជាតិផងដែរ។

## ង- ការអភិវឌ្ឍដំណាំកៅស៊ូជាលក្ខណៈគ្រួសារ

ចាប់តាំងពីឆ្នាំពី២០០៣មក ការដាំដុះកៅស៊ូលក្ខណៈគ្រួសារនិងឯកជន ដែលប្រើប្រាស់ទុនខ្លួនឯងផ្ទាល់មានការរីកលូតលាស់យ៉ាងខ្លាំងទាំងក្នុងតំបន់ប្រពៃណី និងតំបន់មិនប្រពៃណីដែលពីមុនជាតំបន់មិនធ្លាប់ដាំកៅស៊ូក៏ដោយ។

គិតមកត្រឹមឆ្នាំ២០១២នេះ ផ្ទៃដីចម្ការកៅស៊ូគ្រួសារនៅទូទាំងប្រទេស ដែលមានក្នុង១៨ខេត្ត សរុបមានចំនួន ១០៧.៦៩៦ហត ស្មើនឹងចំនួន ២១.០៥៥គ្រួសារ។

## ឃ- ការស្រាវជ្រាវកៅស៊ូកម្ពុជា

ស្រាវជ្រាវកៅស៊ូកម្ពុជាមានភារកិច្ចដឹកនាំនិងសម្រេចរាល់សកម្មភាពស្រាវជ្រាវនិងពិសោធន៍ សំដៅ ជំរុញការអភិវឌ្ឍន៍លើគ្រប់វិស័យផ្នែកដំណាំកៅស៊ូទូទៅ និងចូលរួមក្នុងរាល់សកម្មភាពនៃការជំរុញផ្នែកបច្ចេកទេស សុវុឌ្ឍិកម្ម នៃគុណភាពកៅស៊ូ និងតម្លៃផលិតកម្ម។

## ឃ.១- ការផ្សព្វផ្សាយ បណ្តុះបណ្តាល និងបេសកកម្ម

- បានចុះពិនិត្យដីសម្រាប់ដាំកៅស៊ូ និងច្បារពូជកៅស៊ូគ្រួសារនៅខេត្តមណ្ឌលគិរី
- បានទៅចូលរួមសិក្ខាសាលាថ្នាក់អន្តរជាតិ, (១)ស្តីពីការបង្កាត់ពូជកៅស៊ូនៅប្រទេសឥណ្ឌូនេស៊ី, (២)ស្តីពីការធ្វើអត្តសញ្ញាណកម្មក្លូនកៅស៊ូនៅប្រទេសម៉ាឡេស៊ី, (៣)ការបណ្តុះបណ្តាលថ្នាក់អន្តរជាតិស្តីពី (Physiological and molecular basis of breeding for tolerance to environment stress) នៅប្រទេសឥណ្ឌា
- ទទួលនិស្សិតចុះកម្មសិក្សាបញ្ចប់សារណាបទថ្នាក់បរិញ្ញាចំនួន១១នាក់
- ចុះសិក្សាស្ថានភាពដីលើទីតាំង(១)ក្រុមហ៊ុនម្សៅដំឡូងមីចំកាត់ ស្ថិតនៅខេត្តស្ទឹងត្រែង(២)ក្រុមហ៊ុនភ្នំរៀង ស្ថិតនៅក្នុងស្រុកស្នួល ខេត្តក្រចេះ (៣)ក្រុមហ៊ុនធីង៉ា និងក្រុមហ៊ុនភីអិនធី (PNT) ដែលស្ថិតនៅក្នុងខេត្តព្រះវិហារ (៤)ក្រុមហ៊ុនស៊ីណូមិចស៊ីម អ៊ីនវេសមិនស្ថិតនៅក្នុងស្រុកបុទុមសាគរ ខេត្តកោះកុង (៥)ក្រុមហ៊ុនអេសខេផ្លេនថេសិន (ខេមបូឌា) ភីធីអ៊ី អិលធីឌី ស្ថិតនៅក្នុងខេត្តរតនគិរី

- រៀបចំអត្ថបទសម្រាប់បង្រៀនកសិករស្តីពីការដាំដុះ ថែទាំកៅស៊ូ ជីធីកៅស៊ូ ការប្រើប្រាស់ថ្នាំកសិកម្ម លើដំណាំកៅស៊ូ និងការប្រមូលផលទឹកជ័រ(ការចៀរជ័រ)

- បើកវគ្គបណ្តុះបណ្តាលដល់កសិករអំពីបច្ចេកទេសដាំដុះ ថែទាំ និងរបៀបដាក់ជីកៅស៊ូផ្តល់ផល និងប្រមូលផលទឹកជ័រនៅស្ថានីយពិសោធន៍វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជាដោយមានកសិករចូលរួមចំនួន ១២៧នាក់

- បើកវគ្គបណ្តុះបណ្តាលបុគ្គលិកមន្ទីរពិសោធន៍យថាប្រភេទរបស់ក្រុមហ៊ុនចម្ការកៅស៊ូស៊ីហ្វ៊ីសសស់(ខេមបូឌា) លីមីធីត នៅស្នួលចំនួន៧នាក់ និងក្រុមហ៊ុនក្រែក (ខេមបូឌា) ខូអិលធីឌី ចំនួន៧នាក់អំពីនីតិវិធីធ្វើតេស្តនិងផ្តល់វិញ្ញាបនបត្របញ្ជាក់គុណភាពកៅស៊ូ CSR

- បើកវគ្គបណ្តុះបណ្តាលអំពីកៅស៊ូធម្មជាតិនិងការកែច្នៃកៅស៊ូសន្លឹក(RSS)ដល់សិក្ខាកាមចូលរួមចំនួន ២២នាក់ ដែលមានសិប្បករកៅស៊ូសន្លឹកមកពីខេត្តកំពង់ចាម និងខេត្តរតនគីរី

- បណ្តុះបណ្តាលនិស្សិតវិស្វករឆ្នាំទី៣ ដេប៉ាត៌ម៉ង់ទេពកោសល្យគីមីនិងចំណីអាហារ នៃវិទ្យាស្ថានបច្ចេកទេសកម្ពុជា ចំនួន៨នាក់ អំពីការធ្វើតេស្តនិងផ្តល់វិញ្ញាបនបត្របញ្ជាក់គុណភាពកៅស៊ូ

- ទទួលនិស្សិតមហាវិទ្យាល័យកសិកម្ម នៃសាកលវិទ្យាល័យស្វាយរៀងជំនាញក្សេត្រសាស្ត្រឆ្នាំទី៣ចំនួន ១៦នាក់ ក្នុងនោះស្រី ៩នាក់ ធ្វើទស្សនកិច្ចសិក្សាស្វែងយល់អំពីនីតិវិធីការធ្វើតេស្តនិងផ្តល់វិញ្ញាបនបត្របញ្ជាក់គុណភាពកៅស៊ូ និងរៀបចំកម្មវិធីការប្រើប្រាស់ថ្នាំរំញោចលើចម្ការពិសោធន៍។

## ឃ.២- ការស្រាវជ្រាវផ្នែកក្សេត្រសាស្ត្រ

-ដាំកូនកៅស៊ូ Seedling នៅឡូត៍ SET សរុបទាំងអស់ចំនួន១២៣០ដើមលើផ្ទៃដី 0,៦ ហត

- ដាំពង្រីកក្លូនCMS សរុបទាំងអស់ចំនួន ១០៧៩ក្លូន

- រៀបចំបើកចៀរជ័រឡូត៍ពិសោធន៍ក្លូន IRAA07 លើផ្ទៃដី ៦,៣៥ហត

- រៀបចំរបាយការណ៍បច្ចេកទេសប្រចាំឆ្នាំ២០១២ និងឆ្នាំ២០១៣

- បន្តការងារសហប្រតិបត្តិការជាមួយសាកលវិទ្យាល័យ Nagoya, Kyushu and Hawaii

- ដាំកូនកៅស៊ូធ្វើជាច្បារពូជនៅប្លុក១១ និង៣១ បានចំនួន ៣៥៦៤កូន

- បំប៉ៅកូនកៅស៊ូបានចំនួន ២៣៧៤១កូន

- ធ្វើថ្នាលកូនសម្រាប់ដាំនៅឆ្នាំ២០១៣ លើផ្ទៃដី 0,២៥ហតស្មើនឹង ២៥៩00ថង់

- ដាំកូនកៅស៊ូបាន១២,៥0ហតដែលមានចំនួន ៦៩៧២ដើម គឺពូជ PB 217 និងពូជ IRCA 230 និងដាំជួសកៅស៊ូបានចំនួន ២,៤៨១ដើម។

## ឃ.៣- មន្ទីរពិសោធន៍ជាតិយថាប្រភេទ

- ធ្វើតេស្តភាគសំណាកយថាប្រភេទចំនួន ១៩0ភាគសំណាក

- អនុវត្តប្រព័ន្ធគ្រប់គ្រងគុណភាពនៃវិញ្ញាបនបត្រស្តង់ដារអន្តរជាតិ ISO17025:2005 របស់មន្ទីរពិសោធន៍អំពីសមត្ថភាពធ្វើតេស្ត និងព្យាសកម្មឧបករណ៍ពិសោធន៍ ដើម្បីបន្តសុពលភាពរយៈពេល ៣ឆ្នាំពីឆ្នាំ២០១២-២០១៤

- ចូលរួមនិងសរុបលទ្ធផលធ្វើតេស្តអន្តរមន្ទីរពិសោធន៍លើកទី១០៥ ១០៦ និង ១០៧ ជាមួយសមាគម កៅស៊ូអន្តរជាតិ (IRA) ដើម្បីវាយតម្លៃសមត្ថភាពធ្វើតេស្ត និងការទទួលស្គាល់នៅក្នុងតំបន់សម្រាប់កិច្ចសន្យាកៅស៊ូ TSRs

- រៀបចំនិងធ្វើរបាយការណ៍លទ្ធផលធ្វើតេស្តប្រៀបធៀបមន្ទីរពិសោធន៍ក្នុងស្រុកចំនួន៤ដង ដើម្បីវាយតម្លៃសមត្ថភាពមន្ទីរពិសោធន៍មូលដ្ឋានសម្រាប់ទទួលស្គាល់ជាផ្លូវការពីវិទ្យាស្ថាន

- ចុះបញ្ជិកា និងចេញលិខិតអនុញ្ញាតឲ្យប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា ដល់រោងចក្រកែច្នៃកៅស៊ូ (CSR) របស់ក្រុមហ៊ុន ស៊ីហ្វ៉ាប់ប៊ើ លីមីធីត ចម្ការកៅស៊ូខេត្តរតនគីរី

- ធ្វើបទបង្ហាញ(អំពីបច្ចេកទេសកែច្នៃកៅស៊ូសន្លឹកប្រកបដោយគុណភាព) សម្រាប់សិក្ខាសាលាថ្នាក់ជាតិស្តីពីឧស្សាហកម្មកៅស៊ូធម្មជាតិនៅកម្ពុជា។

### ៥.៥.២- វាយតម្លៃនិងសន្និដ្ឋាន

ក្រោយពីរាជរដ្ឋាភិបាលបានធ្វើអវិនិយោគចំការកៅស៊ូរដ្ឋទាំង៧ និងបានកែសម្រួលអគ្គនាយកដ្ឋានកៅស៊ូ ជាអង្គភាពរដ្ឋបាលថ្នាក់កណ្តាល។ ដើម្បីគ្រប់គ្រងវិស័យកៅស៊ូ ធានាទទួលបានប្រសិទ្ធិភាពខ្ពស់ និងប្រកបដោយចីរភាព គឺត្រូវមានការគាំទ្រពីថ្នាក់ដឹកនាំ និងមានការចូលរួមទទួលខុសត្រូវរបស់មន្ត្រីជំនាញ ស្ថាប័នពាក់ព័ន្ធ និងពីគ្រប់ប្រតិបត្តករកៅស៊ូទាំងអស់ផងដែរ។ ដោយសារថវិកា មធ្យោបាយធ្វើដំណើរ មធ្យោបាយបម្រើការងារ និងធនធានមនុស្សនៅមានកម្រិត និងមិនមានរចនាសម្ព័ន្ធដល់ថ្នាក់មូលដ្ឋានផងនោះ។ អគ្គនាយកដ្ឋានកៅស៊ូ សូមសំណូមពរដូចខាងក្រោម÷

១. ជួយអន្តរាគមន៍ទៅនាយកដ្ឋាននីតិកម្មកសិកម្ម ដើម្បីជួយពិនិត្យកែសម្រួលសេចក្តីព្រាងច្បាប់ស្តីពីកៅស៊ូឲ្យបានឆាប់។

២. ជួយអន្តរាគមន៍ទៅក្រសួងនិងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដីផ្តល់ការសហការល្អជាមួយវិស័យកៅស៊ូ

៣. ជួយអន្តរាគមន៍ទៅក្រសួងនិងស្ថាប័នពាក់ព័ន្ធនិងក្រុមហ៊ុនចម្ការកៅស៊ូកសិឧស្សាហកម្ម ដើម្បីអនុវត្តតាមស្មារតីអនុក្រឹត្យលេខ៥៥ អនក្រ.បក ចុះថ្ងៃទី០៤ខែមិថុនា ឆ្នាំ២០០៧ ស្តីពីការផ្តល់វិញ្ញាបនបត្របញ្ជាក់គុណភាពកៅស៊ូ

៤. ជួយអន្តរាគមន៍ទៅក្រុមហ៊ុនវិនិយោគលើដីសម្បទានសេដ្ឋកិច្ចដាំដុះកៅស៊ូទាំងអស់ សហការជាមួយនាយកដ្ឋានជំនាញនៃអគ្គនាយកដ្ឋានកៅស៊ូ ដើម្បីក្តាប់ឲ្យបានអំពីស្ថិតិកៅស៊ូនិងសម្រាប់រៀបចំគោលនយោបាយកៅស៊ូថ្នាក់ជាតិដែលរាជរដ្ឋាភិបាលបាននិងកំពុងយកចិត្តទុកដាក់ខ្ពស់

៥. ជួយអន្តរាគមន៍និងផ្តល់ទីតាំងផ្ទៃដីសម្រាប់ធ្វើអនុស្ថានីយ៍ពិសោធន៍នៅតាមតំបន់

៦. ជួយផ្តល់ប្រេងឥន្ទនៈ ថវិកា ពិសេសមធ្យោបាយធ្វើដំណើរ (បច្ចុប្បន្នអគ្គនាយកដ្ឋានកៅស៊ូមានតែរថយន្ត Pick Up ចាស់ៗចំនួន២គ្រឿងប៉ុណ្ណោះ) ឱ្យបានសមរម្យនិងទាន់ពេលវេលា ដើម្បីសម្រេចបានទិសដៅខាងមុខក៏ដូចជាយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកៅស៊ូនៅកម្ពុជាផងដែរ។

ជារួមលទ្ធផលការងារវិស័យកៅស៊ូសម្រេចបាននៅក្នុងឆ្នាំ២០១២កន្លងមកនេះ បានបង្ហាញឲ្យឃើញថា ទោះបីជាមានការលំបាកនិងជួបបញ្ហាប្រឈមជាច្រើនយ៉ាងណាក៏ដោយ ឈរលើស្មារតីសាមគ្គីភាពឯកភាពផ្ទៃក្នុងរវាងជួរថ្នាក់ដឹកនាំនិងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ នៃអគ្គនាយកដ្ឋានកៅស៊ូបានខិតខំអស់ពីកម្លាំងកាយចិត្តដើម្បីអនុវត្តឲ្យបានតាមទិសដៅនិងផែនការដែលបានកំណត់។ ម្យ៉ាងទៀត សមិទ្ធផលទាំងនេះមួយចំណែកធំគឺ អាស្រ័យដោយសារការជំរុញ ដាស់តឿន និងណែនាំពីថ្នាក់ដឹកនាំក្រសួងកសិកម្ម ជាពិសេសពីសំណាក់ឯកឧត្តមបណ្ឌិត **ច័ន្ទ សារុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលជានិច្ចកាលតែងបានផ្តល់នូវអនុសាសន៍ល្អៗដល់មន្ត្រីរាជការនិងមានការគាំទ្រទាំងស្មារតីនិងថវិកា ដើម្បីអនុវត្តការងារបានប្រកបដោយផ្លែផ្កានិងមានប្រសិទ្ធភាពខ្ពស់។

### ៥.៥.៣-វិធានការ

ដើម្បីសម្រេចបាននូវគោលដៅក្នុងឆ្នាំ២០១៣ខាងមុខ សមស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការរួមចំណែកជំរុញកំណើនសេដ្ឋកិច្ចជាតិ សេដ្ឋកិច្ចគ្រួសារ និងសង្គម សំដៅកាត់បន្ថយភាពក្រីក្រ លើកកំពស់គុណភាពផលិតផលកៅស៊ូធានាក្នុងការប្រកួតប្រជែងនៅលើទីផ្សារនោះ អគ្គនាយកដ្ឋានកៅស៊ូបានដាក់ជាទិសដៅសម្រាប់អនុវត្តការងារក្នុងឆ្នាំ២០១៣ ដូចខាងក្រោម ÷

- បញ្ចប់ការតាក់តែងសេចក្តីព្រាងច្បាប់ស្តីពីកៅស៊ូ
- បង្កើតច្បារបង្កាត់ពូជកៅស៊ូ និងបន្តការងារស្រាវជ្រាវកៅស៊ូលើគ្រប់ប្រធានបទ
- ចុះស្រង់ស្ថិតិកៅស៊ូគ្រួសារក្នុងគម្រោងថវិកាតាមកម្មវិធីសម្រាប់ឆ្នាំ២០១៣ នៅខេត្តគោលដៅចំនួន១៨ ខេត្តកំពង់ចាម កំពង់ធំ ព្រះវិហារ បាត់ដំបង ប៉ៃលិន ឧត្តរមានជ័យ សៀមរាប រតនគីរី ស្ទឹងត្រែង មណ្ឌលគីរី ក្រចេះ ស្វាយរៀង ព្រៃវែង កំពត ព្រះសីហនុ កោះកុង ពោធិសាត់ និងបន្ទាយមានជ័យ
- ចុះពិនិត្យនិងស្រង់ស្ថិតិច្បារពូជនិងរោចក្រ-សិប្បកម្មកៅស៊ូទូទាំងប្រទេស
- ពង្រឹងចម្ការកៅស៊ូកសិឧស្សាហកម្ម ដើម្បីជាស្នូលក្នុងការជួយទ្រទ្រង់ដល់ចម្ការកៅស៊ូគ្រួសារដែលស្ថិតនៅជុំវិញ

## ៥.៦- លទ្ធផលការងាររុក្ខកម្ម

### ៥.៦.១-លទ្ធផល

### ក. ការប្រមូលចំណូលពីវិស័យព្រៃឈើ

បានប្រមូលចំណូលពីផលព្រៃឈើចូលថវិកាជាតិសរុបចំនួន៦០.៨៦៦.៤៩១.៨៦៦៖០០ ក្នុងនោះ ចំណូលពីថ្លៃសួយសារផល អនុផលព្រៃឈើចំនួន ៣៣.០៧១.២១១.១៨៤៖០០ ចំណូលពីការផាកពិន័យនិងលក់ដោយដេញថ្លៃឈើ ដែលបានមកពីការបង្ក្រាបបទល្មើសចំនួន ២៧.៦៥០.៧៦៤.១៧២៖០០ ចំណូលថ្លៃសួយសារសត្វគ្រប់ប្រភេទចំនួន ១២០.១៦៤.០១០៖០០ និងចំណូលពីការជួលអចលនទ្រព្យចំនួន២៤.៣៥២.៥០០៖០០។

### ខ.- ការគ្រប់គ្រងទីជម្រាល និងវាយតម្លៃគម្របព្រៃឈើ

-បានរៀបចំបោះពុម្ពសៀវភៅបម្រែបម្រួលគម្របព្រៃឈើឆ្នាំ២០១០ជាភាសាជាតិនិងភាសាអង់គ្លេសចំនួន៣.០០០ក្បាល

-វាយតម្លៃការប្រែប្រួលគម្របព្រៃឈើឆ្នាំ២០០២ ២០០៦ និង២០១០ នៅទូទាំងប្រទេស និងវាយតម្លៃការប្រែប្រួលគម្របព្រៃឈើឆ្នាំ២០០២ ២០០៦ និង២០១០ ក្នុងព្រៃសហគមន៍ចំនួន៨៨ ក្នុងខេត្តចំនួន ១៦

-ចូលរួមប្រជុំពិភាក្សាជាមួយដៃគូសហប្រតិបត្តិការជប៉ុនស្តីពី គម្រោងប្រព័ន្ធតាមដានការប្រែប្រួលគម្របព្រៃឈើ REL / MRV តាមគោលការណ៍ Cambodia REDD Road Map

-ផលិតផែនទីគម្របព្រៃឈើឆ្នាំ២០១០ ដើម្បីប្រើប្រាស់ក្នុងខណ្ឌរដ្ឋបាលព្រៃឈើចំនួន១៤ ផ្នែករដ្ឋបាលព្រៃឈើចំនួន៨ និងសង្កាត់រដ្ឋបាលព្រៃឈើចំនួន១៣

-សហប្រតិបត្តិការជាមួយវិទ្យាស្ថានស្រាវជ្រាវព្រៃឈើប្រទេសជប៉ុនជាលទ្ធផលយើង ទទួលបាននូវរូបភាពផ្កាយរណប Spot 4 និង Spot 5 ឆ្នាំ២០០៣និង២០០៦ និង រូបភាពផ្កាយរណប Landsat ឆ្នាំ ១៩៩២ ១៩៩៨ ២០០១ និង ២០០២ សម្រាប់ប្រើប្រាស់ក្នុងវិស័យព្រៃឈើនិងគម្រោង REDD នៅកម្ពុជា។

### គ. ការរៀបចំលិខិតបទដ្ឋាន និងឯកសារបច្ចេកទេស

-បានបញ្ជូនសេចក្តីព្រាងប្រកាសស្តីពីការបង្កើតនិងការគ្រប់គ្រងតំបន់ព្រៃសហគមន៍បានចំនួន២៥កន្លែង មានផ្ទៃដីសរុប២៦.៤៥៨ហត ដូចជាខេត្តកំពង់ធំចំនួន១២កន្លែង កោះកុងចំនួន០១កន្លែង មណ្ឌលគិរីចំនួន០៤កន្លែង កំពង់ស្ពឺចំនួន០២កន្លែង ព្រះសីហនុចំនួន០១កន្លែង ស្ទឹងត្រែងចំនួន០២កន្លែង កំពង់ចាមចំនួន០១កន្លែង និងក្រចេះចំនួន០២កន្លែង

-កំពុងរៀបចំសេចក្តីព្រាងប្រកាសស្តីពីការបង្កើតនិងការគ្រប់គ្រងតំបន់ព្រៃសហគមន៍ បានចំនួន៣៦កន្លែងនៅក្នុងខេត្តមួយចំនួនដូចជា រតនគីរីចំនួន១៤កន្លែង ក្រចេះចំនួន០៦កន្លែង កំពតចំនួន០៩កន្លែង កែបចំនួន០១កន្លែង និងតាកែវចំនួន០៦កន្លែង

-បានសម្របសម្រួលចុះពិនិត្យនិងកំណត់តំបន់សក្តានុពលសម្រាប់បង្កើតសហគមន៍ព្រៃឈើបានចំនួន១៧៥កន្លែង លើផ្ទៃដីសរុប ១៣៩.៦៤៥,៣៤ហត ក្នុងខេត្តចំនួន២០

-បានចុះកិច្ចព្រមព្រៀងសហគមន៍ព្រៃឈើចំនួន១០២កន្លែង លើផ្ទៃដី៤០.៣៩៥ហត ក្នុងខេត្តចំនួន១៣

-បានបោះពុម្ពសៀវភៅស្ថិតិសហគមន៍ព្រៃឈើកម្ពុជាឆ្នាំ២០១១ ចំនួន១០.០០០ក្បាល

-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចេញប្រកាសស្តីពីការបង្កើតនិងការគ្រប់គ្រងតំបន់ព្រៃសហគមន៍បានចំនួន៥១កន្លែង លើផ្ទៃដី១៣.៨៩៥ហត ក្នុងខេត្តពោធិសាត់ចំនួន៣៨កន្លែង ខេត្តឧត្តរមានជ័យចំនួន០២កន្លែង ខេត្តកំពតចំនួន០១កន្លែង និងខេត្តតាកែវចំនួន០៦កន្លែង

-បានរៀបចំនូវ÷ ១) សេចក្តីព្រាងច្បាប់ស្តីពីសត្វព្រៃ និងជីវចម្រុះ និង ២) សេចក្តីព្រាងអនុក្រឹត្យស្តីពី ការបង្កើតតំបន់ព្រៃបៃតងជានិច្ចក្នុងទីទំនាបក្នុងខេត្តកំពង់ចាម កំពង់ធំ ព្រះវិហារ និងស្ទឹងត្រែង

-បានប្រជុំឆ្លងផ្ទៃក្នុងរដ្ឋបាលព្រៃឈើនូវ÷ ១)សេចក្តីព្រាងអនុក្រឹត្យស្តីពីសំលៀកបំពាក់ ឯកសណ្ឋាន សញ្ញាសម្គាល់ និងឋានន្តរសក្តិរបស់មន្ត្រីរដ្ឋបាលព្រៃឈើ ២)សេចក្តីព្រាងអនុក្រឹត្យស្តីពី ការបង្កើតមូលនិធិអភិវឌ្ឍន៍ព្រៃឈើជាតិ ៣)

សេចក្តីព្រាងអនុក្រឹត្យស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការអភិវឌ្ឍន៍ព្រៃឈើជាតិ និង៤)ការធ្វើវិសោធនកម្មច្បាប់ស្តីពីព្រៃឈើ

-បានបញ្ជូនទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនូវ÷ ១)សេចក្តីព្រាងអនុក្រឹត្យស្តីពី ការបង្កើតតំបន់ព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិចរុក្ខជាតិនិងសត្វព្រៃ ស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង និង២)សេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតតំបន់ព្រៃការពារសម្រាប់និយតកម្មប្រភពទឹក ការពារដីជម្រាល និងអភិរក្សជីវចម្រុះតំបន់ជួរភ្នំក្រវាញភាគខាងត្បូងខេត្តកោះកុង។

## ឃ- ការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ

-បានបង្ក្រាបបទល្មើសព្រៃឈើ សត្វព្រៃនិងបទល្មើសកាប់រានដីព្រៃទន្ទ្រានដីព្រៃសរុបចំនួន១.៧៩០ករណី កើនឡើងចំនួន២៨៣ករណីធៀបទៅនឹងឆ្នាំ២០១០ ដែលមានចំនួន១.៥០៧ករណី

-វត្ថុតាងបទល្មើសព្រៃឈើ សត្វព្រៃបានចាប់ឃាត់ និងដកហូតរួមមាន÷ ឈើហ៊ុបមូល-ជ្រុងចម្រុះប្រភេទ ៨១៤ម³៧៣៦ ឈើអារ២.៧០៣ម³៧០៤ ឈើគ្រាក់គ្រញូង៥១៩ម³០៥៩ និង៨៥.៩២៦គក្រនិង១៧ដុំ គល់បេង០១គល់ ពកបេង៤៩០គក្រ គល់គ្រញូង០ម³៤២៧ កូនឈើ១.៨១៥ដើម ខ្លឹមច័ន្ទនិក្រស្នា៩៣,១០គក្រ ប្រេងម្រះព្រៅភ្នំ៤២៨គក្រ ជន្លង់ម្រេច៩៩៥ដើម បង្គោលគ្រាក់៦៥ដើម បង្គោលស្វាច់៦៣០ដើម សសរ៤៧ដើម ទ្វារតម្លើងរួច០២វង់ អុស១៥២,៧៥ស្ទែរ ធ្យូង២០.២២១គក្រ ឫស្សី១.២០០ដើម ម្សៅវល្លិ៍រមៀត៥៥គក្រ ជ័រវ៉ុង២១៨គក្រ កំទេចកិប៩,២០គក្រ សត្វព្រៃចម្រុះប្រភេទ៤.១៧៣ក្បាលនិង១.១២៨,១០គ.ក្រ សំណាកសត្វព្រៃ០៧ប្រភេទនិង២២,៧គក្រ រថយន្ត ១.១២២គ្រឿង ត្រាក់ទ័រ០៤គ្រឿង អេស្កាវ៉ាទ័រ០៣គ្រឿង ប៊ុលឌូហ្សែរ០១គ្រឿង គោយន្ត៣០គ្រឿង ម៉ូតូ១៨៥គ្រឿង ទូក-កាណូត៣១គ្រឿង ឡូរី០៧គ្រឿង រ៉ឺម៉កសណ្តោង៦៧គ្រឿង រទេះគោ៣៣គ្រឿង រទេះកង់ឡាន៣៨គ្រឿង រណារយន្ត៦៣គ្រឿងគោ៤៦ក្បាល ម៉ាស៊ីនផ្សេងៗ ៨១គ្រឿង និងសម្ភារៈផ្សេងៗទៀត ព្រមទាំងដីព្រៃ៩៧ហត៥០៩

-បានចុះស្រង់ស្ថិតិដីព្រៃឈើដែលបានកាប់រាន ដុត ឈូសឆាយ និងហ៊ុមព័ទ្ធដីព្រៃឈើដើម្បីវាតយកដីធ្វើកម្មសិទ្ធិសរុបចំនួន១១.៨៣៧ហតនិងដកហូតដីព្រៃ ដែលបានកាប់រានសរុបចំនួន១៥.៨២៧ហ.ត ក្នុងនោះចេញដីកាដកហូតចំនួន១៣ដីកាស្មើនឹង១២.០៧៥ហត និងដកហូតពុំមានដីកាចំនួន៣.៧៥២ហត

-ចុះស្រង់ស្ថិតិរណារយន្តចំនួន២៧៣គ្រឿងនិងដកហូតរណារយន្តបានចំនួន៣៣៧គ្រឿង។

## ង. ការងារដាំដើមឈើនិងស្តារព្រៃឈើ

### *ង.១-ការងារដាំដើមឈើនិងបណ្តុះកូនឈើ*

#### *១-រដ្ឋបាលព្រៃឈើ*

ការដាំដើមឈើនិងបណ្តុះកូនឈើនៅតាមស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើចំនួន០៧របស់អនុវិស័យរដ្ឋបាលព្រៃឈើទទួលបានលទ្ធផលរួមមាន÷ បណ្តុះកូនឈើបានចំនួន១.៩០៥.០០០ដើមគ្រប់ផែនការ និងធ្វើការដាំដុះនៅតាមទីតាំងនីមួយៗបានចំនួន៥៣០ហតលើផែនការចំនួន៨០០ហត។

#### *២-ក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច*

មានក្រុមហ៊ុនចំនួន៣៦ធ្វើ សកម្មភាពការងារឈូសឆាយដីព្រៃបណ្តុះកូនឈើ និងធ្វើការដាំដំណាំកៅស៊ូ និងដាំឈើព្រៃរួមមានលទ្ធផលដូចជា÷ ឈូសឆាយដីព្រៃបានចំនួន ១៦.៥១១ហត បណ្តុះកូនឈើបានចំនួន ២២.២១១.១៥០ដើម និងការដាំកូនឈើនិងកូនកៅស៊ូបានចំនួន៣.៥៩០ហត។

*៣-ផ្នែកឯកជនខ្នាតតូច/គ្រួសារនិងអង្គការក្រៅរដ្ឋាភិបាល* ក្នុងនោះ : បណ្តុះកូនឈើបានចំនួន ៦២៩.០០០ដើម និងដាំដុះបានចំនួន៣១៤,៥០ហត។

#### *៤- ពិធីបុណ្យរុក្ខទិវា ៩ កក្កដា ២០១១*

**-ការប្រារព្ធពិធីបុណ្យរុក្ខទិវាថ្នាក់ជាតិ**

ពិធីបុណ្យរុក្ខទិវាថ្នាក់ជាតិ ៩កក្កដា២០១១ត្រូវបានប្រារព្ធធ្វើនៅតំបន់ភ្នំសែនហាន ភូមិអូរម្កាក់ ឃុំដំបូកខ្ពស់ ស្រុកអង្គរជ័យ ខេត្តកំពត លើផ្ទៃដីទំហំ២៥ហត ក្រោមព្រះរាជាធិបតីភាពរបស់ ព្រះករុណាព្រះបាទ សម្តេចព្រះបរមនាថ នរោត្តមសីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។

**-ការប្រារព្ធពិធីបុណ្យរុក្ខទិវាថ្នាក់ខេត្ត រាជធានី**

ការប្រារព្ធពិធីបុណ្យរុក្ខទិវាត្រូវបានធ្វើនៅថ្នាក់រាជធានី-ខេត្ត ដោយមានការអញ្ជើញចូលរួមពីគណៈអភិបាល ជាអធិបតីភាពដោយបានដាំដុះដូចជា លក្ខណៈជាចម្ការចំនួន៤២,៥ហត ស្មើនឹង៨៥.៧៨៦ដើម និងលក្ខណៈរាយប៉ាយចំនួន៨៥.៧៨៦ដើម។

## ង.២. ការបណ្តុះកូនឈើសម្រាប់ចែកចាយ

*១-រដ្ឋបាលព្រៃឈើ* ក្នុងនោះ បណ្តុះកូនឈើចំនួន៣.៤១៨.៦៧២ដើម ចែកចាយកូនឈើបានចំនួន២.២៤៦.១៩១ដើម និងកូនឈើសល់ស្តុកក្នុងថ្នាលចំនួន ១.៣១៨.៧១៧ដើម។

*២-វិស័យឯកជន* ក្នុងនោះ កូនឈើបណ្តុះលក់ចែកចាយ៣.៨៨៤.០០០ដើម។

## ង.៣. ការអភិវឌ្ឍធនធានសេនេទិចព្រៃឈើ

*១-កូននៃប្រភេទឈើ* Acacia Hybrid ក្នុងនោះ បានដាំសាកល្បង និងដាំកូនស្តុក(Clonestock)នៅទីតាំងថ្នាលបណ្តុះចំនួន៣កន្លែង និងបានដាំជាចម្ការប្រមាណ៣.៥០០ហត នៅតាមបណ្តាស្ថានីយរដ្ឋនិងមានចំនួន៧.០០០ហត នៅតាមចម្ការក្រុមហ៊ុនឯកជន ក្រុមហ៊ុនសម្បទានសេដ្ឋកិច្ចនៅក្នុងខេត្តកំពត ព្រះសីហនុ កោះកុង និងកំពង់ធំ។

*២-កូននៃប្រភេទឈើ* Eucalypt K7 ក្នុងនោះ ដាំសាកល្បងនៅស្ថានីយមានការសហការជាមួយក្រុមហ៊ុន OJI ចំនួនដាំ ជាចម្ការប្រមាណ១.០០០ហត ជាលក្ខណៈគ្រួសារក្នុងខេត្តបន្ទាយមានជ័យនិងបាត់ដំបង និងការរកឃើញថា ដំណុះពូជឈើនេះមានកើតជំងឺរួញស្លឹកនៅខេត្តបន្ទាយមានជ័យ។

*៣-ចម្ការពូជឈើ* ដូចជាចម្ការពូជឈើចំនួន១៤ប្រភេទស្ថិតនៅទីតាំងទាំង១១ខណ្ឌរដ្ឋបាលព្រៃឈើ មានផ្ទៃដីចំនួន១.៨៤៤,៨០ហត។

## ង.៤. ការរៀបចំសួនអាពាហ៍ពិពាហ៍នៅតាមសង្កាត់រដ្ឋបាលព្រៃឈើ:

- សង្កាត់រដ្ឋបាលព្រៃឈើបានរៀបចំសួនអាពាហ៍ពិពាហ៍បានចំនួន២៨ទីតាំងស្មើនឹងផ្ទៃដីទំហំ ៣៤៩,៣៤៥ហត
- សង្កាត់រដ្ឋបាលព្រៃឈើថ្មគ្រែបានទទួលគូសាមីភរិយាទើបរៀបការរួចចំនួន០៣គូ ។

## ច. ការងារសហប្រតិបត្តិការអន្តរជាតិ

-ការងារឥណទានកាបូនព្រៃឈើនិងការប្រែប្រួលអាកាសធាតុ មន្ត្រីរដ្ឋបាលព្រៃឈើខេត្តសៀមរាបចំនួន១០រូប បានទទួលនូវចំណេះដឹងស្តីពីវិធីសាស្ត្រធ្វើសារពើភ័ណ្ឌព្រៃឈើសម្រាប់គម្រោងឥណទានកាបូន

-រៀបចំផែនការសកម្មភាពរយៈពេល៣០ឆ្នាំរបស់គម្រោងឥណទានកាបោនព្រៃឈើនៅខេត្តឧត្តរមានជ័យ និងបានរៀបចំលិខិតឆ្លើយតបជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទស្តីពីករណីសំណើសុំជួយត្រួតពិនិត្យចុងក្រោយលើខ្លឹមសារសេចក្តីព្រាងឯកសារកម្មវិធីការបន្សាំ នឹងការប្រែប្រួលអាកាសធាតុរបស់គណៈកម្មការទន្លេមេគង្គឆ្នាំ២០១១-២០១៥

-គ្រួសារសហគមន៍គម្រូ ១០ គ្រួសារត្រូវបានជ្រើសរើសសម្រាប់ធ្វើឡជីវឧស្ម័ន

-បានរៀបចំសេចក្តីព្រាងលិខិតស្តីពីការផ្តល់ព័ត៌មានអំពីមន្ត្រីទំនាក់ទំនងថ្នាក់ជាតិផ្នែកព្រៃឈើ (National Focal Point for Forest) សម្រាប់សម្របសម្រួលការងារជាមួយ United Nation Forum on Forests (UNFF)

-បច្ចុប្បន្នរដ្ឋបាលព្រៃឈើមានកម្មវិធីនិងគម្រោង REDD ក្នុងនោះ គម្រោងនិងកម្មវិធីចំនួន០៦ បាននឹងកំពុងដំណើរការ ហើយគម្រោងចំនួន០១ នឹងចាប់ដំណើរការក្នុងពេលឆាប់ៗនេះ ថវិកាបឋមសម្រាប់ដំណើរការកម្មវិធីនិងគម្រោង REDD នេះ មានចំនួនប្រហែល២០លានដុល្លារ។

## ឆ. ការអភិវឌ្ឍឧស្សាហកម្ម និងពាណិជ្ជកម្មឈើ

## ឆ.១. ការងារឧស្សាហកម្មឈើ

*១-ការពិនិត្យឯកសារ* ដូចជាបានពិនិត្យនិងផ្តល់មតិលើសំណើសុំបង្កើត សុំពន្យារសុពលភាព រោងម៉ាស៊ីន រោងសិប្បកម្មអារ-កែច្នៃឈើ និងឃ្លាំង ស្តុកផលិតផលឈើគ្រប់ប្រភេទបានចំនួន៣៦សំណើ។

*២-ការងាររៀបចំលិខិតអនុញ្ញាត*

-បានរៀបចំលិខិតផ្ញើជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីសុំការពិនិត្យសម្រេចលើការអនុញ្ញាតបង្កើត ឬពន្យារសុពលភាពរោងចក្រ រោងសិប្បកម្មអារ-កែច្នៃឈើ ការស្នើសុំបន្ថែមគ្រឿងចក្រជូនអតិថិជនបានចំនួន ៣០សំណើ

-រៀបចំលិខិតទៅខណ្ឌរដ្ឋបាលព្រៃឈើកណ្តាលស្តីពី ការចាត់វិធានការផ្អាកសកម្មភាពរោងម៉ាស៊ីន អារ កែច្នៃឈើ របស់ក្រុមហ៊ុន លាង ស្រ៊ុនហេង អ៊ិនវេសមេន

-រៀបចំលិខិតឆ្លើយតបទៅខណ្ឌរដ្ឋបាលព្រៃឈើកំពង់ចាម ស្តីពីការស្នើសុំការឯកភាពក្នុងការផ្តល់ និងបន្តសុពលភាពលិខិតអនុញ្ញាតរោងសិប្បកម្មកែច្នៃប្រភេទតូច និងរោងសន្និធិ

-រៀបចំលិខិតទៅខណ្ឌរដ្ឋបាលព្រៃឈើ រតនគីរី ស្តីពីការដាក់វិធានការពង្រឹងការងារគ្រប់គ្រងដី សម្បទានសេដ្ឋកិច្ច និងរោងម៉ាស៊ីនអារ-កែច្នៃឈើ

-រៀបចំលិខិតជម្រាបទៅខណ្ឌរដ្ឋបាលព្រៃឈើក្រចេះ ស្តីពីការកំណត់អត្រាកែច្នៃឈើហ៊ុបមូល ទៅជាវីនៀរ រួចផលិតជាក្តារបន្ទះរបស់ក្រុមហ៊ុនសុខ សម្រេច ខេត្តក្រចេះ

-រៀបចំលិខិតជម្រាបទៅខណ្ឌរដ្ឋបាលព្រៃឈើស្ទឹងត្រែង ស្តីពីការកំណត់អត្រាកែច្នៃកូនឈើអង្កត់ផ្ចិតទំហំ១៥-៣០ សង់ទីម៉ែត្រ ទៅជាឈើអាររបស់រោងម៉ាស៊ីនអារកែច្នៃឈើក្រុមហ៊ុន G G World ខេត្តស្ទឹងត្រែង

-រៀបចំលិខិតជម្រាបទៅខណ្ឌរដ្ឋបាលព្រៃឈើកណ្តាល កំពង់ចាម ស្ទឹងត្រែង កំពងឆ្នាំង និងមណ្ឌលគីរី លើករណីសំណើសុំគំរូលិខិតអនុញ្ញាតបង្កើតរោងសិប្បកម្មកែច្នៃនិងរោងសន្និធិលក់ចែកចាយផល អនុផលព្រៃឈើ។

*៣-ការងារផ្តល់លិខិតអនុញ្ញាតបង្កើតរោងចក្រ រោងសិប្បកម្មកែច្នៃផលអនុផលព្រៃឈើ*

រដ្ឋបាលព្រៃឈើបានផ្តល់លិខិតស្នើសុំប្រកាសអនុញ្ញាតរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជូនក្រុមហ៊ុនបង្កើតរោងម៉ាស៊ីនអារ-កែច្នៃឈើបានចំនួន ១៤លិខិត ។

*៤-ការងារផ្តល់លិខិតអនុញ្ញាតពន្យារសុពលភាពរោងចក្រនិងរោងសិប្បកម្មកែច្នៃផល អនុផលព្រៃឈើ*

បានទទួលប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អនុញ្ញាតឱ្យក្រុមហ៊ុនពន្យារសុពលភាពរោងម៉ាស៊ីនអារ-កែច្នៃឈើបានចំនួន១០។

*៥-ការងារផ្តល់លិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើនាំចេញ*

បានផ្តល់លិខិតអនុញ្ញាតដឹកជញ្ជូនផលអនុផលព្រៃឈើនាំចេញចំនួន២៣៦ច្បាប់។

## ឆ.២. ការងារពាណិជ្ជកម្មនាំចេញនាំចូល

-បានផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញចំនួន១៦ក្រុមហ៊ុន (MDS, Angkor Plywood, Green Island, Angkor Sugar, DTC, Pheapimex, Great Field Cambodia, Decowood, North-East, Wood Innovation, Grand Land, Di Duk Cambodia, Khen Chan Norak Cambidia, Tong Min, Green Rich Group, Hillco Corporation) មានបរិមាណឈើកែច្នៃសរុបចំនួន២៧.៧៩៩ម$^{៣}$៥៧៩៤ និងឈើចំការ (ចំណិតឈើ) ចំនួន ៦៨.០០០ តោន

-បានពិនិត្យនិងផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចូលចំនួន០២ក្រុមហ៊ុន មានបរិមាណឈើមូលនិងឈើអារចំនួន៣០០ម$^{៣}$

-បានពន្យាសុពលភាពគោលការណ៍អាជ្ញាប័ណ្ណនាំចេញ ចំនួន០៤ក្រុមហ៊ុន (Brightway Furniture, Angkor Sugar, Green Island, Phu Mady)

-បានពិនិត្យនិងផ្តល់ការអនុញ្ញាតពន្យារទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញចំនួន០១ក្រុមហ៊ុន (GG World) មានបរិមាណឈើកែច្នៃចំនួន ២៥០ម$^{៣}$០០៤

-បានពិនិត្យនិងផ្តល់ការអនុញ្ញាតលើសំណើសុំគោលការណ៍អាជ្ញាប័ណ្ណនាំចេញចំនួន១៣ ក្រុមហ៊ុន (ឌីខ្សូវដ,គង់ ហេង តាណៈ,អ៊ុយ សុខុម អ៊ីមផត អិចផត,ងួន តុងហួរ, ឆៃ ជីងហ៊ាង, ខេន ច័ន្ទណូរ៉ែក្សរស្មីសាមគ្គី២០០០,ក្វីផាម៉ា,មាន សុខជាត្រេឌីង, HSIANG CHENG PEANICH, ផេន តាអេង ខេមបូឌា, ថាញ់ ហ៉រ ខេម៉ាប្រ្កា អ៊ិនវេសមេនគ្រុប)

-បានពិនិត្យនិងផ្តល់ការអនុញ្ញាតលើសំណើសុំគោលការណ៍អាជ្ញាប័ណ្ណនាំចូលចំនួន០១ក្រុមហ៊ុន(ហ្គាម៉ាវ៉ាយហាបហ្វា)។

## ជ. ការអភិរក្សសត្វព្រៃ

-ទីជម្រករបស់សត្វព្រៃត្រូវបានការពារនិងអភិរក្សបានល្អ (បង្កើតសម្រាប់អភិរក្សដោយព្រះរាជាណាចក្រកម្ពុជា)

-សត្វព្រៃគ្រប់ប្រភេទត្រូវបានអភិរក្សបានគង់វង់ និងកម្មវិធីអភិឌ្ឍនផ្សារភ្ជាប់នឹងការអភិរក្សត្រូវបានអនុវត្តនៅតាមបណ្តាភូមិក្នុងនិងជុំវិញតំបន់ព្រៃការពារនិងតំបន់អភិរក្ស (តាមរយៈបង្កើតជាតំបន់អេកូទេសចរណ៍)

-ប្រជាពលរដ្ឋយល់ដឹងច្រើនលើកិច្ចការអភិរក្សសត្វព្រៃនិងព្រៃឈើតាមរយៈការអប់រំ ផ្សព្វផ្សាយផ្សេងៗ

-បង្កើតការយកចិត្តទុកដាក់លើការគាំទ្រពីសំណាក់រាជរដ្ឋាភិបាលកម្ពុជាក៏ដូចជា សហគមន៍អភិវឌ្ឍនិងម្ចាស់ជំនួយនានាលើពិភពលោកទាំងថវិកានិងបច្ចេកទេស

-ក្រុមការងារអនុវត្តគម្រោង បានធ្វើការកត់ត្រានូវក្រុមប្រភេទសត្វស្លាបជិតផុតពូជប្រភេទកម្រ និងប្រភេទមានដោយបង្គួរ

-ទិន្នន័យស្វាក្តាមមេ-បាពូជ និងកូនស្វាក្តាមនៅតាមកសិដ្ឋាននីមួយៗមានចំនួនសរុប៨៥.៩៤៦ក្បាល និងបាននាំចេញស្វាជំទង់ចំនួន៦.១៥២ក្បាល។

## ឈ- ការស្រាវជ្រាវនិងបណ្តុះបណ្តាល

-*ការងារបណ្តុះបណ្តាល* ដូចជាបានផ្តល់វគ្គបណ្តុះបណ្តាលចំនួន២៥វគ្គ ដោយមានសិក្ខាកាមចូលរួមចំនួន ៨៣០នាក់ ។

### *-ការសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍*

វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើ-សត្វព្រៃ បាននិងកំពុងអនុវត្តគម្រោងសហប្រតិបត្តិការចំនួន ១៦ និងបានបើកវគ្គបណ្តុះបណ្តាលចំនួន២២វគ្គ មានអ្នកចូលរួមចំនួន៧៧៥នាក់ ក្នុងនោះមានមន្ត្រីរដ្ឋបាលព្រៃឈើចូលរួមចំនួន ២៤១នាក់ សមាជិកសហគមន៍និងប្រជាជនចំនួន៥៣៤នាក់។

### *-សមភាគីសហការជាមួយដៃគូអភិវឌ្ឍន៍នានា*

វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើ-សត្វព្រៃ បាននិងកំពុងចូលរួមជាសមភាគីជាមួយដៃគូអភិវឌ្ឍន៍នានាចំនួន០៣។

### *-ការងារស្រាវជ្រាវដោយប្រើប្រាស់ថវិកាជាតិ*

ការងារស្រាវជ្រាវគម្រោងស្តារព្រៃឈើឡើងវិញ ក្រោយអាជីវកម្មនៅតំបន់បាក់ស្នាសម្រាប់ឆ្នាំ២០១១ លទ្ធផលសម្រេចបាន÷

-ប្រមូលទិញគ្រាប់ពូជបេងនិងបណ្តុះកូនឈើបានចំនួន៥.០០០ដើម និងដាំកូនឈើបានចំនួន ០៣ហត

-ផ្តល់វគ្គបណ្តុះបណ្តាលស្តីពី រុក្ខវប្បកម្មដល់មន្ត្រីរដ្ឋបាលព្រៃឈើមូលដ្ឋាន និងសហគមន៍ព្រៃឈើចំនួន ០១វគ្គដែលមានអ្នកចូលរួមចំនួន ៧៥នាក់ (ស្ត្រី០៥នាក់) នៅទីរួមខេត្តសៀមរាប។

### *-ការងារលើកគម្រោងបណ្តុះបណ្តាលនិងស្រាវជ្រាវ*

វិទ្យាស្ថានស្រាវជ្រាវ បាននិងកំពុងរៀបចំសំណើគម្រោងចំនួន០៤ ក្នុងនោះ÷ កំពុងរៀបចំគម្រោងសំណើការសិក្សាស្រាវជ្រាវបច្ចេកទេសស្តារព្រៃរេចរឹល គម្រោងរៀបចំចងក្រងឯកសារនិងព្រឹត្តប័ត្រស្រាវជ្រាវព្រៃឈើកម្ពុជា រៀបចំគម្រោងសំណើសាងសង់អគារស្រាវជ្រាវព្រៃឈើនិងរៀបចំគម្រោងសំណើប្រមូល និងសំណាកឈើសម្រាប់ដាក់តាំងបង្ហាញ។

## ញ. ការសង្គ្រោះសត្វព្រៃ

ឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅកំពុងចិញ្ចឹម ថែរក្សាសត្វព្រៃគ្រប់ប្រភេទ កសាងហេដ្ឋារចនាសម្ព័ន្ធឧទ្យានសួនសត្វ ដើម្បីសង្គ្រោះ និងអភិរក្សសត្វព្រៃក្រៅតំបន់។

## ជ. ការងាយស្រួល

-មានការចូលរួម និងគាំទ្រយ៉ាងសកម្មពីកងយោធពលខេមរភូមិន្ទនគរបាល អាជ្ញាធរដែនដី អង្គភាពពាក់ព័ន្ធ អង្គការអន្តរជាតិ ដែលជាដៃគូអភិវឌ្ឍន៍ និងពីប្រជាពលរដ្ឋគ្រប់ទិសទី

-មានច្បាប់ស្តីពីព្រៃឈើ គោលនយោបាយ និងយុទ្ធសាស្ត្រស្តីពីព្រៃឈើច្បាស់លាស់ និងបទបញ្ញាជាច្រើនរបស់រាជរដ្ឋាភិបាលសម្រាប់ជាមូលដ្ឋានពង្រឹងការគ្រប់គ្រង និងអនុវត្តច្បាប់ក្នុងវិស័យព្រៃឈើទូទាំងប្រទេស

-មានការផ្តួចផ្តើមចង្អុលបង្ហាញ និងគាំទ្រយ៉ាងពេញទំហឹងពីថ្នាក់ដឹកនាំជាតិគ្រប់ស្ថាប័ន ជាពិសេសពីសំណាក់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី**នៃព្រះរាជាណាចក្រកម្ពុជាផ្ទាល់ និងឯកឧត្តមរដ្ឋមន្ត្រីថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-មន្ត្រីរដ្ឋបាលព្រៃឈើភាគច្រើនមានសមត្ថភាពជំនាញ ស្មារតីទទួលខុសត្រូវ និងការប្តេជ្ញាចិត្តខ្ពស់ក្នុងការបំពេញតួនាទីភារកិច្ចរបស់ខ្លួនឱ្យសម្រេចជោគជ័យ

-មានក្រុមការងារបច្ចេកទេសស្តីពី កំណែទម្រង់ព្រៃឈើនិងបរិស្ថានជាយន្តការសម្រាប់សម្របសម្រួលផ្តល់ជំនួយសហប្រតិបត្តិការ និងជាវេទិកាពិគ្រោះយោបល់របស់គ្រប់ភាគីពាក់ព័ន្ធសំខាន់ៗ ផ្នែករដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល...។

## ឋ. ការលំបាកនិងភាពប្រឈម

ទន្ទឹមនឹងវឌ្ឍនភាពដែលរដ្ឋបាលព្រៃឈើសម្រេចបាន ក៏មានការលំបាកនិងបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម ÷

-ខ្វះខាតធនធានមនុស្សនិងការលើកទឹកចិត្តដល់មន្ត្រីរដ្ឋបាលព្រៃឈើឱ្យទៅបម្រើការងារនៅតំបន់ដាច់ស្រយាល

-ខ្វះខាតថវិកាសម្ភារៈនិងមធ្យោបាយសម្រាប់ដំណើរការវិស័យព្រៃឈើឱ្យមានប្រសិទ្ធភាព និងទាន់ពេលវេលា

-មន្ត្រីរាជការមួយចំនួនខ្វះសមត្ថភាព មិនទាន់មានវិន័យនិងការប្តេជ្ញាចិត្តខ្ពស់ក្នុងការបំពេញភារកិច្ចនៅឡើយ

-ជនប្រព្រឹត្តបទល្មើសតែងតែផ្លាស់ប្តូរវិធីសាស្ត្រក្នុងការប្រមូលផលឈើ ដឹកជញ្ជូន និងកាប់រានដីព្រៃឈើយកធ្វើជាកម្មសិទ្ធិក្រោមរូបភាពផ្សេងៗ

-កិច្ចសហការនិងការចូលរួមរបស់អាជ្ញាធរមូលដ្ឋាននិងស្ថាប័នពាក់ព័ន្ធនៅមានកម្រិត ជាពិសេសក្នុងការត្រួតពិនិត្យបង្ក្រាបបទល្មើសព្រៃឈើ និងការកំណត់ព្រំប្រទល់ដែនដីព្រៃឈើតែងជួបប្រទះការលំបាក យឺតយ៉ាវ និងមានវិវាទ ជាមួយជនល្មើស ព្រមទាំងមានការលួចវាយបំផ្លាញបង្គោលព្រំដែលបានបោះរួចទៀតផង

-ប្រជាជនមូលដ្ឋានដែលរស់នៅក្នុងនិងជិតតំបន់ព្រៃឈើនៅតែពឹងអាស្រ័យខ្លាំងលើព្រៃឈើ ហើយការគ្រប់គ្រងជនចំណាកស្រុកនៅមានការធូររលុងពីសំណាក់អាជ្ញាធរមូលដ្ឋាន ដែលជាសម្ពាធធ្ងន់ធ្ងរចំពោះធនធានព្រៃឈើ។

### ៩.៦.២. វាយតម្លៃនិងសន្និដ្ឋាន

-អន្តរាគមន៍ទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរាជរដ្ឋាភិបាល ដើម្បីផ្តល់នូវកញ្ចប់ថវិកា សម្ភារៈ មធ្យោបាយសម្រាប់ដំណើរការការងារនៅតាមខណ្ឌ-ផ្នែករដ្ឋបាលព្រៃឈើតាមអណត្តិការងារនិងធនធានមនុស្សបន្ថែមឱ្យបានសមស្របតាមតម្រូវការចាំបាច់នៃការងាររបស់រដ្ឋបាលព្រៃឈើមូលដ្ឋាន

-អន្តរាគមន៍ទៅក្រសួងមហាផ្ទៃឱ្យណែនាំដល់អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ពង្រឹងការគ្រប់គ្រងស្ថិតិប្រជាជន និងការសាងសង់លំនៅដ្ឋានអនាធិបតេយ្យរបស់ជនចំណាកស្រុកនៅក្នុងតំបន់ព្រៃឈើ។

### ៩.៦.៣. វិធានការ

ដើម្បីសម្រេចគោលនយោបាយគ្រប់គ្រង និងអភិវឌ្ឍព្រៃឈើដោយចីរភាពរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់ឆ្នាំ ២០១២នេះ រដ្ឋបាលព្រៃឈើបានលើកវិធានការ ងផែនការសកម្មភាពសម្រាប់អនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ដូចខាងក្រោម÷

-បន្តជំរុញកំណត់ព្រំប្រទល់ដែនព្រៃឈើ ធ្វើចំណាត់ថ្នាក់ និងចុះបញ្ជិកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ឱ្យមានការចូលរួមប្រកបដោយប្រសិទ្ធភាពពីគ្រប់ភាគីពាក់ព័ន្ធ ហើយត្រូវសម្រេចឱ្យបានប្រវែង១.០០០ គីឡូម៉ែត្រ

-បន្តរៀបចំ អនុវត្ត និងធ្វើបច្ចុប្បន្នភាពផែនការសកម្មភាពគ្រប់គ្រងព្រៃឈើ នៅគ្រប់កម្រិតនៃរដ្ឋបាលព្រៃឈើ ដោយធ្វើការសិក្សាសារពើភ័ណ្ឌវាយតម្លៃធនធានព្រៃឈើ និងរៀបចំព្រៃគុបដេញថ្លៃសម្រាប់ផ្គត់ផ្គង់តម្រូវការប្រើប្រាស់ ផល អនុផលព្រៃឈើក្នុងស្រុក រួមទាំងព្រៃគុបក្នុងតំបន់អាងទិនប់វារីអគ្គិសនីនានាដូចជា វារីអគ្គិសនី ឫស្សីជ្រុំ សេសាន ២ តាតៃ...។ល។

-បន្តកំណត់តំបន់ព្រៃឈើរេចរឹល ដើម្បីធ្វើការស្តារព្រៃឈើឡើងវិញឱ្យក្លាយជាតំបន់ព្រៃឈើមានតម្លៃពាណិជ្ជកម្ម ដោយធ្វើការដាំដុះប្រភេទឈើប្រណិតមានតម្លៃ និងថែរក្សា ការពារចម្ការព្រៃពូជ និងប្រមូលពូជឈើ

## ៥.៧- ការងារជលផល ( ឧបសម្ព័ន្ធទី ១៤)

### ៥.៧.១- លទ្ធផល

### ក. ស្ថិតិជលផល÷

- ស្ថិតិផលនេសាទទឹកសាបសរុបមានចំនួន៥០៩.០០០តោន ក្នុងនោះមានដូចខាងក្រោម÷
  - អាជីវកម្មឡូត៍នេសាទ-នេសាទសិប្បកម្មរដូវនេសាទឆ្នាំ២០១១-២០១២ អនុវត្តបាន១០០.០០០តោន ស្មើនឹង ៧៦,៩២% នៃផែនការ១៣០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាថយចុះ៣០.០០០តោន
  - នេសាទគ្រួសារក្នុងដែននេសាទឆ្នាំ២០១២ អនុវត្តបាន ២៦៩.០០០តោន ស្មើនឹង ១៤៩,៤៤% នៃផែនការ ១៨០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាកើនឡើង ៨៩.០០០តោន
  - នេសាទគ្រួសារក្នុងវាលស្រែឆ្នាំ២០១២ អនុវត្តបាន ១៤០.០០០តោន ស្មើនឹង ៩៣,៣៣% នៃផែនការ ១៥០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាកើនឡើង៥.០០០តោន ។

- ស្ថិតិផលនេសាទសមុទ្រការធ្វើអាជីវកម្មនេសាទសមុទ្រឆ្នាំ២០១២ អនុវត្តបាន៩៩.០០០តោន ស្មើនឹង១១០%នៃផែនការ៩០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាកើនឡើង៨.០០០តោន។

### ខ. ការអភិវឌ្ឍវារីវប្បកម្ម ÷

- ការចិញ្ចឹមត្រីអនុវត្តបានចំនួន៧៤.០០០តោន ប្រៀបធៀបឆ្នាំកន្លងទៅកើនឡើង២.០០០តោន
- កន្លែងភ្ញាស់ត្រី ២៩៦កន្លែង ដែលក្នុងនោះមាន ២៨៣កន្លែង ជារបស់ប្រជាជនតាមរយៈការផ្តល់បច្ចេកទេស
- ការផលិតកូនត្រីពូជបានចំនួន ១៤០.០០០.០០០កូន កើនលើសឆ្នាំមុន១០.០០០.០០០កូន។ បានបណ្តុះបណ្តាលអ្នកបច្ចេកទេសចិញ្ចឹម ភ្ញាស់ត្រីនិងបង្កងបានចំនួន៣៥០នាក់ ក្នុងនោះមានកសិករ១៥៤នាក់ជាគ្រូបង្គោលនិងជាអ្នកផ្សព្វផ្សាយនៅតាមមូលដ្ឋាន។ មានប្រជាពលរដ្ឋប្រមាណ៥៥.០០០គ្រួសារ បាន ចូលរួមក្នុងសកម្មភាពចិញ្ចឹមត្រី ដោយបានដាក់ចិញ្ចឹមប្រភេទកូនតត្រីឆ្ពិន កាហែ ប្រា ព្រលូង កន្ធរ ក្រាញ់ បង្កង ទីឡាព្យា កាបស និងត្រីកាបសាមញ្ញជាដើម។ល។ ហើយអាចរកប្រាក់ចំណូលគ្រួសារបានយ៉ាងច្រើន។

### គ. ការកែច្នៃផលនេសាទ

- ការកែច្នៃផលនេសាទទឹកសាបឆ្នាំ២០១២ អនុវត្តបាន៨៥.០០០តោន ស្មើ៥៦,៦៧% នៃផែនការ ១៥០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាកើនឡើង៤០.០០០តោន
- ការកែច្នៃផលនេសាទសមុទ្រឆ្នាំ២០១២ អនុវត្តបាន៦.២០០តោន ស្មើ១០៣,៣៣%នៃផែនការ៦.០០០ តោន ប្រៀបធៀបរយៈពេលដូចគ្នាកើនឡើង១០០តោន
- ការផលិតទឹកត្រីឆ្នាំ២០១២ អនុវត្តបាន៥០.០០០.០០០លីត្រ ស្មើ៨៣,៣៣% នៃផែនការ៦០.០០០.០០០ លីត្រ ប្រៀបធៀបរយៈពេលដូចគ្នាកើនឡើង១០.០០០.០០០លីត្រ ។

### ឃ. ការនាំចេញផលនេសាទ

ការនាំចេញផលនេសាទស្រស់និងកែច្នៃគ្រប់ប្រភេទឆ្នាំ២០១២ អនុវត្តបាន២១.០០០តោន ស្មើ៧០% នៃផែនការ ៣០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាថយចុះ៩.០០០តោន។

## ង. ការអភិវឌ្ឍន៍សហគមន៍នេសាទ

ក្រោយកំណែទម្រង់ស៊ីជម្រៅលើវិស័យជលផលឆ្នាំ២០១២ សហគមន៍នេសាទចំនួន៤៧ ត្រូវបានបង្កើតឡើងបន្ថែមទៀត ពង្រីកសហគមន៍ចំនួន៣៣ ដូច្នេះសហគមន៍នេសាទសរុបទាំងអស់ចំនួន៥១៦បានគ្របដណ្តប់ស្ទើរគ្រប់កន្លែងសំខាន់ៗនៃដែននេសាទទូទាំងប្រទេសអស់ហើយ។ ក្នុងចំណោម៥១៦សហគមន៍នេសាទដែលបានបង្កើតឡើង មានសហគមន៍ នេសាទចំនួន៣២៨បានចុះបញ្ជីទទួលស្គាល់ជាផ្លូវការនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងសហគមន៍ នេសាទចំនួន៣២ បានរៀបចំសំណុំឯកសារស្នើសុំចុះបញ្ជីនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយដែរ។

ដោយឡែក ការបង្កើតធនាគារក្តាមមានចំនួន៣១កន្លែងស្មើនឹង៩២បែ ដែលក្នុងឆ្នាំ២០១២នេះ បានលែងមេក្តាមពងចំនួន៧.៥៥៦គក្រ ស្មើនឹង៥៨.១១៨ក្បាល។ បើគិតពីឆ្នាំ២០០៨មកដល់បច្ចុប្បន្ន គឺបានលែងមេក្តាមចំនួន ២៩.៤០៦គក្រ ស្មើនឹង២០៦.០៩២ក្បាល ដែលបានផ្តល់កូនក្តាមចំនួនប្រមាណ២០៧.១៦៣លានក្បាលចូលទៅក្នុងសមុទ្រវិញ។ សកម្មភាពនេះតាមការស្រាវជ្រាវរបស់វិទ្យាស្ថានឃើញថា បានធ្វើឲ្យផលក្តាមសេះមានកំណើនប្រមាណ៤ដង បើប្រៀបធៀបមុនពេលបង្កើតធនាគារក្តាម។ ដោយឡែក សហគមន៍នេសាទដែលមានដែននេសាទនៅតាមតំបន់ ព្រំដែនប្រទេសវៀតណាមបាននិងកំពុងរៀបចំផែនការដាក់របាំងធ្នួសចាប់ត្រី ដើម្បីរកប្រាក់ចំណូលអភិវឌ្ឍន៍សហគមន៍ផងដែរ។

## ច. ការអភិរក្សធនធានជលផល

ក្រោយការកែទម្រង់ស៊ីជម្រៅវិស័យជលផលដោយរំសាយឡូត៍នេសាទទាំងអស់ទូទាំងប្រទេស មានកន្លែងអភិរក្សជលផលថ្មីចំនួន៥០កន្លែងត្រូវបានបង្កើតឡើង ដែលមានផ្ទៃសរុប៩៧.៥០៣ហត។ រហូតមកដល់សព្វថ្ងៃនេះ កន្លែងអភិរក្សជលផលទាំងនេះត្រូវបានបោះបង្គោលព្រំប្រទល់បណ្តោះអាសន្ន ដោយប្រើបង្គោលឈើចំនួនជាង៦០០បង្គោល និងរៀបចំស្នាក់ការល្បាតចំនួន១៤កន្លែង ព្រមទាំងបានយាមល្បាតជាប្រចាំ។ សកម្មភាពអភិរក្សជលផលផ្សេងៗទៀតមានដូចខាងក្រោម÷

- បង្កើតតំបន់អភិរក្សនៅតាមសហគមន៍នេសាទសរុបបានចំនួន៣៥៨កន្លែង
- អភិរក្សថ្កាថ្ម ស្មៅសមុទ្រចំនួន៣.៨៣១ហតនៅតាមតំបន់ឆ្នេរ
- បាននិងកំពុងដំណើរការបង្កើតតំបន់គ្រប់គ្រងជលផលសមុទ្រជុំវិញកោះរុងនិងកោះរុងសន្លឹម ដែលមាន ទំហំសរុបចំនួន៣៤០គីឡូម៉ែត្រក្រឡា
- ដាំព្រៃលិចទឹកនិងព្រៃកោងកាងបានចំនួន១០៧ហត
- រៀបចំអន្លង់ត្រីមេពូជនៅតាមដងទន្លេមេគង្គបានចំនួន១៧កន្លែង នៅតំបន់មេគង្គលើ
- បានលែងកូនត្រីនិងកូនបង្កងចំនួន៥.០០០.០០០ក្បាល ទៅក្នុងបឹងធម្មជាតិ
- បន្តការអភិរក្សប្រភេទធនធានជលផល ដូចជា ផ្សោតទន្លេមេគង្គ កន្ធាយក្បាលកង្កែប អណ្តើកហ្លួងអណ្តើកសមុទ្រ សេះសមុទ្រ ក្រពើត្រី ត្រីរាជ និងត្រីគល់រាំង ដែលធ្វើឲ្យចំនួនកើនឡើងប្រមាណ៥-១០% ជារៀងរាល់ឆ្នាំ។

## ឆ. ការការពារប្រភពធនធានជលផល

ក្នុងឆ្នាំ២០១២នេះ មន្ត្រីរដ្ឋបាលជលផលគ្រប់ផ្នែកបានសហការ ជាមួយអាជ្ញាធរដែនដីនិងសមត្ថកិច្ចពាក់ព័ន្ធខិតខំបំពេញការងារយ៉ាងសកម្ម ទោះបីខ្វះកម្លាំង មធ្យោបាយធ្វើដំណើរនិងថវិកាក៏ដោយ ជាពិសេសយកចិត្តទុកដាក់ការពារកន្លែងអភិរក្សជលផល មិនឲ្យមានការលួចចូលធ្វើនេសាទអាណាធិបតេយ្យឡើយ។ ប៉ុន្តែទោះជាខិតខំយ៉ាងណាក៏ដោយជាមួយដែននេសាទដ៏ធំធេងនោះ ក៏មិនទាន់អាចទប់ស្កាត់នូវបទល្មើសបាន១០០%នៅឡើយ។

លទ្ធផលជាក់ស្តែងគឺបង្ក្រាបបទល្មើសបាន៥.៣០៧ករណីប្រៀបធៀបឆ្នាំមុនកើនឡើង៨៣៨ករណីក្នុងនោះ÷

- បំផ្លាញចោលវត្ថុតាង: ៤.៩៣៨ករណី
- ពិន័យអន្តរការណ៍: ២០៦ករណី
- បញ្ជូនទៅតុលាការ: ១៦៣ករណី
- ដាក់ពន្ធនាគារ: ១៤២នាក់

- ប្រាក់ពីពិន័យនិងលក់វត្ថុតាងមានចំនួន១៤០.៧៥០.០០០រៀល។

### ជ. ការងារផ្សព្វផ្សាយ

ចំពោះការផលិតឯកសារនិងការផ្សព្វផ្សាយ រដ្ឋបាលជលផលបានខិតខំជំរុញដល់រាជធានី ខេត្តទាំងអស់ ឱ្យដាក់តាំងរូបភាពប៉ាណូរូបភាពផ្សព្វផ្សាយនៅតាមទីប្រជុំជននានា អំពីការហាមឃាត់ប្រព្រឹត្តបទល្មើសនេសាទ និងការចូលរួមអភិរក្សប្រភពធនធានជលផល។ ក្រៅពីនេះ មានបើកវគ្គបណ្តុះបណ្តាលផ្សព្វផ្សាយដល់ប្រជាពលរដ្ឋដល់សមាជិកសហគមន៍ អាជ្ញាធរដែនដី និងកងកំលាំងប្រដាប់អាវុធលើប្រធានបទការអភិវឌ្ឍន៍វារីវប្បកម្ម ការអភិរក្សធនធានជលផល ការកែ ច្នៃក្រោយការប្រមូលផល ។ល។

ដោយឡែកការផ្សព្វផ្សាយច្បាប់ស្តីពី ជលផលនិងលិខិតបទដ្ឋានគតិយុទ្ធពាក់ព័ន្ធអនុវត្តបានចំនួន ៧១៧វគ្គ ដែលមានអ្នកពាក់ព័ន្ធចូលរួមចំនួន៣៩.៥៥៥នាក់ ក្នុងនោះស្រីចំនួន១៧.១១៨នាក់ ។

### ឈ. ការងារស្រាវជ្រាវនិងសហប្រតិបត្តិការអន្តរជាតិ

ការងារស្រាវជ្រាវលើប្រភពធនធានជលផលទាំងទឹកសាបនិងសមុទ្របានដំណើរការល្អ ដោយបានសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍនានាដូចជា DANIDA, JICA, MRC, FAO, AIDA, World Fish Center ជាដើម។ល។ ដោយមានវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍនេសាទទឹកសាប និងសមុទ្រជាអង្គភាពអនុវត្តផ្ទាល់។ ចំពោះលទ្ធផលស្រាវជ្រាវត្រូវបានបោះពុម្ពផ្សាយសៀវភៅជាច្រើនពាន់ក្បាលនិងប៉ុស្ទ័រជាច្រើនម៉ឺនសន្លឹក។

### ញ. ការងាររៀបចំច្បាប់និងលិខិតបទដ្ឋាននានា

ក្នុងឆ្នាំ២០១២នេះ មានលិខិតបទដ្ឋានក្រោមច្បាប់ចំនួន៣៦ ត្រូវបានរៀបចំឡើង ក្នុងនោះ មួយចំនួនត្រូវបានអនុម័ត និងមួយចំនួនទៀតនៅជាសេចក្តីព្រាង។

### ដ. ការងារហិរញ្ញវត្ថុ

ប្រាក់ចំណូលពីគ្រប់ខេត្ត ក្រុងប្រមូលបាន៤.១៨៦.៤៥៧.៥៧៥ រៀល ក្នុងនោះមានប្រាក់ចំណូលពី÷

| | |
|---|---|
| - ថ្លៃឈ្នួលឡូត៍នេសាទ | ៣.១៤៩.៨៧៥.០០០រៀល |
| - ថ្លៃឈ្នួលដែននេសាទសមុទ្រ | ៤៥៦.៦៤៩.៦០០រៀល |
| - ប្រាក់ពិន័យ និងលក់វត្ថុតាង | ១៤០.៧៥០.០០០រៀល |
| - ចំណូលផ្សេងៗ (ឈ្នួលអាគារ រោងចក្រ...) | ៣៩៩.១៨២.៩៧៥រៀល |

### ៥.៧.២. វាយតម្លៃនិងសន្និដ្ឋាន

ការគ្រប់គ្រងនិងអភិវឌ្ឍន៍វិស័យជលផលរយៈពេលកន្លងមកនេះ មានការប្រែប្រួលរីកចម្រើនគួរឱ្យកត់សម្គាល់÷

- ការសាងសង់វិទ្យាស្ថានស្រាវជ្រាវនិងនិងមជ្ឈមណ្ឌលស្រាជ្រាវនានា ជំរុញការស្រាវជ្រាវនិងអភិវឌ្ឍវារីវប្បកម្ម ដែលឈានដល់ការភ្ញាស់ត្រីប្រានិងបង្កងជាប្រវត្តិសាស្ត្រ

- ជំរុញបង្កើតស្រះជម្រកត្រីសហគមន៍បានចំនួន ៧៣៨កន្លែង តាមអនុសាសន៍ដ៏ថ្លៃថ្លារបស់ **សម្តេចតេជោ** បង្កើត អភិវឌ្ឍសហគមន៍នេសាទបានចំនួន៥១៦សហគមន៍ និងបង្កើតធនាគារក្តាមចំនួន៣១កន្លែងនៅតំបន់ឆ្នេរ កំណត់តំបន់ ដើម្បីអភិរក្សធនធានជលផលរួមមានទាំងផ្កាថ្ម ស្មៅសមុទ្រ ព្រៃលិចទឹកនិងព្រៃកោងកាងជាដើម

- បានចុះបង្ក្រាបបទល្មើសជលផលទូទាំងប្រទេស តាមស្មារតីបទបញ្ជាលេខ០១បប របស់រាជរដ្ឋាភិបាល ដែលទទួលបានជោគជ័យគួរជាទីមោទនៈ ប៉ុន្តែទោះបីមានការអនុវត្តយ៉ាងច្រើនយ៉ាងណាក្តី ក៏នៅមានការងារជាច្រើនទៀត ដែលត្រូវបំពេញជាបន្ទាន់ ជាពិសេសការបង្ក្រាបបទល្មើសនេសាទ ដែលតែងតែកើតមានឡើងជាបន្តបន្ទាប់នៅក្នុងខេត្តមួយចំនួន។ ការបង្ក្រាបបទល្មើសនេះគឺជាការយកចិត្តទុកដាក់យ៉ាងខ្លាំងពីមន្ត្រីរដ្ឋបាលជលផលគ្រប់ជាន់ថ្នាក់ ដោយបង្ក្រាបបានជាច្រើនពាន់ករណី ដែលអាចនិយាយបានថា បង្ក្រាបបានមួយភាគធំហើយ ក៏ប៉ុន្តែនៅមានមួយផ្នែកតូចទៀត ដែលទាមទារការខិតខំប្រឹងប្រែង ដោយប្រើកម្លាំងសរុបបន្ថែមទៀត។

### ៥.៧.៣. វិធានការ

ដើម្បីគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព រដ្ឋបាលជលផលបានលើកផែនការសម្រាប់អនុវត្តបន្ត ដូចខាងក្រោម÷

- ខិតខំបន្តអនុវត្តអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ** ***"ធ្វើឱ្យទីណាមានទឹក ទីនោះមានត្រីឡើងវិញ"***

- ពង្រឹងសមត្ថភាពមន្ត្រីរដ្ឋបាលជលផលឱ្យកាន់តែប្រសើរឡើង តាមរយៈការរៀបចំវគ្គបណ្តុះបណ្តាលជំនាញរយៈពេលខ្លី និងវែងទាំងក្នុងនិងក្រៅប្រទេស ដោយរួមទាំងអ្នកនេសាទ សហគមន៍នេសាទ និងអ្នកចិញ្ចឹមត្រីផងដែរ ដើម្បីធានានិរន្តភាពធនធានជលផល

- បន្តការងារសហប្រតិបត្តិការជាមួយអង្គការជាតិនិងអន្តរជាតិដើម្បីគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តភាព

- បន្តជំរុញការត្រួតពិនិត្យនិងបង្ក្រាបបទល្មើសជលផលនៅទូទាំងប្រទេស

- រៀបចំបោះបង្គោលបេតុងតាមព្រំប្រទល់កន្លែងអភិរក្សទាំង៥០កន្លែង និងបង្កើតស្លាក់ការល្បាតនៅទីតាំងសំខាន់ៗចំនួន៤៣កន្លែង

- បន្តពង្រឹងសមត្ថភាពសហគមន៍នេសាទនៅទូទាំងប្រទេស ដោយរៀបចំសហគមន៍គំរូគ្មានបទល្មើស និងម្រេបសម្រួលការដាក់របាំងធ្នូស សហគមន៍នេសាទតាមព្រំដែន

- រៀបចំផ្លូវភ្លើងនិងប៉មយាមសម្រាប់ត្រួតពិនិត្យភ្លើងឆេះព្រៃ

- បន្តបង្កើត និងពង្រឹងសហគមន៍ស្រះជម្រកត្រីបន្ថែមទៀតឱ្យបានគ្រប់ឃុំ

- បន្តរៀបចំទិវាមច្ឆជាតិ១កក្កដារៀងរាល់ឆ្នាំ សំដៅបង្កើនការយល់ដឹងពីអំពី សារៈសំខាន់នៃធនធានជលផលដោយលែងកូនបង្កងឱ្យបានច្រើនជាអតិបរិមា (៦-១០លានក្បាល)

### ៥.៧.៤. សំណូមពរ

ដើម្បីគ្រប់គ្រងវិស័យជលផលឱ្យមានប្រសិទ្ធភាពតាមកំណែទម្រង់ស៊ីជម្រៅវិស័យជលផល រដ្ឋបាលជលផលសំណូមពរដូចខាងក្រោម÷

- ស្នើសុំជ្រើសរើសមន្ត្រីបច្ចេកទេសជលផលបន្ថែម ដើម្បីជំនួសមន្ត្រីចូលនិវត្តន៍

- ស្នើបង្កើនថវិកា សម្ភារៈ ប្រេងឥន្ធនៈ សម្រាប់ពង្រឹង ការងារសហគមន៍នេសាទ ការអភិវឌ្ឍន៍វារីវប្បកម្ម ការសិក្សាស្រាវជ្រាវ ការអភិរក្ស ការផ្សព្វផ្សាយ និងការបង្ក្រាបបទល្មើសជលផលឱ្យមានប្រសិទ្ធភាព

- សំណើសុំថវិកាសម្រាប់សាងសង់អាគារវិទ្យាស្ថានស្រាវជ្រាវជលផលសមុទ្រ អធិការដ្ឋាន ខណ្ឌ និងផ្នែករដ្ឋបាលជលផល និងសម្រាប់ទិញនាវាត្រួតពិនិត្យបង្ក្រាបបទល្មើសជលផលនៅដែនសមុទ្រ។

## ៥.៨- ការងារសេវាកម្មនិងការគាំទ្រ

### ៥.៨.១- ការងារគោលនយោបាយផែនការនិងវិនិយោគ

លទ្ធផលសម្រេចបានឆ្នាំ២០១២-២០១៣ ក្នុងក្របខ័ណ្ឌខាងលើជាគន្លឹះសំខាន់នៃការងារដំណោះស្រាយការលំបាក ដែលរាំងស្ទះនានា ហើយទាមទារឱ្យមានការត្រួតពិនិត្យតាមដាននិងវាយតម្លៃច្បាស់លាស់ ទើបមានមូលដ្ឋានគ្រឹះដើម្បីធ្វើការសម្រេចចិត្តកែលម្អ ក្នុងការគ្រប់គ្រងនិងដឹកនាំបានល្អ។ សភាពការណ៍ និងលទ្ធផលតាមផ្នែកនីមួយៗ នៃការងារបម្រើសេវាកម្មនេះ មានដូចខាងក្រោម ÷

### ក- ការងារផែនការគោលនយោបាយ

### ក.១- ការងារគោលនយោបាយយុទ្ធសាស្ត្រ

-បន្តតាមដានការអនុវត្តនិងរបាយការណ៍ជឿនលឿន នៃលទ្ធផលសម្រេចបាន ចំពោះការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ សំដៅចូលរួមជំរុញកំណើនសេដ្ឋកិច្ចជាតិ និងពន្លឿនការកាត់បន្ថយភាពក្រីក្រតាមរយៈការលើកកំពស់ការអភិវឌ្ឍវិស័យកសិកម្ម

-រៀបចំផែនការសកម្មភាព ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០០៩-២០១៣

-ត្រៀមរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០១៤-២០១៨

-ត្រៀមរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៤-២០១៨

-រៀបចំ និងកសាងផែនការមេរយៈពេលវែងសម្រាប់អភិវឌ្ឍន៍វិស័យកសិកម្ម ២០១៣-២០៣៣

-រៀបចំផែនកសាងផែនការសកម្មភាព ដើម្បីអនុវត្តគោលនយោបាយស្ដីពី ការជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករ

-ណែនាំតម្រង់ទិស និងជំរុញតាមដានការអនុវត្ត ផែនការសកម្មភាពរបស់អង្គភាពក្រោមឱវាទតាមកម្មវិធី និងអនុកម្មវិធីស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ ២០០៩-២០១៣

-ជំរុញការអនុវត្តប្រព័ន្ធផែនការផ្ទៃក្នុង (Internal Planning) និងការកសាងផែនការថវិកា ដោយផ្អែកតាមថវិកាកម្មវិធីប្រចាំឆ្នាំ (Program Budgeting) នៃក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រថវិកា (BSP) របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយជំរុញការអនុវត្តតាមទម្រង់ P3 និង P4 និងកំណត់ឱ្យបានច្បាស់លាស់ នូវគោលដៅលទ្ធផលចុងក្រោយ សូចនាករ និងធនធានដែលមានដោយផ្អែកតាមកម្មវិធី អនុកម្មវិធីរបស់អនុវិស័យនីមួយៗ

-សម្រសម្រួលតាមដានត្រួតពិនិត្យ និងវាយតំលៃល្បឿននៃការអនុវត្តផែនការ និងកម្មវិធីនានា ដើម្បីលើកជាសំណើតម្រង់ទិសនៅឆ្នាំខាងមុខ

### ក.២-ការងារវិនិយោគសាធារណៈនិងជំនួយអភិវឌ្ឍន៍ផ្លូវការ

#### -ការងារវិនិយោគសាធារណៈ

នៅក្នុងឆ្នាំ២០១២ បានរៀបចំស្នើសុំគម្រោងវិនិយោគសាធារណៈ ២០១៣-២០១៥ សម្រាប់វិស័យកសិកម្ម និងបានដាក់ស្នើទៅក្រសួងផែនការមានទាំងអស់៣១គម្រោង ក្នុងនោះ÷

- គម្រោងស្នើសុំថ្មី (Planned-Project) មានចំនួន១៩គម្រោង មានថវិកាសរុបចំនួន ១១២.១២៣.៧00,00 ដុល្លារអាមេរិក ក្នុងនោះ គម្រោងវិនិយោគជាទុន (Investmet project) មាន ០៥គម្រោង និងគម្រោងជំនួយបច្ចេកទេស (Technical asstance project) ២៦ គម្រោង
- គម្រោងកំពុងដំណើរការ (On-going Project) មានចំនួន ១២គម្រោង មានថវិកាសរុបចំនួន ២៣៦.១២៣.១០៧,០០ ដុល្លាអាមេរិក។

#### -ការងារផែនការថវិកាតាមកម្មវិធី

នៅឆ្នាំ២០១២ បានទទួលថវិកាតាមកម្មវិធី ដែលជាថវិការដ្ឋនិងត្រូវបានអនុម័ត ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលមានទឹកប្រាក់សរុប ២១.៩៥៧.៤០០.០០០ រៀល ក្នុងនោះ ÷

**<u>គម្រោងថវិកាតាមកម្មវិធីនៅឆ្នាំ២០១៣</u> ( ២១.៩៥៧.៤០០.០០០ )**

**ក-<u>កម្មវិធីទី១ :</u>** មានទឹកប្រាក់ចំនួន ៩.៩៩០.៤០០.០០០ រៀល

**ខ-<u>កម្មវិធីទី២ :</u>** មានទឹកប្រាក់ចំនួន ៤៨៨.០០០.០០០ រៀល

**គ-<u>កម្មវិធីទី៣ :</u>** មានទឹកប្រាក់ចំនួន ៧១០.០០០.០០០ រៀល

**ឃ-<u>កម្មវិធីទី៤ :</u>** មានទឹកប្រាក់ចំនួន ៥.៥៧២.០០០.០០០ រៀល

**ង-<u>កម្មវិធីទី៥ :</u>** មានទឹកប្រាក់ចំនួន ៥.១៩៧.០០០.០០០ រៀល

### ក-៣-ការងារវិនិយោគឯកជន

មកទល់ពេលនេះ រាជរដ្ឋាភិបាលកម្ពុជាបានផ្ដល់គោលការណ៍វិនិយោគជូនក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច និងបានចុះកិច្ចសន្យាជាមួយក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ សរុបចំនួន ១២១ក្រុមហ៊ុន លើផ្ទៃដីកិច្ចសន្យាសរុប

ចំនួន ១.២៣០.៣៦៤ហត ស្ថិតនៅខេត្តចំនួន១៧។ ក្រុមហ៊ុនទាំង ១២១ មានក្រុមហ៊ុនក្នុងស្រុកចំនួន៣៩ ក្រុមហ៊ុន លើផ្ទៃដីចំនួន ៦០៩.៣៧៧ហត ដាំដុះបានចំនួន ៥៩.៣៦៥ហត និងក្រុមហ៊ុនមកពីបរទេសសរុបចំនួន ៨២ ក្រុមហ៊ុន លើផ្ទៃដីសរុបចំនួន ៦២០.៩៨៧ហត ដាំដុះបានចំនួន ១៣៥.៣២២ហត។ ប្រភេទដំណាំដែលបានដាំដុះរួមមានកៅស៊ូ ឈើ ដូងប្រេង ស្វាយចន្ទី ដំឡូងមី និងចិញ្ចឹមសត្វ។

ក្រុមហ៊ុនមកពីបរទេសចំនួន ៨២ក្រុមហ៊ុន មានមកពី÷ ប្រទេសវៀតណាមចំនួន៣៤ ក្រុមហ៊ុនលើផ្ទៃដីចំនួន ២៥៣.៦២៣ហត ប្រទេសចិនចំនួន ២៥ក្រុមហ៊ុន លើផ្ទៃដីចំនួន ២០៣.៩៦០ហត ប្រទេសឥណ្ឌាចំនួន០៣ក្រុមហ៊ុន លើផ្ទៃដីចំនួន ១៧.៧២៧ហត ក្រុមហ៊ុនមកពីប្រទេសកូរ៉េចំនួន ០៧ក្រុមហ៊ុន លើផ្ទៃដីចំនួន ៣៨.៣៣៩ហត ប្រទេសម៉ាឡេស៊ីចំនួន០៣ក្រុមហ៊ុនលើផ្ទៃដីចំនួន២៣.៩៩២ហត ប្រទេសថៃឡង់ចំនួន០៤ក្រុមហ៊ុនលើផ្ទៃដីចំនួន ៣០.៧៧៣ហត អូស្ត្រាលីចំនួន ០១ក្រុមហ៊ុនលើផ្ទៃដីចំនួន ៨.៩៧៧ហត ប្រទេសសិង្ហបុរីចំនួន០២ ក្រុមហ៊ុន លើផ្ទៃដីចំនួន ១៦.២០២ហត ប្រទេសអ៊ីស្រាអែលចំនួន០១ក្រុមហ៊ុនលើផ្ទៃដីចំនួន ២.៤០៩ហត ប្រទេសអាមេរិកចំនួន ០១ក្រុមហ៊ុន លើផ្ទៃដីចំនួន ៩.៨២០ហត ប្រទេសរុស្ស៊ីចំនួន ០១ក្រុមហ៊ុន លើផ្ទៃដីចំនួន ១៥.១៦៥ហត ។

ក្នុងឆ្នាំ២០១២ រាជរដ្ឋាភិបាលបានសម្រេចលុបគោលការណ៍និងកិច្ចសន្យាវិនិយោគសរុបចំនួន ១១ក្រុមហ៊ុន លើផ្ទៃដីចំនួន ៨៥.៦៩៨ ហត។

នៅឆ្នាំ២០១២ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានស្នើចុះបញ្ជីដីឯកជនរបស់រដ្ឋសរុបបានចំនួន ៤៣ក្រុមហ៊ុន។ តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចូលរួមផ្តិតមេដៃលើឯកសារចុះបញ្ជីដីសរុបបានចំនួន ១៥ក្រុមហ៊ុនទទួលប័ណ្ណសម្គាល់សិទ្ធិអចលនវត្ថុសរុបចំនួន ០៥ក្រុមហ៊ុន។

## ខ. ការងារសម្របសម្រួល តាមដាន និងវាយតម្លៃគម្រោង

### ខ.១ ការតាមដាននិងវាយតម្លៃថវិកាតាមកម្មវិធី

- បានចុះតាមដាននិងវាយតម្លៃការអនុវត្តថវិកាតាមកម្មវិធីនៅតាមអង្គភាពថ្នាក់កណ្តាល ចំនួន ០៩ អង្គភាព
- បានចុះតាមដានការអនុវត្តថវិកាតាមកម្មវិធីនៅទីវាល បានចំនួន០៩លើក
- បានប្រជុំបូកសរុបលទ្ធផលការងារនៃការអនុវត្តថវិកាក្នុងក្របខ័ណ្ឌថវិកាតាមកម្មវិធី និងកិច្ចប្រជុំពាក់ព័ន្ធចំនួន០៣លើក
- បានសម្របសម្រួលនិងរៀបចំបើកសិក្ខាសាលាចំនួន០២លើក នៅខេត្តបាត់ដំបងនិងខេត្តសៀមរាប លើប្រធានបទថវិកាតាមកម្មវិធី ក្រោមគម្រោងជំនួយបច្ចេកទេស ADB-Grant. 0222-CAM/Component1: PFMRDs

### ខ.២ ការតាមដាននិងវាយតម្លៃគម្រោងអភិវឌ្ឍន៍ក្នុងវិស័យកសិកម្ម

-បានចុះតាមដាននិងវាយតម្លៃលើការអនុវត្តគម្រោងចំនួន០៣របស់អង្គការ JICA, FIDR, ADDA

-បានរៀបចំសិក្ខាសាលា ទស្សនកិច្ចសិក្សា កិច្ចប្រជុំបច្ចេកទេសទាក់ទង និងការរៀបចំកសាងឯកសារគម្រោងស្តីពី ការបង្កើតផែនការមេសម្រាប់ជំរុញការវិនិយោគក្នុងវិស័យកសិកម្ម ក្រោមគម្រោងជំនួយបច្ចេកទេសរបស់អង្គការ KOICA។

-បានរៀបចំសិក្ខាសាលាថ្នាក់ជាតិស្តីពី អភិក្រមគោលនយោបាយគាំទ្រដល់ជនក្រីក្រ ដើម្បីឆ្លើយតបហានិភ័យ និងភាពងាយរងគ្រោះនៅកម្រិតប្រទេស ក្រោមគម្រោងជំនួយបច្ចេកទេសរបស់អង្គការ FAO។

### ខ.៣ ការសម្របសម្រួលការងាររៀបចំបង្កើតផែនទីបង្ហាញផ្លូវក្រោមយុទ្ធសាស្ត្រសម្រាប់វិស័យកសិកម្មនិងទឹក

-បានសម្របសម្រួលនិងសហការជាមួយទីប្រឹក្សាជាតិនិងអន្តរជាតិក្នុងការចុះសម្ភាសន៍ និងពិគ្រោះយោបល់ជាមួយស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ទាក់ទងទៅនឹងកិច្ចដំណើរការនិងការអនុវត្តអភិក្រមផ្អែកលើកម្មវិធី (PBAs)។

ជារួមលទ្ធផលដែលសម្រេចបានដូចខាងលើនេះ គឺអាស្រ័យដោយមានការដឹកនាំគាំទ្រពីថ្នាក់ដឹកនាំរបស់នាយកដ្ឋាន ក៏ដូចជាក្រសួង និងការរួមយ៉ាងសកម្មរបស់មន្ត្រី។ ដូចនេះសម្រាប់ទិសដៅអនុវត្តបន្ត ការិយាល័យសម្របសម្រួល តាមដាន និងវាយតម្លៃគម្រោង នឹងបន្តពង្រឹង និងកែលម្អការងារបន្ថែមទៀត ដើម្បីឆ្លើយតបទៅនិងប្រសិទ្ធភាព និងតម្រូវការរបស់នាយកដ្ឋានក៏ដូចជាក្រសួង ក្នុងសម្របសម្រួល ការតាមដាន និងការវាយតម្លៃគម្រោង ទាំងក្នុងក្របខ័ណ្ឌជាតិនិងអន្តរជាតិ។

## គ-ការងារស្ថិតិ

ជារួមការងារស្ថិតិកសិកម្មត្រូវបានពង្រឹងនិងបន្តបង្កើនសមត្ថភាពធនធានមនុស្ស ជំនាញបច្ចេកទេសនិងវិធីសាស្ត្រនៃការធ្វើអង្កេតជំរឿន និងវិភាគ។ ផ្នែកស្ថិតិកសិកម្មជាសេនាធិការមានយន្តការនៃការដឹកនាំគ្រប់គ្រង ប្រមូល វិភាគ ចងក្រង និងចែកចាយនៃទិន្នន័យស្ថិតិកសិកម្ម។ លទ្ធផលសម្រេចបានតាមផ្នែកមានដូចខាងក្រោម÷

## គ.១- ផ្នែកតាមដានបូកសរុបនិងវិភាគទិន្នន័យ

-ការប្រមូលព័ត៌មាននិងរបាយការណ៍តាមបណ្ដានាយកដ្ឋានក្រោមឱវាទក្រសួង និងតាមបណ្ដារាជធានី ខេត្ត ដែលពាក់ពន្ធ័ការងារប្រព័ន្ធទិន្នន័យស្ថិតិកសិកម្ម

-តាមដានការងារបង្កបង្កើនផលដំណាំកសិកម្ម (ដំណាំស្រូវរដូវវស្សានិងរដូវប្រាំង ដំណាំរដូវផ្សេងៗ និងដំណាំអចិន្ត្រៃយ៍ ដើម្បីធ្វើការវាយតម្លៃលើផ្ទៃដីដាំដុះ ទិន្នផល បរិមាណផលប្រចាំឆ្នាំ

-តាមដានពិនិត្យ វាយតម្លៃ វិភាគ និងធ្វើរបាយការណ៍ជាប្រចាំស្ដីពី ល្បឿនបង្កបង្កើនផលស្រូវរដូវវស្សា និងរដូវប្រាំង និងដំណាំរួមផ្សំឆ្នាំ២០១២-២០១៣ នៅតាមបណ្ដារាជធានី ខេត្តទូទាំងប្រទេស

-វិភាគនិងបកស្រាយលើទិន្នន័យ ដែលបានបញ្ចូលក្នុងប្រព័ន្ធអេឡិចត្រូនិចនិងផ្ទៀងផ្ទាត់លើផ្ទៃដី ទិន្នផល បរិមាណផល ដែលបានប្រមូលតាមបណ្ដារាជធានី ខេត្តទូទាំងប្រទេស

-ពិនិត្យវាយតម្លៃនិងសិក្សាវិភាគទិន្នន័យ ដែលបានបញ្ចប់ការដាំដុះដំណាំរដូវវស្សានិងប្រាំង ដើម្បីធ្វើការវាយតម្លៃ ប៉ាន់ស្មានតុល្យភាពស្បៀងប្រចាំឆ្នាំតាមបណ្ដារាជធានី ខេត្តទូទាំងប្រទេស

-តាមដានទឹកភ្លៀងនិងគ្រោះធម្មជាតិ (រាំងស្ងួត ទឹកជំនន់ សត្វល្អិត) នៅតាមបណ្ដារាជធានីខេត្តនិងធ្វើការផ្ទៀងផ្ទាត់ទិន្នន័យដែលប្រមូលបាន ដើម្បីធ្វើការកែច្នៃនិងវិភាគសកម្មភាពការងារបង្កបង្កើនផលដំណាំកសិកម្មរដូវវស្សានិង រដូវប្រាំង។

សកម្មភាពនិងលទ្ធផលការងារនេះ បានផលិតចេញជារបាយការណ៍កសិកម្មរៀងរាល់សប្ដាហ៍ផ្ញើជូនខុទ្ទកាល័យ **សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** របាយការណ៍ប្រចាំឆ្នាំ និងរបាយការណ៍ពិសេសដោយឡែកមួយចំនួនទៀត និងសៀវភៅស្ថិតិកសិកម្មប្រចាំឆ្នាំ។ល។

## គ.២- ផ្នែករៀបចំវិធីសាស្ត្រអង្កេតដំណាំ

-ធ្វើការជ្រើសរើសចំនួនភូមិ ចំនួនគ្រួសារ និងចំនួនសំណាកគំរូតាមបណ្ដារាជធានី ខេត្តទូទាំងប្រទេស ដើម្បីដំណើរការធ្វើអង្កេតស្ទង់ទិន្នផលស្រូវរដូវវស្សានិងរដូវប្រាំងឆ្នាំ២០១២-២០១៣

-ធ្វើទម្រង់បញ្ជីសំណួរថ្នាក់ភូមិ សម្រាប់ការធ្វើអង្កេតស្ទង់ទិន្នផលស្រូវរដូវវស្សានិងរដូវប្រាំង

-ធ្វើបញ្ជីឈ្មោះគ្រួសារដាំដំណាំស្រូវក្នុងភូមិ ដែលត្រូវធ្វើការជ្រើសរើសចៃដន្យសំណាកគំរូ បញ្ជីសំណួរអង្កេតស្ទង់ទិន្នផលដំណាំស្រូវ និងស្លាកកំណត់ត្រាដំណើរការធ្វើអង្កេតស្ទង់

-ធ្វើការជ្រើសរើសគ្រួសារចៃដន្យតាមប្រព័ន្ធអេឡិត្រូនិច ដើម្បីអនុវត្តការធ្វើអង្កេតស្ទង់ទិន្នផលស្រូវរដូវវស្សា និងរដូវប្រាំងប្រចាំឆ្នាំ២០១២-២០១៣ តាមបណ្ដារាជធានី ខេត្ត

-ធ្វើការសាកល្បងលើសំណាកគំរូតាមប្រភេទស្រូវ (ស្រាល កណ្ដាល និងធ្ងន់) នៅមូលដ្ឋានស្រុក ភូមិ និងគ្រួសារ និងដំណើរការធ្វើអង្កេតស្ទង់ទិន្នផលស្រូវរដូវវស្សានិងរដូវប្រាំងឆ្នាំ២០១២-២០១៣

-ដំណើរការធ្វើអង្កេតស្ទង់ទិន្នផលដំណាំអចិន្ត្រៃយ៍ឆ្នាំ២០១២

-បង្កើតនិងកែច្នៃទម្រង់សម្រាប់ធ្វើការអង្កេតក្នុងប្រព័ន្ធអេឡិត្រូនិចដើម្បីងាយស្រួលក្នុងការបញ្ចូលនិងវិភាគទិន្នន័យ

-បែងចែកទិន្នន័យមួយចំនួនទៅតាមលំដាប់បណ្ដារាជធានី ខេត្ត ដើម្បីជាមូលដ្ឋានគ្រឹះសម្រាប់ប្រព័ន្ធព័ត៌មានស្ថិតិថ្នាក់ជាតិ

-ទទួលអនុវត្តនូវគម្រោងប្រព័ន្ធព័ត៌មានដីកសិកម្មជាលើកទី២ ក្រោមគម្រោងប្រព័ន្ធព័ត៌មានសន្តិសុខស្បៀងអាស៊ានឧបត្ថម្ភថវិកាដោយរាជរដ្ឋាភិបាលជប៉ុន

- សហការជាមួយក្រសួងផែនការ (វិទ្យាស្ថានជាតិស្ថិតិ) ដើម្បីសិក្សាស្រាវជ្រាវនូវវិធីសាស្ត្រ សម្រាប់ការគិតគូរគណនាកំណើនរបស់វិស័យកសិកម្ម GDP ប្រចាំឆ្នាំ និងចំនួនប្រជាជនទូទាំងប្រទេស២៤រាជធានី ខេត្ត

- សហការជាមួយក្រសួងផែនការ (វិទ្យាស្ថានជាតិស្ថិតិ) ក្រោមការជួយឧបត្ថម្ភគាំទ្រថវិកាបដិភាគពីរាជរដ្ឋាភិបាល អង្គការ FAO និងដៃគូអភិវឌ្ឍ ក្នុងដំណើរការធ្វើជំរឿនកសិកម្មជាលើកទី១នៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៣។

ជារួមសមត្ថភាពនៃការធ្វើអង្កេតស្ទង់ទិន្នផលស្ថិតិកសិកម្ម ដោយមានការជួយឧបត្ថម្ភគាំទ្រពីរាជរដ្ឋាភិបាល បានជំរុញឱ្យដំណើរការងារនេះ មានការរីកចម្រើនបន្ថែមនូវការអភិវឌ្ឍន៍បច្ចេកទេសថ្មីៗ បានមួយកម្រិត។ តែទោះជាយ៉ាងណាក្តី ក៏ការធ្វើអង្កេតស្ទង់ដំណាំកសិកម្ម នៅមានការសេសសល់ការងារជាច្រើនទៀត ដែលមិនបានធ្វើដោយកត្តាផ្សេងៗ ដូចជាខ្វះខាតថវិកា និងធនធានមនុស្សនៅមានកម្រិតនៅឡើយ។

## ឃ-ការងារទីផ្សារកសិកម្ម

រាជរដ្ឋាភិបាលកម្ពុជាបានទទួលស្គាល់ថា ដើម្បីកាត់បន្ថយភាពក្រីក្រឱ្យបានឆាប់ គឺត្រូវធ្វើការអភិវឌ្ឍនៅក្នុងវិស័យកសិកម្មឱ្យបានលឿនដោយសារប្រទេសកម្ពុជាមានប្រជាជនភាគច្រើនជាកសិករ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអ្នកពាក់ព័ន្ធបានកំណត់ថា ការផ្តល់ព័ត៌មានទីផ្សារកសិផលជាអាទិភាពដ៏ចម្បងដែលនឹងនាំទៅដល់ការអភិវឌ្ឍបណ្តាញទីផ្សារ និងឈានទៅដល់ការធ្វើឱ្យប្រសើរឡើងវិស័យកសិកម្មនៅកម្ពុជា។

ផ្នែកទីផ្សារកសិកម្ម នៃនាយកដ្ឋានផែនការនិងស្ថិតិ បានខិតខំបំពេញការផ្នែកទីផ្សារ កសិកម្មដោយផ្តល់នូវសេវាសំខាន់ៗពីរ គឺសេវាព័ត៌មានទីផ្សារកសិផល និងការអភិវឌ្ឍទីផ្សារកសិកម្ម ដើម្បីឱ្យអ្នកពាក់ព័ន្ធមានលទ្ធភាពទទួលបានព័ត៌មានទីផ្សារប្រមូល និងវិភាគព័ត៌មានត្រឹមត្រូវទាន់ពេល និងជាប់ជាប្រចាំ។ សេវាព័ត៌មានទីផ្សារកសិកម្មនឹងជួយធ្វើឱ្យជីវភាពប្រជាកសិករបានប្រសើរឡើង និងដើម្បីរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងចូលរួមកាត់បន្ថយភាពក្រីក្រ។

### ឃ.១- ផ្នែកសេវាព័ត៌មានទីផ្សារកសិកម្ម:

ក្នុងឆ្នាំ២០១២ការិយាល័យទីផ្សារកសិកម្ម សម្រេចបានក្នុងការងាររបស់ខ្លួនស្របតាមសារាចររបស់ក្រសួងកសិកម្មស្តីពីផ្សព្វផ្សាយព័ត៌មានទីផ្សារកសិផលឱ្យដល់មូលដ្ឋានភូមិ-ឃុំ ដោយបានពង្រីកសេវាកម្មពី១៤រាជធានី ខេត្ត ទៅដល់ ២៤រាជធានី ខេត្ត។ សេវាព័ត៌មានទីផ្សារកសិផលនេះ ត្រូវបានធ្វើការផ្សព្វផ្សាយតាមរយៈ ១.វិទ្យុចំនួន៩ស្ថានីយ៍និងទូរទស្សន៍ចំនួន១ស្ថានីយ៍ ២.ព្រឹត្តិបត្រប្រចាំខែ ដែលបានចែកជូនថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ក្រសួងពាក់ព័ន្ធផ្សេងៗ និងអង្គការជាតិ និងអន្តរជាតិ ៣.គេហទំព័រ (www.agriculturalmarketinformation.org.kh) និង ៤.ផ្ញើសារជាអក្សរ (SMS)។ការិយាល័យទីផ្សារកសិកម្មបានសហការជាមួយក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍កសិកម្ម និងជនបទ (CARD)អង្គការស្បៀងនិងកសិកម្ម (FAO) ប្រចាំកម្ពុជា និងអង្គការកម្មវិធីស្បៀងអាហារពិភពលោក (WFP) បានផលិតព្រឹត្តិបត្រតាមដានព័ត៌មានតម្លៃប្រចាំខែ និងព្រឹត្តិបត្រសន្តិសុខស្បៀងនិងអាហារូបត្ថម្ភប្រចាំត្រីមាស។

### ឃ.២- ផ្នែកអភិវឌ្ឍន៍ទីផ្សារ

ការងារទីផ្សារកសិកម្ម បានចុះតាមដាននិងពង្រឹងសមត្ថភាពមន្ត្រីផ្នែកទីផ្សារកសិកម្មខេត្តនិងបើកវគ្គបណ្តុះបណ្តាលផ្សព្វផ្សាយសេវាព័ត៌មានទីផ្សារកសិកម្មដល់កសិករ អាជីវករដូចជា÷

-បានចុះតាមដាន និងពង្រឹងសមត្ថភាពមន្ត្រីផ្នែកទីផ្សារកសិកម្មខេត្តព្រៃវែង បន្ទាយមានជ័យ កំពង់ចាម បាត់ដំបង កំពង់ឆ្នាំង ពោធិ៍សាត់ កណ្តាល សៀមរាប កំពង់ធំ កំពង់ស្ពឺ ព្រះវិហារព្រះសីហនុ តាកែវ កំពត កោះកុង កែប ប៉ៃលិន ឧត្តរមានជ័យ ស្ទឹងត្រែង ក្រចេះ រតនគីរី មណ្ឌលគីរី និងស្វាយរៀង

-បានបើកវគ្គបណ្តុះបណ្តាលជាមួយអាជីវករលក់ដុំបន្លែចំនួន០៥វគ្គ ស្តីពីការប្រើប្រាស់សេវា ព័ត៌មានទីផ្សារកសិកម្មតាមរយៈSMS ដែលមានអាជីវករចូលរួមសរុបចំនួន៥៩នាក់ ក្នុងនោះស្ត្រីចំនួន៤០នាក់ ដែលឧបត្ថម្ភថវិកាដោយអង្គការកម្មវិធីស្បៀងអាហារពិភពលោក WFP

-បានបើកវគ្គបណ្តុះបណ្តាលស្តីពីការប្រើប្រាស់សេវាព័ត៌មានទីផ្សារកសិកម្មតាមរយៈ SMS ដល់ក្រុមកសិករផលិតដំណាំបន្លែចំនួន០៥វគ្គ ដែលមានកសិករចូលរួមសរុបចំនួន៩០នាក់ ក្នុងនោះស្ត្រីចំនួន៣៣នាក់ឧបត្ថម្ភថវិកាដោយអង្គការកម្មវិធីស្បៀងអាហារពិភពលោក។

-បើកវគ្គបណ្តុះបណ្តាល ដើម្បីបង្កើនសមត្ថភាពដល់មន្ត្រីទទួលបន្ទុកផ្នែកទីផ្សារកសិកម្មទូទាំង២៤រាជធានី ខេត្តបានចំនួន០២លើកមានសិក្ខាកាមសរុប៤៨នាក់ ក្នុងនោះស្ត្រី២៦នាក់

ជារួមផ្នែកទីផ្សារកសិកម្ម បានបំពេញការងារទទួលបានជោគជ័យដូចផែនការគ្រោងទុក។ ជាពិសេសអាជីវករ និងកសិករមានចំណាប់អារម្មណ៍ចំពោះសេវាព័ត៌មានទីផ្សារកសិផល ដែលជួយឲ្យអាជីវករ-កសិករទទួលបានចំណូលខ្ពស់ជាងមុន និងមានបណ្តាញទីផ្សារធំទូលាយ។

## ង-ការងារវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

- ចូលរួមប្រជុំផ្តល់យោបល់ លើរបាយការណ៍ វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូងសម្រាប់ គម្រោងដាំដំណាំកៅស៊ូរបស់ក្រុមហ៊ុន Ba RaiKompong Thom AphivathCaoutchchoucco,ltd និងក្រុមហ៊ុន PhucHoaKompong Thom AphivathCaoutchchoucco,ltd ដែលមានទីតាំងស្រុកសន្ទុក ខេត្តកំពង់ធំ
- ចូលរួមប្រជុំផ្តល់យោបល់ លើរបាយការណ៍វាយតម្លៃផលប៉ះពាល់បរិស្ថានដំបូង សម្រាប់គម្រោងវិនិយោគអភិវឌ្ឍន៍រមណីដ្ឋានកោះសង្ហារបស់ក្រុមហ៊ុន Brocon Investment Co.,Ltd. មានទីតាំងស្ថិតនៅកោះរុង ខេត្តព្រះសីហនុ
- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដែលបានរៀប ចំដោយក្រសួងបរិស្ថាន សហការជាមួយអង្គការ American Friend Service Committee (AFSC) និងមជ្ឈមណ្ឌល Appraisal Center for Envionment and Engineering (ACEE)
- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ASEAN ECOMIC COMMUNITY (For Cambodai) និងវគ្គបណ្តុះបណ្តាលស្តីពី Project Proposal Writing in ASEAN (For Cambodai) នៅមជ្ឈមណ្ឌលបណ្តុះបណ្តាលកម្ពុជា-សិង្ហបុរី

## ច- វាយតម្លៃនិងសន្និដ្ឋាន

ជារួមការងារផែនការ និងស្ថិតិ គឺជាសេនាធិការឱ្យក្រសួងក្នុងផ្នែកការងារគោលនយោបាយយុទ្ធសាស្ត្រ ផែនការសេដ្ឋកិច្ច និងវិនិយោគ។ ការងារវិភាគគោលនយោបាយយុទ្ធសាស្ត្រ និងការកសាងកម្មវិធី និងគម្រោងការងារនានា ជាបញ្ហាគន្លឹះ ដើម្បីសម្រេចបានជោគជ័យក្នុងវិស័យ។ កន្លងមកក្នុងឆ្នាំ ២០១២ ការងារក្នុងផ្នែកនេះ សម្រេចបានលទ្ធផលល្អប្រសើរជាងឆ្នាំកន្លងមក និងតាមផែនការដែលបានគ្រោងទុក។ ក៏ប៉ុន្តែជាមួយនឹងការខិតខំនេះ យើងក៏ជួបការប្រឈមនិងបញ្ហាខ្លះៗ ដូចជា កង្វះធនធានមនុស្ស ដែលមានសមត្ថភាពបរិបូរណ៍ និងមធ្យោបាយសម្ភារធ្វើការ ដែលទាំងអស់នេះទាមទារឱ្យមានការជួយគាំទ្រពីអ្នកពាក់ព័ន្ធ ដើម្បីជំរុញឱ្យការងារនេះ កាន់តែមានប្រសិទ្ធិភាពខ្ពស់ថែមទៀត។

## ឆ- វិធានការ

-បន្តកិច្ចសហការជាមួយស្ថាប័ន និងអង្គភាពពាក់ពន្ធ័ពិនិត្យដោះស្រាយទំនាស់ផ្សេងៗ ក្នុងតំបន់វិនិយោគសម្បទានដីសេដ្ឋកិច្ច ដែលមានគោលការណ៍ និងចុះកិច្ចសន្យាជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បន្តជំរុញឱ្យក្រុមហ៊ុនវិនិយោគសម្បទានដីសេដ្ឋកិច្ច គោរពតាមកិច្ចសន្យាផែនការមេនិងការណែនាំរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បន្តការសហការជាមួយអង្គភាពជំនាញ ដើម្បីពិនិត្យលើការយកថ្លៃសម្បទានពីក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ចដែលដល់កំណត់ពេលត្រូវយកថ្លៃសម្បទាន

-បន្តជំរុញឱ្យក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច ធ្វើ EIA និងចុះបញ្ជីដីជាដីឯកជនរបស់រដ្ឋ ចំពោះក្រុមហ៊ុនណាដែលពុំបានធ្វើ

-បន្តធ្វើបច្ចុប្បន្នភាពលើការរៀបចំ ចងក្រង ប្រមូលព័ត៌មាន និងទិន្នន័យគម្រោង ដែលផ្តល់ហិរញ្ញប្បទាន សហប្រតិបត្តិការរបស់ដៃគូអភិវឌ្ឍន៍ និងត្រៀមលក្ខណៈចុះត្រួតពិនិត្យ តាមដាន និងវាយតម្លៃ

-បន្តជំរុញការអនុវត្តសេវាព័ត៌មានទីផ្សារកសិកម្មរាជធានី ខេត្ត ធ្វើការវិភាគកែច្នៃព័ត៌មានទីផ្សារកសិកម្មឱ្យកាន់តែល្អប្រសើរឡើង ដើម្បីចងក្រងព្រឹត្តិប័ត្រប្រចាំខែ ប្រចាំឆ្នាំ ជាមូលដ្ឋានសម្រាប់ផ្សព្វផ្សាយបន្តដល់ប្រជាកសិករនៅតាមជនបទ

-បន្តជំរុញការផ្សព្វផ្សាយព័ត៌មានទីផ្សារតាមរយៈគេហទំព័រ ទូរទស្សន៍ វិទ្យុ និងបោះពុម្ពខិត្តប័ណ្ណ និងពិនិត្យតាមដានការប្រមូលព័ត៌មានថ្លៃទីផ្សារនៅតាមរាជធានី ខេត្ត និងសិក្សាបញ្ហាទីផ្សារ ដែលធ្វើឱ្យមានឥទ្ធិពលដល់ការប្រែប្រួលតម្លៃរបស់ផលិតផល។

### ៥.៤.២-ការងារសហប្រតិបត្តិការអន្តរជាតិ

### ក-លទ្ធផល

### ក.១. ការគ្រប់គ្រងឯកសារនិងកិច្ចការទំនាក់ទំនង

– មុខការលិខិតចូលចំនួន ២៤០១ ច្បាប់ ព្រមទាំងរៀបចំ និងបញ្ជូនលិខិតចេញបានចំនួន ១២០៨ ច្បាប់

– បានទំនាក់ទំនង និងបំពេញបែបបទជូនថ្នាក់ដឹកនាំ និងមន្ត្រី ដើម្បីចូលរួមប្រជុំ សន្និសីទ វគ្គបណ្តុះបណ្តាល វេទិកា សិក្ខាសាលា និងទស្សនកិច្ចនៅបរទេសចំនួន ៧៣៨នាក់ ក្នុងនោះ ៩៥នាក់ចូលរួមព្រឹត្តិការណ៍ខាង លើទាក់ទងនឹងកិច្ចសហប្រតិបត្តិការជាមួយអង្គការអន្តរជាតិ ២០៥នាក់ ទាក់ទងនឹងកិច្ចការអាស៊ាន និង ចំនួន ២០៥នាក់ ទាក់ទងនឹងកិច្ចសហប្រតិបត្តិការទ្វេភាគី ពហុភាគី

– បានសម្របសម្រួលរៀបចំការជួបពិភាក្សារវាងថ្នាក់ដឹក និងតំណាងស្ថាប័ន ព្រមទាំងដៃគូអភិវឌ្ឍន៍នានាអំពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងវិនិយោគលើវិស័យកសិកម្ម។

### ក.២. ការងារអាស៊ានកសិកម្ម

បានធ្វើជាម្ចាស់ផ្ទះក្នុងការរៀបចំកិច្ចប្រជុំចំនួន ៣ នៅខេត្តសៀមរាប ÷

– កិច្ចប្រជុំលើកទី ៦ នៃបណ្តាញការងារព្រៃឈើសង្គមអាស៊ាន និងសន្និសីទស្តីពីបណ្តាញការងារព្រៃសង្គម អាស៊ាន លើកទី ៣ ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី១២ ដល់ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១២

– កិច្ចប្រជុំលើកទី ៣២ នៃគណៈកម្មការត្រៀមបម្រុងសន្តិសុខស្បៀងអាស៊ាន ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី ១៩ ដល់ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១២

– កិច្ចប្រជុំលើកទី៩ នៃក្រុមអ្នកជំនាញសាយតេសអាស៊ាន ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី០៦ ដល់ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១២

បានសម្របសម្រួលរៀបចំឯកសារ និងបំពេញបែបបទក្នុងការត្រៀមរៀបចំសិក្ខាសាលាលើកទី២ស្តីពី ASEAN-Australia Development Cooperation Program (AADCP) និង ASEAN GAP project ដែលគ្រោងនឹង ប្រារព្ធធ្វើនៅថ្ងៃទី ២៩ ដល់ ៣០ ខែមេសា ឆ្នាំ២០១៣ និងកិច្ចប្រជុំលើកទី១០ ស្តីពីបណ្តាញត្រួតពិនិត្យអាស៊ាន លើចំណីអាហារដែលមានប្រភពពីផលិតផលបម្រែបម្រួលសេណេទិច ដែលគ្រោងនឹងប្រារព្ធធ្វើនៅឆ្នាំ២០១៣។

### ក.៣. ការងារកសិ-ពាណិជ្ជកម្មពិភពលោក

– បានសម្របសម្រួលឲ្យមានការពិនិត្យ និងផ្តល់យោបល់លើខ្លឹមសារនៃកិច្ចព្រមព្រៀងស្តីពីការទិញ-លក់ ផ្លាស់ប្តូរទំនិញ និងសេវាពាណិជ្ជកម្មនៅតំបន់ព្រំដែន និងកិច្ចព្រមព្រៀងស្តីពីទំនិញឆ្លងកាត់រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម

– បានសម្របសម្រួលជាមួយអង្គភាពជំនាញពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការពិនិត្យកែសម្រួលឯកសារស្តីពីអជ្ញាប័ណ្ណនាំចេញ និងបញ្ជូនទៅក្រសួងពាណិជ្ជកម្ម

– សម្របសម្រួលរៀបចំកិច្ចប្រជុំពិភាក្សា និងផ្តល់មតិលើសេចក្តីព្រាងស្តីពី Work Program of the Royal Government of Cambodia on WTO Requirement and Related Issues

– រៀបចំគម្រោងសំណើប្រើប្រាស់ថវិកាតាមកម្មវិធី P3 P4 ឆ្នាំ២០១៣ សម្រាប់វគ្គបណ្តុះបណ្តាលទាក់ទងនឹងវិស័យកសិ-ពាណិជ្ជកម្ម។

### ក.៤. ការងារសហប្រតិបត្តិការជាមួយអង្គការមិនមែនរដ្ឋាភិបាល

– បានសម្របសម្រួល និងពិនិត្យឯកសារស្តីពីកិច្ចព្រមព្រៀងអនុវត្តគម្រោងសម្រាប់ចុះហត្ថលេខារវាងក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ ព្រមទាំងដៃគូអភិវឌ្ឍន៍នានា

| ល.រ | ឈ្មោះអង្គការ | ឈ្មោះគម្រោង | រយៈពេលគម្រោង | ថវិកាគម្រោង | |
|---|---|---|---|---|---|
| | | | | USD | EUR |
| ១ | Wildlife Alliance | Southern Cardamom Forest Protection in the Southern Cardamom Mountain Range | 01.10.2012<br>31.09.2015 | 7 108 605 | |

| | | | | | |
|---|---|---|---|---|---|
| ២ | ACIAR (AusAID) | Improved Irrigation Management to Increase rice productivity in Cambodia | 01.01.2011<br>31.12.2014 | 1 068 962 | |
| ៣ | WCS | "Seima" Protected Forest and Biodiversity Conservation Area, Mondulkiri and Kratie | 01.01.2012<br>31.12.2014 | 613 000 | |
| | | Tonle Sap Bird Conservation Area | 01.01.2012<br>31.12.2014 | 188 182 | |
| | | Global Health Program, Cambodia | 01.01.2012<br>31.12.2014 | 707 620 | |
| | | Conservation and Landscape Management in the Northern Plain | 01.01.2012<br>31.12.2014 | 1 567 200 | |
| | | BatagurBaska Conservation Project | 01.01.2012<br>31.12.2014 | 109 935 | |
| ៤ | Heifer Cambodia | Improving Income and Nutrition through Community Empowerment (INCOME) | 01.07.2012<br>30.06.2017 | 2 581 123 | |
| ៥ | ADRA | Enabling Household to Apply necessary Cultivation for Economic Development | 01.02.2012<br>31.01.2015 | 278 900 | |
| ៦ | FAO | Macro and Small Enterprise Development to Achieve Food Security, Food Safety and Self-reliance for Urban Poor | August 2012<br>March 2014 | 342 000 | |
| | | Fighting Financial Illiteracy among Poor Rural Household | July 2012<br>June 2014 | 314 000 | |
| | | Designing a Multipurpose National Forest Inventory to Support Reduced Emission from Deforestation and Forest Degradation (REDD+) Mechanism | January 2012<br>December 2013 | 305 000 | |
| | | Emergency Assistance to restore the livelihood of Vulnerable Farming Families affected by the Floods in the District of Pea Rang and SithorKandal of Prey Veng Province, Cambodia | February 2012<br>October 2012 | 300 000 | |
| | | Improving Food Security and Market Linkages for Smallholders in OtdoMeanchay and PreahVihear Provinces, Cambodia | January 2012<br>June 2015 | | 4 000 000 |
| **សរុប** | | **14 គម្រោង** | | **15 484 527** | **4 000 000** |

– បានចុះពិនិត្យ និងវាយតម្លៃលទ្ធផលនៃការអនុវត្តគម្រោងរបស់អង្គការ AFSCADRA Wildlife Alliance AVSF និង FIDR នៅខេត្តកោះកុង ពោធិ៍សាត់ កំពុងឆ្នាំង តាកែវ និងព្រៃវែង។

– បានសម្របសម្រួលបំពេញបែបបទអន្តរាគមន៍ស្នើសុំបន្តទិដ្ឋាការស្នាក់ជូនទីប្រឹក្សាបច្ចេកទេសបរទេស ស្លាកលេខ ONG សម្រាប់រថយន្ត និងម៉ូតូរបស់អង្គការមិនមែនរដ្ឋាភិបាល បន្តអនុស្សារណៈនៃការយោគយល់គ្នារវាងរាជរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ។

## គ.៥.ការសហប្រតិបត្តិការទ្វេភាគី ពហុភាគី

– បានសម្របសម្រួលបំពេញបែបបទ ឯកសារស្នើសុំលិខិតឆ្លងដែនផ្លូវការជូនថ្នាក់ដឹកនាំក្រសួង ថ្នាក់ដឹកនាំនាយកដ្ឋាន និងថ្នាក់ដឹកនាំការិយាល័យចំនួន ៦០ ច្បាប់

– បានទទួលជួបពិភាក្សាការងារជាមួយដៃគូអភិវឌ្ឍរួមមាន÷ សហគមន៍អឺរ៉ុប ជប៉ុន សាធារណរដ្ឋបេឡារុស្ស សាធារណរដ្ឋហ្វីណេ អូស្ត្រាលី ឥណ្ឌា គុយវ៉ែត សហរដ្ឋអាមេរិក បារាំង សាធារណរដ្ឋឆែក សាធារណរដ្ឋសែប៊ី ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) អារ៉ាប់រួមអេមីរ៉ាត សាធារណរដ្ឋសហព័ន្ធនីហ្សេរីយ៉ា សាធារណរដ្ឋកូរ៉េ ព្រមទាំងជាមួយឯកអគ្គរដ្ឋទូតប្រចាំកម្ពុជា រួមមាន÷ ឯកអគ្គរដ្ឋទូតគុយបា ព្រះរាជាណាចក្រអារ៉ាប៊ីសាអូឌីត និងសាធារណរដ្ឋប្រជាធិបតេយ្យកូរ៉េ។

– បានរៀបចំឯកសារគំរូវិញ្ញាបនប័ត្រភូតគាមអនាម័យជាមួយអគ្គរដ្ឋបាលត្រួតពិនិត្យគុណភាព អធិការកិច្ច និងចត្តាឡីស័កនៃសាធារណរដ្ឋប្រជាមានិតចិន ឯកសារអំពីជំហរកម្ពុជាក្នុងការគាំទ្រប្រទេសជប៉ុន បន្តជាសមាជិក IWC សេចក្តីព្រាងអនុស្សារណៈនៃការយោគយល់គ្នាស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យា ក្នុងក្របខ័ណ្ឌ ACMECS ឯកសារស្តីពីសារប្រយោជន៍នៃការ

ចុះហត្ថលេខាលើ Agreement Establishingthe International Fund for Agricultural Development (IFAD) សេចក្តីព្រាងឯកសារស្តីពី 2012 Country Performance Assessment របស់ ADB និងសេចក្តីព្រាងអនុស្សារណៈនៃការយោគយល់គ្នាស្តីពី កិច្ចសហប្រតិបត្តិការបច្ចេកទេស និងវិទ្យាសាស្ត្រក្នុងវិស័យកសិកម្ម រវាងកម្ពុជា និងបង់ក្លាដេស។

– បានចុះបញ្ជីគម្រោង "Forest Restoration and Establishment of Forest Research Facilities" ដែលឧបត្ថម្ភថវិកាដោយសាធារណរដ្ឋកូរ៉េ និងបញ្ជូនគម្រោងសំណើស្តីពី "Soil/Land Management Land Use Mapping and Agricultural Zoning for Sustainable Agricultural Production in Cambodia" ទៅទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ

– បានចុះហត្ថលេខាលើអនុស្សារណៈនៃការយោគយល់គ្នាចំនួន ៤ រវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងប្រទេស ស្ថាប័នដៃគូអភិវឌ្ឍន៍ ÷

| ល.រ | អនុស្សារណៈនៃការយោគយល់គ្នា | ជាមួយ | ថវិកា | | កាលបរិច្ឆេទ |
|---|---|---|---|---|---|
| | | | US$ | Au$ | |
| ១ | Design Contract for the Project of Agricultural Laboratory Building | China | | | July, 2012 |
| ២ | Management of the Emerald Triangle Protected Forest Complex to Promote Cooperation for Transboundary Biodiversity Conservation between Thailand, Cambodia and Laos (Phase III) | ITTO, Thailand | 2 051 039 | | May, 2012 |
| ៣ | Domestic and International Market Development for High-value Cattle and Beef in Southeast Cambodia | Australia | | 317 310 | 12 April 2012 |
| ៤ | Market-focused Integrated Crop and Livestock Enterprise for Northwestern Cambodia | Australia | | 551 848 | 13 March 2012 |
| សរុប | | | **2 051 039** | **986 158** | |

## ខ- វិធានការ

បន្តអភិវឌ្ឍសមត្ថភាព ដើម្បីអនុវត្តតួនាទីឲ្យកាន់តែមានប្រសិទ្ធភាពក្នុងការសហការ សម្របសម្រួល ពិគ្រោះយោបល់ជាមួយអង្គភាពជំនាញ ក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការមិនមែនរដ្ឋាភិបាល អន្តជាតិ ប្រទេស ស្ថាប័នដៃគូអភិវឌ្ឍន៍ក្នុងអភវឌ្ឍន៍វិស័យកសិកម្មតាមទិសដៅ និងផែនការយុទ្ធសាស្ត្ររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏ដូចជារាជរដ្ឋាភិបាល។

## ៥.៤.៣-ការងារកិច្ចការរដ្ឋបាល

## ក. លទ្ធផល

ឆ្នាំ២០១២នេះ ដោយអនុវត្តតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល និងទិសដៅការងាររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានខិតខំបំពេញតួនាទីយ៉ាងសកម្មលើការងាររៀបចំនិងចរាចរឯកសារផ្សព្វផ្សាយច្បាប់គោលការណ៍ផ្សេងៗ÷

### ក.១. ផ្នែករៀបចំទទួលលិខិតចូលនិងចរាចរឯកសារ

- ទទួលពីស្ថាប័ននានា សរុបចំនួន៤.២៥៥ច្បាប់
- ទទួលពីអង្គភាពក្រោមឱវាទ សរុបចំនួន៤.២៦៣ច្បាប់
- ទទួលពីរាជធានី ខេត្ត សរុបចំនួន ១.៨០៥ច្បាប់

### ក.២ ផ្នែកចុះលិខិតចេញ

- បញ្ជូនទៅក្រសួងស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទរាជធានី ខេត្តសរុបចំនួន៩.៧១៩ច្បាប់
- សេចក្តីសម្រេច និងប្រកាស សរុបចំនួន ៥៩០ ច្បាប់
- ថតចម្លង និងបែងចែងតាមអង្គភាពក្រោមឱវាទ សរុបចំនួន ៥១១ ច្បាប់

-បញ្ជូនលិខិតបទដ្ឋានចុះក្នុងរាជកិច្ច សរុបចំនួន ១០ ច្បាប់

### គ.៣-ការងារសន្តិសុខអនុវត្តនល្អប្រសើរដូចជា

-ភ្ញៀវមកពីអង្គភាពក្រោមឱវាទ សរុបចំនួន ៣.៥៩០ នាក់

-ភ្ញៀវមកពីអន្តរក្រសួង សរុបចំនួន ៣៤២ នាក់

-ភ្ញៀវមកពី រាជធានី ខេត្ត សរុបចំនួន ៤៧១ នាក់

-ភ្ញៀវជាអតិថិជន សរុបចំនួន ៥.៣៥០ នាក់

-ភ្ញៀវអន្តរជាតិ សរុបចំនួន ៥៤ នាក់

### ខ. វាយតម្លៃនិងសំណើ

ជារួមការងារកិច្ចការរដ្ឋបាល បានដំណើរការប្រព្រឹត្តទៅយ៉ាងរលូន និងប្រកបដោយប្រសិទ្ធភាពល្អប្រសើរ។

### គ. វិធានការ

- បណ្តុះបណ្តាលធនធានមនុស្ស ទាំងផ្នែករដ្ឋបាល ផ្នែកជំនាញ និងភាសាបរទេស

-បន្តពង្រឹងប្រសិទ្ធភាពការងាររដ្ឋបាល និងការងារគ្រប់គ្រង និងបែងចែកបញ្ជូនលិខិតស្នាមតាមបែបបទរដ្ឋបាលឱ្យបានទាន់ពេលវេលា។

### ៥.៤.៤-ការងារនីតិកម្មកសិកម្ម

ក្នុងឆ្នាំ ២០១២ នេះ ការងារនីតិកម្មកសិកម្ម បានផ្តោតលើសកម្មភាពដូចខាងក្រោម ÷

-ពង្រឹងការគ្រប់គ្រងការធ្វើអាជីវកម្មសម្ភារកសិកម្ម តាមរយៈការត្រួតពិនិត្យនៅពេលនាំចូលចែកចាយនិងតាមដានត្រួតពិនិត្យជាប្រចាំ ដល់សកម្មភាពធ្វើអាជីវកម្មលក់ដុំ លក់រាយសម្ភារកសិកម្មនៅគ្រប់មូលដ្ឋានរាជធានី ខេត្ត

-ពង្រឹងយន្តការគ្រប់គ្រងសម្ភារកសិកម្មនីតិកម្មកសិកម្មរាជធានី ខេត្ត ដើម្បីជំរុញការអនុវត្តច្បាប់ ការលើកកំពស់ប្រសិទ្ធភាពការគ្រប់គ្រង និងអនុវត្តកម្មវិធីផ្សព្វផ្សាយដល់គ្រប់មូលដ្ឋានរាជធានី ខេត្ត នូវការយល់ដឹងផ្នែក បច្ចេកទេស និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

### ក-លទ្ធផល

### ក.១-ការងារអាជីវកម្មសម្ភារកសិកម្ម

-លិខិតអនុញ្ញាតធ្វើអាជីវកម្មសម្ភារកសិកម្មត្រូវបានផ្តល់ជូន២៧ក្រុមហ៊ុន

-វិញ្ញាបនបត្របញ្ជាក់បញ្ជិកាសម្ភារកសិកម្មត្រូវបានផ្តល់ជូន១២០ក្រុមហ៊ុន ក្នុងនោះ ចំនួន១៩៩៣មុខ ជីកសិកម្មចំនួន៤០០មុខ ថ្នាំកសិកម្មចំនួន៩៦៧មុខ ចំណីសត្វចំនួន២៨០មុខ បសុឱសថ ចំនួន៣២២មុខ និងគ្រាប់ពូជចំនួន២៤មុខ

-ប្រាក់ចំណូលទទួលបានពីសេវាកម្មចុះបញ្ជិកាសម្ភារកសិកម្ម ដែលបានបង់ចូលថវិការដ្ឋចំនួន២៩៨,៩៥០,០០០រៀល

-លិខិតអនុញ្ញាតឱ្យនាំចូលសម្ភារកសិកម្ម ត្រូវបានផ្តល់ជូន១២៦ក្រុមហ៊ុនក្នុងនោះចំនួន ១៥៦មុខ ដូចជា ជីកសិកម្មចំនួន៧០១.១១១តោន នាំចេញជីកសិកម្មចំនួន ៥.០០០តោន ថ្នាំកសិកម្មចំនួន ១១.៧៤៥តោន ចំណីសត្វចំណីបន្ថែមចំនួន ៤០០.០៩៥តោន បសុឱសថចំនួន១.៨០៤តោន ពូជដំណាំចំនួន ១.៩៨៩តោន និងវត្ថុធាតុដើមសម្រាប់ផលិតស្រាបៀរ ចំនួន៤៥៨មុខ

-មូលដ្ឋានអាជីវកម្មលក់ដុំលក់រាយសម្ភារកសិកម្មរាជធានី ខេត្ត ចំនួន៥,៣៣៥កន្លែងក្នុងនោះ មូលដ្ឋានមានលិខិតអនុញ្ញាតបានចំនួន៤,៦៤៤កន្លែង ស្មើនឹង៨៧%និងមូលដ្ឋានគ្មានលិខិតអនុញ្ញាតចំនួន៦៩១កន្លែង ស្មើនឹង១៣%។

### ក.២-ការងារនីតិកម្មកសិកម្មនិងផ្សព្វផ្សាយច្បាប់កសិកម្ម÷

-អភិវឌ្ឍន៍លិខិតបទដ្ឋានគតិយុត្តក្នុងក្រសួងបានចំនួន ១២ច្បាប់ ក្នុងនោះ សេចក្តីព្រាងច្បាប់ចំនួន ០៤ច្បាប់ សេចក្តីព្រាងប្រកាស ចំនួន០៨ច្បាប់ និងពិនិត្យ និងផ្តល់មតិលើលិខិតបទដ្ឋានក្នុងនិងក្រៅក្រសួង ចំនួន៣២ច្បាប់

-អភិវឌ្ឍន៍លិខិតបទដ្ឋានច្បាប់ពាក់ព័ន្ធការគ្រប់គ្រងសម្ភារកសិកម្ម÷ច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម ច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងអនុសញ្ញា Rotterdam ស្តីពី នីតិវិធីនៃការយល់ព្រមផ្តល់ព័ត៌មានជាមុនចំពោះសារធាតុគីមី និងថ្នាំកសិកម្មគ្រោះថ្នាក់ក្នុងពាណិជ្ជកម្មអន្តរជាតិ បទដ្ឋាន គតិយុត្តក្រោមច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម បទដ្ឋានគតិយុត្ត (ប្រកាស) ដែលបានអនុម័តដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងបទដ្ឋានគតិយុត្តដែលបានរៀបចំរួចនិងកំពុងដំណើរការឆ្លងការពិនិត្យ

-ការងារផ្សព្វផ្សាយ អប់រំ និងការបណ្តុះបណ្តាលក្នុងការគ្រប់គ្រងសម្ភារកសិកម្ម÷

- រៀបចំសិក្ខាសាលាថ្នាក់ជាតិចំនួន០១លើក ដើម្បីផ្សព្វផ្សាយច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម នៅរាជធានីភ្នំពេញ ដោយមានសិក្ខាកាមចូលរួមសរុបចំនួន ២៥៣នាក់ និងរៀបចំសិក្ខាសាលាថ្នាក់ក្រោមជាតិចំនួន០៤លើក ដើម្បីផ្សព្វផ្សាយនូវច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មនៅខេត្តចំនួន០៩ ដែលមានអ្នកចូលរួមចំនួន៨០០នាក់
- ប្រជុំផ្សព្វផ្សាយនិងណែនាំស្តីពី នីតិវិធីនិងការតម្រូវក្នុងការចុះបញ្ជីឡើងវិញនិងការតម្រូវលិខិតអនុញ្ញាតក្នុងការធ្វើពាណិជ្ជកម្មថ្នាំកសិកម្មនិងជីកសិកម្ម ដែលមានសិក្ខាកាមចូលរួមសរុប ចំនួន១២២នាក់
- ធ្វើការបែងចែកសៀវភៅច្បាប់ស្តីពី ការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មដល់ថ្នាក់ដឹកនាំក្រសួងអង្គភាពក្រោមឱវាទក្រសួងមន្ទីរកសិកម្ម និងសាលារាជធានី ខេត្តព្រមទាំងក្រសួង ស្ថាប័នពាក់ព័ន្ធសរុបចំនួន ២.១៩០ក្បាល
- សហការជាមួយមន្ទីរកសិកម្មរៀបចំវគ្គ និងធ្វើជាគ្រូឧទ្ទេសនាមក្នុងវគ្គអប់រំសមត្ថភាព វិជ្ជាជីវៈ ដល់អាជីវករលក់ដុំលក់រាយសម្ភារកសិកម្ម នៅក្នុងខេត្តចំនួន១២ខេត្ត ស្មើនឹង ១៧វគ្គ ដែលមានអាជីវករចូលរួមសរុបចំនួន ១,៨៧១នាក់
- ធ្វើសិក្ខាសាលាផ្សព្វផ្សាយនូវលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធការគ្រប់គ្រងសម្ភារកសិកម្មដល់អាជីវករលក់ដុំលក់រាយ លើឃុំចំនួន១២៧ ក្នុងស្រុកចំនួន៩៧ ដែលមានសិក្ខាកាមចូលរួមសរុបចំនួន៨,៩៧៧ នាក់។

## ក.៣- ការងារត្រួតពិនិត្យនិងអនុវត្តច្បាប់ក្នុងការគ្រប់គ្រងសម្ភារកសិកម្ម:

-បានចុះត្រួតពិនិត្យការនាំចូលសម្ភារកសិកម្ម៩៥ក្រុមហ៊ុន បាននាំចូល១៤៤ករណី និងស្នើសុំវិធានការទណ្ឌកម្មចំពោះក្រុមហ៊ុនចំនួន៣៧ក្រុមហ៊ុន ក្នុងនោះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានសម្រេចចេញលិខិតព្រមានចំនួន១៩ក្រុមហ៊ុន ដោយឡែកចំនួន១៨ក្រុមហ៊ុនទៀត ក្រសួងសម្រេចកោះអញ្ជើញមកទទួលសេចក្តីណែនាំនិងបទបញ្ជា ដើម្បីកែតម្រូវកំហុសក្នុងការធ្វើអាជីវកម្មសម្ភារកសិកម្ម

-ត្រួតពិនិត្យមូលដ្ឋានធ្វើអាជីវកម្មលក់ដុំលក់រាយសម្ភារកសិកម្មក្នុងរាជធានី ខេត្ត និងការប្រើប្រាស់សម្ភារកសិកម្មលើដីសម្បទានសេដ្ឋកិច្ចនៅក្នុងខេត្តកំពង់ធំនិងខេត្តរតនគិរី

-ការវិធានការណ៍ចំពោះបទល្មើស÷ (១)-ធ្វើកិច្ចសន្យាបញ្ឈប់បទល្មើសចំនួន៣២ករណី (២)-ធ្វើកិច្ចសន្យាកែតម្រូវចំនួន៦៦៣ករណី (៣)-ចេញលិខិតព្រមានដោយមន្ទីរកសិកម្មចំនួន២៤ករណី (៤)-បញ្ជូនសំណុំរឿងទៅតុលាការ០១ករណីស្នើសុំរឹបអូសវត្ថុតាងជាសម្បត្តិរដ្ឋ (៥)-ចេញលិខិតព្រមានដោយក្រសួងចំនួន០៩ករណី ចំពោះអាជីវករ០៤ខេត្ត និង(៦)-ឃាត់ទុកជាបណ្តោះអាសន្ននូវវត្ថុតាងបទល្មើសមួយចំនួនមាន÷ ថ្នាំកសិកម្មចំនួន២១៩ដប ចំនួន២៥៤កញ្ចប់ និង៥០ប្រអប់ ជីបំប៉នចំនួន ៣៨ដប និងជី NPK ចំនួន៤៤បាវ។

## ក.៤- ចំណូលនិងថវិកាឆ្នាំ២០១២

-ប្រាក់ចំណូលបានពីកម្រៃសេវាកម្មចុះបញ្ជិកាសម្ភារកសិកម្ម ចំនួន២៩៨,៩៥០,០០០រៀល

-ថវិកាចំណាយសម្រាប់គម្រោងថវិការដ្ឋ P3-P4 មាន÷ ផែនការថវិកាចំនួន ១២៦.៧៦០.០០០រៀល ចំណាយជាក់ស្តែងចំនួន ៨១.៤៤៩.០០០រៀល។

### ខ- វាយតម្លៃនិងសំណើ

ទោះជាភាពខ្វះខាតក្នុងការគ្រប់គ្រងសម្ភារកសិកម្ម តែនៅមានសេសសល់នៅឡើយ ប៉ុន្តែភាពជឿនលឿន ចំពោះមុខ បានធ្វើឱ្យមានការប្រែប្រួលច្រើនក្នុងការគ្រប់គ្រងសម្ភារកសិកម្មបច្ចុប្បន្ន ដែលបាន បង្ហាញនូវការខិតខំដ៏ សកម្មរបស់អង្គភាពនីតិកម្ម កសិកម្មកន្លងមកក្នុងការជំនះលើរាល់ឧបសគ្គ និងភាពខ្វះខាត។ លទ្ធផលនេះនឹងបង្កនូវភាពសុទិដ្ឋិនិយមសម្រាប់អង្គភាព ឱ្យបន្តបេសកកម្មរបស់ខ្លួនទៅមុខទៀតរហូតទទួលបានជោគជ័យស្របតាមទិសដៅកំណត់។

### គ- វិធានការ

-បន្តសិក្សារៀបចំបទដ្ឋានគតិយុត្តក្រោមច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម សម្រាប់កម្មវិធីនីតិកម្មឆ្នាំ ២០១៣ និងត្រៀមដាក់ឆ្លងការពិភាក្សានិងពិនិត្យសម្រេចនូវសេចក្តីព្រាងបទដ្ឋាន គតិយុត្តដែលនាយកដ្ឋាននីតិកម្មកសិកម្ម បានសិក្សារៀបចំរួចក្នុង ឆ្នាំ២០១២កន្លងមក

-បន្តអនុវត្តនីតិវិធី និងពង្រឹងសមត្ថភាពក្នុងការអនុវត្តអនុសញ្ញារ៉ូថឺដាមស្តីពី នីតិវិធីនៃការយល់ព្រមផ្តល់ព័ត៌មានជាមុន ចំពោះសារធាតុគីមីនិងថ្នាំកសិកម្មគ្រោះថ្នាក់ក្នុងពាណិជ្ជកម្មអន្តរជាតិ

-បន្តអនុវត្តកម្មវិធីផ្សព្វផ្សាយថ្នាក់ក្រោមជាតិនិងថ្នាក់មូលដ្ឋាននូវច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម ដោយយកចិត្តទុកដាក់ចំពោះខេត្តគោលដៅ និងស្រុក ក្រុង ចំណុះខេត្តគោលដៅ

-បន្តពង្រឹងសមត្ថភាពមន្ទីរពិសោធន៍វិភាគគុណភាពជីកសិកម្ម ដើម្បីវិភាគសារធាតុលោហៈធ្ងន់នៅក្នុងជីកសិកម្ម ដែលជាសារធាតុបង្កគ្រោះថ្នាក់សម្រាប់ការស្នើសុំចុះបញ្ជីជីកសិកម្ម

-បន្តសម្របសម្រួលក្នុងការបង្កើតសមាគមពាណិជ្ជករសម្ភារកសិកម្មកម្ពុជា (C.A.M.T.A) ដើម្បីលើកកម្ពស់ការសម្របសម្រួល និងកិច្ចសហការរវាងក្រុមហ៊ុនពាណិជ្ជកម្មសម្ភារកសិកម្ម ជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងលើកកម្ពស់ការចូលរួមរបស់សមាជិកសមាគមក្នុងការអនុវត្តក្រមសីលធម៌ក្នុងពាណិជ្ជកម្មសម្ភារកសិកម្ម

-បន្តការពង្រឹងសមត្ថភាពរបស់អង្គភាពនីតិកម្មកសិកម្មរាជធានី ខេត្ត តាមរយៈការចុះដឹកនាំធ្វើអធិការកិច្ច ហ្វឹកហាត់ការងារ និងផ្តល់បទពិសោធន៍អនុវត្តដល់មន្ត្រីនៅមូលដ្ឋានដោយផ្ទាល់។

## ៥.៨.៥-ការងារអធិការកិច្ចនិងសវនកម្មផ្ទៃក្នុង

### ក-ការងារអធិការកិច្ច

### ក.១. សកម្មភាពការងារ

-ចុះត្រួតពិនិត្យត្រួតពិនិត្យលើការងារគ្រប់គ្រងលផិតកម្មនិងបសុព្យាបាលដូចជាខេត្ត កំពង់ចាម កណ្តាល ក្រចេះ ព្រះវិហារ ព្រៃវែង រតនគិរី ស្ទឹងត្រែង ស្វាយរៀង តាកែវ ឧត្តរមានជ័យ និងរាជធានីភ្នំពេញ

-ចុះត្រួតពិនិត្យនិងស្រាវជ្រាវបាតុភាពខណ្ឌរដ្ឋបាលជលផលខេត្តរតនគីរីនិងបាតុភាពនៅមន្ទីរកសិកម្មខេត្តព្រះវិហារ និងករណីបាត់ឈើ ដែលជាវត្ថុតាងបទល្មើសព្រៃឈើនៅខណ្ឌរដ្ឋបាលព្រៃឈើខេត្តកំពង់ឆ្នាំង

-ចុះស្រាវជ្រាវបណ្តឹងរបស់តំណាងអាជីវករលក់ថ្នាំកសិកម្ម និងត្រួតពិនិត្យលើការងារគ្រប់គ្រងផ្នែកនីតិកម្មនៃមន្ទីរកសិកម្មខេត្តតាកែវ

-ចុះត្រួតពិនិត្យទីតាំងដីសម្រាប់សាងសង់ស្នាក់ការផ្នែករដ្ឋបាលព្រៃឈើនៅខេត្តតាកែវ និងពង្រឹងការដឹកនាំនិងការគ្រប់គ្រងរបស់មន្ទីរកសិកម្មខេត្តព្រៃវែង

-ចុះត្រួតពិនិត្យមន្ទីរកសិកម្មពាក់ព័ន្ធជាមួយប្រជាពលរដ្ឋស្ថិតនៅភូមិធ្នង់ សង្កាត់រកាក្រៅ ក្រុងដូនកែវ

-ចុះពង្រឹងការអនុវត្តច្បាប់និងទប់ស្កាត់ការកាប់រានដីព្រៃដូចជាខេត្ត ស្ទឹងត្រែងនិងរតនគិរី

-ចុះត្រួតពិនិត្យស្រាវជ្រាវការនាំចូលត្រីរស់ពីប្រទេសវៀតណាម

-ចុះចូលរួមវគ្គបណ្តុះបណ្តាលស្តពី កិច្ចព្រមព្រៀងស្តីពី របាំងបច្ចេកទេសពាណិជ្ជកម្ម អនាម័យនិងភូតគាមអនាម័យ (SPS) និងទីផ្សារកសិកម្មអន្តរជាតិ នៅខេត្តតាកែវ

-ចុះពង្រឹងការងារដឹកនាំនិងគ្រប់គ្រងមន្ត្រីរាជការរបស់មន្ទីរកសិកម្មខេត្តព្រះវិហារ

-ចុះពិនិត្យការរៀបចំសហគន់នេសាទ នៅខេត្ត កណ្តាល តាកែវ ព្រៃវែង និងកំពង់ចាម។

-ចុះពង្រឹងការងារដឹកនាំគ្រប់គ្រងរបស់ខណ្ឌរដ្ឋបាលជលផលព្រៃវែង

## ក.២- លទ្ធផលការងារ

-បានពង្រឹង និងធ្វើការណែនាំដល់ផ្នែកផលិតកម្ម និងបសុព្យាបាលខេត្ត និងមន្ត្រីផលិតកម្ម និងបសុព្យាបាលឲ្យយកចិត្តទុកដាក់លើការងារសត្តឃាតដ្ឋាន និងចាត់វិធានការ នៅតាមបណ្តាខេត្តមួយចំនួន រួមមានខេត្ត ក្រចេះ ស្ទឹងត្រែង និងខេត្តរតនគីរី ដូចជា÷ បញ្ហាអនាម័យសត្តឃាតដ្ឋានត្រូវធ្វើជារៀងរាល់ថ្ងៃឲ្យបានស្អាតល្អនិងត្រូវបាញ់ថ្នាំ TH4 សត្វត្រូវបង្ខាំងទុកឲ្យ បានគ្រប់ចំនួនពី ១២-២៤ ម៉ោងទៅតាមគោលការណ៍បច្ចេកទេសកំណត់ទើបអនុញ្ញាតឲ្យយកទៅពិឃាត ត្រួតពិនិត្យអនាម័យសត្វសាច់ និងផលិតផលមានដើមកំណើតពីសត្វ និងលុបបំបាត់ការពិឃាតសត្វតាមផ្ទះ ឬនៅក្រៅសត្តឃាតដ្ឋាន។

-ជំរុញផ្នែកផលិតកម្មនិងបសុព្យាបាលបង្កើនការខិតខំប្រមូលចំណូលពីវិស័យផលិតកម្មនិងបសុព្យាបាល ទៅតាម លទ្ធភាពជាក់ស្តែង ជាពិសេសនៅតាមសត្តឃាតដ្ឋានតាមក្រុង-ស្រុកនីមួយៗ

-ស្វែងរកដៃគូវិនិយោគលើសត្តឃាតដ្ឋាន ធ្វើយ៉ាងណាឲ្យមានគ្រប់ទីប្រជុំជនស្រុក ដើម្បីឈានបំបាត់ទាំងស្រុងនូវការធ្វើអាជីវកម្មពិឃាតសត្វតាមផ្ទះ

-ត្រូវពង្រឹងការណែនាំដល់ក្រុមត្រួតពិនិត្យដែលមន្ទីរកសិកម្មបានចាត់តាំងនោះ ឲ្យអនុវត្តឲ្យបានម៉ឺងម៉ាត់លើការងារត្រួតពិនិត្យនិងបង្ក្រាបបទល្មើសចលនាសត្វ ជាពិសេសនៅខេត្តកណ្តាល ព្រោះក្នុងករណីតម្លៃជ្រូកសាច់រស់នៅប្រទេសវៀតណាមទាបជាងនៅកម្ពុជានោះជ្រូកវៀតណាម អាចនឹងហូរចូលមកទៀត ។

-បង្កើនការប្រមូលចំណូលនៅតាមសត្តឃាតដ្ឋាន ជាពិសេសគឺចំណូលពីកម្រៃត្រួតពិនិត្យអនាម័យសត្វស្បែកគោក្របី

-ការវិនិយោគទៅលើកសិដ្ឋានចិញ្ចឹមសត្វ (គោ ក្របី) ឲ្យបានច្រើននិងបង្កើនការចាក់ថ្នាំការពារជំងឺសត្វជូនកសិករ ដើម្បីជួយជំរុញផលិតកម្មសត្វមានភាពរីកចម្រើន ជាពិសេសជំរុញនិងមានវិធានការ ចំពោះសត្តឃាតដ្ឋានមានស្រាប់ និងនីតិវិធីនៃការត្រួតពិនិត្យអនាម័យសត្តឃាតដ្ឋានអនាម័យសត្វ និងផលិតផលសត្វ និងពិនិត្យនៅកន្លែងជំងឺសត្វពាហនៈកើតមានឡើងជាយថាហេតុក្នុងរដូវវស្សា

-បានពង្រឹងការងារដល់មន្ត្រីផលិតកម្ម និងបសុព្យាបាលដែលប្រចាំការនៅតាមទីសត្តឃាតដ្ឋានក្នុងខេត្ត ឲ្យធ្វើការកត់ត្រាស្ថិតិសត្វពិឃាត ដោយមានសៀវភៅកត់ត្រាសត្វចូលនិងសត្វពិឃាតប្រចាំថ្ងៃឲ្យបានច្បាស់លាស់ និងធ្វើការអូសត្រាលើសាច់ឲ្យបានត្រឹមត្រូវតាមគំរូត្រាថ្មី ដើម្បីចៀសវាងការយកស្ថិតិសត្វពិឃាតតាមម្ចាស់ទីសត្តឃាតដ្ឋាន ដែលនាំឲ្យបាត់ចំណូលពីកម្រៃសេវាកម្មត្រួតពិនិត្យអនាម័យសត្វ និងសាច់។ ជាមួយគ្នានេះ ត្រូវណែនាំម្ចាស់ទីសត្តឃាតដ្ឋានរៀបចំកន្លែងទីសត្តឃាតដ្ឋាន ឲ្យមានអនាម័យល្អបន្ថែមទៀត និងបាញ់ថ្នាំ TH4 យ៉ាងតិចចំនួន១ដង ក្នុងមួយសប្តាហ៍។

-បានសម្របសម្រួលជាមួយអាជ្ញាធរខេត្ត ដើម្បីផ្ទេរភារកិច្ចការគ្រប់គ្រងសត្តឃាតដ្ឋាន ឲ្យមកសមត្ថកិច្ចជំនាញផលិតកម្មនិងបសុព្យាបាលវិញស្របតាមខ្លឹមសារនៃអនុក្រឹត្យលេខ ១០៨ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០០៧ ស្តីពី ការគ្រប់គ្រងទីសត្តឃាតដ្ឋាន និងធ្វើការត្រួតពិនិត្យការដឹកជញ្ជូនសត្វគោក្របីពីប្រទេសថៃឆ្លងកាត់ទៅកាន់ប្រទេសវៀតណាម ជាខេត្តចំណុចចុងទី ដើម្បីចៀសវាងមានការលួចបន្លំគោក្របីក្នុងប្រទេសចេញដោយខុសច្បាប់ជ្រកក្រោមស្លាកក្រុមហ៊ុន។

## ក.៣. សន្និដ្ឋាន

ទោះបីយើងបានជួបប្រទះនូវការលំបាកមួយចំនួនក្នុងអនុវត្តនៅតាមតំបន់នីមួយៗនៃរាជធានី ខេត្តក៏ដោយ ក៏យើងខិតខំប្រឹងប្រែងពីសំណាក់ថ្នាក់ដឹកនាំនិងមន្ត្រីគ្រប់ផ្នែក អនុវត្តការងារសម្រេចបានលទ្ធផលគួរឲ្យកត់សម្គាល់ និងទទួលបានជោគជ័យ ។

## ក.៤. វិធានការ

-បន្តពង្រឹងសមត្ថភាពមន្ត្រីក្រោមឱវាទឲ្យខិតខំរៀនសូត្រនូវបទពិសោធន៍ល្អៗ ដើម្បីបំពេញភារកិច្ចប្រកបដោយប្រសិទ្ធភាព និងក្តាប់សភាពការណ៍ពាក់ព័ន្ធនឹងវិស័យកសិកម្ម ដើម្បីជាមូលដ្ឋានក្នុងការអនុវត្តការងារ

-បន្តពិនិត្យស្រាវជ្រាវការងារដឹកនាំគ្រប់គ្រងរបស់មន្ទីរកសិកម្មរាជធានី ខេត្ត ដោយផ្តោតលើការងារប្រពលវប្បកម្មដំណាំស្រូវតាមគោលការណ៍ធម្មជាតិឲ្យស្របតាមគោលនយោបាយស្តីពី ការជំរុញផលិតកម្មស្រូវ និងការនាំអង្ករចេញ និងវិស័យផលិតកម្មនិងបសុព្យាបាល។

## ខ-សវនកម្មផ្ទៃក្នុង

### ខ.១. ការងារចុះធ្វើសវនកម្មផ្ទៃក្នុង

ក្នុងឆ្នាំ២០១២នេះ ផ្នែកសវនកម្មផ្ទៃក្នុងបានចុះធ្វើសវនកម្មតាមផែនការសកម្មភាពសវនកម្មប្រចាំឆ្នាំ២០១២ បានចំនួន៣៦អង្គភាព ក្នុងនោះមាន ÷

- អង្គភាពថ្នាក់កណ្តាល : នាយកដ្ឋានកសិ-ឧស្សាហកម្ម នាយកដ្ឋានផលិតកម្មនិងបសុព្យាបាល នាយកដ្ឋាននីតិកម្មកសិកម្ម អគ្គនាយកដ្ឋានកសិកម្ម អគ្គនាយកដ្ឋានកៅស៊ូ រដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ។

- គ្រឹះស្ថានសាធារណៈរដ្ឋបាល : វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា សាកលវិទ្យាល័យភូមិន្ទកសិកម្ម សាលាជាតិកសិកម្មព្រែកលៀប និងសាលាជាតិកសិកម្មកំពង់ចាម។

- មន្ទីរកសិកម្មរាជធានី ខេត្ត : ខេត្តរតនគិរី មណ្ឌលគិរី ស្ទឹងត្រែង ស្វាយរៀង ក្រចេះ កណ្តាល ព្រៃវែង កំពង់ចាម កំពត កែប កំពង់ឆ្នាំង កំពង់ស្ពឺ តាកែវ កោះកុង ព្រះសីហនុ កំពង់ធំ សៀមរាប បាត់ដំបង ព្រះវិហារ ពោធិ៍សាត់ បន្ទាយមានជ័យ ឧត្តរមានជ័យ ប៉ៃលិននិងរាជធានីភ្នំពេញ ។

ជារួមធ្វើការកែលម្អបន្ថែមទៀតលើការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ការគ្រប់គ្រងហិរញ្ញវត្ថុដូចខាងក្រោម ÷

***-ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ*** ដូចជា ស្ថានីយ៍ពិសោធន៍កសិកម្មនៅតាមមន្ទីរកសិកម្មខេត្តមួយចំនួនគ្មាន សកម្មភាព និងត្រូវរងការរំលោភកាន់កាប់ដី រីឯដីមួយចំនួនបានធ្វើប័ណ្ណសម្គាល់ម្ចាស់អចលនវត្ថុរួចហើយ។ ចំពោះកសិកម្មស្រុកមួយចំនួនត្រូវបានសាងសង់រួចរាល់តាមរយៈថវិកាគម្រោងអង្គការនានា និងថវិការដ្ឋ។ ការធ្វើបញ្ជីសារពើភណ្ឌប្រចាំឆ្នាំភាគ ច្រើនបានធ្វើរួចរាល់និងមួយចំនួនទៀតមិនទាន់បានធ្វើការផ្ទៀងផ្ទាត់ឲបានត្រឹមត្រូវ និងចុះហត្ថលេខាជាផ្លូវការនៅឡើយ។ ជាមួយនោះ សម្ភារ សង្ហារិមដែលទិញក្នុងឆ្នាំ បានចុះក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋបានទាន់ពេលវេលា យឺតយ៉ាវក្នុងការជម្រះចេញពីបញ្ជីសារពើភណ្ឌនូវសម្ភារខូចខាតប្រើប្រាស់លែងកើត។ អង្គភាពមួយចំនួនមិនទាន់បានកំណត់តម្លៃដី និងអគារនៅក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ហើយការដោះស្រាយវិវាទដីធ្លីដែលប្រជាពលរដ្ឋកាន់កាប់នៅពុំទាន់បានដោះស្រាយរួចនៅឡើយ ចំពោះរថយន្ត ម៉ូតូ មួយចំនួនដែលប្រើប្រាស់នៅតាមអង្គភាពមិនទាន់មានស្លាកលេខ និង ការគ្រប់គ្រងស្រូវពូជមានភាពអសកម្មនៅតាមមន្ទីរមួយចំនួនអំពីការផ្តល់ស្រូវពូជឱ្យកសិករខ្ចីនិងការប្រមូលមកវិញ។

***-ការគ្រប់គ្រងហិរញ្ញវត្ថុ*** ដូចជា កិច្ចបញ្ជិកាគណនេយ្យ សកម្មភាពការងារនៅតាមមន្ទីរកសិកម្មខេត្តមួយចំនួន មានដំណើរការល្អ ដោយមានគម្រោងនានាជួយឧបត្ថម្ភ ចំពោះរជ្ជទេយ្យករចំណូលបានអនុវត្តការចុះបញ្ជីគណនេយ្យទ្វេភាគតាមគោលការណ៍ហិរញ្ញវត្ថុ តែការប្រមូលចំណូលអាករសត្តឃាតដ្ឋានមកប្រគល់ឲ្យរជ្ជទេយ្យករចំណូល ដើម្បីបង់ចូលថវិកាខេត្តនៅមានភាពយឺតយ៉ាវ។ ការប្រើប្រាស់ប្រេងនៅមានតម្រិតនិងពុំទាន់មានឯកសារសក្ខីប័ត្រគាំទ្រគ្រប់គ្រាន់ និងសម្ភារផ្សេងទៀតសម្រាប់អន្តរាគមន៍នៅមិនទាន់មានលិខិតយុត្តិការគ្រប់គ្រាន់។ ជាមួយនោះ មន្ទីរកសិកម្មមួយចំនួនមិនទាន់បានគ្រោងថវិកាសម្រាប់បង់ពន្ធអាករនិងប្រាក់រង្វាន់លើកទឹកចិត្តមន្ត្រី និងបញ្ហាបំណុលមួយចំនួនមិនទាន់បានដោះស្រាយឱ្យជ្រះស្រឡះ ដូចជាបំណុលសម្ភារកសិកម្ម ចំណូលឡូត៍នៃសាទស្រូវពូជនិងបំណុលត្រូវបង់ចូលថវិការដ្ឋផ្សេងៗទៀត ។

### ខ.២. សន្និដ្ឋាន

ជារួមដោយមានការគាំទ្រពីថ្នាក់ដឹកនាំក្រសួងនិងរាជរដ្ឋាភិបាលលើការងារសវនកម្មផ្ទៃក្នុង ផ្នែកសវនកម្មផ្ទៃក្នុង បានចុះធ្វើសវនកម្មសម្រេចបានលទ្ធផលល្អប្រសើរ ដោយអង្គភាពរងសវនកម្មភាគច្រើនបានយកចិត្តទុកដាក់ ធ្វើការកែលម្អរាល់ចំណុចខ្វះខាតកន្លងមកនិងនៅមានអង្គភាពមួយចំនួនតូចប៉ុណ្ណោះដែលការអនុវត្តកែលម្អតាមអនុសាសន៍នៃការធ្វើសវនកម្មមិនទាន់បានល្អ និងទាន់ពេលវេលា ។

### ខ.៣. ទិសដៅអនុវត្ត

-បន្តស្វែងយល់លិខិតបទដ្ឋានច្បាប់និងប្រមូលព័ត៌មានដែលពាក់ព័ន្ធការងារសវនកម្ម
-បន្តចូលរួមវគ្គបណ្តុះបណ្តាលនានាដែលរៀបចំឡើងដោយក្រុមប្រឹក្សាកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ
-បន្តសហការជាមួយក្រុមជំនាញការធនាគារអភិវឌ្ឍន៍អាស៊ី ADB នៃគម្រោង PFMRDP Component 2 (Public Financial Management for Rural Development)។

## ៩.៤.៦- ការងារកសិ-ឧស្សាហកម្ម

### ក. លទ្ធផល

-បាននឹងកំពុងបន្តកែសម្រួលអត្ថន័យនៃសេចក្តីព្រាងច្បាប់ស្តីពី“ គុណភាពនិងសុវត្ថិភាពផលិតផលកសិកម្ម” ពីភាសាអង់គ្លេសជាភាសាខ្មែរឲ្យស្របទៅនឹងបរិបទនៃព្រះរាជាណាចក្រកម្ពុជា។
-បានសហការជាមួយអង្គការ USAID រៀបចំសេចក្តីព្រាងច្បាប់ស្តីពី គុណភាព និងសុវត្ថិភាពផលិតផលកសិកម្ម
-បានសហការណ៍ជាមួយ AFD ចុះសិក្សាអំពី លទ្ធភាពនៃការអនុវត្តភាពជាដៃគូរវាងក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច និងដីសម្បទានសង្គមកិច្ច។
-បានសហការជាមួយអង្គការ AFD និង GIZ រៀបចំផែនការសកម្មភាពការងារស្តីអំពី“ ផលិតកម្មកសិកម្មតាមកិច្ចសន្យា និងភាពជាដៃគូ”
-បានសម្របសម្រួលដល់ក្រុមហ៊ុន CamAgra ដើម្បីទទួលបានថវិកាគាំទ្រក្នុងការសិក្សា ការពិនិត្យលទ្ធភាព និងការអនុវត្តគម្រោងសាកល្បងស្តីអំពី“ ផលិតកម្មកសិកម្មតាមកិច្ចសន្យា” ពី AFD
-បានចុះបណ្តុះបណ្តាលស្តីពី “បច្ចេកទេសកែច្នៃនិងផ្សំចំណីសត្វ” ក្នុងខេត្តចំនួន ០៣ សរុបចំនួន ៣៦០ នាក់ ដែលចំណាយថវិកាអស់ចំនួន ១១០.៩៧២.០០០៖០០
-បានចុះបណ្តុះបណ្តាលស្តីពី“ ការលើកកំពស់ស្តង់ដា គុណភាពសុវត្ថិភាពនៃផលិតផលកសិកម្ម” ក្នុងខេត្តចំនួន ០៣ សរុបចំនួន ៣៦០ នាក់ ដែលចំណាយថវិកាអស់ចំនួន ១០៩.៧៨៤.០០០៖០០
-បានចុះបណ្តុះបណ្តាលស្តីពី “ផលិតកម្មកសិកម្មតាមកិច្ចសន្យា” ក្នុងខេត្តចំនួន ០៣ សរុបចំនួន ៣៩០ នាក់ ដែលចំណាយថវិកាអស់ចំនួន ១០៦.៨២៩.០០០៖០០។

### ខ. វិធានការ

បន្តពង្រឹងសកម្មភាពចុះត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច និងសមត្ថភាពរបស់មន្រ្តីការិយាល័យកសិឧស្សាហកម្មនៃមន្ទីរកសិកម្មខេត្ត អំពី“ ដំណើរការអភិវឌ្ឍន៍វិស័យកសិឧស្សាហកម្ម”
-បន្តរៀបចំលិខិតបទដ្ឋានច្បាប់និងផ្សព្វផ្សាយជាសាធារណៈអំពី ការអនុវត្តយន្តការអនុក្រឹត្យលេខ៣៦អនក្រ ស្តីពី “ផលិតកម្មកសិកម្មតាមកិច្ចសន្យា”។
-បន្តទំនាក់ទំនង និងសហការជាមួយដៃគូអភិវឌ្ឍន៍នានា លើការអនុវត្តយន្តការផលិតកម្មកសិកម្មតាមកិច្ចសន្យា និងភាពជាដៃគូ រវាងគ្រួសារកសិករខ្នាតតូច និងក្រុមហ៊ុនវិនិយោគខ្នាតធំលើវិស័យកសិឧស្សាហកម្ម

## ៩.៤.៧- ការងារយេនឌ័រ

### ក. ការបណ្តុះបណ្តាល

-បានបើកវគ្គបណ្តុះបណ្តាលនិងផ្សព្វផ្សាយចំណេះដឹងយេនឌ័រអំពី អនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនិងស្ត្រីភេទពីរបាយការណ៍ជាតិលើកទី៤និងលើកទី៥និងពិធីសារ តាមជម្រើសតាំងពីឆ្នាំ២០០៦មកដល់ឆ្នាំ២០១២នេះ ដល់មន្ត្រីរាជការក្នុងក្រសួងតាំងពីថ្នាក់ជាតិរហូតដល់ថ្នាក់ក្រោមជាតិរហូតដល់ថ្នាក់ក្រោមជាតិបានចំនួន១៣០វគ្គ និងមានអ្នកចូលរួមសរុបចំនួន៦.២៥០នាក់ ក្នុងនោះស្ត្រីចំនួន៣.១២០នាក់ស្មើ៨៦%នៃផែនការ
-ក្នុងឆ្នាំ២០១២នេះ បើកវគ្គបណ្តុះបណ្តាលពីចំណេះដឹងយេនឌ័រនិងផ្សព្វផ្សាយពីអនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនិងស្ត្រីភេទ ពីរបាយការណ៍ជាតិលើកទី៤និងលើកទី៥និងពិធីសារតាមជម្រើសក្រុមការងារ មានសិក្ខា

កាមជាភ្នាក់ងារសុខភាពសត្វភូមិបានចំនួន៦វគ្គ ចូលរួមសរុបចំនួន៣០០នាក់ ក្នុងនោះ ស្ត្រីចំនួន១១៤នាក់ ស្មើនឹង៣៨% នៃចំនួនសរុប នៅតាមបណ្តាខេត្តមួយចំនួនដូចជា កំពង់ធំ ពោធិ៍សាត់ សៀមរាប ស្វាយរៀង តាកែវ និងកែប ក្រោមការជួយឧបត្ថម្ភគាំទ្រពីរាជរដ្ឋាភិបាល។

### ខ. ការងារតាមសហគមន៍

ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ អង្គការជាតិ និងអន្តរជាតិ ដែលបានសហការណ៍ជំរុញការងារផ្សព្វផ្សាយពីបច្ចេកទេសនិងបើកវគ្គបណ្តុះបណ្តាលគ្រប់មុខជំនាញ ជូនដល់ប្រជាកសិករផ្ទាល់ក៏ដូចជាកសិករ នៅក្នុងសហគមន៍ដូចជា÷ សហគមន៍អភិវឌ្ឍន៍កសិកម្ម សហគមន៍ព្រៃឈើ សហគមន៍នេសាទជាដើម។ល។ ជាពិសេសកសិករជាស្ត្រីសំដៅ ជំរុញឱ្យចេះប្រើប្រាស់ធនធានធម្មជាតិមាននិរន្តរភាព តុល្យភាព និងជួយលើកកម្ពស់ជីវភាពឱ្យកាន់តែប្រសើរឡើងថែមទៀត និងឱ្យបានសមស្របតាមគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល។

បច្ចុប្បន្នមានស្ត្រីជាច្រើនបានចូលរួមយ៉ាងច្រើនកុះករនៅតាមសហគមន៍ដូចជា÷

-សហគមន៍កសិកម្មមានចំនួន៣៤៦សហគមន៍ដែលមានសមាជិកសរុបចំនួន៣៣.៩០៦នាក់ក្នុងនោះមានស្ត្រីចំនួន១៥.៥៤៧នាក់ ស្មើនិង៤៦%

-សហគមន៍ព្រៃឈើមានចំនួន៤៥០ សហគមន៍ ដែលមានសមាជិកសរុបចំនួន៣០៣.៣១៣ នាក់ ក្នុងនោះមានស្ត្រីចំនួន១៤៦.៣១៤នាក់ ស្មើនិង៤៨%

-សមាគមន៍នេសាទមានចំនួន៥១៦សមាគមន៍ ដែលមានសមាជិកសរុបចំនួន១៥០.០០០នាក់ ក្នុងនោះមានស្ត្រីចំនួន៥៧.០០០នាក់ ស្មើនិង៣៨%។

### គ. វាយតម្លៃនិងសន្និដ្ឋាន

បច្ចុប្បន្នក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ បានដំណើរការអនុវត្តកិច្ចការឆ្ពោះទៅរកសមភាពយេនឌ័រ ដោយផ្តោតគោលដៅទៅលើស្ត្រីនិងបុរស ជាពិសេសលើស្ត្រី គឺធ្វើយ៉ាងណាឱ្យមានតុល្យភាពនៃការចូលរួមរបស់ស្ត្រីក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិនិងសង្គមជាតិប្រកបដោយសមធម៌ ក្នុងន័យចូលរួមបង្កើនផលិតភាពនិងពិពិធភាវូបនីយកម្មកសិកម្ម ដើម្បីចូលរួមក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ តាមទិសដៅអភិវឌ្ឍសហវត្សរ៍នៅកម្ពុជា។

### ឃ. វិធានការ

-បន្តអនុវត្តតាមអនុសាសន៍ របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្នុងការផ្សព្វផ្សាយពីអនុសញ្ញាលុបបំបាត់ទម្រង់នៃការរើសអើងប្រឆាំងនិងស្ត្រីភេទ និងឯកសារដែលពាក់ព័ន្ធឱ្យបានទូលំទូលាយក្នុងវិស័យកសិកម្ម

-បន្តអនុវត្តន៍ទិសដៅទាំង៤នៃគោលនយោបាយនិងយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្ម ឱ្យទទួលបានលទ្ធផលល្អប្រសើរតាមផែនការកំណត់។

## ៥.៩- ធនធានមនុស្សនិងថវិកា

### ៥.៩.១ ការងារបុគ្គលិក និងអភិវឌ្ឍន៏ធនធានមនុស្ស

### ក. លទ្ធផលៈ

ការគ្រប់គ្រងនិងការអភិវឌ្ឍន៍ធនធានមនុស្ស បានដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើន ប្រសិទ្ធិភាពការងារប្រកបដោយសមធម៌ និងជាគោលដៅចម្បងក្នុងការលើកស្ទួយសមត្ថភាពធនធានមនុស្ស ស្របតាមជំនាញបច្ចេកទេស និងវិទ្យាសាស្ត្រ ដើម្បីរួមចំណែកលើកស្ទួយការអភិវឌ្ឍន៍ប្រទេស ដែលជាជ្រុង មួយនៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល។ ក្នុងតួនាទីជាសេនាធិការផ្ទាល់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នាយកដ្ឋានបុគ្គលិកនិអភិវឌ្ឍន៍ធនធានមនុស្សបានខិតខំយកចិត្តទុកដាក់ក្នុងការ ពង្រឹងការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្ស មានជាអាទិ៍ ការងារគ្រប់គ្រងមន្ត្រីរាជការ

ការងាររៀបចំមន្ត្រី កាន់មុខតំណែង ការងាររៀបចំស្នើសុំគ្រឿងឥស្សរិយយស ការងាររៀបចំបៀវត្ស ប្រាក់ធានារ៉ាប់រងសង្គម ការងាររៀបចំតម្លើងកាំបៀវត្ស ការងាររៀបចំដាក់មន្ត្រីគ្រប់អាយុឱ្យចូលនិវត្តន៍ និងការងារអភិវឌ្ឍន៍ធនធាន មនុស្ស ឱ្យស្រប ទៅតាមគោលការណ៍ ច្បាប់ និងលិខិតបទដ្ឋាននានា ។

បច្ចុប្បន្នដំណើរការផលិតកម្មកសិកម្ម បានកំពុងវិវឌ្ឍន៍តាមរបត់នៃទីផ្សារសេរី ដូចនេះ រចនាសម្ព័ន្ធតួនាទី និងភារកិច្ចនៃអង្គភាពនីមួយៗ ចាំបាច់ត្រូវតែកែលំអឱ្យសមស្របតាមសភាពការណ៍ជាក់ស្តែង។ វិស័យកសិកម្មអាចអភិវឌ្ឍន៍ទៅបានគឺ តម្រូវឱ្យមានរចនាសម្ព័ន្ធគ្រប់គ្រងរឹងមាំ និងធនធានមនុស្សមានសមត្ថភាពសមស្រប នៅតាមបណ្តាលអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ មានក្របខណ្ឌ មន្ត្រីរាជការសរុបទូទាំងប្រទេសមានចំនួន៦.៨៧២នាក់ ជានារីចំនួន១.២១៤នាក់ ស្មើនឹង១៧,៦៦% ក្នុងនោះ :

-អង្គភាពថ្នាក់កណ្តាលមានចំនួន៤.១៦៤នាក់ជានារីមានចំនួន៦៧៨នាក់ ស្មើនឹង១៦,២៨%

-អង្គភាពថ្នាក់រាជធានី ខេត្ត មានចំនួន២.៧០៨នាក់ ជានារីមានចំនួន៥៣៦នាក់ ស្មើនឹង១៩,៧៩%

-បានតែងតាំងតម្លើងឋានៈនិងផ្ទេរសម្រួលភារកិច្ចមន្ត្រីរាជការសរុបចំនួន៣៦៣នាក់ ជានារីចំនួន៧៨នាក់

-បានលុបឈ្មោះមន្ត្រីចេញពីក្របខណ្ឌ មានចំនួន៥៥នាក់ ក្នុងនោះ បោះបង់ការងារមានចំនួន១០នាក់ សុំលាឈប់ពីការងារ ចំនួន១០នាក់ និងមរណភាព ចំនួន៣៥នាក់

-បានផ្ទេរមន្ត្រីរាជការចេញក្រៅក្រសួង០៧នាក់ ផ្ទេរចូលក្រសួង០៣នាក់ និងផ្ទេរចេញ-ចូលផ្ទៃក្នុងក្រសួងមានចំនួន៤១នាក់

-បានចេញលិខិតអនុញ្ញាតច្បាប់សម្រាកការងារមានចំនួន៦៩នាក់ ក្នុងនោះ ច្បាប់សម្រាកប្រចាំឆ្នាំមានចំនួន៣៩នាក់ ច្បាប់ព្យាបាលជំងឺមានចំនួន០៨នាក់ និងច្បាប់សម្រាកមាតុភាព មានចំនួន១៧នាក់

-ក្នុងឆ្នាំ២០១២ ក្រសួងបានប្រឡងជ្រើសរើសក្របខណ្ឌថ្មីបានចំនួន ១៦០នាក់ តាមគោលការណ៍របស់រាជរដ្ឋាភិបាលនិងបានបែងចែកមន្ត្រីក្របខណ្ឌថ្មី ឱ្យទៅបម្រើការងារនៅតាមអង្គភាពថ្នាក់កណ្តាល និងមន្ទីរកសិកម្មរាជធានី ខេត្ត

-បានពិនិត្យកែតម្រូវលើការប្រែប្រួលនៃស្ថានភាពបុគ្គលិក និងស្ថានភាពគ្រួសារសម្រាប់ខែមករាដល់ខែធ្នូ ឆ្នាំ២០១២ របស់មន្ត្រីរាជការគ្រប់អង្គភាពថ្នាក់កណ្តាល បញ្ចូលក្នុងតារាងបៀវត្សថ្មី តាមប្រព័ន្ធព័ត៌មានវិទ្យា

-បានចេញប្រកាសដាក់មន្ត្រីរាជការឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស មានចំនួន ៦៦នាក់

-បានចេញប្រកាសឱ្យមន្ត្រីរាជការ ចូលបម្រើការងារនៅអង្គភាពដើមវិញ ចំនួន៤១នាក់

-បានចេញប្រកាសដាក់មន្ត្រីឱ្យចូលនិវត្តន៍ និងបាត់បង់សប្បទាវិជ្ជាជីវៈ ចំនួន២២៥នាក់

-បានចេញប្រកាស ស្តីពីការអនុញ្ញាតឱ្យជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា មានចំនួន១៩៤នាក់ និងពលករអណ្តែត មានចំនួន៨៧១នាក់

-បានបានចេញប្រកាសតម្លើងមួយថ្នាក់តាមកំរិតសញ្ញាបត្រដល់មន្ត្រីរាជការចំនួន៤២នាក់

-បានចេញប្រកាសតម្លើងថ្នាក់ប្រចាំឆ្នាំ២០១២ ជូនមន្ត្រីរាជការកសិកម្មចំនួន២.២៨៣នាក់

-ក្រសួងបានបញ្ជូនមន្ត្រីចូលរួមបណ្តុះបណ្តាលបានចំនួន២៨២នាក់ ក្នុងនោះការបណ្តុះបណ្តាលក្នុងប្រទេសរយៈពេលខ្លី មានចំនួន១១នាក់ និងនៅក្រៅប្រទេសថ្នាក់ក្រោយបណ្ឌិត០១នាក់ និងបណ្ឌិតមានចំនួន០៥នាក់ ថ្នាក់អនុបណ្ឌិតមាន០៨នាក់ និងរយៈពេលខ្លីចំនួន២៥៧នាក់ ដោយឡែកមន្ត្រីរាជការ ជានារីមានចំនួន៣៥នាក់

-នៅឆ្នាំ២០១២នេះ បានធ្វើសំណើសុំផ្តល់គ្រឿងឥស្សរិយយសជូនដល់មន្ត្រីកសិកម្ម បានចំនួន១៩៦៤នាក់ ក្នុងនោះស្រី៣១០នាក់ ចាប់ពីមេដាយការងារសិរិទ្ធ រហូតដល់មេដាយព្រះរាជាណាចក្រថ្នាក់មហាសេរីវឌ្ឍន៍

-បានចេញប្រកាសស្តីពី ការដាក់ឱ្យប្រើប្រាស់គំរូសេចក្តីសម្រេចស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅរបស់ផ្នែកចំណុះការិយាល័យកសិកម្ម ស្រុក ខណ្ឌ

-បានចេញសេចក្តីសម្រេចស្តីពីការកែសម្រួលប្រកាសលេខ ៦០២ ប្រក.កសក.ប ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យ និងអង្គភាពចំណុះនាយកដ្ឋានវិទ្យាស្ថាន និងឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅនៃរដ្ឋបាលព្រៃឈើ។

ក្នុងឆ្នាំ២០១២នេះដែរ ផ្នែកបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស បានអនុវត្តគម្រោងថវិកាតាមកម្មវិធី ដោយបានរៀបចំរចនាសម្ព័ន្ធកសិកម្មឱ្យដល់ថ្នាក់ឃុំ សង្កាត់ ក្នុងនោះបានរៀបចំឯកសារ គតិយុត្តិ សម្រាប់បង្កើតមជ្ឈមណ្ឌលកសិកម្មថ្នាក់ឃុំ-សង្កាត់។ ការបង្កើតមជ្ឈមណ្ឌលកសិកម្មឃុំ-សង្កាត់នេះឡើងគឺ ដើម្បីឆ្លើយតបទៅនឹងគោលនយោបាយស្តីពី ការប្រជុំផលិតកម្មស្រូវ និងការនាំចេញអង្ករបស់រាជរដ្ឋាភិបាល។

ទន្ទឹមនឹងសកម្មភាពដែលបានអនុវត្តខាងលើ ផ្នែកបុគ្គលិកនិងបានកសាងផែនការសម្រាប់ឆ្នាំ២០១៣ ក្នុងនោះ មានផែនការថវិកាតាមកម្មវិធី និងមិនមែនកម្មវិធី ផែនការជ្រើសរើស ក្របខណ្ឌ និងផែនការជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា និងពលកររអណ្តែត ។

**ខ. វាយតម្លៃនិងសំណើរ**

ថ្វីបើមានការខិតខំប្រឹងប្រែងរបស់មន្ត្រីនាយកដ្ឋាន និងដោយមានការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំក្រសួង យ៉ាងណាក៏ដោយក៏ការអនុវត្តន៍ភារកិច្ចទាំងនោះតែងជួបប្រទះនូវការលំបាក ស្មុគស្មាញជាច្រើនទៀតដែលនឹងត្រូវ មានវិធានការមួយចំនួនសម្រាប់កែលំអ និងដោះស្រាយបន្ថែមទៀត ដូចជាៈ

-ការបញ្ជូនឯកសារសម្រាប់តាំងស៊ប់ ពីអង្គភាពថ្នាក់កណ្តាល និងថ្នាក់រាជធានី ខេត្តមួយចំនួនមានការយឺតយ៉ាវ

-ការបញ្ជូនសំណុំឯកសារអំពីស្ថានភាពប្រែប្រួលរបស់មន្ត្រីរាជការ សម្រាប់បញ្ចូលក្នុងតារាងបៀវត្សប្រចាំខែ នៅតែយឺតនាំឱ្យការបញ្ជូនឯកសារទៅរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលមានភាពអូសបន្លាយដែលបានប៉ះពាល់ដល់ការបើកផ្តល់បៀវត្សប្រចាំខែរបស់អង្គភាពក្រោមឱវាទក្រសួង

-រាល់ការបញ្ជូនឯកសារចាត់មន្ត្រីឱ្យទៅចូលរួមវគ្គបណ្តុះបណ្តាលក្នុង និងក្រៅប្រទេស នៅតែមិនទាន់បានអនុវត្តត្រឹមត្រូវតាមការណែនាំរបស់ក្រសួង ពោលគឺឯកសារផ្ញើមកនៅពុំទាន់បានគ្រប់គ្រាន់ និងមានការយឺតយ៉ាវមកមិនទាន់ពេលវេលាកំណត់

-រាល់ការបញ្ជូនឯកសារស្នើសុំមេដាយការងារជូនមន្ត្រីរាជការ នៅតាមបណ្តាអង្គភាពនានាចំណុះក្រសួងគឺនៅមានការយឺតយ៉ាវមិនទាន់ពេលវេលាកំណត់ ទោះបីមានការក្រើនរំលឹកក៏ដោយ ហើយក៏ពុំបានអនុវត្តទៅតាមគោលការណ៍១០% របស់រាជរដ្ឋាភិបាលជាហេតុនាំឱ្យមានការលំបាកក្នុងការអនុវត្តការងារ។

**គ. វិធានការៈ**

-បន្តយកចិត្តទុកដាក់លើការសិក្សាស្រាវជ្រាវ និងកសាងគោលការណ៍ លិខិតបទដ្ឋានណែនាំជាសារាចរ សេចក្តីណែនាំ អំពីការងារគ្រប់មន្ត្រីរាជការ និងរៀបចំបែបបទការអនុវត្តន៍ជាក់ស្តែងក្នុងការគ្រប់គ្រងធនធាន មនុស្សឱ្យល្អប្រសើរតាមប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យាដោយចងក្រងតាមកំរិតសញ្ញាបត្រ មុខជំនាញ និងតាម មុខតំណែង ដើម្បីជាឯកសារសម្រាប់ក្រសួងប្រើប្រាស់

-បន្តរៀបចំសម្របសម្រួលការងារកសាងគោលការណ៍ លិខិតបទដ្ឋាន សេចក្តីសម្រេចនិងប្រកាសជូនអង្គភាពពាក់ព័ន្ធសម្រាប់ពង្រឹងលើការងារបណ្តុះបណ្តាលធនធានមនុស្ស ដោយលើកគម្រោងបញ្ជូនមន្ត្រីរាជការទៅសិក្សារយៈពេលវែង មធ្យម ខ្លីនៅក្នុងនិងក្រៅប្រទេស តាមជំនាញឱ្យបានច្រើន

### ៥.៩.២- ការអភិវឌ្ឍន៍ធនធានមនុស្សនៅតាមគ្រឹះស្ថានអប់រំ

### ក. សាកលវិទ្យាល័យភូមិន្ទកសិកម្ម

**ក.១. លទ្ធផល**

ដោយអនុវត្តតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាកលវិទ្យាល័យ២០១០-២០១៥ និងក្រោមការដឹកនាំតម្រង់ទិសរបស់

ក្រុមប្រឹក្សាភិបាលអាណត្តិទី៣ សាកលវិទ្យាល័យភូមិន្ទកសិកម្មសម្រេចបាននូវលទ្ធផលការងារសំខាន់ៗជាច្រើន ជាពិសេសការងារអប់រំបណ្តុះបណ្តាលធនធានមនុស្ស ការងារស្រាវជ្រាវវិទ្យាសាស្ត្រ ការងារផ្សព្វផ្សាយ និងការងារសហប្រតិបត្តិការជាតិនិងអន្តរជាតិ ។

ក្នុងឆ្នាំ២០១២ មាននិស្សិតសរុបចំនួន ៥ ៦៥៧នាក់ ក្នុងនោះនារី ១ ២៣៣នាក់ (ស្មើនឹង ២២% នៃនិស្សិតសរុប) កំពុងសិក្សានៅក្នុងសាកលវិទ្យាល័យភូមិន្ទកសិកម្ម លើមហាវិទ្យាល័យជំនាញ១០ គឺមហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ បច្ចេកវិទ្យានិងគ្រប់គ្រងកសិកម្ម វិទ្យាសាស្ត្រជលផល កសិឧស្សាហកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ រៀបចំដែនដីនិងរដ្ឋបាលដីធ្លី និងមហាវិទ្យាល័យវិទ្យាសាស្ត្រកៅស៊ូ ដែលបណ្តុះបណ្តាលថ្នាក់បរិញ្ញា និងនៅសាលាក្រោយឧត្តមដែលទទួលបន្ទុកបណ្តុះបណ្តាលថ្នាក់បរិញ្ញាជាន់ខ្ពស់និងបណ្ឌិត ។

យោងតាមក្រាហ្វិកខាងក្រោមបង្ហាញឲ្យឃើញថា ចំនួននិស្សិតចូលសិក្សាក្នុងឆ្នាំទី១នៅសាកលវិទ្យាល័យភូមិន្ទកសិកម្មមាននិន្នាការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំគួរកត់សម្គាល់ ជាពិសេសក្នុងរយៈពេលបីឆ្នាំចុងក្រោយនេះមានកំណើនទ្វេដង។

កំណើននិស្សិតចូលសិក្សាឆ្នាំទី១នៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម ពីឆ្នាំ ២០០៧-២០១៣




ចាប់តាំងពីបើកទ្វារសារជាថ្មីនាឆ្នាំ១៩៨៥មកដល់ឆ្នាំ២០១២នេះ សាកលវិទ្យាល័យភូមិន្ទកសិកម្ម បានរួមចំណែកបណ្តុះបណ្តាលនិស្សិតឲ្យបញ្ចប់ការសិក្សាដោយជោគជ័យលើវិស័យកសិកម្ម អភិវឌ្ឍន៍ជនបទ និងវិស័យពាក់ព័ន្ធផ្សេងៗ សរុបបានចំនួន ៥ ៩៩៣នាក់ (នារី ៩៥៣នាក់ស្មើនឹង ១៦ភាគរយ) ដែលបែងចែកជាថ្នាក់បណ្ឌិតចំនួន ៤នាក់ (នារី១នាក់) បរិញ្ញាជាន់ខ្ពស់ចំនួន ៦១៤នាក់ (នារី៨៦នាក់) បរិញ្ញាចំនួន ៤ ៨៦៩នាក់ (នារី ៨០៨នាក់) និងថ្នាក់បរិញ្ញារងចំនួន ៥០៦នាក់ (នារី ៥៨នាក់) ។ ស្ថិតិនិស្សិតបញ្ចប់ការសិក្សាថ្នាក់បរិញ្ញា បែងចែកតាមជំនាញផ្សេងៗមានបង្ហាញជូនក្នុងក្រាហ្វិកខាងក្រោម ។

ស្ថិតិនិស្សិតថ្នាក់បរិញ្ញាបញ្ចប់ការសិក្សាពី ស.វ.ភ.ក (គិតត្រឹមឆ្នាំ ២០១២)




## ១.១ សហប្រតិបត្តិការជាតិនិងអន្តរជាតិ

ដើម្បីពង្រឹងសមត្ថភាពសាកលវិទ្យាល័យឲ្យកាន់តែរឹងមាំ និងជាពិសេសដើម្បីឈានទៅដល់បទដ្ឋានអន្តរជាតិ សាកលវិទ្យាល័យភូមិន្ទកសិកម្មបានយកចិត្តទុកដាក់ខ្ពស់ជាចម្បងលើកិច្ចសហប្រតិបត្តិការជាតិនិងអន្តរជាតិ។ ជារួមកិច្ច

សហប្រតិបត្តិការអន្តរជាតិបានផ្តល់ឱកាសដល់សាកលវិទ្យាល័យគៀងគរបានមូលនិធិផ្សេងៗ សម្រាប់ដំណើរការការស្រាវជ្រាវវិទ្យាសាស្ត្របច្ចេកទេស ការផ្លាស់ប្តូរនិស្សិតនិងសាស្ត្រាចារ្យទៅវិញទៅមកជាមួយសាកលវិទ្យាល័យដៃគូ ការធ្វើកម្មសិក្សារបស់និស្សិតនិងសាស្ត្រាចារ្យក្នុងនិងក្រៅប្រទេស ការផ្តល់អាហារូបករណ៍ ការផ្សព្វផ្សាយបច្ចេកទេសដល់កសិករ និងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជាដើម ។ ក្នុងឆ្នាំ ២០១២នេះ សាកលវិទ្យាល័យភូមិន្ទកសិកម្មបានបង្កើតកិច្ចសហប្រតិបត្តិការថ្មីបានចំនួន៧ដៃគូ ដូចមានបង្ហាញជូនក្នុងតារាងខាងក្រោម បន្ថែមពីលើដៃគូដែលមានស្រាប់នាពេលកន្លងមក ។

**បញ្ជីឈ្មោះដៃគូសហប្រតិបត្តិការអន្តរជាតិថ្មីក្នុងឆ្នាំ ២០១២**

| ល.រ | ស្ថាប័ន | ប្រទេស | សកម្មភាពកំពុងអនុវត្ត |
|---|---|---|---|
| ១ | Institute for Global Environment Strategies, Center for International Studies in Ecology | ជប៉ុន | ផ្លាស់ប្តូរនិស្សិត |
| ២ | Duksung Women's University | កូរ៉េខាងត្បូង | ផ្លាស់ប្តូរនិស្សិតនិងការងារស្រាវជ្រាវ |
| ៣ | Tokyo University of Agriculture and Technology | ជប៉ុន | ផ្លាស់ប្តូរនិស្សិតនិងការងារស្រាវជ្រាវ |
| ៤ | Gyeong Sang University | កូរ៉េខាងត្បូង | ផ្លាស់ប្តូរនិស្សិត បុគ្គលិក និងការងារស្រាវជ្រាវ |
| ៥ | Kasetsart University | ថៃ | ផ្លាស់ប្តូរនិស្សិត បុគ្គលិក និងការងារស្រាវជ្រាវ |
| ៦ | Nagoya University | ជប៉ុន | ផ្លាស់ប្តូរនិស្សិត បុគ្គលិក និងការងារស្រាវជ្រាវ |
| ៧ | Maejo University | ថៃ | ផ្លាស់ប្តូរនិស្សិត បុគ្គលិក និងការងារស្រាវជ្រាវ |

## ១.២ អាហារូបករណ៍និស្សិត

ក្នុងនាមជាគ្រឹះស្ថានសាធារណរដ្ឋបាល សាកលវិទ្យាល័យភូមិន្ទកសិកម្មបានយកចិត្តទុកដាក់ខ្ពស់ក្នុងការស្វែងរកអាហារូបករណ៍ផ្សេងៗ និងផ្តល់អាហារូបករណ៍ទាំងនោះដល់និស្សិត ជាពិសេសនិស្សិតពូកែ និស្សិតក្រីក្រ និងនិស្សិតមកពីតំបន់ដាច់ស្រយាល ។ ដោយឡែក ក្នុងឆ្នាំសិក្សា២០១២-២០១៣នេះ បន្ថែមលើ អាហារូបករណ៍ផ្តល់ឲ្យដោយរាជរដ្ឋាភិបាល អាហារូបករណ៍ស**ម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត** អាហារូបករណ៍ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាហារូបករណ៍ធនាគារពិភពលោក អាហារូបករណ៍សាកលវិទ្យាល័យភូមិន្ទកសិកម្ម និងដៃគូអភិវឌ្ឍន៍នានា និស្សិតបានទទួលអាហារូបករណ៍ RUA-JICF-JINNAI ជប៉ុន មានចំនួនសរុប ៧០ នាក់ (និស្សិតម្នាក់ៗទទួលបាន ៤០០ ទៅ ៦១៥ USD/ឆ្នាំ) និងអាហារូបករណ៍ Nagao Environment Scholarship ជប៉ុន ចំនួន ៤ នាក់ (និស្សិតម្នាក់ៗទទួលបានថវិកា ២ ០០០យ៉េន/ខែ សម្រាប់ចំណាយលើការរស់នៅ)។

## ១.៣ ការស្រាវជ្រាវនិងផ្សព្វផ្សាយ

ដោយមានកិច្ចសហប្រតិបត្តិការល្អជាមួយដៃគូជាតិនិងអន្តរជាតិ ក្នុងឆ្នាំ២០១២នេះមន្ត្រីសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទកសិកម្មបានចូលរួមអនុវត្តគម្រោងស្រាវជ្រាវ និងគម្រោងអភិវឌ្ឍន៍ចំនួន២០គម្រោង ដែលមានប្រភេទគម្រោង ប្រភព និងថវិកាគម្រោងរួម ដូចខាងក្រោម÷

| | ប្រភេទគម្រោង | ប្រភព | ថវិការួម | លរ | ប្រភេទគម្រោង | ប្រភព | ថវិការួម |
|---|---|---|---|---|---|---|---|
| ១ | កសិកម្មសមស្រប | JICA | 67 669 298 ¥ | ១១ | វេទិកាស្រាវជ្រាវ | IDRC | 182 759$ |
| ២ | កែឆ្នៃអាហារ-ស្រា | JICA | 45 465 000¥ | ១២ | អភិវឌ្ឍន៍ទីផ្សារគោ | ACIAR | 90 000$ |
| ៣ | សហការបណ្តុះបណ្តាល *MSc* | *Belgium* | 534 895 € | ១៣ | ស្មៅចម្រៃនិងទិន្នផលស្រូវ | ACIAR | 30 000$ |
| ៤ | ប៉ារ៉ាស៊ីតសត្វ | Belgium | 65 000 € | ១៤ | កសិកម្មចម្រុះសត្វនិងដំណាំ | ACIAR | 70 000$ |
| ៥ | *EURASIA II* | EC | n/a | ១៥ | ប៉ារាស៊ីតដំណាំ | CARF | 2 72 |
| ៦ | *Techno I, II* | EC | n/a | ១៦ | វារីវប្បកម្ម | CARF | 17 660 $ |
| ៧ | LOTUS III | n/a | n/a | ១៧ | ពង្រឹងសមត្ថភាពកសិករ -បម្រែបម្រួលអាកាសធាតុ | MoE, EC, UNDP, SIDA, Denmark | 300 000 $ |
| ៨ | ពង្រឹងសមត្ថភាពបសុពេទ្យ | USDA | 51 000 | ១៨ | បង្កើនសមត្ថភាព អប់រំកសិកម្ម | Czech | n/a |
| ៩ | គ្រប់គ្រងធនធានធម្មជាតិ | USAID | 53 000 | ១៩ | ប្រព័ន្ធចិញ្ចឹមសត្វ | IFAD, CIAT | 65 000$ |
| ១០ | បន្លែសុវត្ថិភាព | USAID | 50 000 $ | ២០ | ការអនុវត្តន៍ទីវាល | LI | 3 800 $ |

## ១.៤ ការបណ្តុះបណ្តាលក្នុងនិងក្រៅប្រទេស

សាកលវិទ្យាល័យបានធ្វើការអភិវឌ្ឍន៍ធនធានសាស្ត្រាចារ្យ ដោយបានបញ្ជូនមន្ត្រីទៅចូលរួមវគ្គបណ្តុះបណ្តាលក្នុងប្រទេសចំនួន២៥វគ្គ ក្រៅប្រទេសចំនួន២១វគ្គ និង ចូលរួមកម្មវិធីបទបង្ហាញ-សិក្ខាសាលា ក្នុងប្រទេសចំនួន៤៧ដង ចូលរួមកិច្ចប្រជុំ សន្និសីទ សិក្ខាសាលា និងទស្សនកិច្ចសិក្សានៅបរទេសចំនួន២២ដង។ ក្រៅពីនេះមន្ត្រីនិងបុគ្គលិកចំនួន៩រូបកំពុងសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និង៣រូបថ្នាក់បណ្ឌិតនៅក្រៅប្រទេស។ បន្ថែមពីលើនេះ សាកលវិទ្យាល័យបានបញ្ជូននិស្សិតចំនួន៣០រូបទៅធ្វើកម្មសិក្សាទៅប្រទេសអ៊ីស្រាអែល។

## ១.៥ ការកសាងហេដ្ឋារចនាសម្ព័ន្ធសិក្សា

ក្នុងឆ្នាំ២០១២ នេះ សាកលវិទ្យាល័យបាននិងកំពុងធ្វើការសាងសង់អគារសិក្សាមួយខ្នង មាន២៨បន្ទប់ ជាអំណោយ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន និង លោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត ។

## ១.៦ ការចូលរួមអនុវត្តន៍នយោបាយចាស់សកម្មភាពថ្មី

ក្រោយពីរាជរដ្ឋាភិបាល ជាពិសេស **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បានដាក់ចេញនូវការអនុវត្តន៍នយោបាយចាស់សកម្មភាពថ្មី ក្នុងឆ្នាំ២០១២នេះ និស្សិតសាកលវិទ្យាល័យភូមិន្ទកសិកម្មសរុបចំនួន ៤២៩នាក់ បានស្ម័គ្រចិត្តចូលក្នុងក្រុមយុវជនស្ម័គ្រចិត្តសម្តេចតេជោ ចូលរួមចំណែកជាប្រវត្តិសាស្ត្រអនុវត្តនយោបាយនេះ ចុះវាស់វែងដីធ្លីផ្តល់ប័ណ្ណកម្មសិទ្ធិជូនប្រជាជន ក្នុងវគ្គទី ១ ដើម្បីធានាសុវត្ថិភាពក្នុងការកាន់កាប់ដីធ្លី កាត់បន្ថយជម្លោះ កែលម្អជីវភាពប្រជាជន និងជំរុញសេដ្ឋកិច្ចជាតិ។ ហើយសាកលវិទ្យាល័យភូមិន្ទកសិកម្មក៏បានរួមចំណែកផ្តល់ទីតាំងសាកលវិទ្យាល័យសម្រាប់ហ្វឹកហ្វឺនបច្ចេកទេសវាស់វែងដីធ្លី ដល់និស្សិតស្ម័គ្រចិត្ត មុនពេលចេញដំណើរផងដែរ ។

## ក.២. សន្និដ្ឋាននិងការវាយតម្លៃ

ជារួមអាស្រ័យដោយមានការដឹកនាំដ៏ត្រឹមត្រូវរបស់ថ្នាក់ដឹកនាំក្រសួង និងក្រុមប្រឹក្សាភិបាលរបស់សាកលវិទ្យាល័យ និងជាពិសេសការខិតខំប្រឹងប្រែងផ្ទាល់របស់ថ្នាក់ដឹកនាំ មន្ត្រីសាស្ត្រាចារ្យ បុគ្គលិក និងកម្មករ ពេលនេះសាកលវិទ្យាល័យភូមិន្ទកសិកម្មបានទទួលនូវទំនុកចិត្តខ្ពស់ ពីសំណាក់និស្សិតនិងអាណាព្យាបាល ហើយដែលធ្វើឱ្យកំណើននិស្សិតចូលសិក្សាមានការកើនឡើងជាលំដាប់។ សាកលវិទ្យាល័យបានយកចិត្តទុកដាក់ជាសំខាន់ លើការអប់រំប្រកប

ដោយគុណភាព និងផ្សាភ្ជាប់ជាមួយសេចក្តីត្រូវការទីផ្សារការងារនាពេលបច្ចុប្បន្ន និងទៅអនាគត ដោយយកកិច្ចសហប្រតិបត្តិការជាតិនិងអន្តរជាតិជាកត្តាចំបង ។

អ្វីដែលសាកលវិទ្យាល័យភូមិន្ទកសិកម្មសម្រេចបានមកដល់ពេលនេះ គ្រាន់តែជាភាពជោគជ័យមួយផ្នែកប៉ុណ្ណោះ បើប្រៀបធៀបនឹងសេចក្តីត្រូវការអភិវឌ្ឍន៍ដ៏ធំធេងរបស់សាកលវិទ្យាល័យ ។ ដូចនេះសាកលវិទ្យាល័យនៅមានផ្លូវវែងឆ្ងាយបន្តទៀត ក្នុងការកសាងធនធានសាស្ត្រាចារ្យឱ្យបានរឹងមាំនិងគ្រប់ចំនួន កសាងហេដ្ឋារចនាសម្ព័ន្ធអាគារសិក្សា បន្ទប់ពិសោធន៍ សម្ភារពិសោធន៍ស្រាវជ្រាវ ស្ថានីយ៍អនុវត្តជាក់ស្តែង និងហេដ្ឋារចនាសម្ព័ន្ធសម្រាប់ទ្រទ្រង់ជីវិតសិក្សារបស់និស្សិតចាំបាច់ជាច្រើនទៀត ដូចជា អាហារដ្ឋានទំនើប បណ្ណាល័យនិងបណ្ណាគារទំនើប ពហុកីឡដ្ឋាន អន្តេវាសិកដ្ឋាន និងមណ្ឌលសិល្បៈកំសាន្តជាដើម ។

# ខ. សាលាជាតិកសិកម្មព្រែកលៀប

## ខ.១. លទ្ធផល

### ខ.១.១-ការបង្កើនប្រសិទ្ធភាពការដឹកនាំនិងគ្រប់គ្រងអង្គភាព

#### ១.១ ការងារដឹកនាំ

បានរៀបចំកិច្ចប្រជុំពិនិត្យនិងពិភាក្សាលើការងារទាក់ទងទៅនឹងក្រុមប្រឹក្សាភិបាលសាលា សំណើសុំប្រែក្លាយសាលាជាតិកសិកម្មកំពង់ចាមឱ្យទៅវិទ្យាស្ថានជាតិកសិកម្ម ការពង្រឹងការងារគ្រប់គ្រងសារពើភ័ណ្ឌទ្រព្យសម្បត្តិ ចលនៈ និងអចលនៈវត្ថុរបស់រដ្ឋនៅក្នុងសាលាជាតិកសិកម្មកំពង់ចាម ការរៀបចំឯកសារ ដើម្បីសហការជាមួយសម្ព័ន្ធភាពទីក្រុងកាណាដា ការរៀបចំសហប្រតិបត្តិការជាមួយសាកលវិទ្យាល័យហ្វ្រេស៍វ៉ាឡីប្រទេសកាណាដា មន្ត្រីរាជការក្នុងអង្គភាព ការណែនាំនិស្សិតក្នុងការគោរពវិន័យនិងបទបញ្ជាផ្ទៃក្នុង ក្រុមយុវនិស្សិតគ្រប់ជំនាន់គ្រប់ជំនាញស្តីពីយុវជនស្ម័គ្រចិត្តអនុវត្តនយោបាយចាស់-សកម្មភាពភាពថ្មីរបស់សម្តេចតេជោ ។

#### ១.២ ការងារដឹកនាំ

បានប្រជុំវាយតម្លៃលក្ខណៈសម្បត្តិមន្ត្រីរាជការដើម្បីស្នើសុំគ្រឿងឥស្សរិយសសំរាប់ឆ្នាំ២០១៣ បានទទួលគ្រឿងឥស្សរិយសសំរាប់មន្ត្រីរាជការចំនួន១៨រូប ទទួលការតែងតាំងមន្ត្រីរាជការថ្នាក់ប្រធាន-អនុប្រធានការិយាល័យចំណុះឱ្យអង្គភាព សជកកច ចំនួន ១៨រូប ដឹកនាំនិងចាត់តាំងរៀបចំអបអរសាទទិវាបុណ្យជាតិសំខាន់ៗ (៨មិនាទិវានារីអន្តរជាតិ បុណ្យ៧មករា ថ្ងៃជ័យជំនះ បុណ្យអុំទូកអកអំបុក) ផ្តល់រង្វាន់លើកទឹកចិត្តចំពោះនារីដែលមានស្នាដៃក្នុងការបំពេញការងារជូនអង្គភាព បានចាត់ចែងឱ្យសាស្ត្រាចារ្យគ្រប់ជំនាញដើម្បីដឹកនាំនិស្សិតចុះទស្សនៈកិច្ចសិក្សានិងធ្វើកម្មសិក្សារយៈពេលខ្លីដើម្បីពង្រឹងការងារបណ្តុះបណ្តាលតាមដេប៉ាតឺម៉ង់ជំនាញ ។

#### ១.៣ ការងារត្រួតពិនិត្យនិងវាយតម្លៃ

បានរៀបចំទទួលនិងអនុញ្ញាតឱ្យប្រតិភូអធិការកិច្ចនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចុះធ្វើអធិការកិច្ចនៅ សជកកច ស្តីពីការប្រើប្រាស់ថវិការដ្ឋឆ្នាំ២០១១ ទទួលនិងអនុញ្ញាតិឱ្យប្រតិភូត្រួតពិនិត្យទ្រព្យរដ្ឋនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីចុះត្រួតពិនិត្យចំណូល-ចំណាយនិងបញ្ជីសារពើភ័ណ្ឌឆ្នាំ២០១១ ទទួលនិងអនុញ្ញាតិឱ្យមន្ត្រីនៃក្រុមការ ងារសវនកម្មផ្ទៃក្នុងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទចុះ ធ្វើសវនកម្មផ្ទៃក្នុងនៅ សជកកច សម្រាប់អនុវត្តសារពើព័ន្ធឆ្នាំ២០១១ ទទួលនឹងអនុញ្ញាតិឱ្យប្រតិភូគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា (ACC) ចុះណែនាំដើម្បីវាយតម្លៃដំណើរការបណ្តុះបណ្តាលនៅ សជកកច សំរាប់ឆ្នាំសិក្សា២០១១-២០១២ ទទួលនិងអនុញ្ញាតិឱ្យនាយកដ្ឋានលទ្ធកម្មធ្វើការត្រួតពិនិត្យនិងវាយតម្លៃលើសកម្មភាពប្រតិបត្តិការងារលទ្ធកម្មសម្រាប់ឆ្នាំ២០១១ បានរៀបចំប្រជុំបូកសរុបការងារនិងវាយតម្លៃការងារដឹកនាំរបស់អង្គភាពសរាប់ឆមាសទី១ និងលើកទិសដៅអនុវត្តបន្តសម្រាប់ឆមាសទី២ ។

#### ១.៤ ការងាររដ្ឋបាល

បានរៀបចំចាត់ចែងចរាចរឯកសារចេញ-ចូលបានចំនួន ២១៨៧ច្បាប់ ក្នុងនោះ មានលិខិតបេសកកម្មមន្ត្រីរាជការសាស្ត្រាចារ្យ និងថ្នាក់ដឹកនាំ ច្បាប់ ព្រះរាជក្រិត្យ អនុក្រិត លិខិតបទដ្ឋានសារាចរ សេចក្តីណែនាំ និងលិខិតជូនដំណឹង។

### ខ.១.២-កសាងសមត្ថភាពមន្ត្រីសេវាកម្មផ្នែករដ្ឋបាល ផ្នែកបច្ចេកទេស និងសាស្ត្រាចារ្យ

#### ២.១-ស្ថានភាពមន្ត្រីរាជការ,សាស្ត្រាចារ្យ

នៅសាលាជាតិកសិកម្ម កំពង់ចាម មានមន្ត្រីសារុបចំនួន៤៤នាក់ ស្រី០៨នាក់ និងមានសាស្ត្រាចារ្យខាងក្នុងនិងខាងក្រៅសារុបចំនួន ២០៦នាក់ ក្នុងនោះគ្រូបង្រៀនរបស់សាលាបាន៣៨ នាក់ ។ សមត្ថភាពសាស្ត្រាចារ្យដែលបំពេញការងារបណ្តុះបណ្តាលនៅសជកកច មានកម្រិតបណ្ឌិត៩នាក់ កម្រិតបរិញ្ញាបត្រជាន់ខ្ពស់៤៨នាក់ បរិញ្ញា បត្រ ៧០នាក់ និងបរិញ្ញាបត្ររង ១៦នាក់ ។

#### ២.២ ការបង្កើនសមត្ថភាពមន្ត្រីសេវាកម្មផ្នែករដ្ឋបាល

បានបញ្ជូនមន្ត្រីផ្នែករដ្ឋបាលទៅចូលរួមប្រជុំស្តីពី ការគ្រប់គ្រងបុគ្គលិកនិងកិច្ចការរដ្ឋបាលធ្វើសំណើសុំជ្រើសរើសមន្ត្រីក្របខ័ណ្ឌបន្ថែមចំនួន១១នាក់ សម្រាប់ឆ្នាំ២០១៣ ដើម្បីបំពេញសេចក្តីត្រូវការរបស់អង្គភាព ធ្វើសំណើសុំជ្រើសរើសមន្ត្រីជាប់កិច្ចសន្យាចំនួន១០នាក់ និងពលករអណ្តែតចំនួន១៤នាក់ ដើម្បីបម្រើការងារនៅក្នុងអង្គភាព បំពាក់បំប៉នមន្ត្រីជាប់កិច្ចសន្យានិងពលករអណ្តែតលើចំណេះដឹងខាងផ្នែករដ្ឋបាលនិងផ្នែកបច្ចេកទេស ដើម្បីបំពេញការងារក្នុងអង្គភាព បានរៀបចំពង្រឹងសេវាកម្មរក្សាសន្តិសុខសណ្តាប់ធ្នាប់ និងបរិស្ថានអនាម័យក្នុងបរិស្ថាននៃអង្គភាព បានរៀបចំអាហារដ្ឋានសម្រាប់បម្រើសេចក្តីត្រូវការរបស់បុគ្គលិក មន្ត្រីរាជការ និស្សិត នៅក្នុងអង្គភាពសាលា និងការពង្រឹងសកម្មភាពគ្រប់គ្រងឯកសាររដ្ឋបាលនិងចរន្តឯកសារការងារ។

#### ២.៣ ការងារបង្កើនសមត្ថភាពបច្ចេកទេសសម្រាប់មន្ត្រីនិងសាស្ត្រាចារ្យ

បានបញ្ជូនមន្ត្រីទៅសិក្សាអំពីភូតគាមអនាម័យ និងសត្វល្អិតវិទ្យា សិក្ខាសាលាស្តីពី បច្ចេកទេសកសិកម្មការងាររដ្ឋបាល ការដឹកនាំគ្រប់គ្រង វគ្គបំពាក់បំប៉នបច្ចេកទេសកសិកម្ម វគ្គបំពាក់បំប៉នបច្ចេកទេសគ្រប់គ្រង និងវិធីសាស្ត្របង្រៀនបានចំនួន៣៩លើក។

### ខ.១.៣-ការលើកកម្ពស់គុណភាពអប់រំបណ្តុះបណ្តាលបច្ចេកទេសកសិកម្ម

#### ៣.១ ការងារបណ្តុះបណ្តាល

សាលាបានទទួលការបណ្តុះបណ្តាលនិស្សិតសិក្សានៅក្នុងឆ្នាំ២០១២-២០១៣មានចំនួនសរុប១៥៥៩នាក់ ក្នុងនោះមានស្ត្រី៦០៨នាក់ ចែកចេញជានិស្សិតអាហារូបករណ៍ចំនួន១២៩៥ នាក់ ស្ត្រី៥៣៥នាក់ (បរិញ្ញាប័ត្រវិទ្យាសាស្ត្រកសិកម្ម៩១៣នាក់ ស្រី ៣៣៩នាក់ បរិញ្ញាប័ត្ររងបច្ចេកទេសកសិកម្ម៣៨២នាក់ ស្រី ១៩៦ នាក់) និងនិស្សិតសិក្សាបង់ថ្លៃចំនួន២៦៤នាក់ ស្រី៧៣នាក់ បរិញ្ញាបត្រវិទ្យាសាស្ត្រកសិកម្ម២៥២នាក់ ស្រី៧៣នាក់ និងបរិញ្ញាបត្ររង១២នាក់ ស្រី ០នាក់) ។

#### ៣.២ ការពង្រឹងការងារបណ្តុះបណ្តាល

សាលាបានរៀបចំកម្មវិធីពង្រឹងការបណ្តុះបណ្តាល តាមរយៈការផ្តល់ឱកាសឱ្យនិស្សិតនិងសាស្ត្រាចារ្យចំនួន ១.០៨៣នាក់ ចូលរួមប្រជុំសិក្ខាសាលាចុះធ្វើកម្មសិក្សា និងធ្វើទស្សនៈកិច្ចសិក្សារយៈពេលខ្លីនៅតាមបណ្តាមូលដ្ឋានផលិតកម្មកសិកម្មនានា ក្នុងនិងក្រៅប្រទេស ។

#### ៣.៣ ការងារអនិវឌ្ឍផ្នែកអប់រំបណ្តុះបណ្តាល

#### ៣.៣.១ ការកែលម្អការអប់រំបណ្តុះបណ្តាល

បានរៀបចំសម្រួលសមាសភាពគណៈកម្មការពិនិត្យគុណភាពសិក្សា ដើម្បីកែលម្អវិធីសាស្ត្រអប់រំនិងបណ្តុះបណ្តាលរៀបចំធ្វើសិក្ខាសាលាស្តីពីការអភិវឌ្ឍន៍កម្មវិធីសិក្សា ចុះពង្រឹងនិងត្រួតពិនិត្យលើការអនុវត្តសកម្មភាពរបស់ថ្នាក់ឆ្នាំសិក្សា

មូលដ្ឋាន បានបង្កើនការសិក្សាអនុវត្តឱ្យបានច្រើនដើម្បីផ្តល់ឱកាសឱ្យនិស្សិតបានទទួលចំណេះដឹងជាក់ស្តែងបានសហការរៀបចំការចែករំលែកនិងការផ្លាស់ប្តូរបទពិសោធន៍ តាមរយៈការអញ្ជើញវាគ្មិនវិទ្យាសាស្រ្តក្នុងស្រុកធ្វើបទអន្តរាគមន៍វិទ្យាសាស្ត្រនិងបច្ចេកទេសកសិកម្ម ។

### ៣.៣.២ ការងារអភិវឌ្ឍកម្មវិធីសិក្សា

បានរៀបចំគណកម្មការអភិវឌ្ឍកម្មវិធីសិក្សា បានរៀបចំនិងកែលម្អកម្មវិធីសិក្សា បានធ្វើការកែលម្អគោលការណ៍សម្រាប់សរសេររបាយការណ៍បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្ររងបច្ចេកទេសកសិកម្មនិងគោលការណ៍ចងក្រងសារណាបទបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រកសិកម្ម បានរៀបចំប្រតិទិនការងារសម្រាប់ផ្តល់ឱ្យនិស្សិត-សាស្ត្រាចារ្យមានឱកាសធ្វើការស្រាវជ្រាវពិសោធន៍ចងក្រងសារណាបទបញ្ចប់ការសិក្សា។

### ៣.៣.៣ ការងារអភិវឌ្ឍកម្មវិធីសិក្សា

កសាងផែនការបណ្តុះបណ្តាល ផែនការសម្រាប់ធ្វើការវាយតម្លៃការងារនិងការងាររៀនរបស់និស្សិត និងការបង្រៀនរបស់សាស្ត្រាចារ្យ។

### ៣.៣.៤ ការងារបណ្តុះបណ្តាលកសិករនៅតាមមូលដ្ឋាន

បានរៀបចំវគ្គបណ្តុះបណ្តាលកសិករចំនួន ២៤២នាក់ នៅក្នុងខេត្តកំពង់ចាមនិងខេត្តតាកែវ ដោយផ្តោតលើការធ្វើប្រព័ន្ធកសិកម្មចំរុះ ការចិញ្ចឹមត្រីក្នុងថង់ប្លាស្ទិច ការធ្វើជីកំប៉ុស្ត ការដាំដំណាំផ្សិត ការចិញ្ចឹមជ្រូក ការចិញ្ចឹមមាន់ ការដាំដំណាំបន្លែ ការសង់ចង្ក្រានកែច្នៃធ្វើស្តុរគ្នោតជាដើម។

### ៣.៣.៥ ការងារសហការជាមួយគម្រោងនានា

បានសហការចូលរួមនិងអនុវត្តកម្មវិធីគម្រោងមួយចំនួន ដូចជា កម្មវិធីឥណទានពូជស្រូវ កម្មវិធីឥណទានជ្រូកមេ កម្មវិធីឥណទានគោមេ កម្មវិធីឡជីវៈឧស្ម័ន កម្មវីធីចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ កម្មវិធីដាំដំណាំបន្លែ កម្មវិធីឥណទានជ្រូកមេ និងកម្មវិធីឥណទានមេគោ។ ក្រៅពីនេះ សាលាក៏បានសហការជាមួយអង្គការ ACIAR (Australia Center International Agricultural Research) OSICA –International Cambodia, DelPHE-UK, TOYO University, FCM (Federation of Canadian Municipalities), Palm Tree School International, Cel-Agrid, CEDAC ទាក់ទងទៅនឹងការងារស្រាជ្រាវដំណាំកសិកម្ម ផលិតកម្មកសិកម្ម ការចិញ្ចឹមសត្វ ការអភិវឌ្ឍន៍សេដ្ឋកិច្ចមូលដ្ឋាននិងភាសាបរទេស។

## ខ.២. សន្និដ្ឋាន

ដោយផ្អែកលើលទ្ធផលសម្រេចបានក្នុងឆ្នាំ២០១២ ជាមួយនិងបញ្ហាប្រឈមមួយចំនួន សាលាជាតិកសិកម្មកំពង់ចាម អាចវាយតម្លៃបានថា សាលាកំពុងបោះជំហ៊ានក្នុងរូបភាពវិជ្ជមានឆ្ពោះទៅកាន់ការអភិវឌ្ឍន៍ និងពង្រឹងខ្លួនឲ្យក្លាយទៅជាគ្រឹះស្ថានអប់រំបច្ចេកទេសផ្នែកឧត្តមសិក្សាលើការអភិវឌ្ឍន៍ធនធានមនុស្ស ឆ្លើយតបបាន និងរួមចំណែកក្នុងការអភិវឌ្ឍន៍យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលសម្រាប់អណត្តិថ្មីនេះ។

## ខ.៣. ទិសដៅ

-បន្តលើកកម្ពស់ និងបង្កើនប្រសិទ្ធភាពនៃការដឹកនាំគ្រប់គ្រងអង្គភាព សជកកច ឱ្យទទួលបាននូវការឆ្លើយតបពីគុណភាពនៃការអប់រំនិងបណ្តុះបណ្តាល ក្នុងនោះផ្តោតសំខាន់ទៅលើការដឹកនាំ ការគ្រប់គ្រង និងចាត់តាំង ការងារត្រួតពិនិត្យនិងវាយតម្លៃ ការងាររដ្ឋបាលសាធារណៈ និងការងារសង្គម

-បន្តលើកកម្ពស់និងបង្កើនសមត្ថភាពមន្ត្រីរាជការ សាស្ត្រាចារ្យ គ្រូបង្រៀនឱ្យសមស្របសម្រាប់ការបណ្តុះបណ្តាលវិស័យកសិកម្ម និងធានាបានគុណភាពអ្នកបច្ចេកទេស

-បន្តលើកកម្ពស់គុណភាពបណ្តុះបណ្តាលបច្ចេកទេសកសិកម្ម ក្នុងនោះ សាលាត្រូវផ្តោតសំខាន់ទៅលើការងារបណ្តុះបណ្តាលផ្នែកទ្រឹស្តី និងការអនុវត្តជាក់ស្តែង កែលម្អកម្មវិធីសិក្សា និងការបណ្តុះបណ្តាលរៀបរយ និងបណ្តុះបណ្តាលមិនរៀបរយ

-បន្តការលើកកម្ពស់គុណភាពនៃការគោរពវិន័យនិងបទបញ្ជាផ្ទៃក្នុង។ ផ្នែកនេះសាលាមានគម្រោងរៀបចំកែលម្អវិន័យគ្រូបង្រៀន វិន័យសម្រាប់និស្សិតនិងកែលម្អបទបញ្ជាផ្ទៃក្នុង ឱ្យបានសមស្របទៅនឹងការអបរំជាន់ខ្ពស់លើវិស័យកសិកម្ម

-បន្តការកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការងារបំពាក់ទព្វសម្ភារៈ។ អង្គភាព សជកកច ស្ថិតនៅស្ថានភាពលំបាកផ្នែកថវិកាសម្រាប់ការកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការបំពាក់ទព្វសម្ភារៈ

-បន្តការលើកកម្ពស់សម្រាប់ការផ្ទេរបច្ចេកវិជ្ជាជូនដល់កសិករ ក្នុងនោះសាលាបានរៀបចំគម្រោងសហការជាមួយអាជ្ញាធរមូលដ្ឋានក្នុងការបណ្តុះបណ្តាលកសិករតាមកម្មវិធីបើកវគ្គបណ្តុះបណ្តាលខ្លីៗ និងធ្វើការបង្ហាញតាមរូបភាពដែលបានមកពីការពិសោធន៍

-បន្តលើកកម្ពស់រួមចំណែកអនុវត្តនយោបាយកាត់បន្ថយភាពក្រីក្រ ក្នុងនោះសាលានៅតែរក្សាការផ្តល់អាហារូបករណ៍ជូនដល់និស្សិតក្រីក្រតាមរយៈ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន និង លោកជំទាវសម្តេចអគ្គមហាពញាចក្រី ហេង សំរិន ឯកឧត្តម ចាន់ សារុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ**ព្រមទាំងរួម ចំណែកចុះសកម្មភាពកសាងធនធានសម្រាប់ធ្វើឥណទានជ្រូក ឥណទានស្រូវ និងឥណទានគោជាដើម សំដៅគាំទ្រនិងលើកកម្ពស់ចំណូលប្រជាពលរដ្ឋក្រីក្រនៅទីជនបទ

-បន្តលើកកម្ពស់រក្សាការពារសន្តិសុខ សុវត្ថិភាពក្នុងអង្គភាព ក្នុងនោះសាលាចាំបាច់ចាត់ការរៀបចំកម្លាំងយាមកាម និងការពារទ្រព្យសម្បត្តិអង្គភាពក៏ដូចជាទ្រព្យសម្បត្តិរបស់បុគ្គលិក សាស្ត្រាចារ្យ គ្រូបង្រៀននិងនិស្សិត។ បង្កើនការយកចិត្តទុកដាក់លើអនាម័យ បរិស្ថាននិងការរៀបចំឱ្យមានអាហារដ្ឋានឱ្យបានសមរម្យសម្រាប់អង្គភាព

-បន្តការងារពង្រឹងកិច្ចសហប្រតិបត្តិការជាតិនិងអន្តរជាតិ ដោយនៅតែបន្តការសហការជាមួយដៃគូចាស់ ហើយខិតខំស្វែងយល់រកដៃគូថ្មីៗទៀតសម្រាប់ការអភិវឌ្ឍអង្គភាព ក្នុងនោះសាលាសម្លឹងឃើញដៃគូប្រទេសកូរ៉េ និងប្រទេសចិន

-បន្តលើកម្ពស់ការងារស្រាវជ្រាវនិងការងារផ្សព្វផ្សាយ កិច្ចការនេះសាលាត្រូវការលើកគម្រោងសម្រាប់ស្នើសុំថវិកាចំណាយលើការងារពិសោធន៍ស្រាវជ្រាវ ពិសេស ការងារចិញ្ចឹមសត្វ ការងារដាំដុះ និងការងារចិញ្ចឹមត្រីជាដើម។

### ៥.៩.៣- ការងារគណនេយ្យ-ហិរញ្ញវត្ថុ

### ១. លទ្ធផល

### ក. ការងារចំណូល

ក្នុងឆ្នាំ២០១២ ការប្រមូលចំណូលចូលថវិកាជាតិសម្រេចបានចំនួន ៤៤.៦៤៩.១៧៤.៦៧៦ រៀល ដែលមានប្រមាណ ១៤៧% នៃផែនការរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចំនួន ៣១.៥៥៨.០០០.០០០ រៀល ក្នុងនោះ ÷

-ចំណូលពីផលទុននៃទ្រព្យសម្បត្តិរដ្ឋសម្រេចបានចំនួន ៣១.៧០១.០៦៦.៧៩៦ រៀល ដែលមានប្រមាណ ១២៦%នៃផែនការចំនួន ២៥.១៦២.០០០.០០០រៀល

-ចំណូលផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និងសេវាប្រមូលបានចំនួន ៦.៥៥៥.៤៧៩.០៩០ រៀលស្មើនឹង១២១ % នៃផែនការដែលមានចំនួន៥.៣៩៦.០០០.០០០រៀល ។

-ចំណូលបានមកពីការផាកពិន័យ និងដាក់ទណ្ឌកម្មចំនួន ៦.៣៩២.៦២៨.៧៩០ រៀលស្មើនឹង៦៣៩% នៃផែនការចំនួន១.០០០.០០០ ០០០រៀល។

### ខ. ការងារចំណាយ

ការអនុវត្តនិងគ្រប់គ្រងថវិកាប្រចាំឆ្នាំ២០១២ សម្រេចបានប្រមាណ ៨៩,៨០% នៃថវិកាកែតម្រូវ។ ការចំណាយថវិការបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានញែកដាច់ពីគ្នារវាងថវិកាតាមកម្មវិធី និងថវិកាមិនមែនតាមកម្មវិធី ដូច្នេះយើងអាចវិភាគខ្ទង់ចំណាយថវិកានីមួយៗដូចខាងក្រោម ÷

**១-ថវិកាមិនមែនកម្មវិធី**: ការចំណាយលើការងាររដ្ឋបាលប្រចាំថ្ងៃ និងការអនុវត្តប្រចាំឆ្នាំ អនុវត្តបាន

ប្រមាណ៤៩ ៥៣១ ៧១២ ៥៨២ រៀល ស្មើនឹង៨៩,៨៨ ភាគរយ នៃថវិកាកែតម្រូវចំនួន៥៥ ១០៧ ៥០០ ០០០ រៀល។ការចំណាយតាមជំពូកនីមួយៗមានដូចខាងក្រោម:

**ជំពូក ៦០**: ការទិញអនុវត្តជាក់ស្តែងបានចំនួន១២ ៣៣៥ ៨៧៣ ៦៩៧រៀល ស្មើនឹង៩៧,២១% នៃថវិកាកែតម្រូវដែលមានត្រឹមតែចំនួន១២ ៦៩០ ០០០ ០០០រៀល

**ជំពូក ៦១**: សេវាខាងក្រៅអនុវត្តជាក់ស្តែងបានចំនួន១ ៣៩២ ៥៥៤ ៩៥៩រៀល ស្មើនឹង៧៧,៣៦%នៃថវិកាកែតម្រូវដែលមានចំនួន១ ៨០០ ០០០ ០០០រៀល

**ជំពូក ៦២**: សេវាក្រៅផ្សេងៗអនុវត្តជាក់ស្តែងបានចំនួន៤ ៧១០ ៣៦២ ២៥២រៀលស្មើនឹង៩១,៦៩%នៃថវិកាកែតម្រូវដែលមានចំនួន៥ ១៣៧ ៥០០ ០០០រៀល

**ជំពូក ៦៣**: ពន្ធ និងអាករ អនុវត្តជាក់ស្តែងបានចំនួន១៦៨ ១៦២ ០០០រៀល ស្មើនឹង៧០,០៧%នៃថវិកាកែតម្រូវដែលមានចំនួន២៤០ ០០០ ០០០រៀល

**ជំពូក ៦៤**: បន្ទុកបុគ្គលិកអនុវត្តជាក់ស្តែងបានចំនួន២៣ ៧៨២ ០០០ ៧៦៣រៀល ស្មើនឹង៨៧,១១%នៃថវិកាកែតម្រូវដែលមានចំនួន២៧ ៣០០ ០០០ ០០០រៀល

**ជំពូក ៦៥**: ឧបត្ថម្ភកធន និងជំនួយសង្គមអនុវត្តជាក់ស្តែងបានចំនួន៧ ១៤២ ៧៥៨ ៩១១រៀលស្មើនឹង៨៩,៩៦% នៃថវិកាកែតម្រូវដែលមានចំនួន៧ ៩៤០ ០០០ ០០០រៀល។

**២-ថវិកាតាមកម្មវិធី** :ការចំណាយថវិកាសំដៅសម្រេចឲ្យបានគោលបំណង គោលដៅ និងលទ្ធផលរំពឹងទុក របស់វិស័យនិមួយៗដែលបានកំណត់ពីដើមឆ្នាំ២០១២នេះ ការប្រើប្រាស់ថវិកាតាមកម្មវិធីមានលក្ខណៈល្អប្រសើរច្រើនធៀបនឹងឆ្នាំ ២០១១ ជាក់ស្តែងក្រសួងអនុវត្តបានចំនួន១៦ ៤៦៧ ១៥៣ ៥០០រៀល ដែលមានប្រមាណ៩៣,៦៣ភាគរយនៃថវិកាកែតម្រូវចំនួនប្រមាណ១៧ ៥៨៧ ៤០០ ០០០រៀល។ ការចំណាយតាមជំពូកនីមួយៗមានដូចខាងក្រោម

**ជំពូក ៦០**: ការទិញអនុវត្តជាក់ស្តែងបានចំនួន៤ ៨៥៤ ៤៨៥ ៤០០ រៀល ស្មើនឹង ៩៤,៣៤%នៃថវិកាកែតម្រូវដែលមានចំនួន៥ ១៤៦ ០០០ ០០០រៀល

**ជំពូក ៦១**: សេវាខាងក្រៅអនុវត្តជាក់ស្តែងបានចំនួន៥ ៨៤៣ ៧៥៦ ២០០រៀល ស្មើនឹង៩៣,៤៧%នៃថវិកាកែតម្រូវដែលមានចំនួន៦ ២៥៦ ០០០ ០០០រៀល

**ជំពូក ៦២**: សេវាក្រៅផ្សេងៗអនុវត្តជាក់ស្តែងបានចំនួន៥ ៧៣៨ ៩១១ ៩០០រៀល ស្មើនឹង៩៣,២៣%នៃថវិកាកែតម្រូវដែលមានចំនួន៦ ១៥៥ ៤០០ ០០០រៀល

**ជំពូក ៦៥**: ឧបត្ថម្ភកធន និងជំនួយសង្គមអនុវត្តជាក់ស្តែងបានចំនួន ៣០ ០០០ ០០០ រៀល ស្មើនឹង ១០០%នៃថវិកាកែតម្រូវដែលមានចំនួន៣០ ០០០ ០០០រៀល។




## គ. ការងារផ្គត់ផ្គង់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-ប្រេងឥន្ធនៈគិតជាទឹកប្រាក់សរុបចំនួន:**១ ៩៨៤ ៧៩២ ០០០៖០០** ក្នុងនោះ :

| | | |
|---|---|---|
| +ប្រេងម៉ាស៊ូត | មានទឹកប្រាក់ ចំនួន | ១ ៦៤៩ ៩៩៦ ០០០៖០០ |
| +ប្រេងសាំង | មានទឹកប្រាក់ចំនួនៈ | ៣៣៤ ៧៩៦ ០០០៖០០ |
| -សម្ភារការិយាល័យ | មានទឹកប្រាក់ចំនួន | ៤០៩ ៨៩០ ០០០៖០០ |
| -សម្ភារបរិក្ខារនិងសង្ហារឹម | មានទឹកប្រាក់ចំនួន | ៦៥៦ ៨៧០ ០០០៖០០ |
| -ឯកសណ្ឋាន | មានទឹកប្រាក់ចំនួន | ២៤៨ ៥៧៤ ០០០៖០០ |
| -សម្ភារនិងបរិក្ខារពិសោធន៍ | មានទឹកប្រាក់ចំនួន | ៤ ៤៨៦ ៥៧០ ០០០៖០០ |

### ឃ. ការងារគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ

-បានសហការជាមួយតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចូលរួមពិនិត្យនិងបិទបញ្ជីគណនេយ្យ ការិយបរិច្ឆេទ ២០១១ របស់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា សាកលវិទ្យាល័យភូមិន្ទកសិកម្ម សាលាជាតិកសិកម្មកំពង់ចាម វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា និងសាលាជាតិកសិកម្មព្រែកលៀប

-ចូលរួមផ្ទៀងផ្ទាត់តារាងប្រៀបធៀបទ្រព្យសម្បត្តិរដ្ឋកើនឡើង ថយចុះឆ្នាំ២០១១ នៅមន្ទីរកសិកម្មខេត្តដូចជា បន្ទាយមានជ័យ បាត់ដំបង កំពង់ចាម កំពង់ឆ្នាំង កំពង់ធំ កណ្តាល ក្រចេះ មណ្ឌលគិរី ព្រះវិហារ ព្រៃវែង ពោធិ៍សាត់ សៀមរាប ព្រះសីហនុ ស្ទឹងត្រែង ឧត្តរមានជ័យ កែប និងប៉ៃលិន

-បានចូលរួមប្រជុំនិងចុះពិនិត្យវាស់វែងជាក់ស្តែងទីតាំងផ្ទៃដី ដែលមន្ទីរកសិកម្មខេត្តបាត់ដំបងត្រូវផ្ទេរជូនសាកលវិទ្យាល័យបាត់ដំបងរបស់ក្រសួងអប់រំយុវជននិងកីឡា

-បានរៀបចំរបាយការណ៍និងលិខិតសុំគោលការណ៍សម្រេចពីថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីលទ្ធផលនៃការពិនិត្យសិក្សានិងវាយតម្លៃដីនិងអគារចំនួន០១កន្លែង ស្ថិតនៅផ្លូវមុនីយ៉ាតកែងផ្លូវព្រះបាទជ័យវរ្ម័នទី៧ ក្នុងក្រុមទី១ ភូមិទី១៣ សង្កាត់ ក្រុងកំពង់ចាមដែលអគ្គនាយកដ្ឋានកៅស៊ូ សុំជម្រះចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ

-ធ្វើលិខិតជម្រាបជូនអគ្គនាយកដ្ឋានកៅស៊ូស្តីពី សំណើសុំផ្តល់របាយការណ៍ប្រចាំខែអំពី ស្ថានភាពទូទៅនិងស្ថានភាពគ្រប់គ្រងចម្ការកៅស៊ូរដ្ឋឡាបានសៀក ខេត្តរតនគិរីរបស់ក្រុមហ៊ុនស៊ីសរ៉ាប់បើលីមីតធីត

-បានចូលរួមសហការជាមួយមន្ទីររៀបចំដែនដីនគរូបនីយកម្មនិងសំណង់ និងសុរិយោដីខេត្តកំពង់ចាមក្នុងដំណើរការអនុវត្តនីតិវិធីចុះបញ្ជីនិងចេញប័ណ្ណកម្មសិទ្ធិកាន់កាប់ដីចម្ការកៅស៊ូមេមត់ខេត្តកំពង់ចាម

-បានចុះពិនិត្យតាមដានការងារដោះដូរទីតាំងរបស់មន្ទីរកសិកម្មខេត្តសៀមរាបនិងរៀបចំឯកសារប្រគល់ទទួលទ្រព្យសម្បត្តិទីតាំងសំណង់ថ្មីនិងផ្ទេរកម្មសិទ្ធិទីតាំងចាស់ជូនក្រុមហ៊ុនហ្វុយជីហ្វ៊ីម ខូ អិលធីឌី

-បានធ្វើលិខិតជម្រាបជូនក្រុមហ៊ុនណំអ៊ីស ឡាំប៊ឺរស្តីពីករណីសំណើសុំជួលបន្តរោងចក្រអារឈើថ្នល់បំបែកខេត្តកំពង់ធំរបស់រដ្ឋបាលព្រៃឈើ

-បានចុះពិនិត្យ វាយតម្លៃជាក់ស្តែង និងរៀបចំ ឯកសារសុំគោលការណ៍ទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវរថយន្ត ម៉ូតូ សម្ភារ ឧបករណ៍ការិយាល័យនិងសង្ហារឹម ដែលស្នើសុំជម្រះ ចេញពីបញ្ជីសារពើភណ្ឌរបស់អគ្គាធិការដ្ឋាន នាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ អគ្គនាយកដ្ឋានកសិកម្ម មន្ទីរកសិកម្មខេត្តព្រៃវែង និងមន្ទីរកសិកម្មខេត្តកំពត

-បានចុះជំរុញឲ្យសាកលវិទ្យាល័យភូមិន្ទកសិកម្ម វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជាសាលាជាតិកសិកម្មកំពង់ចាម និងសាលាជាតិកសិកម្មព្រែកលៀប រៀបចំឲ្យបានឆាប់នូវការរៀបចំឯកសារកំណត់ទុនគ្រាដំបូងដើម្បីដាក់សុំការពិនិត្យសម្រេចពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានចុះពិនិត្យស្រាវជ្រាវជាក់ស្តែងនិងរៀបចំលិខិតទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្នើសុំគោលការណ៍ជួលនូវទីតាំងដីរបស់ខណ្ឌរដ្ឋបាលព្រៃឈើក្រុងព្រះសីហនុចំនួន៤ហត សម្រាប់ដាក់កាកសំណល់ស្រាបៀរអង្គរជូនក្រុមហ៊ុនយសសុវណ្ណគន្ធារស់ ចំកាត់

-បានចូលរួមពិនិត្យទីតាំងដីរបស់មន្ទីរកសិកម្មខេត្តតាកែវដែលរដ្ឋបាលព្រៃឈើស្នើសុំសម្រាប់សាងសង់ស្នាក់ការផ្នែករដ្ឋបាលព្រៃឈើតាកែវនិងទីតាំងដីដែលមន្ទីរកសិកម្មខេត្តតាកែវស្នើសុំកាត់ជូនប្រជាជនចំនួន១០ គ្រួសារ

-បានចូលរួមដេញថ្លៃលក់ជាសាធារណៈនូវទ្រព្យសម្បត្តិ ដែលចាស់ខូច ទ្រុឌទ្រោមប្រើប្រាស់លែងកើតស្នើសុំជម្រះចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់រោងចក្របង្កកជលផល II ក្រុងព្រះសីហនុនៃរដ្ឋបាលជលផលរបស់មន្ទីរកសិកម្មខេត្តព្រះវិហារ និងរបស់មន្ទីរកសិកម្មខេត្តព្រៃវែង

-បានចូលរួមប្រគល់ ទទួលទ្រព្យសម្បត្តិជាថ្នូរនៃការដោះដូរអធិការដ្ឋានរដ្ឋបាលព្រៃឈើខាងត្បូងបឹងទន្លេសាបរបស់រដ្ឋបាលព្រៃឈើ ស្ថានីយ៍ស្រាវជ្រាវជលផលរបស់រដ្ឋបាលជលផល និងរៀបចំធ្វើប្រកាសអន្តរក្រសួងផ្ទេរទីតាំងចាស់ជូនក្រុមហ៊ុន ទ្រី ភាព អ៊ីមផត អ៊ិចផត

-បានចុះពិនិត្យជាក់ស្តែងទីតាំងដីស្ថិតនៅភូមិធ្នង់ សង្កាត់រកាក្រៅ ក្រុងដូនកែវ ខេត្តតាកែវរបស់មន្ទីរកសិកម្មខេត្តតាកែវដែលប្រជាពលរដ្ឋ១០ គ្រួសារចូលកាន់កាប់

-បានចូលរួមកំណត់ឲ្យបានច្បាស់លាស់នូវផ្ទៃដីកៅស៊ូកំពុងធ្វើអាជីវកម្ម ផ្ទៃដីកៅស៊ូចាស់ ផ្ទៃដីច្បារពូជផ្ទៃដីថ្នាលបណ្តុះកូនកៅស៊ូ ផ្ទៃដីទំនេរមិនអាចដាំកៅស៊ូបាន និងផ្ទៃដីផ្សេងៗទៀតរបស់ចម្ការកៅស៊ូរដ្ឋ ឡាបានសៀកខេត្តរតនគីរី

-បានចូលរួមប្រគល់ ទទួលទីតាំងរោងចក្របង្កកជលផល II ក្រុងព្រះសីហនុដែលត្រូវបានបញ្ចប់ការជួលជូនក្រុមហ៊ុន លាន ហេងត្រេឌីង

-បានចុះពិនិត្យជាក់ស្តែងទីតាំងដីចំការកៅស៊ូក្រុមហ៊ុនស៊ីសរ៉ាប់ប៊ើខេត្តរតនគីរី ដែលអង្គការ SOS សុំដើម្បីសាងសង់សាលារៀន SOS

-សហការជាមួយគណៈកម្មការអន្តរក្រសួងចុះកំណត់ឲ្យបានច្បាស់លាស់នូវផ្ទៃដីកៅស៊ូសិក្សាស្រាវជ្រាវ ផ្ទៃដីកៅស៊ូមិនទាន់ឲ្យផល ផ្ទៃដីទីស្នាក់ការស្ថានីយអនុវត្ត ផ្ទៃដីទំនេរមិនអាចដាំកៅស៊ូបាន និងចុះពិនិត្យស្រាវជ្រាវជាក់ស្តែងនូវផ្ទៃដីលំអៀងខ្វះទំហំ៣៨,៥០៨០ហត របស់ស្ថានីយ៍អនុវត្តនៃវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជាដែលប្រជាជនកាន់កាប់និងដាំដំណាំផ្សេងៗ

-លិខិតជម្រាបជូនទៅក្រុមហ៊ុនពិភពអេស៊ាត្រេឌីងឆ្លើយតបករណីសំណើសុំបើកការដ្ឋានសាងសង់ អគារអគ្គនាយកដ្ឋានកៅស៊ូ អគារអគ្គនាយកដ្ឋានកសិកម្ម និងអគារវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា។

-ចុះពិនិត្យនិងរៀបចំកំណត់ហេតុប្រគល់ ទទួល ថវិកា សម្ភារ ទ្រព្យសម្បត្តិ ដើម្បីបញ្ឈប់បញ្ជីសម្រាប់ប្រធានមន្ទីរកសិកម្មចាស់ និងបើកបញ្ជីសម្រាប់ប្រធានមន្ទីរកសិកម្មចូលកាន់ដំណែងថ្មីដូចជាខេត្ត កំពង់ធំ ព្រៃវែង បាត់ដំបង និងបន្ទាយមានជ័យ

-សហការជាមួយគណៈកម្មការអន្តរក្រសួងចុះពិនិត្យវាស់វែងនិងកាត់ចេញផ្ទៃដីទំហំ ១១១៣,៧៥២ហត ពីផ្ទៃដីចម្ការកៅស៊ូពាមជាំងជូនប្រជាពលរដ្ឋចំនួន ៥៣១គ្រួសារ

-ចូលរួមធ្វើការប្រគល់ទទួល ស្ថានីយប្រេងឥន្ទនៈស្ទឹងមានជ័យរបស់រដ្ឋបាលព្រៃឈើដែលបានបញ្ចប់ កិច្ចសន្យាជួលជាមួយអ្នកស្រី ចូ ឆវី

-ចូលរួមធ្វើការប្រគល់ ទទួល រោងចក្រអារឈើថ្នល់បំបែកខេត្តកំពង់ធំរបស់រដ្ឋបាលព្រៃឈើដែលបានបញ្ចប់កិច្ចសន្យាជួលជាមួយក្រុមហ៊ុន ណ័រអ៊ីស ឡាំប៊ើរ

-បានសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុចូលរួមប្រជុំពិភាក្សាឆ្លងកំណត់ហេតុស្តីពី ការកំណត់ទុនគ្រាដំបូងរបស់សាកលវិទ្យាល័យភូមិន្ទកសិកម្មនិងសាលាជាតិកសិកម្មកំពង់ចាម និងបានលើកសំណើសុំពិនិត្យនិងចុះហត្ថលេខាពីថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុលើតារាងតុល្យការចាប់ផ្តើមរបស់សាកលវិទ្យាល័យភូមិន្ទកសិកម្មនិងសាលាជាតិកសិកម្មកំពង់ចាម

-ចុះត្រួតពិនិត្យការអនុវត្តន៍ផែនការចំណូល ចំណាយថវិកានិងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋឆ្នាំ២០១២ និងឆ្នាំពាក់ព័ន្ធរបស់មន្ទីរកសិកម្មខេត្តកំពង់ធំ ខេត្តកំពង់ចាម ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តរតនគីរី ខេត្តមណ្ឌលគីរី រាជធានី

ភ្នំពេញ ខេត្តកណ្តាល ខេត្តតាកែវ ខេត្តកែប ខេត្តកំពត ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប ខេត្តព្រះវិហារ ខេត្តឧត្តរមានជ័យ ខេត្តព្រៃវែង ខេត្តស្វាយរៀង ខេត្តកំពង់ស្ពឺ ខេត្តព្រះសីហនុ ខេត្តកោះកុង ខេត្តពោធិ៍សាត់ និងខេត្តប៉ៃលិន

-ចុះត្រួតពិនិត្យផែនការចំណូល ចំណាយ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋឆ្នាំ២០១២ និងឆ្នាំពាក់ព័ន្ធរបស់រដ្ឋបាលជលផល នៅខណ្ឌកណ្តាល តាកែវ និងកំពត

-សហការជាមួយអគ្គាធិការដ្ឋាន នាយកដ្ឋានសវនកម្មផ្ទៃក្នុង និងនាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្សចុះស្រាវជ្រាវបាតុភាពនៅមន្ទីរកសិកម្មខេត្តព្រះវិហារ

-ចុះពិនិត្យនិងវាយតម្លៃគុណភាពបច្ចេកទេសនូវទ្រព្យសម្បត្តិចាស់ ខូច ទ្រុឌទ្រោមប្រើប្រាស់លែងកើតរបស់រដ្ឋបាលព្រៃឈើដែលស្នើសុំជម្រះចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ (ខណ្ឌរដ្ឋបាលព្រៃឈើ កំពង់ធំ ព្រះវិហារ ឧត្តរមានជ័យ កណ្តាល តាកែវ កំពតបាត់ដំបង បន្ទាយមានជ័យ កំពង់ចាម ក្រចេះ មណ្ឌលគិរី និងរតនគិរី)

-ចូលរួមចុះពិនិត្យគុណភាពនិងសន្និធិស្រូវពូជជាក់ស្តែងដើម្បីត្រៀមស្តារការខូចខាតដោយគ្រោះថ្នាក់ធម្មជាតិ នៅខេត្តកណ្តាល កំពង់ចាម ក្រចេះ និងស្ទឹងត្រែង

-ចូលរួមប្រជុំនិងចុះពិនិត្យផ្ទៀងផ្ទាត់ព្រំប្រទល់ ផ្ទៃដីចម្ការកៅស៊ូរដ្ឋឡាបានសៀក ខេត្តរតនគិរីរបស់ក្រុមហ៊ុនស៊ីសរ៉ាប់ប៊ឺរ លីមីតធីត

-ចូលរួមប្រជុំពិភាក្សាស្តីពី ការផ្តល់ទិន្នន័យលើលទ្ធផលនៃវាស់វែងជាក់ស្តែងទីតាំងស្ថានីយអនុវត្ត របស់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

-សហការជាមួយអគ្គធិការដ្ឋានចុះអនុវត្តខ្លឹមសារលិខិតលេខ ៤១៤/១២ ទ.រ.ព.អ.រ.ប ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១២ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច នៅខណ្ឌរដ្ឋបាលព្រៃឈើព្រះវិហារ

-រៀបចំធ្វើលិខិតជូនទៅសាលាខេត្តរតនគិរី និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីសំណើសុំចាត់តំណាង ០១រូប ចូលរួមក្នុងគណៈកម្មការត្រួតពិនិត្យ និងវាយតម្លៃជាក់ស្តែងនូវផ្ទៃដីកៅស៊ូធ្វើអាជីវកម្ម របស់ក្រុមហ៊ុនស៊ីហ្សរ៉ាប់ប៊ើលីមីតធីត

-រៀបចំធ្វើលិខិតជម្រាបទៅក្រុមហ៊ុនស៊ីហ្សរ៉ាប់ប៊ើរ លីមីតធីតស្តីពី ការបង់ថ្លៃឈ្នួលចម្ការកៅស៊ូរដ្ឋឡាបានសៀក ខេត្តរតនគិរី។

## ង. ការងាររៀបចំនិងអនុវត្តកិច្ចលទ្ធកម្មសាធារណៈ

សម្រេចអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈដើម្បីផ្គត់ផ្គង់ទំនិញ សម្ភារបរិក្ខា ការងារសាងសង់ ជួលជុល និងសេវាកម្មផ្សេងៗ ជូនក្រសួង និងអង្គភាពនានាក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានចំនួន ៣៣គម្រោង (លទ្ធកម្មទំនិញ ២២ គម្រោង លទ្ធកម្មសំណង់ ០៦ គម្រោង លទ្ធកម្មសេវាកម្ម ០៥ គម្រោង)។

## ច. ចំនួនលេខគណនីធនាគារ (Bank Account NO.)

ក្នុងឆ្នាំ២០១២នេះ ចំនួនលេខគណនីធនាគារមានការថយចុះពី៣៥គណនីនៅឆ្នាំមុន មកនៅត្រឹមចំនួន២៦គណនីនៅចុងឆ្នាំ២០១២ ក្នុងនោះ NBC: 7, FTB: 11, ACLEDA: 6, ANZ :2។ ចំនួនគណនីដែលបានថយចុះនេះយើងបានទទួលព័ត៌មានប្រចាំខែពីបណ្តាអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ បានផ្តល់របាយការណ៍រៀងរាល់ប្រចាំខែឆ្នាំ២០១២ ជូនទៅអគ្គនាយកដ្ឋានរតនាគារជាតិស្តីអំពីស្ថានភាពប្រើប្រាស់គណនីរបស់បណ្តាអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនិងគម្រោងនានា នៅតាមប្រព័ន្ធធនាគារដែលបាន និងកំពុងបម្រើការងារក្នុងវិស័យកសិកម្ម ។

## ជ. ប្រាក់កក់ និងថ្លៃឈ្នួលសម្បទានដីសេដ្ឋកិច្ច

-ប្រាក់កក់ធានាអនុវត្តកិច្ចសន្យា: ក្នុងឆ្នាំ២០១២ នេះនាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុបានទទួលបង្កាន់ដៃប្រាក់

កក់ចំនួន១៦ ពីក្រុមហ៊ុនសរុបទឹកប្រាក់ 709,454.00$ និងបានជូនដំណឹងទៅនាយកដ្ឋានផែនការនិងស្ថិតិ និងលេខាធិការដ្ឋានសម្បទានដីសេដ្ឋកិច្ចដើម្បីជ្រាបជាព័ត៌មាន

-ក្នុងឆ្នាំ២០១២ នាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ បានទទួលបង្កាន់ដៃបង់ចំណូលថ្លៃសម្បទានដីសេដ្ឋកិច្ចពីក្រុមហ៊ុនចំនួន ០៥ សរុប 38,836.00$ និងបានធ្វើការផាកពិន័យក្រុមហ៊ុនចំនួនពីរ ដែលបានបង់ប្រាក់ថ្លៃសម្បទានយឺតសរុបបានចំនួន 1,910.00$ និងបានបញ្ជូនបង្កាន់ដៃទាំងនោះដើម្បីកត់ត្រាចំណូល

-បានរៀបចំសេចក្តីជូនដំណឹងដល់គ្រប់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចទាំងអស់ (ទាំងចាស់ទាំងថ្មី) អនុវត្ត ការបង់ថ្លៃសម្បទានតាមសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលលេខ ១១៣០ សជណ ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០១២ដែល មានតម្លៃ 5$/ha/1ឆ្នាំ ចាប់ពីឆ្នាំទី៦ តទៅនិងមានកំណើន ១% រៀងរាល់ឆ្នាំ។

## ២. វាយតម្លៃនិងសំណើ

-បន្តពង្រឹងការគ្រប់គ្រងប្រព័ន្ធ SERVER កុំព្យូទ័ររបស់នាយកដ្ឋាន

-កែប្រែប្រព័ន្ធ Internet ADSL ទៅជាប្រព័ន្ធ Fiber Optics លឿនរហ័ស

-ប្រឹងប្រែងពង្រីកថវិកាតាមកម្មវិធីដល់បណ្តាអង្គភាពក្រោមឱវាទ

-បន្តចូលរួមជាមួយគណៈកម្មការអន្តរក្រសួងចុះដេញថ្លៃ ផល អនុផលព្រៃឈើដែលរឹបអូស ដោយសាលក្រមដីកាសម្រេចពិន័យអន្តរការណ៍ និងឈើអញ្ញាតិជន (ឈើគ្មានម្ចាស់) នៅខណ្ឌរដ្ឋបាលព្រៃឈើទូទាំងប្រទេស

-បន្តអនុវត្តផ្ទាល់នូវប្រព័ន្ធគណនេយ្យកុំព្យូទ័រពីរបៀបបញ្ចូលទិន្នន័យនិងគ្រប់គ្រងទិន្នន័យនៅក្នុងប្រព័ន្ធកុំព្យូទ័រតែមួយ

-ត្រៀមចុះពង្រឹងការងារបញ្ជិកាគណនេយ្យនៅតាមបណ្តាមន្ទីរកសិកម្មរាជធានី ខេត្ត និងបណ្តាអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-សហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចុះត្រួតពិនិត្យ និងបិទបញ្ជីគណនេយ្យការិយបរិច្ឆេទឆ្នាំមុន នៅតាមគ្រឹះស្ថានសាធារណៈរដ្ឋបាលទាំងបួនស្ថិតក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ

-បន្តសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីចូលរួមកំណត់ទុនគ្រាដំបូងឲ្យគ្រឹះស្ថានសាធារណៈរដ្ឋបាលទាំងបួនស្ថិតក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលនៅពុំទាន់បានកំណត់ទុនគ្រាដំបូងនៅឡើយ

-ត្រៀមសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីចូលរួមពិនិត្យ និងផ្ទៀងផ្ទាត់តារាងប្រៀបធៀបទ្រព្យសម្បត្តិរដ្ឋកើនថយចុះ នៅតាមមន្ទីរកសិកម្មរាជធានី-ខេត្ត និងអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បន្តខិតខំប្រឹងប្រែងរៀបចំឯកសារកិច្ចលទ្ធកម្មសាធារណៈឲ្យបានទាន់ពេលវេលា បន្ទាប់ពីទទួលបានលិខិតគោលការណ៍ធានាចំណាយរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-ខិតខំរៀបចំកសាងផែនការលទ្ធកម្មប្រចាំឆ្នាំ២០១៣របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឲ្យបានទាន់ពេលវេលា ដោយសហការជាមួយផ្នែកហិរញ្ញកិច្ចនិងមន្ត្រីផ្នែកជំនាញគណនេយ្យ ហិរញ្ញវត្ថុរបស់អង្គភាពក្រោមឱវាទរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ

-រៀបចំនិងអនុវត្តនូវគម្រោងកិច្ចលទ្ធកម្មសម្រាប់ឆ្នាំ២០១៣ នៅពេលទទួលបានគោលការណ៍ធានាចំណាយពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ជួយរៀបចំឲ្យដំណើរការនូវគម្រោងនានាដែលត្រូវការថវិកាបដិភាគតាមការណែនាំរបស់ថ្នាក់ដឹកនាំ

-បន្តសហការចូលរួមកិច្ចលទ្ធកម្មគម្រោងហិរញ្ញប្បទានដោយធនាគារអភិវឌ្ឍន៍អាស៊ីដែលកំពុងដំណើរការនិងគម្រោងផ្សេងៗទៀតតាមការចាត់តាំងរបស់ថ្នាក់ដឹកនាំ

-បន្តចូលរួមអនុវត្តសកម្មភាព PFM/MAP ក្នុងក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ

-ស្រង់ឈ្មោះក្រុមហ៊ុនដែលបង់ប្រាក់កក់អនុវត្តកិច្ចសន្យាយឺតដើម្បីដាក់ជូនថ្នាក់ដឹកនាំពិនិត្យនិងសម្រេច ។

### ៥.១០- កម្មវិធី និងគម្រោងជំនួយដោយដៃគូអភិវឌ្ឍន៍

### គម្រោងកាត់បន្ថយភាពក្រីក្រនិងអភិវឌ្ឍន៍កសិកម្មខ្នាតតូចនៅតំបន់ទន្លេសាប

(TS-PRSDP)៖

គម្រោងកាត់បន្ថយភាពក្រីក្រនិងអភិវឌ្ឍន៍កសិកម្មខ្នាតតូច នៅតំបន់ទន្លេសាបក្រោមហិរញ្ញប្បទានសហប្រតិបត្តិការ ជាមួយធនាគារអភិវឌ្ឍន៍អាស៊ីរដ្ឋាភិបាលហ្វាំងឡង់មូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍កសិកម្មនិងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជា អនុវត្តនៅក្នុងស្រុកចំនួន២៨ឃុំចំនួន១៩៦ក្នុងខេត្តចំនួន៤មានខេត្តកំពង់ចាម (៦១ឃុំ) ខេត្តកំពង់ធំ (៤៥ឃុំ) ខេត្តសៀមរាប (៥៨ឃុំ) និងខេត្តបន្ទាយមានជ័យ (៣២ឃុំ) ដែលមានប្រជាជនទទួលផលប្រហែល៦៣,០០០គ្រួសារ។ការអនុវត្តគម្រោងមានរយៈពេលអនុវត្ត៧ឆ្នាំដែលបានចាប់ផ្តើមអនុវត្តពីថ្ងៃទី៣១ខែមីនាឆ្នាំ២០១០ដល់ថ្ងៃទី២៨ខែកុម្ភៈឆ្នាំ២០១៨និងមានថវិកាសរុបចំនួន៥៥.៣០១.២០០ដុល្លារអាមេរិក ដែលក្នុងនោះមានថវិកាកម្ចីហិរញ្ញប្បទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី(Grant) ចំនួន៣.៤០០.០០០ដុល្លារអាមេរិកជំនួយហិរញ្ញប្បទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (Loan) ចំនួន ២៧.៣០០.០០០ដុល្លារអាមេរិកកម្ចីហិរញ្ញប្បទានរបស់អង្គការមូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍កសិកម្មចំនួន៦.៦៩០.០០០ ដុល្លារអាមេរិកជំនួយហិរញ្ញប្បទានរបស់អង្គការមូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍កសិកម្ម (Grant) ចំនួន៦.៦៩០.០០០ដុល្លារអាមេរិកជំនួយហិរញ្ញប្បទានរបស់រដ្ឋាភិបាលហ្វាំងឡង់ (Grant) ចំនួន ៥.៧៤៧.៩០០ដុល្លារអាមេរិកនិងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជាចំនួន៥.៤៧៣.២០០ដុល្លារអាមេរិក។

គម្រោងមានភ្នាក់ងារប្រតិបត្តិ(Executing Agency) ចំនួនពីរគឺ (១) លេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិនិង (២) ភ្នាក់ងារប្រតិបត្តិរបស់ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទដែលមានអង្គភាពសម្របសម្រួលការអភិវឌ្ឍជាអ្នកសម្របសម្រួលការអនុវត្តគម្រោងនៅក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ។ភ្នាក់ងារអនុវត្ត (Implementing Agency) មានអគ្គនាយកដ្ឋានកសិកម្មនិងអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍វិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានវិទ្យារបស់ទីស្តីការគណៈរដ្ឋមន្ត្រី។ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទមានតួនាទីជាគណៈកម្មាធិការតម្រង់ទិសគម្រោង។

គោលដៅរបស់គម្រោងគឺជំរុញការអភិវឌ្ឍសកម្មភាព នៅសហគមន៍មូលដ្ឋានតាមរយៈការវិនិយោគកែលំអផលិតភាពហេដ្ឋារចនាសម្ព័ន្ធនៅជនបទនិងអភិវឌ្ឍន៍ធនធានមនុស្ស។ គោលបំណងរបស់គម្រោងគឺបង្កើនជីវភាពរបស់កសិករក្រីក្រក្នុងតំបន់គោលដៅក្នុងអំឡុងឆ្នាំ២០២០។គម្រោងមានសមាសភាគបី (១) ការអភិវឌ្ឍឃុំ-សង្កាត់តាមរយៈការផ្តល់កញ្ចប់ថវិកា (Block Grant) (២) បង្កើនផលិតភាពកសិកម្មនិងពិពិធកម្ម (៣) ការគ្រប់គ្រងគម្រោងប្រកបដោយប្រសិទ្ធភាព។

អង្គភាពសម្របសម្រួលការអភិវឌ្ឍ (DCU) ជាភ្នាក់ងារប្រតិបត្តិនៃគម្រោងកាត់បន្ថយភាពក្រីក្រនិងអភិវឌ្ឍន៍កសិកម្មខ្នាតតូចនៅតំបន់ទន្លេសាបបានសម្របសម្រួលអនុវត្តសកម្មភាពនៅក្នុងឆ្នាំ២០១២ និងបានសម្រេចលទ្ធផលតាមផែនការគ្រោងទុក។ ក្រុមហ៊ុនជំនាញការ SMEC International Pty Ltd បានអនុវត្តការងារពីខែកក្កដាឆ្នាំ២០១២។ ការចំណាយរបស់អង្គភាពសម្របសម្រួលការអភិវឌ្ឍន៍ក្នុងឆ្នាំ២០១២ មានចំនួន១.២៩៣.៧៥០ដុល្លារអាមេរិក។ ចាប់ពីគម្រោងចាប់ផ្តើមមកដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ ការចំណាយសរុបរបស់អង្គភាពសម្របសម្រួលការអភិវឌ្ឍន៍មានចំនួន១.៦៨៥.៧៨០ ដុល្លារអាមេរិក (29.8%) ក្នុងនោះមានថវិកាជំនួយរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ចំនួន១.៦៧៦.៤៥៥ ដុល្លារអាមេរិក និងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលចំនួន ៩.៣២៦ ដុល្លារអាមេរិក។

នៅក្នុងឆ្នាំ២០១២ការអនុវត្តរបស់គម្រោងកាត់បន្ថយភាពក្រីក្រនិងអភិវឌ្ឍន៍កសិកម្មខ្នាតតូច នៅតំបន់ទន្លេសាបបានសម្រេចលទ្ធផលល្អប្រសើរបន្ទាប់ពីផែនការរយៈពេល១៥ខែរបស់គម្រោងបានអនុម័តនាថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១១ដោយធនាគារអភិវឌ្ឍន៍អាស៊ី។ មន្ត្រីធនាគារអភិវឌ្ឍន៍អាស៊ី បានខិតខំជួយសហការជាមួយភ្នាក់ងារប្រតិបត្តិនិងភ្នាក់ងារអនុវត្តគម្រោងដែលជាលទ្ធផលសម្រេចបានក្នុងឆ្នាំ២០១២កន្លងមកទទួលបានគួរជាទីពេញចិត្ត។

**គម្រោងជំនួយបច្ចេកទេស** ADB-Grant . 0222-CAM/Component1: PFMRDs

គម្រោងបានផ្តល់នូវជំនួយបច្ចេកទេសដល់ក្រសួងតាមរយៈការកសាងសមត្ថភាពស្ថាប័ននិងមន្ត្រី លើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី២ដែលផ្តោតលើការលើកកម្ពស់និងការពង្រឹងសមត្ថភាពស្ថាប័នរបស់ក្រសួងអភិវឌ្ឍន៍ក្នុងវិស័យជនបទ។

បានសហការនិងរៀបចំបើកសិក្ខាសាលាចំនួន០២លើកនៅខេត្តបាត់ដំបង និងខេត្តសៀមរាប ក្នុងគោលដៅលើកកំពស់និងពង្រឹងសមត្ថភាពមន្ត្រីតាមអង្គភាពជំនាញដែលពាក់ព័ន្ធ និងកែលំអប្រសិទ្ធភាពការងារ ជាពិសេស លើការងារអនុវត្តថវិកាតាមកម្មវិធី។

## គម្រោងអភិវឌ្ឍន៍កសិកម្ម និងជំរុញកំណើនសេដ្ឋកិច្ចក្នុងខេត្តកំពត កណ្តាល ព្រៃវែង ស្វាយរៀង និងខេត្តតាកែវ

### ក. លទ្ធផល

**១. ភាពផ្នែកកសិកម្ម**

- ទីតាំងអនុវត្តគម្រោង÷ ចំនួនសរុបស្រុកគោលដៅ ១២ ចំនួនឃុំ ៨៩ និងភូមិគោលដៅ ៣៥៦
- ចំនួនមន្ត្រីគាំទ្រចល័តសរុប ១៣៨នាក់ ស្ត្រី ៥៦នាក់
- ចំនួនភ្នាក់ងារផ្សព្វផ្សាយកសិកម្មសរុប ១៧៨នាក់ ស្ត្រី ៨៩នាក់
- ការចងក្រងក្រុមបានរួចរាល់សម្រាប់ខេត្តព្រៃវែង និងតាកែវ ចំពោះខេត្តកណ្តាល ស្វាយរៀង និងកំពត
- បានជ្រើសរើសជនបង្គោលឃុំម្នាក់/ឃុំ
- បានតែងតាំងមន្ត្រីពិនិត្យបញ្ជាក់

**២. វគ្គបណ្តុះបណ្តាល**

- វគ្គបណ្តុះបណ្តាលគ្រូបង្គោលបានចំនួន ០៥វគ្គ សរុប ២៥នាក់ ស្ត្រី ០៨នាក់
- វគ្គបណ្តុះបណ្តាលភ្នាក់ងារផ្សព្វផ្សាយកសិកម្មបានចំនួន ០៥វគ្គ សរុបសិក្ខាកាម ១៧៨នាក់ ស្ត្រី៨៩នាក់
- វគ្គបណ្តុះបណ្តាលមន្ត្រីចល័តបានចំនួន ០៣វគ្គសរុបសិក្ខាកាម ៩០នាក់ ស្ត្រី ៣១នាក់

តារាងទី ១÷ សិក្ខាសាលា និងការប្រជុំ

| ពេលវេលា | សិក្ខាសាលា និងប្រជុំ |
|---|---|
| ១៧-១៩ ឧសភា ២០១២ | ប្រជុំអំពីក្បួនអនុវត្តគម្រោង (១) MoU (២) ពិភាក្សា និងឯកភាពគ្នាលើគោលការណ៍ណែនាំ (៣) រៀបចំពង្រាងផែនការសកម្មភាពសម្រាប់អនុវត្តឆ្នាំ២០១២នៅសណ្ឋាគារឡាផារេនដា (ភ្នំពេញ) |
| ១៣-១៥ មិថុនា ២០១២ | ប្រជុំអំពីផែនការសកម្មភាពសម្រាប់អនុវត្តឆ្នាំ២០១២នៅអគ្គនាយកកសិកម្ម |
| ១៩-២០ កក្កដា ២០១២ | សិក្ខាសាលាចាប់ផ្តើមអនុវត្តគម្រោងនៅសណ្ឋាគារភ្នំពេញ |
| ២៩-៣១ សីហា ២០១២ | ប្រជុំបច្ចេកទេសលើកទី១÷ (១) កិច្ចព្រមព្រៀង (២) ទម្រង់របាយការណ៍ (៣) លក្ខណៈវិនិច្ឆ័យសម្រាប់ការជ្រើសរើសភូមិគោលដៅ (៤) ដំណើរ ការនៃការចង់ក្រងក្រុម (៥) ដំណើរការជ្រើសរើសក្រុមគាំទ្រចល័ត ភ្នាក់ ងារផ្សព្វផ្សាយឃុំ និង FBA ដែលមានអ្នកចូលចំនួន ១១១នាក់ (ស្ត្រី ២៣នាក់) នៅសណ្ឋាគារឆ្នេរទន្លេ ខេត្តព្រះសីហនុ ។ |
| ១៧-១៨ កញ្ញា ២០១៣ | ប្រជុំអំពីដំណើរការ និងលក្ខណៈវិនិច្ឆ័យសម្រាប់ជ្រើសរើសក្រុមដែលមានស្រាប់នៅខេត្តព្រៃវែង និងស្វាយរៀង ។ |

តារាងទី ២÷ ទីតាំងអនុវត្តគម្រោង ២០១២

| ឈ្មោះខេត្ត | ចំនួនស្រុក/ក្រុង | | | ចំនួនឃុំ/សង្កាត់ | | | ចំនួនភូមិ | | |
|---|---|---|---|---|---|---|---|---|---|
| | សរុប | គោលដៅ | % | សរុប | គោលដៅ | % | សរុប | គោលដៅ | % |
| កំពត | ០៨ | ០២ | ២៥ | ៩៣ | ១៤ | ១៥ | ៤៨៨ | ៥៦ | ១១.៤៧ |
| កណ្ដាល | ១១ | ០២ | ១៨ | ១២៧ | ១៤ | ១១ | ៩១២ | ៥៦ | ៦,១៤ |
| ព្រៃវែង | ១២ | ០៤ | ៣៣.៣៣ | ១១៦ | ៣០ | ២៥.៨៦ | ១,១៣៧ | ១២០ | ១០.៥៥ |
| ស្វាយរៀង | ០៧ | ០១ | ១៤.២៨ | ៨០ | ០៨ | ១០ | ៦៩០ | ៣២ | ៤.៦៣ |
| តាកែវ | ១០ | ០៣ | ៣០ | ១០០ | ២៣ | ២៣ | ១,៣១៦ | ៩២ | ៧ |
| **សរុប** | ៤៨ | ១២ | ២៤.១២ | ៥១៦ | ៨៩ | ១៦.៩៧ | ៤,៥៤៣ | ៣៥៦ | ៣៩.៧៩ |

តារាងទី៣ ÷ ចំនួនគ្រូបង្គោល មន្ត្រីចល័ត និងភ្នាក់ងារផ្សព្វផ្សាយកសិកម្មដែលបានបណ្ដុះបណ្ដាលឆ្នាំ ២០១២

| ឈ្មោះខេត្ត | ចំនួនគ្រូបង្គោល | | ចំនួនមន្ត្រីចល័ត | | ចំនួន CEWs | |
|---|---|---|---|---|---|---|
| | សរុប | ស្ត្រី | សរុប | ស្ត្រី | សរុប | ស្ត្រី |
| កំពត | ០៥ | ០២ | ១០ | ០៥ | ២៨ | ១៤ |
| កណ្ដាល | ០៥ | ០១ | ២០ | ០៧ | ២៨ | ១៤ |
| ព្រៃវែង | ០៥ | ០២ | ៣០ | ០៦ | ៦០ | ៣០ |
| ស្វាយរៀង | ០៥ | ០១ | ១២ | ០៦ | ១៦ | ០៨ |
| តាកែវ | ០៥ | ០២ | ១៨ | ០៦ | ៤៦ | ២៣ |
| **សរុប** | ២៥ | ០៨ | ៩០ | ៣១ | ១៧៨ | ៨៩ |

តារាងទី៤ ÷ ការជ្រើសរើសក្រុមគោលដៅសម្រាប់ ឆ្នាំ ២០១២

| ឈ្មោះខេត្ត | ចំនួនក្រុម |
|---|---|
| កំពត | ៥៦ |
| កណ្ដាល | ៥៦ |
| ព្រៃវែង | ១២០ |
| ស្វាយរៀង | ៣២ |
| តាកែវ | ៩២ |
| សរុប | ៣៥៦ ក្រុម |

ថវិកាចំណាយសរុបក្នុងឆ្នាំ២០១២ ចំនួន៣២០.៦០០ដុល្លាអាមេរិក ។

**ខ. បញ្ហាជួបប្រទះ**

១. ការយល់ដឹងអំពីដំណើរការជ្រើសរើសក្រុមកែលំអទុនបង្វិលនៅមានកម្រិត ក្រុមការងាររបស់អង្គភាពគាំទ្រគម្រោងបានបណ្ដុះបណ្ដាលបន្ថែមនៅខេត្តកណ្ដាល និងតាកែវ ដោយមានការចូលរួមពីប្រធានសម្របសម្រួលគម្រោងស្រុក មន្ត្រីផែនការ តាមដាន និងវាយតម្លៃស្រុក មន្ត្រីយែនឌ័រស្រុក ក្រុមប្រឹក្សាឃុំ ជនបង្គោលស្ត្រី និងកុមារឃុំ និងភ្នាក់ងារផ្សព្វផ្សាយឃុំ

២. ក្រុមកែលំអទុនបង្វិលទាំង ៣៥៦ក្រុម បានបង្កើតនៅឆ្នាំ២០១២ ហើយរង់ចាំទទួលការបណ្ដុះបណ្ដាល និងដំណើរការផ្ទេរទុនក្រុមដោយមានល័ក្ខខ័ណ្ឌ:

- គណនីធនាគារសម្រាប់ក្រុម និងបុគ្គល
- ការបណ្ដុះបណ្ដាលចំណេះដឹងហិរញ្ញវត្ថុ(មានការប្រឡង)
- ការបណ្ដុះបណ្ដាលផ្នែកយែនឌ័រ និងអាហារូបត្ថម្ភ

**គ. ទិសដៅ**

- ត្រៀមបើកវគ្គបណ្តុះបណ្តាលស្តីពីវិធីសាស្ត្រផ្សព្វផ្សាយកសិកម្មដល់ភ្នាក់ងារផ្សព្វផ្សាយឃុំ
- ត្រៀមបើកវគ្គបណ្តុះបណ្តាលស្តីពីកសិកម្មចម្រុះដល់ក្រុមគាំទ្រចល័ត
- បើកវគ្គបណ្តុះបណ្តាលស្តីពីចំណេះដឹងគ្រប់គ្រងហិរញ្ញវត្ថុដល់កសិករគោលដៅចំនួន ៣៥៦ក្រុម
- បើកវគ្គបណ្តុះបណ្តាលអំពីយេនឌ័រនិងអាហារូបត្ថ ដែលរៀបចំដោយអង្គភាពអនុវត្តគម្រោង (ISU) របស់ក្រសួងកិច្ចការនារី
- ទំលាក់ទុនក្រុមដល់កសិករគោលដៅទាំង ៣៥៦ក្រុម និងបើកវគ្គបណ្តុះបណ្តាលស្តីពីសាលារៀនស្រែកសិករ (កសិកម្មចម្រុះ)
- ជ្រើសរើសភូមិគោលដៅថ្មីសម្រាប់ខេត្តទាំងប្រាំ និងចងក្រងក្រុមកែលម្អទុនបង្វិលក្រុមចំនួន
- ត្រៀមរៀបចំប្រជុំបច្ចេកទេសលើកទី៣
- ចុះពិនិត្យ និងតាមដានលើការអនុវត្តគម្រោង។

**ថវិកាគម្រោង** គម្រោងចំណាយថវិកាសរុបចំនួន១០.៧៨៧.៦៥០ដុល្លាអាមេរិក។

## គម្រោងបន្សាំនឹងការប្រែប្រួលអាកាសធាតុ សម្រាប់លើកកម្ពស់ការគ្រប់គ្រងធនធានទឹក និងការប្រកបរបរកសិកម្មខេត្តក្រចេះនិងខេត្តព្រះវិហារ (NAPA-FU) ÷

គម្រោងបន្សាំនឹងការប្រែប្រួលអាកាសធាតុសម្រាប់ការលើកកម្ពស់ការគ្រប់គ្រង ទឹកនិងការប្រកបរបរកសិកម្ម សម្របសម្រួលដោយអង្គភាពគាំទ្រគម្រោងនៃក្រសួង កសិកម្ម រុក្ខាប្រមាញ់និងនេសាទ ក្រោមកិច្ចសហការជាមួយក្រសួងធនធានទឹកនិង ឧតុនិយម និងក្រសួងកិច្ចការនារី។ នៅថ្នាក់ក្រោមជាតិ គម្រោងត្រូវបានសម្របសម្រួល ដោយរដ្ឋបាលសាលាខេត្ត និងអនុវត្តដោយមន្ទីរកសិកម្ម មន្ទីរធនធានទឹកនិងឧតុនិយម និងមន្ទីរកិច្ចការនារី។ គម្រោងមានលទ្ធផលរំពឹងទុកសំខាន់ៗចំនួន៣ គឺ ១).កសាង សមត្ថភាពអាជ្ញាធរមូលដ្ឋានក្នុងការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ ២).ការធ្វើបង្ហាញនូវបច្ចេកទេសបន្សាំសមស្របនានា ៣). ចងក្រងមេរៀននិងបទពិសោធល្អៗ សម្រាប់ផ្សព្វផ្សាយ និងចូលរួមចំណែកដល់ការរៀបចំគោលនយោបាយ។

**ក. លទ្ធផល÷**

ក្នុងឆ្នាំ២០១២ គម្រោងអនុវត្តសម្រេចបាន ១០២% នៃថវិកាអនុម័តសរុប ១.១៧៧.១១៥ដុល្លា (មួយលានមួយសែនប្រាំពីរម៉ឺនប្រាំពីរពាន់មួយរយដប់ប្រាំដុល្លា អាមេរិក) ដោយសម្រេចបាននូវលទ្ធផលសំខាន់ៗដូចខាងក្រោម ÷

- មន្ត្រីថ្នាក់ជាតិនិងខេត្ត ៧០នាក់ (ស្ត្រី៥១នាក់)ទទួលបានចំណេះដឹង និងបទពិសោធន៍ អំពីវិធានការចម្រុះបន្សាំនឹងការប្រែប្រួលអាកាសធាតុពីទស្សនៈកិច្ចសិក្សានិងសិក្ខាសាលាថ្នាក់តំបន់ពីវគ្គបណ្តុះបណ្តាលអំពីយេនឌ័រនិងការប្រែប្រួលអាកាសធាតុ និងវិធានការបន្សាំរបស់វា ព្រមទាំងមានសមត្ថភាពផ្សព្វផ្សាយបន្តដល់អ្នកទទួលផល។ អាជ្ញាធរមូលដ្ឋាន និងកសិករ ជិត១ម៉ឺននាក់ ពី២០២ភូមិ ៥៤ឃុំ ១០ស្រុកក្នុងខេត្តក្រចេះ និងព្រះវិហារ បានទទួលការយល់ដឹងអំពីឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ និងវិធានការបន្សាំរបស់វាពីវគ្គបណ្តុះ បណ្តាល សិក្ខាសាលា និងវេទិការសហគមន៍

- បានបញ្ជ្រាបវិធានការបន្សាំនឹងការប្រែប្រួលអាកាសធាតុក្នុងវិស័យកសិកម្មនិងធនធានទឹក ទៅក្នុងផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគឃុំចំនួន ១៦ឃុំ តាមរយៈ នៃការផ្សព្វផ្សាយការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុ ការវាយតម្លៃការកាត់បន្ថយភាពងាយរងគ្រោះ(VRA) និងការប្រជុំឃុំដើម្បីដាក់បញ្ចូលវិធានការបន្សាំ

- ភ្នាក់ងារផ្តល់ព័ត៌មានភូមិ ចំនួន១០៤នាក់ (ស្ត្រី៤៥នាក់) ក្នុង៥៤ភូមិ ត្រូវបានជ្រើសរើស បណ្តុះបណ្តាល និងបានផ្សព្វផ្សាយព័ត៌មានទាន់ពេលវេលាស្តីពី ធាតុអាកាសនិងទឹកជំនន់ដល់អ្នកភូមិរបស់ខ្លួនចំនួនប្រមាណ ១១.០០០គ្រួសារ គឺស្មើនឹង ៥៦% នៃគ្រួសារសរុបក្នុងភូមិគោលដៅ

- អណ្តូងស្នប់ថ្មីចំនួន៣០អណ្តូង (សរុបទាំងអស់៦២អណ្តូង) ស្រះសហគមន៍ចំនួន ៣កន្លែង អាងត្រងទឹកភ្លៀងចំនួន៤១កន្លែង ប្រព័ន្ធបូមទឹកដោយថាមពលពន្លឺ ព្រះអាទិត្យធុនមធ្យមចំនួន៣កន្លែង ប្រព័ន្ធបូមទឹកដោយថាមពលខ្យល់

២កន្លែង និងធុនតូចចំនួន៧កន្លែង ត្រូវបានបង្កើតឡើងដើម្បីផ្តល់ទឹកសម្រាប់ប្រើប្រាស់ក្នុងគ្រួសារ ការស្រោចស្រពដំណាំរួមផ្សំនិងការចិញ្ចឹមសត្វ។ កសិករចំនួន១.០១៥ គ្រួសារ ស្មើនឹង១៨%នៃគ្រួសារសរុបក្នុងភូមិគោលដៅ១៨ភូមិ។ ក្រុមកសិករប្រើ ប្រាស់ទឹកចំនួន៤៥ ក្រុមត្រូវបានបង្កើតឡើង ដើម្បីគ្រប់គ្រង និងថែទាំអណ្តូង ស្រះ និងប្រព័ន្ធបូមទឹកដោយថាមពលព្រះអាទិត្យ។

- សាលារៀនស្រែកសិករចំនួន២៧សាលា និងក្រុមកសិករសម្រិតសម្រាំងពូជ១២ក្រុម ត្រូវបានរៀបចំ និងដំណើរការដោយជោគជ័យក្នុងឆ្នាំ២០១២។ កសិករចំនួន ៩៤២នាក់ (ស្ត្រី៦៥៤នាក់) បានចូលរួម និងទទួលផលពីគម្រោង តាមរយៈសកម្ម ភាពកសិកម្មដែលមានភាពស៊ាំនឹងការប្រែប្រួលអាកាសធាតុដូចជា ប្រព័ន្ធកសិកម្មចម្រុះ ការចិញ្ចឹមសត្វ ប្រពលវប្បកម្មដំណាំស្រូវ កម្មវិធីបន្សុទ្ធពូជស្រូវ និងការ ពិសោធន៍ពូជស្រូវដែលធន់នឹងការលិចលង់ និងភាពរាំងស្ងួត ការចិញ្ចឹមត្រីក្នុងស្រះ ប្លាស្ទិក លើសពីនោះ កសិករ២.៧៨៤គ្រួសារទទួលបានផលពីកម្មវិធីវ៉ាក់សាំងសត្វសម្រាប់គោ និងក្របីចំនួន១៩.៨១៥ក្បាល នៅក្នុង៤៧ភូមិ

- សហគមន៍កសិករប្រើប្រាស់ទឹក៣កន្លែងត្រូវបានបង្កើត។ ប្រព័ន្ធធារាសាស្ត្រ ២កន្លែង ត្រូវបានសាងសង់និងស្តារឡើងវិញ ក្នុងនោះរួមមាន ÷ ទំនប់ដីក្រាល គ្រួសក្រហមជាង២គ.ម ទំនប់បង្វៀរ ទ្វារទឹក ប្រឡាយដី ប្រឡាយបេតុងដែលអាចផ្គត់ផ្គង់ទឹកស្រោចស្រពក្នុងពេលរាំងស្ងួតអូសបន្លាយបានប្រមាណ ៨៤៨ហត។ កសិករប្រមាណ ២.០០០គ្រួសារទទួលផលពីគម្រោងស្តារឡើងវិញនេះ

- គម្រោងបានព្រាងឯកសារបណ្តុះបណ្តាលស្តីពី ប្រព័ន្ធធារាសាស្ត្រដែលមានភាពធន់ប្រែសម្រួលឯកសារសកលស្តីពីយេនឌ័រនិងការប្រែប្រួលអាកាសធាតុ និងឯកសារ បណ្តុះបណ្តាលថ្នាក់ខេត្តស្តីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុ។ ឯកសារទាំង នេះ នឹងរៀបចំរចនា និងបោះពុម្ពផ្សព្វផ្សាយក្នុងឆ្នាំ២០១៣

- គម្រោងបានចងក្រងបទពិសោធន៍ និងចែករំលែកបទពិសោធន៍ពីការអនុវត្ត គម្រោងដល់ថ្នាក់តំបន់តាមរយៈប្រព័ន្ធគេហទំព័រ វិទ្យុ និងទូរទស្សន៍ និងបានរៀបចំ កិច្ចប្រជុំបច្ចេកទេស សិក្ខាសាលាផ្សព្វផ្សាយបទពិសោធន៍គម្រោង និងសិក្ខា សាលារៀបចំផែនទីបង្ហាញផ្លូវ សម្រាប់ការរៀបចំគោលការណ៍ណែនាំស្តីពីការ បញ្ជ្រាបវិធានការបន្សាំនឹងការប្រែប្រួលអាកាសធាតុក្នុងផែនការអភិវឌ្ឍន៍ និង កម្មវិធីវិនិយោគថ្នាក់ក្រោមជាតិ (ខេត្ត ស្រុក និងឃុំ) ដែលមានអ្នកពាក់ព័ន្ធ ថ្នាក់ជាតិ និងក្រោមជាតិ ១២៧នាក់ចូលរួម។

### ខ. បញ្ហាប្រឈម÷

- ការបញ្ចប់ការផ្តល់ប្រាក់ឧបត្ថម្ភដល់មន្ត្រី (ប្រតិបត្តិការអាទិភាព) ធ្វើឱ្យមន្ត្រីបាក់ ទឹកចិត្ត និងចូលរួមសកម្មក្នុងការអនុវត្តគម្រោង

- ការផ្លាស់ប្តូររចនាសម្ព័ន្ធនៅថ្នាក់ក្រោមជាតិ នាំឱ្យមានភាពយឺតយ៉ាវមួយចំនួនក្នុងការអនុវត្តគម្រោង ដូចជា÷ ការធ្វើលទ្ធកម្ម ការធ្វើបុរេប្រទាន ការទូទាត់...។ល។

- ការសម្របសម្រួលកិច្ចសហការរវាងមន្ទីរអនុវត្តគម្រោងទាំង៣ក្នុងការអនុវត្តវិធីសាស្ត្របែបប្រមូលផ្តុំ

- ខ្វះវិធីសាស្ត្រនិងឧបករណ៍សមស្របសម្រាប់ការតាមដានឥទ្ធិពលគម្រោង ។

### គ. ទិសដៅ÷

- បន្តជួយក្រុមប្រឹក្សាឃុំ និងគ.ផ.ថ ក្នុងការបញ្ចូលវិធានការបន្សាំនឹងការប្រែប្រួល អាកាសធាតុ ក្នុងកម្មវិធីវិនិយោគឃុំឆ្នាំ២០១៣

- វាយតម្លៃការកាត់បន្ថយភាពងាយរងគ្រោះ (VRA) ក្នុង១៦ឃុំដើម្បីវាស់វែងការយល់ ដឹងភាពងាយរងគ្រោះ និងកម្រិតនៃភាពងាយរងគ្រោះ

- បន្តជួយគាំទ្រទាំងការពង្រឹងសមត្ថភាពនិងផ្តល់សម្ភារៈដល់ភ្នាក់ងារស្ម័គ្រចិត្តផ្តល់ព័ត៌មានភូមិ-៥៣ភូមិ។

- បន្តពង្រឹងការយល់ដឹងបន្ថែមដល់មន្ត្រីពាក់ព័ន្ធ ពិសេសមន្ត្រីបង្គោលថ្នាក់ស្រុក ឃុំ និងសហគមន៍អំពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុ

- បន្តការគាំទ្រលើការកសាងសមត្ថភាព និងសម្ភារៈដល់សហគមន៍កសិករប្រើប្រាស់ទឹក និងក្រុមប្រើប្រាស់

ទឹកចំនួន ៤៥ក្រុម ព្រមទាំងបណ្តុះបណ្តាលសមាជិកក្រុមអំពី ប្រសិទ្ធភាពនៃការប្រើប្រាស់ទឹក

- រៀបចំតបណ្តាញផ្គត់ផ្គង់ទឹកសម្រាប់ក្រុមប្រើប្រាស់ទឹកស្វូឡាចំនួន៧កន្លែងក្នុងស្រុកជាំក្សាន្តខេត្តព្រះវិហារ

- បន្តគាំទ្រការកសាងសមត្ថភាព និងផ្តល់សម្ភារៈកសិកម្មដល់ក្រុមកសិករគោលដៅ ៣៩ក្រុម ដូចជាផ្តល់ពូជបន្លែ ស្រូវ សត្វ ឧបករណ៍កសិកម្ម...

- អនុវត្តសាកល្បងវិធីសាស្ត្របែបចម្រុះ ក្នុង៤ភូមិ (one village approach)

- សម្របសម្រួលទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍សម្រាប់កសិករគោលដៅនៅ ក្នុងនិងក្រៅខេត្ត

- បណ្តុះបណ្តាលថ្នាក់ដឹកនាំក្រុមអំពីនីតិវិធីនៃការកត់ត្រាទុនបង្វិលក្រុមចំនួន២១ក្រុម

- បណ្តុះបណ្តាលដល់ក្រុមបន្សុទ្ធពូជ ក្រុមកែលម្អប្រព័ន្ធកសិកម្ម សហគមន៍កសិករ ប្រើប្រាស់ទឹកអំពី ស្ត្រីនិងភាពជាអ្នកដឹកនាំ និងការសម្រេចចិត្ត

- រចនានិងបោះពុម្ពឯកសារស្តីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុ ឯកសារបណ្តុះបណ្តាលស្តីពី ប្រព័ន្ធធារាសាស្ត្រដែលធន់នឹងអាកាសធាតុ និងករណីសិក្សា បទពិសោធន៍របស់គម្រោង...

- បន្តគាំទ្រការកសាងសមត្ថភាពនិងការចែករំលែកបទពិសោធន៍គម្រោងតាមរយៈ ការចូលរួមសិក្ខាសាលា និងវេទិកានានានៅថ្នាក់ជាតិ និងក្នុងតំបន់

- រៀបចំការតាមដាននិងការវាយតម្លៃបញ្ចប់គម្រោង និងការរៀបចំសិក្ខាសាលា ឆ្លុះបញ្ចាំងនិងបិទគម្រោង

- ថវិកាសម្រាប់៨ខែ ក្នុងឆ្នាំ២០១៣ ចំនួន៥១៧.០៤០,០៩ ដុល្លារអាមេរិក ត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាលគម្រោង ដើម្បីអនុវត្តសកម្មភាពគ្រោងខាងលើ។

## គម្រោងកាត់បន្ថយភាពក្រីក្រនៅតំបន់ជនបទក្នុងខេត្តព្រៃវែងនិងស្វាយរៀង (RPRP)

គម្រោងកាត់បន្ថយភាពក្រីក្រនៅតំបន់ជនបទក្នុងខេត្តព្រៃវែងនិងស្វាយរៀង មានគោលបំណងដើម្បីកាត់បន្ថយភាពក្រីក្រនៃគ្រួសារអ្នកក្រីក្រ ដោយមានការចូលរួមយ៉ាងសកម្ម ពីកសិករក្រីក្រ តាមរយៈការកែលំអជីវភាពរស់នៅប្រចាំថ្ងៃពង្រឹងសមត្ថភាព កម្មវិធីប្រព័ន្ធ កសិកម្ម ឱ្យមាននិរន្តរភាព និងការគ្រប់គ្រងធនធានធម្មជាតិ ការជួសជុលនិងការសាងសង់ថ្មីនូវសំណង់ហេដ្ឋារចនាសម្ព័ន្ធ នឹងបង្កើនលទ្ធភាពសមស្របនូវបច្ចេកទេស សេវាកម្មនានា និងទីផ្សារសម្រាប់ការអភិវឌ្ឍន៍ សេដ្ឋកិច្ចនិងសង្គម។ គម្រោងនេះ បានអនុវត្តរយៈពេលប្រាំពីរឆ្នាំនឹងបានបញ្ចប់ការអនុវត្តនៅឆ្នាំ២០១១ ដោយប្រើប្រាស់ថវិកាសរុបចំនួនប្រមាណ ១៦លានដុល្លាអាមេរិក ជាកម្ចីហិរញ្ញប្បទានពីមូលនីធិអន្តរជាតិ អភិវឌ្ឍកសិកម្ម (IFAD)។ ក្នុងរយៈពេលប្រាំពីរឆ្នាំគម្រោងបានអនុវត្តបានក្នុងខេត្តគោលដៅចំនួនពីរគឺខេត្តព្រៃវែងនិងខេត្តស្វាយរៀង ១៦ស្រុក និង១៤៨ឃុំ នឹងទទួលបានសមិទ្ធផលដូចខាងក្រោម ÷

-បានចងក្រងក្រុមកសិករក្រីក្រចំនួន១០០៨ក្រុម ដែលមានសមាជិកសរុបចំនួន ២៥.២០០គ្រួសារ គម្រោងបានផ្តល់ការបណ្តុះបណ្តាលជំនាញកសិកម្មនិងរៀបចំជាក្រុមទុនបង្វិលដែលមានទុនចាប់ ផ្តើមគម្រោងចំនួន២.១៤៣.៣៩០ដុល្លារអាមេរិក និងមកដល់បច្ចុប្បន្នទុននេះកើនឡើងចំនួន៣.០៩៣.០៤៣ដុល្លារអាមេរិក

-បានបណ្តុះបណ្តាលអំពីជំនាញកសិកម្ម ការចិញ្ចឹមសត្វ មុខរបរខ្នាតតូច និង ការបញ្ជ្រាបយេនឌ័រ ព្រមទាំងរៀបចំធ្វើបង្ហាញដល់កសិករចំនួន ៥០.៤០០ គ្រួសារ

-បានជួសជុកផ្លូវលំជនបទចំនួន១,៩១៤គ.ម សាលារៀនសងអំពីឥដ្ឋ១៧៤បន្ទប់ ប្រព័ន្ធស្រោចស្រព៤៦៣គ.មទ្វារទឹក៨០កន្លែង និងសាងសង់ស្ពាន៣កន្លែង។

## គម្រោងលើកកំពស់ជីវភាពរស់នៅតាមជនបទខេត្តក្រចេះ ព្រះវិហារ និងរតនគិរី

### ១.លទ្ធផល

### ក.ក្រុមកែលម្អជីវភាព:

- បណ្តុះបណ្តាលសាលារៀនស្រែកសិករ២០សប្តាហ៍ដល់កសិករក្រុមកែលម្អជីវភាពចំនួន១៦៩ ក្រុមមានអ្នកចូលរួម ៣៨៣៥នាក់ (ស្ត្រីមេគ្រួសារ ១៨២៧នាក់)

- បណ្តុះបណ្តាលសាលារៀនស្រែកសិករ២០សប្តាហ៍ដល់កសិករក្រុមងាយរងគ្រោះចំនួន២១ក្រុម មានអ្នកចូលរួម ២៧២នាក់ (ស្ត្រីមេគ្រួសារ ១៨១នាក់)

- ការធ្វើបង្ហាញចំនួន៥៣៨ ក្នុងនោះមានបង្ហាញដំណាំស្រូវ១៤១ បន្លែ១០៥ ចិញ្ចឹមមាន់១៦៤ ចិញ្ចឹមទាកាប៉ា ៣៣ ចិញ្ចឹមជ្រូក៩២ និងចិញ្ចឹមត្រី៣បង្ហាញ

- រៀបចំទិវាសាលារៀនស្រែកសិករចំនួន១២៥ មានកសិករចូលរួមសរុប ៤១៥៧នាក់(ស្ត្រី ១៩៤៨នាក់) កសិករក្រៅក្រុម ៥៨៥នាក់(ស្ត្រី៣១២នាក់)

- ផ្តល់ទុនភ្នាក់ងារផ្សព្វផ្សាយឃុំក្លាយជាសមាជិកក្រុមកែលម្អជីវភាពចំនួន ១៩នាក់/ស្រី៨នាក់

- វគ្គរំលឹកដល់គ្រូIPMចំនួន៥១នាក់ (ស្ត្រី១៤នាក់)និងភ្នាក់ងារផ្សព្វផ្សាយឃុំចំនួន១១៦នាក់ (ស្ត្រី៦០នាក់)

- ផ្តល់វគ្គបណ្តុះបណ្តាលស្តីពី បញ្ជីស្នាមឥណទាន មុខជំនួញទីផ្សារ និងគណនេយ្យ ដល់សហគមអភិវឌ្ឍន៍កសិកម្មចំនួន៨ មានអ្នកចូលរួមសរុប ៨១នាក់ (ស្ត្រី៤៤នាក់) ខេត្តព្រះវិហារ

- រៀបចំធ្វើមហាសន្និបាតវិសាមញ្ញសហគមន៍ អភិវឌ្ឍន៍កសិកម្មស្រូវសេរីរាង្គនាងអំស្វាយជ្រះ ដែលមានសមាជិកចូលរួមសរុប ៨២នាក់ (ស្ត្រី ៣២នាក់) ខេត្តក្រចេះ

- ខេត្តព្រះវិហារបានបង្កើតសហគមអភិវឌ្ឍន៍កសិកម្មចំនួនថ្មីចំនួន៥ និងបញ្ចូលសមាជិកក្រុមកែលម្អជីវភាព និងក្រុមងាយរងគ្រោះទៅក្នុងសហគមអភិវឌ្ឍន៍កសិកម្មចាស់ចំនួន២ គឺសហគម ក្របៅព្រហ្មទេព និងសហគមអូរខ្លែងព័រមានជ័យ

- រៀបចំទស្សនៈកិច្ចដល់កសិករក្រុមគោលដៅចំនួន១៣៨ក្រុមដែលកសិករចូលរួមសរុបចំនួន២៨៤០នាក់ ស្ត្រី១៦៣៩នាក់។

**ខ. កម្មវិធីបំពេញបន្ថែម:**

- វគ្គរំលឹកឡើងវិញពេទ្យសត្វភូមិ ២៥៨នាក់(ស្ត្រី ៤០នាក់)

- ចុះកិច្ចសន្យាជាមួយភ្នាក់ងារសុខភាពសត្វភូមិចំនួន ៣០៣នាក់

-យុទ្ធនាការចាក់វ៉ាក់សាំងសត្វចំនួន២១៦ភូមិ ចាក់វ៉ាក់សាំងមាន់បាន ២៩៦៥៣១ក្បាល ទា៤០៧២ ក្បាល ជ្រូក ១៣៩២ក្បាល

- បំពាក់សម្ភារៈសម្រាប់ថែរក្សាវ៉ាក់សាំងដោយប្រើថាមពលពន្លឺព្រះអាទិត្យ (Sola System) ដល់សមាគមន៍ពេទ្យសត្វភូមិចំនួន២

- ប្រជុំភូមិពីការត្រួតពិនិត្យទីផ្សារនិងជម្ងឺសត្វសម្រាប់រៀបចំធ្វើយុទ្ធនាការ អ្នកចូលរួមសរុប ១៣៤៤ នាក់ (ស្ត្រី ៩៩៦នាក់) ខេត្តព្រះវិហារនិងរតនគីរី

- រៀបចំកិច្ចសន្យាប្រចាំឆ្នាំដល់ភ្នាក់ងារផ្សព្វផ្សាយឃុំចំនួន ១៦៨នាក់ (ស្ត្រី៨៣នាក់)។

**គ. ការគាំទ្រសេវាកម្មកសិកម្ម**

- សិក្ខាសាលាស្តីពីការអង្កេតលទ្ធផលប្រចាំឆ្នាំនិងការវិភាគទិន្នន័យ អ្នកចូលរួម២៥នាក់

- សិក្ខាសាលាឆ្លុះបញ្ចាំងការអនុវត្តគម្រោងថ្នាក់ខេត្ត ២៣៥នាក់ (ស្ត្រី ៧៨នាក់) ខេត្តរតនគីរីនិង ក្រចេះ

**ឃ. យេនឌ័រក្នុងវិស័យកសិកម្ម:**

- បើកវគ្គបណ្តុះបណ្តាលគ្រូបង្គោលស្តីពី មូលដ្ឋានគ្រឹះអាហារូបត្ថម្ភដល់មន្ត្រីថ្នាក់ជាតិ និងថ្នាក់ខេត្តចំនួន ៤៤ នាក់ (ស្ត្រីចំនួន៣១នាក់) រយៈពេល៣ថ្ងៃនៅខេត្តកំពង់ចាម

- វគ្គស្តីពីវិភាគការយេនឌ័រដល់ភ្នាក់ងារផ្សព្វផ្សាយឃុំ អ្នកទទួលបន្ទុកកិច្ចការនារីឃុំនិងមន្ត្រីបង្គោលយេនឌ័រ ស្រុក មានអ្នកចូលរួម ៤៥នាក់ (ស្ត្រី ៣៧នាក់) ខេត្តក្រចេះនិងរតនគីរី

- វគ្គរំលឹកឡើងវិញស្តីពីគោលគំនិតនៃការបញ្ជ្រាបយេនឌ័រដល់ភ្នាក់ងារផ្សព្វផ្សាយឃុំ មន្ត្រីគាំទ្រថ្នាក់ស្រុក-ខេត្ត អ្នកចូលរួម១០៧នាក់ (ស្ត្រី ៨៨នាក់)

- វគ្គបណ្តុះបណ្តាលស្តីពីមូលដ្ឋានគ្រឹះនៃអាហារូបត្ថម្ភដល់គ្រូបង្គោល និងភ្នាក់ងារផ្សព្វផ្សាយឃុំ អ្នកចូលរួមសរុប១៩៧នាក់ (ស្ត្រី ៨៧នាក់)

- វគ្គបណ្តុះបណ្តាលស្តីពីមូលដ្ឋានគ្រឹះនៃអាហារូបត្ថម្ភ ដល់កសិករក្រុមកែលម្អជីវភាព និងក្រុមងាយរងគ្រោះសរុប១៩០ក្រុម មានអ្នកចូលរួមសរុប៥៣៦៤នាក់ (ស្ត្រី៣៣៧៨នាក់) ក្នុងនោះ កសិករក្រៅក្រុម ៨៦២នាក់

- បោះពុម្ពសៀវភៅរូបភាពអាហារូបត្ថម្ភចំនួន ៤៦០ក្បាល សម្រាប់ចែកជូនគ្រូបង្គោល និងផ្ទាំងរូបភាពចំនួន ៩៣០០ផ្ទាំងសម្រាប់ចែកជូនដល់កសិករក្រុមកែលម្អជីវភាពនិងក្រុមងាយរងគ្រោះ

- បានអនុវត្តការតាមដានសកម្មភាពបញ្ហាបយេនឌ័រតាមរយៈករណីសិក្សា ដោយផ្តោតលើផ្នែកផ្លាស់ប្តូរសំខាន់ៗ ដែលមានទំនាក់ទំនងជាមួយយេនឌ័រ។

**តារាង- លទ្ធផលនៃការអនុវត្តហិរញ្ញវត្ថុ**

| ប្រភពថវិកា | ថវិកាប្រចាំឆ្នាំ (គិតជាដុល្លារ) | ចំណាយជាក់ស្តែង (គិតជាដុល្លារ) | ភាគរយសម្រេចបាន |
|---|---|---|---|
| **IFAD** | **១.៩៤២.៣៩៦,១៥** | **១.៣៨០.១៥៤,៦៥** | **៧១.០៥** |
| បដិភាគរដ្ឋាភិបាល | ៥៨.០៤២,៤១ | ៥៣.០៩៣.៨២ | ៩១.៤៧ |
| **សរុប** | ២.០០០.៤៣៨,៥៦ | **១.៤៣៣.២៤៨.៤៧** | **៧១.៦៤** |

## ២. បញ្ហាជួបប្រទះ

- ការចូលរួម និងការទទួលយកបច្ចេកទេសរបស់កសិករនៅមានកម្រិត
- ការអនុវត្តសកម្មភាពមិនបានសម្រេចតាមផែនការពីព្រោះការអនុម័តថវិកានិងលំហូរថវិកាមានការយឺតយ៉ាវ
- ការផ្លាស់ប្តូរមន្ត្រី នឹងការជ្រើសរើសមន្ត្រីជំនួសមានការលំបាកនិងយឺតយ៉ាវ (ខ្វះធនធានមនុស្ស)
- ការគាំទ្រសម្ភារសម្រាប់ដំណើរការសាលារៀនស្រែកសិករមានការយឺតយ៉ាវ
- សាលារៀនស្រែកសិករមានចំនួនច្រើនមិនសមាមាត្រទៅនឹងចំនួនគ្រូបង្គោលIPMមិនសមស្របសម្រាប់ដំណើរការសាលាតាមនិយាម IPM ឡើយ (គ្រូបង្គោល១នាក់អាចទទួល២ទៅ៣សាលាយ៉ាងច្រើន)
- ការចូលរួមរបស់កសិករក្នុងដំណើរការសាលារៀនស្រែកសិករមិនបានពេញលេញ ហើយតែងមានការផ្លាស់ប្តូរពេលចូលរៀន និងមានការលំបាកក្នុងការជ្រើសរើសកសិករធ្វើបង្ហាញ
- ទុនបង្វិលនៅតាមក្រុមមួយចំនួនកំពុងមានបញ្ហា មូលហេតុមកពីមានការប្រើប្រាស់ទុនមិនត្រឹមត្រូវ ការយល់ដឹងពីគោលការណ៍ទុនបង្វិលក្រុមនៅមានកម្រិតចំណេះដឹងពី ការគ្រប់គ្រងនិងធ្វើប្រតិបត្តិការឥណទាន ក្រុមមិនច្បាស់ និងមានការលួចបំពានកេងប្រវ័ញ្ចពីថ្នាក់ដឹកនាំ សមាជិកក្រុមនិងមន្ត្រីអនុវត្តគម្រោងមួយចំនួនយកទុនក្រុមចាយ ដោយខុសគោលការណ៍ក្រុម។

# គម្រោងបង្កើតផែនការមេសម្រាប់ការសម្របសម្រួលជំរុញការវិនិយោគក្នុងវិស័យកសិកម្ម

បានចាប់ផ្តើមអនុវត្តក្រោមកិច្ចសហការរវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអង្គការ KOICA (ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ)។ គម្រោងមានថវិកាសរុបជាជំនួយឥតសំណងចំនួន១លានដុល្លាអាមេរិក អនុវត្តក្នុងរយៈពេល២០១១-២០១៣។ គម្រោងនេះអនុវត្តលើសកម្មភាពសំខាន់ៗចំនួន៣ រួមមានសកម្មភាព (១) រៀបចំផែនការ ដើម្បីបង្កើតភ្នាក់ងារសម្របសម្រួល សម្រាប់ជំរុញការវិនិយោគក្នុងវិស័យកសិកម្ម (២) សិក្សាស្រាវជ្រាវ និងពិគ្រោះយោបល់លើផ្នែកនានាដែលទាក់ទងទៅនឹងការជំរុញវិនិយោគក្នុងវិស័យកសិកម្ម និង (៣) រៀបចំបើកវគ្គបណ្តុះបណ្តាលសម្រាប់ពង្រឹងសមត្ថភាពស្ថាបននិងមន្ត្រីសមភាគី ។

**ក. លទ្ធផល÷**

-បានរៀបចំពិគ្រោះយោបល់ជាមួយស្ថាប័នពាក់ព័ន្ធមួយចំនួន រួមមាន ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួងពាណិជ្ជកម្ម ក្រសួងអភិវឌ្ឍន៍ជនបទ និងបណ្តាក្រុមហ៊ុនឯកជន ដែលវិនិយោគក្នុងវិស័យកសិកម្ម

-បានចុះសិក្សាស្វែងយល់អំពីស្ថានភាពវិស័យកសិកម្មនៅខេត្តកំពង់ចាម និងខេត្តក្រចេះ

-បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីការចាប់ផ្តើមអនុវត្ត និងលទ្ធផលនៃការអនុវត្តគម្រោង

-បានជួបប្រជុំពិភាក្សាការងារបច្ចេកទេសជាមួយមន្ត្រីសមភាគី និងគណៈកម្មការតម្រង់ទិសគម្រោង លើការងាររៀបចំបង្កើតផែនការមេសម្រាប់ជំរុញការវិនិយោគក្នុងវិស័យកសិកម្ម ។

- បានបញ្ចប់ការរៀបចំឯកសារផែនការមេ នឹងគ្រោងរៀបចំផ្សព្វផ្សាយដាក់ឲ្យប្រើប្រាស់នាពេលខាងមុខ។

# ជំពូក ៣
# វាយតម្លៃនិងសន្និដ្ឋាន

## ៦-វាយតម្លៃរួម

ផ្អែកលើលទ្ធផលទទួលបានក្នុងឆ្នាំ២០១២-២០១៣ កន្លងមកនេះ យើងអាចវាយតម្លៃជារួមក្នុងការអនុវត្តនារយៈពេលមួយឆ្នាំកន្លងមកនេះ ទោះបីជាបានជួបប្រទះនូវគ្រោះធម្មជាតិដូចជាគ្រោះទឹកជំនន់ ជាពិសេសជំនន់ទឹកភ្លៀងនារដូវវស្សាភាពរាំងស្ងួតកង្វះខាតទឹកនារដូវវស្សា និងការខ្វះទឹកក្នុងរដូវប្រាំងកន្លងមកយ៉ាងណាក៏ដោយ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមការណែនាំនិងតម្រង់ទិស ក៏ដូចជាវិធានការឆ្លើយតបយ៉ាងមានប្រសិទ្ធភាពរបស់រាជរដ្ឋាភិបាល និងមានការចូលរួមពីគ្រប់ក្រសួងស្ថាប័ន អាជ្ញាធរថ្នាក់ក្រោមជាតិ កងកម្លាំងប្រដាប់អាវុធ និងប្រជាកសិករទូទាំងប្រទេស ព្រមទាំងការរួមចំណែកពីដៃគូអភិវឌ្ឍន៍ បានធ្វើឱ្យផលិតកម្មកសិកម្មក្នុងឆ្នាំ២០១២-២០១៣ មានការវិវឌ្ឍរីកចម្រើនគួរជាទីមោទនៈ។

ជាក់ស្តែងស្រូវរដូវវស្សាឆ្នាំ២០១២នេះ យើងបានដាំដុះស្រូវរដូវវស្សាលើផ្ទៃដីសរុប ២,៥១លានហត ដែលមានទិន្នផលជាមធ្យមចំនួន**២,៨៧២ត/ហត** ដោយទទួលបរិមាណផលសរុបប្រមាណ **៧,១៤លានតោន** និងស្រូវរដូវប្រាំងឆ្នាំ២០១២-២០១៣ លើផ្ទៃដីប្រមាណ**០,៤៩៥លានហត** ដែលមានទិន្នផលជាមធ្យម **៤,៣៩៥ត/ហត** ដោយទទួលបានបរិមាណផលសរុប២,១៥៤លានតោន។ សរុបទាំងរដូវវស្សានិងរដូវប្រាំង យើងអនុវត្តបានលើផ្ទៃដីសរុបប្រមាណ**៣លានហត** ដោយទទួលបរិមាណផលសរុបប្រមាណ **៩,២៩លានតោនស្រូវ** និងទិន្នផលមធ្យមប្រចាំឆ្នាំ **៣,១១៧ត/ហត**។ ដូច្នេះតុល្យភាពស្បៀងនៅសល់ប្រមាណ**៣លានតោនអង្ករ** គិតជា**ស្រូវជាង៤,៧លានតោន** លើសឆ្នាំមុន០,៣៩លានតោនស្រូវ និងខ្ពស់ជាងមធ្យមភាគ១០ឆ្នាំ កន្លងមកប្រមាណ១,២លានតោនអង្ករ ដែលនេះជាជោគជ័យមួយធំណាស់។ ការស្រាវជ្រាវដំណាំស្រូវ ស្វែងរកបច្ចេកទេសមស្រប ដើម្បីយកទៅផ្សព្វផ្សាយជូនប្រជាកសិករប្រើប្រាស់ក្នុងការធ្វើប្រពលវប្បកម្មដំណាំស្រូវ បានអនុវត្ត ការងារពិសោធន៍ស្រាវជ្រាវលើដំណាំស្រូវយ៉ាងសកម្មនៅតាមកសិដ្ឋាន ស្ថានីយ៍ មណ្ឌលអភិវឌ្ឍកសិកម្មនិងស្រែកសិករ មានជាអាទិ៍ ការពិសោធន៍ពាក់ព័ន្ធនឹងប្រសិទ្ធិភាពនៃការប្រើប្រាស់ជី ការពិសោធន៍ប្រៀបធៀបពូជ ការពិសោធន៍បន្សាំពូជ និងការពិសោធន៍អំពីវិធីសាស្ត្រដាំដុះដំណាំស្រូវផ្សេងៗទៀត ។

ក្នុងការអនុវត្តឯកសារគោលនយោបាយជំរុញផលិតកម្មស្រូវនិងនាំចេញអង្កររបស់រាជរដ្ឋាភិបាលកម្ពុជា ក្រៅពីបាន និងកំពុងជំរុញផលិតកម្មស្រូវដែលសម្រេចបាននូវលទ្ធផលគួរជាទីមោទនៈ ជាមួយនឹងអតិរេកគិតជាអង្ករប្រមាណ៣លានតោនក្នុងឆ្នាំ២០១២-២០១៣ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ បានសម្រេចសកម្មភាពជំរុញអង្ករកម្ពុជាឈានចូលទៅក្នុងទីផ្សារអន្តរជាតិ៥៧ ប្រទេសជាមួយបរិមាណអង្ករប្រមាណ២០ម៉ឺនតោន ក្នុងឆ្នាំ២០១២ និង៩៥ពាន់តោនក្នុងត្រីមាសទី១ឆ្នាំ២០១៣។

ដំណាំរួមផ្សំនិងដំណាំឧស្សាហកម្មសំខាន់ៗ ក៏មានការកើនឡើងលើសឆ្នាំមុន ជារួមឈានមកដល់ពេលបច្ចុប្បន្ន ការងារបង្កបង្កើនផលឆ្នាំ២០១២-២០១៣ នេះ ទទួលបានផលយ៉ាងល្អប្រសើរ។ ចំពោះអនុវិស័យដំណាំនឹងកាន់មានភាពរីកចម្រើនកាន់តែខ្លាំង ទន្ទឹមនឹងលទ្ធផលនៃការអនុវត្តគោលនយោបាយ ចាស់សកម្មភាពថ្មីលើវិស័យដីធ្លី ដែលផ្តល់សន្តិសុខនិងសុវត្ថិភាពដីធ្លីដល់ប្រជាពលរដ្ឋយូរអង្វែង។

រីឯផលិតកម្មសត្វជាពិសេស គោ ក្របី និងបក្សីមានការវិវឌ្ឍន៍ជាវិជ្ជមានគួរកត់សម្គាល់ ទាំងចំនួនសត្វទាំងបែបផែនផលិតកម្ម ដោយផលិតកម្មនេះអាចធានាការផ្គត់ផ្គង់សេចក្តីត្រូវការក្នុងស្រុក និងគោ-ក្របីត្រូវបាននាំចេញទៅបរទេសមួយចំនួនផងដែរ។ ដោយធ្វើការប្រៀបធៀបផលិតកម្មសត្វរយៈពេល៥ឆ្នាំ (២០០៨-២០១២) ឃើញថា ផលិតកម្ម គោបានថយចុះចំនួន២,៣៤%។ ដោយឡែក បើប្រៀបធៀបនឹងឆ្នាំ២០១១ ការចិញ្ចឹមគោបានថយចុះប្រមាណ០,៨៦% រីឯក្របីសរុបមានចំនួនជាង៦៥៧ពាន់ក្បាល ថយចុះ៤,៧៦% ដែលបណ្តាលមួយផ្នែកធំមកពីការរីកចម្រើន ក្នុងការប្រើប្រាស់គ្រឿងយន្តកសិកម្មក្នុងការបង្កបង្កើនផលដំណាំ និងជ្រូកចិញ្ចឹមបានកើនប្រមាណ៥,២១%។ ការចិញ្ចឹមសត្វស្លាប (មាន់ ទា) ជាលក្ខណៈ

គ្រួសារពីឆ្នាំ២០០៨ដល់២០១២ មានការកើនឡើងយ៉ាងខ្លាំងរហូតដល់៣៦%។ ចំពោះដំណាំអចិន្ត្រៃយ៍ដូចជា កៅស៊ូ ស្វាយចន្ទី ដំណាំឈើហូបផ្លែផ្សេងៗនិងចំការ។ល។ កំពុងមានការរីកចំរើនជាបន្តបន្ទាប់ ជាលក្ខណៈគ្រួសារនិងជាលក្ខណៈវិនិយោគខ្នាតតូច មធ្យម និងធំ។ គួរកត់សម្គាល់ថា នៅឆ្នាំ២០១២ ផ្ទៃដីដាំដុះកៅស៊ូនៅកម្ពុជាបានកើនឡើង៣១,៥% បើប្រៀបធៀបទៅនឹងឆ្នាំ២០១១។

វិស័យព្រៃឈើកំពុងតែត្រូវបានយកចិត្តទុកដាក់ខ្ពស់ សំដៅធានាឱ្យមាននិរន្តរភាពសម្រាប់ការគ្រប់គ្រងធនធានព្រៃឈើ និងការប្រើប្រាស់ធនធានព្រៃឈើដល់ប្រជាជនក្រីក្រ តាមរយៈកំណែទម្រង់ព្រៃឈើ។ ក្នុងរយៈពេល៥ឆ្នាំ២០០៨-២០១២ លទ្ធផលនៃការងារដាំឈើទទួលបានសរុបចំនួន៨០.៦៩៣ហត ក្នុងនោះ ដាំដោយរដ្ឋបាលព្រៃឈើចំនួន ៣.៨៣៨ហត កងយោធពលខេមរភូមិន្ទចំនួន៣០០ហត ដាំជាលក្ខណៈគ្រួសារចំនួន៦.១២០ហត រុក្ខទិវាចំនួន ៣៣៦,៧៣ហត និងក្រុមហ៊ុនឯកជនចំនួន៧០.០៩៨ហត។

ចំណែកឯវិស័យជលផល ការធ្វើអាជីវកម្មនេសាទទឹកសាបបានកើនឡើង ១០,៦% ធៀបនឹងឆ្នាំមុន និងមានកំណើនប្រមាណ៣៩% ធៀបក្នុងរយៈពេល៥ឆ្នាំ (ឆ្នាំ២០០៨-២០១២)។ អាជីវកម្មនេសាទសមុទ្របានកើនប្រមាណ ១១% និងមានកំណើនប្រមាណ៥០%ធៀបក្នុងរយៈពេល៥ឆ្នាំ (ឆ្នាំ២០០៨-២០១២)។ ការអភិវឌ្ឍវារីវប្បកម្ម ដូចជាការចិញ្ចឹមត្រី បង្គា ការភ្ញាស់កូនត្រីពូជ ក្រពើ កំពុងត្រូវបានអនុវត្តយ៉ាងសកម្ម និងសហគមន៍នេសាទចំនួន ៥១៦សហគមន៍ត្រូវបានបង្កើត និងពង្រឹងសមត្ថភាពគ្រប់គ្រង។ ឆ្នាំ២០១២ ក៏ជាការកត់សម្គាល់នូវកំណែទម្រង់ផ្តាច់ព្រ័ត្យក្នុងវិស័យជលផលក្រោមការដឹកនាំដ៏មោះមុតរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**ដែលឡូតិ៍នេសាទមានប្រវត្តិជាង១០០ឆ្នាំ ត្រូវបានរំសាយចោលដោយមួយភាគធំជូនប្រជាពលរដ្ឋប្រើប្រាស់ និងគ្រប់គ្រងតាមរយៈសហគមន៍នេសាទ និងមួយផ្នែកតូចទុកសម្រាប់អភិរក្សនិងបង្កើនផលស្តុកឡើងវិញ។ កំណែទម្រង់នេះបានរួមចំណែកយ៉ាងសំខាន់ ដល់ការកាត់បន្ថយកម្រិតអតិផរណានៅកម្ពុជា។

ការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ និងច្បាប់ស្តីពីជលផល កំពុងត្រូវបានយកចិត្តទុកដាក់ និងកាត់បន្ថយឱ្យបានជាអតិបរមា នូវគ្រប់រូបភាពនៃបទល្មើសផ្សេងៗ ក្រោមកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរថ្នាក់ក្រោមជាតិ និងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ។

ទន្ទឹមនឹងអនុវិស័យខាងលើ (ផលិតកម្មដំណាំស្រូវ ផលិតកម្មនិងបសុព្យាបាល ផលិតកម្មដំណាំកៅស៊ូ រុក្ខកម្ម ជលផល) ផ្នែកសេវាកម្មនិងការគាំទ្រផ្សេងៗ ក៏បានសម្រេចនូវលទ្ធផលការងារតាមផ្នែកនីមួយៗបានល្អប្រសើរ ស្របតាមគោលការណ៍និងទិសដៅរបស់រាជរដ្ឋាភិបាល ដូចជាការងារវិនិយោគសាធារណៈ ការរៀបចំគម្រោងជាច្រើនសម្រាប់អភិវឌ្ឍន៍វិស័យកសិកម្ម ការងារវិនិយោគផ្នែកឯកជនលើវិស័យកសិកម្មមានការកើនឡើងខ្លាំង ការងារស្រាវជ្រាវនិងផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ត្រូវបានអនុវត្តកាន់តែទូលំទូលាយ រួមនឹងកិច្ចការសហប្រតិបត្តិការអន្តរជាតិកាន់តែល្អប្រសើរឡើង និងការរៀបចំលិខិតបទដ្ឋានច្បាប់ លិខិតបទដ្ឋានក្រោមច្បាប់ ដែលពាក់ព័ន្ធនឹងវិស័យកសិកម្ម ត្រូវបានរៀបចំរួចរាល់បានកាន់តែច្រើនជាលំដាប់ផងដែរ។

ជារួមសមិទ្ធផល ដែលសម្រេចបានដូចក្នុងរបាយការណ៍លំអិតនេះ គឺជាផ្លែផ្កានៃកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍នានា និងការចូលរួមយ៉ាងសស្រាក់សស្រាំរបស់ប្រជាពលរដ្ឋផងដែរ។

ជាសន្និដ្ឋាន កសិកម្មកម្ពុជាក្នុងឆ្នាំ២០១២-២០១៣ សម្រេចបាននូវលទ្ធផលល្អប្រសើរ ដោយសារការដាក់ចេញនិងអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់នូវគោលនយោបាយនិងយុទ្ធសាស្ត្រ ជាពិសេសយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយភាពឈ្លាសវៃ និងម៉ឺងម៉ាត់បំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**។

## ៧-ទិសដៅរួម

វិស័យកសិកម្មជាវិស័យអាទិភាព ដែលរាជរដ្ឋាភិបាលបានកំណត់នៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ តាមរចនាសម្ព័ន្ធមុំបួននៃចតុកោណប្រទាក់ក្រឡាគ្នា។ ចតុកោណយុទ្ធសាស្ត្រទី១ ពាក់ព័ន្ធនឹងភារៈកិច្ចសំខាន់ៗ ជាស្នូលរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺបន្តការលើកស្ទួយវិស័យកសិកម្ម ដែលនៅក្នុងនោះមាន៤មុំជាចំបង (១)-ការលើកកំពស់ផលិតភាពកសិកម្ម និងពិពិធកម្មកសិកម្ម (២)-កំណែទំរង់ដីធ្លីនិងបោសសំអាតមីន (៣)-កំណែទម្រង់វិស័យនេសាទនិងជលផល (៤)-កំណែទម្រង់ព្រៃឈើ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំនិងអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម (២០០៩-២០១៣) ស្របទៅនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ក៏ដូចជាផែនការយុទ្ធសាស្ត្រកសិកម្មនិងទឹក និងបានដាក់បញ្ចូលនូវសកម្មភាពអាទិភាពតាមផ្នែក នៅក្នុងគម្រោងវិនិយោគសាធារណៈ (PIP) បីឆ្នាំរំកិល សំដៅការស្វែងរកប្រភពទុន និងជំនួយបច្ចេកទេសពីដៃគូអភិវឌ្ឍន៍ ក្នុងការធ្វើឱ្យសម្រេចបាននូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិនេះ។ ដោយឡែកសម្រាប់ឆ្នាំ២០១៣-២០១៤នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានដាក់ចេញនូវទិសដៅរួមមួយចំនួនដូចខាងក្រោម ÷

**ទី(១) <u>ផលិតកម្មដំណាំនិងការស្រាវជ្រាវកសិកម្ម</u>÷**

- បន្តជំរុញការលើកកំពស់ផលិតភាព និងពិពិធភាវូបនីយកម្មកសិកម្ម តាមរយៈការពង្រឹង និងកសាងហេដ្ឋារចនាសម្ព័ន្ធនៅតាមកសិដ្ឋាន ស្ថានីយ៍ពិសោធន៍កសិកម្ម និងមជ្ឈមណ្ឌលអភិវឌ្ឍន៍កសិកម្ម ដើម្បីបម្រើឱ្យការងារពិសោធន៍ស្រាវជ្រាវ អភិវឌ្ឍ និងផ្ទេរបច្ចេកវិទ្យាទំនើបសមស្រប លើគ្រប់មុខជំនាញពាក់ព័ន្ធនឹងការអភិវឌ្ឍផលិតកម្មដំណាំទៅដល់ស្រទាប់ប្រជាកសិករនិងផលិតករគ្រប់កំរិតនាំទៅដល់ការបង្កើនទិន្នផលនិងគុណភាពផលិតផល ឆ្លើយតបទៅនឹងសេចក្តីត្រូវទីផ្សារក្នុងស្រុកនិងក្រៅស្រុក
- បន្តពង្រឹងសេវាអប់រំផ្សព្វផ្សាយបច្ចេកទេសជូនដល់ប្រជាកសិករឱ្យបានកាន់តែទូលំទូលាយ និងស៊ីជម្រៅថែមទៀត ដើម្បីពង្រីកការទទួលយកទៅអនុវត្តនូវបច្ចេកទេសសមស្របសម្រាប់ការដាំដុះ ការគ្រប់គ្រងជីជាតិដី ការការពារដំណាំ ការប្រើប្រាស់និងថែទាំគ្រឿងយន្តនិងឧបករណ៍កសិកម្ម ការប្រមូលផលទុកដាក់និងកែច្នៃក្រោយពេលប្រមូលផលប្រកបដោយប្រសិទ្ធភាព។ លើសពីនេះទៀតត្រូវខិតខំបង្វិតសេវាផ្សព្វផ្សាយកសិកម្មឱ្យបានកាន់តែជិតកសិករតាមរយៈការបណ្តុះបណ្តាលភ្នាក់ងារផ្សព្វផ្សាយកសិកម្មភូមិ-ឃុំ ការរៀបចំបង្កើតឱ្យមានជាមណ្ឌលកសិកម្មឃុំសង្កាត់និងដាក់មន្ត្រីជំនាញ បំពាក់មធ្យោបាយ និងបរិក្ខារ និងបង្កើតមណ្ឌលព័ត៌មានកសិកម្មតាមខេត្ត ស្រុក និងមូលដ្ឋានឃុំសង្កាត់
- បន្តកិច្ចខិតខំជំរុញការចងក្រងនិងព្រងឹងសហគមន៍កសិកម្ម តាមរយៈការកសាងសមត្ថភាពដឹកនាំគ្រប់គ្រងជំនាញក្នុងការធ្វើផែនការ ដំណើរការមុខរបរ ការធ្វើជំនួញ និងទីផ្សារ និងសេវាកម្មពាក់ព័ន្ធនឹងខ្សែចង្វាក់ផលិតកម្មកសិកម្ម ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការអភិវឌ្ឍកសិកម្មមានលក្ខណៈប្រមូលផ្តុំក្នុងភាពជាដៃគូជាមួយផ្នែកឯកជនក្រោមក្របខ័ណ្ឌផលិតកម្មកសិកម្មតាមកិច្ចសន្យាដើម្បីទទួលបានទាំងបច្ចេកវិទ្យាថ្មី និងឥណទានគ្រប់គ្រាន់ ធានាបានស្ថេរភាពនៃការផ្គត់ផ្គង់ផលិតផលទៅកាន់ទីផ្សារទាំងបរិមាណនិងគុណភាពនិងជាពិសេសដើម្បីព្រងឹងអំណាចតថ្លៃរបស់កសិករនៅក្នុងខ្សែសង្វាក់ផលិតកម្ម
- ខិតខំជំរុញការងារអង្កេតសិក្សា វាយតម្លៃ និងការធ្វើសារពើភណ្ឌ ការប្រើប្រាស់ដីកសិកម្មឱ្យបាននៅទូទាំងប្រទេស ដើម្បីទទួលបាននូវទិន្នន័យជាក់លាក់ជាធាតុចូលសម្រាប់បម្រើឱ្យការរៀបចំផែនការអភិវឌ្ឍន៍វិស័យកសិកម្ម ដោយអាចកំណត់បានដំបន់ដាំដុះជាក់លាក់ដើម្បីតម្រង់ទិសដល់ការធ្វើប្រពលវប្បកម្ម និងពិពិធភាវូបនីយកម្មកសិកម្ម និងធានានិរន្តរភាពនៃការប្រើប្រាស់ដីកសិកម្ម
- បន្តខិតខំស្រាវជ្រាវនិងកំណត់ប្រតិទិនដាំដុះស្របតាមប្រព័ន្ធបរិស្ថានដំណាំនិងលក្ខខណ្ឌអាកាសធាតុដើម្បីធានាបាននូវផលិតភាពកសិកម្មខ្ពស់ ធានាការផ្គត់ផ្គង់កសិផលគ្រប់គ្រាន់នៅគ្រប់រដូវកាលតាមតម្រូវការទីផ្សារ និង

អាចកាត់បន្ថយបាននូវផលប៉ះពាល់ដោយគ្រោះធម្មជាតិដូចជាគ្រោះរាំងស្ងួតនិងទឹកជំនន់ដែលកើតឡើង ដោយសារឥទ្ធិពលនៃបំរែបំរួលអាកាសធាតុ

- បន្តជំរុញការស្រាវជ្រាវនិងការអភិវឌ្ឍបច្ចេកទេសក្រោយប្រមូលផលឱ្យល្អប្រសើរ ដោយត្រូវពង្រឹងទាំងផ្នែកបច្ចេកទេសនិងធ្វើឱ្យមានទំនើបកម្មផ្នែកសម្ភារៈនិងឧបករណ៍ និងការអនុវត្តប្រកបដោយភាពប្រាកដប្រជាក្នុងទិសដៅកាត់បន្ថយការបាត់បង់កសិផលនិងធានាបាននូវគុណភាពកសិផល
- ក្នុងទិសដៅបង្កើនសុវត្ថិភាពនិងការឈានចូលទីផ្សារនៃកសិផលកម្ពុជា ត្រូវជំរុញការអនុវត្តផលិតកម្មតាមគោលការណ៍នៃការអនុវត្តកសិកម្មល្អ និងបង្កើតស្តង់ដារផលិតផលសុវត្ថិភាពផ្សារភ្ជាប់នឹងយន្តការត្រួតពិនិត្យនិងចេញវិញ្ញាបនបត្របញ្ជាក់ដើម្បីបង្កើនភាពជឿជាក់ពីអតិថិជននិងភាពអះអាងផ្នែកគុណភាព។
- ជំរុញការស្រាវជ្រាវនិងប្រើប្រាស់ភ្នាក់ងារជីវសាស្ត្រ ថ្នាំកសិកម្មជីវសាស្ត្រ និងថ្នាំផ្សំពីរុក្ខជាតិ ដើម្បីកម្ចាត់សមាសភាពចង្រៃការពារដំណាំ ក្នុងទិសដៅកាត់បន្ថយជាបណ្តើរៗការប្រើប្រាស់ថ្នាំកសិកម្ម គីមីសំយោគ ដែលពុលខ្លាំងប៉ះពាល់ធ្ងន់ធ្ងរដល់សុខភាពមនុស្សនិងបរិស្ថាន ស្របតាមគោលនយោបាយអភិវឌ្ឍបៃតងរបស់រាជរដ្ឋាភិបាល
- បន្តខិតខំសហការរួមគ្នាជាមួយវិស័យឯកជននិងដៃគូអភិវឌ្ឍន៍នានាក្នុងការលើកកំពស់សមត្ថភាពយល់ដឹងដល់ប្រជាកសិករយើងលើការចេះប្រើប្រាស់ ថែទាំ និងជួសជុលគ្រឿងយន្តកសិកម្ម និងឧបករណ៍កសិកម្មដែលប្រជាកសិករកំពុងប្រើប្រាស់ក្នុងពេលបច្ចុប្បន្ន ដើម្បីជួយដល់ប្រជាកសិករយើងឱ្យមានមូលដ្ឋាន ក្នុងការងារធ្វើផលិតកម្មកសិកម្មទំនើបស្របតាមសភាពការណ៍ប្រទេសជាតិដែលកំពុងវិវឌ្ឍន៍លើគ្រប់វិស័យ ពិសេសសម្រាប់គាំទ្រដល់គោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករនាពេលបច្ចុប្បន្ននេះដែរ
- បន្តខិតខំរៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដើម្បីជាឧបករណ៍អនុវត្តការងារ ដើម្បីឆ្លើយតបទៅនឹងនិន្នាការរីកចម្រើនរបស់វិស័យកសិកម្មនាពេលបច្ចុប្បន្ននិងអនាគត ក្នុងក្របខ័ណ្ឌសន្តិសុខស្បៀង លើកកម្ពស់គុណភាពផលិតផលកសិកម្មជំរុញការនាំចេញកសិផល និងធានានិរន្តរភាពធនធានធម្មជាតិនិងបរិស្ថាន រួមមានជាអាទិ៍ សេចក្តីព្រាងច្បាប់ស្តីពីការប្រើប្រាស់និងគ្រប់គ្រងដីកសិកម្ម សេចក្តីព្រាងច្បាប់ស្តីពី ការការពារដំណាំនិងភូតគាមអនាម័យ និងលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធក្រោមច្បាប់ស្តីពី ការគ្រប់គ្រងពូជដំណាំនិងសិទ្ធិអ្នកបង្កាត់ពូជ និងឯកសារយុទ្ធសាស្ត្របន្សាំនិងកាត់បន្ថយផលប៉ះពាល់ ដោយសារបំរែបំរួលអាកាសធាតុក្នុងផលិតកម្មដំណាំកសិកម្ម
- កសាងទំនាក់ទំនងសហប្រតិបត្តិការល្អជាមួយដៃគូអភិវឌ្ឍជាតិនិងអន្តរជាតិ សំដៅគៀងគរជំនួយឧបត្ថម្ភគ្រប់ប្រភេទសម្រាប់ការស្តារនិងកសាងនូវហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តតាមបណ្តាកសិដ្ឋាន ស្ថានីយ៍ ដើម្បីពង្រឹងនិងពង្រីកសមត្ថភាពស្រាវជ្រាវនិងផ្សព្វផ្សាយបច្ចេកទេសដល់កសិករ ក៏ដូចជាដើម្បីអនុវត្តផែនការសកម្មភាពការងារពាក់ព័ន្ធនឹងឯសារគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករ
- ពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តការជាមួយដៃគូអភិវឌ្ឍន៍ អង្គភាពស្រាវជ្រាវជាតិនិងអន្តរជាតិ មន្ទីរកសិកម្មរាជធានី ខេត្ត អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកនិងក្រៅស្រុកនានាដើម្បី (១)បន្តអភិវឌ្ឍពូជដំណាំកសិកម្មដែលមានសក្តានុពលទិន្នផលខ្ពស់ ហើយប្រកបដោយគុណភាពល្អប្រពៃធន់ទ្រាំទៅនឹងទឹកជំនន់គ្រោះរាំងស្ងួត ជាតិប្រៃនិងកំដៅ ពូជស្រូវអាយុកាលខ្លីជាង១០០ថ្ងៃនិងបន្តធ្វើការស្រាវជ្រាវ ដោយប្រើវិធីសាស្ត្ររួមគ្នាប្រកបដោយសុវត្ថិភាពនិងមាននិរន្តរភាព ដើម្បីជួយកសិករក្នុងការការពារការបាត់បង់ទិន្នផលដំណាំនិងប្រាក់ចំណេញ (២)បន្តស្រាវជ្រាវនិងអភិវឌ្ឍបច្ចេកទេសនៃប្រព័ន្ធគ្រប់គ្រងជីជាតិដី សារធាតុចិញ្ចឹមប្រកបដោយលក្ខណៈសេដ្ឋកិច្ចនិងនិរន្តរភាពខ្ពស់ ដើម្បីជួយប្រជាកសិករក្នុងការបង្កើននិងធ្វើឲ្យមានស្ថេរភាពទិន្នផលដំណាំ នៅក្នុងប្រព័ន្ធកសិកម្មនៃតំបន់ទំនាបតំបន់ស្រោចស្រពនិងតំបន់ខ្ពង់រាប តាមរយៈការធ្វើឱ្យកាន់តែប្រសើរឡើងនូវចំណេះដឹងលើផ្នែកគ្រប់គ្រងដីនិងសារធាតុចិញ្ចឹមរបស់ដំណាំ (៣)បន្តសិក្សារកលទ្ធភាពបង្កើនផលិតភាពនិងពិពិធកម្មដំណាំកសិកម្ម ក្នុងប្រព័ន្ធកសិកម្មនៃតំបន់ទំនាបនិងតំបន់ខ្ពង់រាប នៃប្រព័ន្ធផលិតកម្មដំណាំកសិកម្ម (៤)បន្តស្រាវជ្រាវដើម្បីអភិវឌ្ឍន៍សមត្ថភាពវិភាគក្នុងមន្ទីរពិសោធន៍ផ្នែកវិភាគដី ទឹក រុក្ខជាតិ ជំងឺ រុក្ខវិទ្យា និងជាលិកាវប្បកម្ម (៥)បន្តពង្រឹងនិងជំរុញការ

ផ្សព្វផ្សាយបច្ចេកវិទ្យាទៅដល់កសិករនិងអ្នកពាក់ព័ន្ធនានាតាមរយៈការបោះពុម្ពផ្សាយគេហទំព័រ កាសែត វិទ្យុនិងទូរទស្សន៍ (៦)លើកកម្ពស់សមត្ថភាពរបស់មន្ត្រី តាមរយៈវគ្គបណ្តុះបណ្តាល សិក្ខាសាលា ទស្សនកិច្ចសិក្សានិងកិច្ចប្រជុំផ្សេងៗទាំងក្នុងប្រទេសនិងក្រៅប្រទេស និង (៧)ប្រើប្រាស់អគ្គិសនីដោយសន្សំសំចៃ។

**ទី(២) <u>ផលិតកម្មដំណាំកៅស៊ូ</u>**

- បញ្ចប់ការតាក់តែងសេចក្តីព្រាងច្បាប់ស្តីពីកៅស៊ូ និងពង្រីកសេវាណែនាំបច្ចេកទេសបន្តដល់កសិករក្នុងការជ្រើសរើសពូជ ការដាំដុះ ការថែទាំ និងការប្រមូលផល។ល។
- រៀបចំយន្តការធ្វើវិញ្ញាបនកម្មច្បារពូជនិងបណ្តុះបណ្តាលអ្នកធ្វើច្បារពូជ និងអនុវត្តគម្រោងធម្មយាមកម្មច្បារពូជកៅស៊ូ និងរៀបចំចម្ការពិសោធន៍ដីលើកៅស៊ូធ្វើអាជីវកម្ម
- រៀបចំកម្មវិធីផ្លាស់ប្តូរក្លូនកៅស៊ូក្នុងរង្វង់ប្រទេសជាសមាជិក IRRDB និងពិធីសារពិសោធន៍ ព្រមទាំងបង្កើតចម្ការពិសោធន៍ដី លើក្លូនកៅស៊ូដាំលើដីខ្សត់ជីជាតិ និងបង្កើតច្បារបង្កាត់ពូជកៅស៊ូ និងបន្តការងារស្រាវជ្រាវកៅស៊ូលើគ្រប់ប្រធានបទ
- ចុះបើកវគ្គផ្សព្វផ្សាយបច្ចេកទេសលើដំណាំកៅស៊ូ ដល់កសិករកៅស៊ូគ្រួសារនិងឯកជន នៅក្នុងខេត្តគោលដៅចំនួន០៩ គឺកំពង់ចាម កំពង់ធំ ព្រះវិហារ បាត់ដំបង ប៉ៃលិន រតនគិរី ស្ទឹងត្រែង មណ្ឌលគិរី និងក្រចេះ
- បង្កើតអនុស្ថានីយនៅតាមបណ្តាខេត្ត និងបើកវគ្គបណ្តុះបណ្តាលបច្ចេកទេសដំណាំកៅស៊ូ ការប្រមូលផលទឹកជ័រ និងការបង្កើនគុណភាពកៅស៊ូធម្មជាតិរបស់កសិករ និងការបង្កើនគុណភាពកៅស៊ូ TSR និងផលិតកម្មកៅស៊ូ TSR ថ្នាក់ខ្ពស់ដល់កសិករ មន្ត្រីបង្គោលតាមខេត្ត ម្ចាស់រោងចក្រកែច្នៃកៅស៊ូ TSR និងសិប្បករកៅស៊ូសន្លឹក និងបណ្តុះបណ្តាលបច្ចេកទេសដំណាំកៅស៊ូដល់មន្ត្រីបង្គោលតាមខេត្តគោលដៅ
- ចុះពិនិត្យនិងស្រង់ស្ថិតិច្បារពូជនិងរោចក្រ-សិប្បកម្មកៅស៊ូទូទាំងប្រទេស និងស្ថានភាពបណ្តាចម្ការកៅស៊ូកសិឧស្សាហកម្មនិងចម្ការកៅស៊ូគ្រួសារ នៅក្នុងទូទាំងប្រទេស ដើម្បីប្រមូលទិន្នន័យនិងធ្វើការវាយតម្លៃ។ ពង្រឹងចម្ការកៅស៊ូកសិឧស្សាហកម្ម ដើម្បីជាស្នូលក្នុងការជួយទ្រទ្រង់ដល់ចម្ការកៅស៊ូគ្រួសារ ដែលស្ថិតនៅជុំវិញ
- រៀបចំលិខិតគតិយុត្តិឬប្រកាសមួយចំនួនពាក់ព័ន្ធនឹងវិស័យកៅស៊ូ និងរៀបចំកែសម្រួលនិងធ្វើបច្ចុប្បន្នភាពយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍន៍ដំណាំកៅស៊ូនៅកម្ពុជា២០១១-២០២០
- ចុះចងក្រងនិងបណ្តុះបណ្តាលដល់កសិករអំពីទីផ្សារកៅស៊ូ រៀបចំចងក្រងនិងបោះពុម្ពព្រឹត្តិបត្រកៅស៊ូធម្មជាតិ និងឯកសារបច្ចេកទេសកៅស៊ូ
- សហការជាមួយអាជ្ញាធរថ្នាក់ក្រោមជាតិ ដើម្បីចុះទប់ស្កាត់សកម្មភាពមិនស្របច្បាប់លើអាជីវកម្មជ័រកៅស៊ូ និងការនាំចេញជ័រនិងឈើកៅស៊ូមិនទាន់កែច្នៃទៅបរទេសដោយខុសច្បាប់
- ទំនាក់ទំនងកិច្ចសហប្រតិបត្តិការជាមួយសមាគមបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ ក្រុមប្រឹក្សាស្រាវជ្រាវនិងអភិវឌ្ឍន៍កៅស៊ូអន្តរជាតិ ជាពិសេសពិនិត្យគោលនយោបាយ បេសកកម្ម និងសកម្មភាពរបស់ក្រុមប្រឹក្សាកៅស៊ូត្រីភាគីអន្តរជាតិដែលស្នើសុំអញ្ជើញកម្ពុជា ឡាវ និងវៀតណាម ឲ្យចូលជាសមាជិកក្នុងក្រុមប្រឹក្សានេះ
- អនុវត្តការចុះបញ្ជិការោងចក្រកែច្នៃកៅស៊ូនិងផ្តល់លិខិតឲ្យប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា(CSR)ដល់មន្ទីរពិសោធន៍មូលដ្ឋានដើម្បីទទួលសិទ្ធិចេញវិញ្ញាបនបត្របញ្ជាក់គុណភាពកៅស៊ូ
- ពង្រឹងគុណភាពធ្វើតេស្ត និងចេញវិញ្ញាបនបត្របញ្ជាក់គុណភាពកៅស៊ូ និងការពារសិទ្ធិប្រើប្រាស់ស្លាក សញ្ញាយថាប្រភេទ CSR) តាមរយៈការធ្វើតេស្តប្រៀបធៀបមន្ទីរពិសោធន៍ក្នុងស្រុក ពង្រឹងសម្ថភាពការធ្វើតេស្ត និងការទទួលស្គាល់ជាមន្ទីរពិសោធន៍យោងនៅក្នុងតំបន់ចំពោះកៅស៊ូ TSRs ដោយសមាគមកៅស៊ូអន្តរជាតិ (IRA) តាមរយៈការចូលរួមធ្វើតេស្តអន្តរមន្ទីរពិសោធន៍ (Round Robin Crosscheck)
- តាក់តែងឯកសារបច្ចេកទេសដូចជា បច្ចេកទេស និងវិទ្យាសាស្ត្រ សៀវភៅណែនាំ និងមគ្គុទេសបច្ចេកទេស។

**ទី(៣) ផលិតកម្មនិងបសុព្យាបាល**

- រៀបចំគោលនយោបាយ ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យ ផែនការសកម្មភាព កម្មវិធីនិងគម្រោងសកម្មភាពអាទិភាពលើវិស័យផលិតកម្មសត្វនិងសុខភាពសត្វ
- រៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្តិ លើវិស័យផលិតកម្មសត្វ និងសុខភាពសត្វ ជាពិសេសពង្រឹងសមត្ថភាពមន្រ្តីរាជការផ្នែកសុខភាពសត្វ និងផលិតកម្មសត្វ ដើម្បីបង្កើនសមត្ថភាពបំពេញកិច្ចការប្រកបដោយប្រសិទ្ធភាព និងជំរុញការអភិវឌ្ឍលើផ្នែកចិញ្ចឹមសត្វគ្រប់ប្រភេទ ដោយផ្តោតលើការកែលំអពូជសត្វ បង្កាត់ពូជសត្វ ចំណីសត្វ សុខភាពសត្វ បញ្ញាបបច្ចេកវិជ្ជា និងបច្ចេកទេសជំនាញក្នុងការចិញ្ចឹម ការថែទាំសត្វ ការធ្វើអនាម័យ ដល់ប្រជាកសិករអ្នកចិញ្ចឹមសត្វ ក្នុងគោលដៅបង្កើនផលិតភាពសត្វទាំងបរិមាណ និងគុណភាព
- ជំរុញបន្ថែមទៀតលើការសាងសង់ឡជីវឧស្ម័ន ដោយធ្វើការកែទម្លាប់កសិករពីការចិញ្ចឹមសត្វការលែងមកការចិញ្ចឹមសត្វដាក់ទ្រុង
- ពង្រឹងការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ និងទប់ស្កាត់ការរីករាលដាលជំងឺឆ្លងពីសត្វទៅមនុស្ស និងពីមនុស្សទៅសត្វ ឬពីតំបន់មួយទៅតំបន់មួយទៀត តាមរយៈការអនុវត្តវិធានបសុពេទ្យរួមមានៈ ការចាក់ថ្នាំការពារសត្វ ការព្យាបាលសត្វ ការគ្រប់គ្រងជីវសុវត្ថិភាព ការធ្វើអនាម័យ និងការត្រួតពិនិត្យចលនាសត្វចេញ-ចូល និងឆ្លងកាត់ក្នុងព្រះរាជាណាចក្រកម្ពុជា។ល។
- ពង្រឹងសមត្ថភាពបន្ថែមដល់ភ្នាក់ងារសុខភាពសត្វភូមិ តាមរយៈការបណ្តុះបណ្តាល និងការបំពាក់បំប៉នបន្ថែមដល់ភ្នាក់ងារសុខភាពសត្វភូមិ និងខិតខំធ្វើយ៉ាងណាឱ្យមាននិរន្តរភាពភ្នាក់ងារសុខភាពសត្វភូមិ
- រៀបចំការលើកផែនការសម្រាប់ការផលិតវ៉ាក់សាំងសាទឹកគោ ក្របី និងពង្រឹងការគ្រប់គ្រងសត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតផលសត្វ គឺសំដៅលើការជំរុញឱ្យអាជីវករយល់ដឹងពីការអនុវត្តច្បាប់ការត្រួតពិនិត្យអនាម័យសាច់ដើម្បីធានាសុខភាពសាធារណៈ
- ជំរុញនិងបង្កើនការងារស្រាវជ្រាវ អង្កេតតាមដាន ឃ្លាំមើលលើសុខភាពសត្វ និងជំងឺឆ្លងសត្វ ដើម្បីបង្កើនសមត្ថភាពត្រួតពិនិត្យ និងទប់ស្កាត់ការរាលដាលជំងឺឆ្លងសត្វ
- ជំរុញនិងបង្កើនការងារផ្សព្វផ្សាយបច្ចេកទេសផលិតកម្ម និងសុខភាពសត្វ តាមរយៈការបណ្តុះបណ្តាល អប់រំផ្សព្វផ្សាយ និងការធ្វើបង្ហាញ ចងក្រង បោះពុម្ពឯកសារបច្ចេកទេស ផលិតកម្ម និងបសុព្យាបាល
- ជំរុញការលើកទឹកចិត្តដល់ផ្នែកឯកជន និងអ្នកវិនិយោគលើវិស័យចិញ្ចឹមសត្វ និងសេវាកម្មសុខភាពសត្វ និងជួយស្វែងរកទីផ្សារសត្វឱ្យប្រជាកសិករចិញ្ចឹមសត្វ ដោយយកចិត្តទុកដាក់បំផុត
- ចងក្រងសហគមន៍អ្នកចិញ្ចឹមសត្វ និងភ្នាក់ងារសុខភាពសត្វភូមិ
- បន្តនិងធ្វើឱ្យប្រសើរឡើងនូវកិច្ចសហប្រតិបត្តិការលើវិស័យផលិតកម្ម និងបសុព្យាបាល ជាមួយបណ្តាប្រទេសជាមិត្ត ដៃគូអភិវឌ្ឍន៍ អង្គការជាតិ អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល ស្ថាប័នពាក់ពន្ធ័ និងកិច្ចសហការជាមួយផ្នែកឯកជន

**ទី(៤) ការអភិវឌ្ឍផ្នែករុក្ខកម្ម**

- បន្តជំរុញកំណត់ព្រំប្រទល់ដែនព្រៃឈើ ធ្វើចំណាត់ថ្នាក់ និងចុះបញ្ជិកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ឱ្យមានការចូលរួមប្រកបដោយប្រសិទ្ធភាពពីគ្រប់ភាគីពាក់ព័ន្ធ ហើយត្រូវសម្រេចឱ្យបានប្រវែង១.០០០គីឡូម៉ែត្រ
- បន្តរៀបចំ អនុវត្ត និងធ្វើបច្ចុប្បន្នភាពផែនការសកម្មភាពគ្រប់គ្រងព្រៃឈើ នៅគ្រប់កម្រិតនៃរដ្ឋបាលព្រៃឈើ ដោយធ្វើការសិក្សាសារពើភ័ណ្ឌវាយតម្លៃធនធានព្រៃឈើ និងរៀបចំព្រៃគុបដេញថ្លៃសម្រាប់ផ្គត់ផ្គង់តម្រូវការប្រើប្រាស់ផល អនុផលព្រៃឈើក្នុងស្រុក រួមទាំងព្រៃគុបក្នុងតំបន់អាងទំនប់វារីអគ្គិសនីនានា ដូចជា វារីអគ្គិសនីឬស្សីជ្រុំ សេសាន២ តាតៃ...។ល។
- បន្តពង្រឹងការអនុវត្តច្បាប់និងអភិបាលកិច្ច ដោយធ្វើការផ្សព្វផ្សាយច្បាប់ បទបញ្ជា លិខិតបទដ្ឋាន ពាក់ព័ន្ធនឹងវិស័យព្រៃឈើ (ច្បាប់ស្តីពីព្រៃឈើ បទបញ្ជាលេខ០១-០២សជណ និងអនុសាសន៍របស់ **សម្តេចអគ្គមហាសេនាបតី**

តេជោ **ហ៊ុន សែន** ព្រមទាំងចាត់វិធានការស៊ើបអង្កេតស្រាវជ្រាវ ចុះល្បាត ទប់ស្កាត់ និងបង្ក្រាបបទល្មើស ឱ្យបានទាន់ពេលវេលា

- គ្រប់គ្រងនិងពង្រឹងការងារប្រមូលចំណូលពីព្រៃឈើនៅតាមបណ្ដាដីសម្បទានសេដ្ឋកិច្ច ដែលត្រូវឈូសឆាយសំអាតដីព្រៃ ដោយប្រមូលផលអនុផលព្រៃឈើដែលឈូសឆាយបានមកបង់ថ្លៃសួយសារ បុព្វលាភរួចកែច្នៃប្រើប្រាស់ឲ្យអស់លទ្ធភាព
- ជំរុញដាក់ឱ្យដេញថ្លៃជាសាធារណៈចំពោះវត្ថុតាងបទល្មើសព្រៃឈើ ដែលបានរឹបអូសតាមសាលក្រមរបស់តុលាការ ពិន័យអន្តរការណ៍រួច
- បន្តតាមដានត្រួតពិនិត្យ និងវាយតម្លៃប្រសិទ្ធភាពនៃកម្មវិធី ដោយលើកកម្ពស់កម្រិតជីវភាពប្រជាជននៅតំបន់ជនបទ ស្ថិរភាពធនធានព្រៃឈើ និងការពង្រីកសហគមន៍ព្រៃឈើឱ្យបានកាន់តែទូលំទូលាយ ដោយរៀបចំបែបបទទទួលស្គាល់ជាផ្លូវការ និងអភិវឌ្ឍសហគមន៍ព្រៃឈើថ្មីចំនួន១០០កន្លែងបន្ថែមទៀត
- ផ្ដល់ការលើកទឹកចិត្តដល់គ្រប់មជ្ឈដ្ឋាន រួមទាំងវិស័យឯកជនចូលរួមដាំដុះដើមឈើបង្កើតជាចម្ការព្រៃដាំ ដែលផ្ដល់ផលប្រយោជន៍ច្រើនយ៉ាង ដោយមានបទដ្ឋានបច្ចេកទេសច្បាស់លាស់ នៅក្នុងតំបន់ព្រៃរេចរឹល តាមរយៈបង្កើនការដាំដុះព្រៃឈើ ការចែកកូនឈើជូនប្រជាពលរដ្ឋសម្រាប់ដាំតាមគេហដ្ឋាន តាមទីសាធារណៈ វត្តអារាម រៀបចំប្រារព្ធបុណ្យរុក្ខទិវា៩កក្កដាទូទាំងប្រទេស រៀបចំបង្កើតស្ថានីយផ្សព្វផ្សាយនិងស្ដារព្រៃឈើ ថ្នាលបណ្ដុះកូនឈើ សួនដាំឈើអនុស្សាវរីយ៍ សួនអាពាហ៍ពិពាហ៍ និងបន្តអភិវឌ្ឍគុណភាពសេណេទិចពូជ និងបច្ចេកទេសដាំដុះឱ្យកាន់តែមានប្រសិទ្ធភាព...។ល។
- បង្កើនប្រសិទ្ធភាពគ្រប់គ្រងព្រៃការពារ តាមរយៈការរៀបចំផែនការគ្រប់គ្រង និងធ្វើការអភិវឌ្ឍសេវាកម្មបរិស្ថាន រួមទាំងទេសចរណ៍ធម្មជាតិ និងឥណទានកាបូនព្រៃឈើ ដើម្បីបង្កើតការងារនិងប្រភពចំណូលបន្ថែមជូនប្រជាជន និងចូលរួមក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ពិភពលោកក្នុងការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ និងការកើនឡើងកំដៅនៃភពផែនដី
- បន្តសហការជាមួយដៃគូនានាអនុវត្តគម្រោងការបណ្ដុះបណ្ដាលពង្រឹងសមត្ថភាពរដ្ឋបាលព្រៃឈើ និងភាគីពាក់ព័ន្ធតាមរយៈការបង្កើតប្រព័ន្ធចែករំលែកព័ត៌មាន និងរៀបចំវគ្គបណ្ដុះបណ្ដាលចាំបាច់នានា រួមទាំងប្រព័ន្ធព័ត៌មានភូមិសាស្ត្រព្រៃឈើ (GIS) និងបំពាក់សម្ភារដល់អង្គភាពរដ្ឋបាលព្រៃឈើមូលដ្ឋាន ឱ្យមានលទ្ធភាពផលិតផែនទីប្រើប្រាស់ដោយខ្លួនឯង
- បន្តលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការអប់រំផ្សព្វផ្សាយព្រៃឈើ បង្កើនសកម្មភាពសិក្សាស្រាវជ្រាវនិងអភិវឌ្ឍព្រៃឈើសត្វព្រៃ តាមរយៈការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពស្រាវជ្រាវបង្កើតតំបន់ ឬស្ថានីយស្រាវជ្រាវព្រៃឈើ សត្វព្រៃ និងបន្តពង្រីកការអនុវត្តគម្រោងការស្រាវជ្រាវនានា ជាមួយដៃគូអភិវឌ្ឍន៍ដែលមានស្រាប់និងស្វែងរកដៃគូថ្មីៗទៀត ស្របតាមតម្រូវការអភិវឌ្ឍរបស់សង្គមជាតិ និងអន្តរជាតិ
- បន្តកំណត់តំបន់ព្រៃឈើរេចរឹល ដើម្បីធ្វើការស្ដារព្រៃឈើឡើងវិញ ឱ្យក្លាយជាតំបន់ព្រៃឈើមានតម្លៃពាណិជ្ជកម្មដោយធ្វើការដាំដុះប្រភេទឈើប្រណិតមានតម្លៃ និងថែរក្សាការពារចម្ការព្រៃពូជ និងប្រមូលពូជឈើ
- បន្តកសាងហេដ្ឋារចនាសម្ព័ន្ធ ការិយាល័យ កន្លែងស្នាក់អាស្រ័យ រៀបចំធនធានមនុស្ស និងលិខិតបទដ្ឋានក្រោមច្បាប់ដើម្បីអនុវត្តរចនាសម្ព័ន្ធរដ្ឋបាលព្រៃឈើថ្មីតាមអនុក្រឹត្យលេខ១៨៨អន.ក្រ ចុះថ្ងៃទី១៤-១១-២០០៨ និងធ្វើបច្ចុប្បន្នភាពសេចក្ដីព្រាងអនុក្រឹត្យស្ដីពី សម្លៀកបំពាក់ឯកសណ្ឋាន សញ្ញាសម្គាល់ និងឋានន្តរសក្តិរបស់មន្ត្រីរដ្ឋបាលព្រៃឈើ
- បន្តបង្កើនកិច្ចសហប្រតិបត្តិការល្អជាមួយស្ថាប័ន សមត្ថកិច្ច និងភាគីពាក់ព័ន្ធនានា ជាពិសេសអ្នកសារព័ត៌មាន និងព្រះរាជអាជ្ញាឱ្យជួយគាំទ្រដល់ការងារពង្រឹងការអនុវត្តច្បាប់ប្រកបដោយតម្លាភាពនិងប្រសិទ្ធភាពខ្ពស់។ កិច្ច

សហប្រតិបត្តិការអន្តរជាតិ ក្នុងតំបន់ និងជាមួយប្រទេសជិតខាង ក៏នឹងត្រូវបានយកចិត្តទុកដាក់ពង្រឹងពង្រីកជាប្រចាំ តាមរយៈកិច្ចសហការទ្វេភាគី និងការចូលរួមអនុវត្តកម្មវិធីតំបន់ឬអន្តរជាតិ ។

**ទី(៥) ការអភិវឌ្ឍផ្នែកជលផល**

– ខិតខំបន្តអនុវត្តអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ***"ធ្វើឱ្យទីណាមានទឹក ទីនោះមានត្រីឡើងវិញ"***

– ពង្រឹងសមត្ថភាពមន្ត្រីរដ្ឋបាលជលផលឱ្យកាន់តែប្រសើរឡើង តាមរយៈការរៀបចំវគ្គបណ្តុះបណ្តាលជំនាញរយៈពេលខ្លី និងវែងទាំងក្នុងនិងក្រៅប្រទេស ដោយរួមទាំងអ្នកនេសាទ សហគមន៍នេសាទ និងអ្នកចិញ្ចឹមត្រីផងដែរ ដើម្បីធានានិរន្តរភាពធនធានជលផល

– បន្តការងារសហប្រតិបត្តិការជាមួយអង្គការជាតិនិងអន្តរជាតិ ដើម្បីគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព

– បន្តជំរុញការត្រួតពិនិត្យនិងបង្ក្រាបបទល្មើសជលផលនៅទូទាំងប្រទេស

– រៀបចំបោះបង្គោលបេតុងតាមព្រំប្រទល់កន្លែងអភិរក្សទាំង៥០កន្លែង និងបង្កើតស្នាក់ការល្បាតនៅទីតាំងសំខាន់ៗ ចំនួន៤៣កន្លែង

– បន្តពង្រឹងសមត្ថភាពសហគមន៍នេសាទនៅទូទាំងប្រទេស ដោយរៀបចំសហគមន៍គំរូគ្មានបទល្មើស និងសម្របសម្រួលការដាក់របាំងធ្នូស សហគមន៍នេសាទតាមព្រំដែន

– រៀបចំផ្លូវភ្លើងនិងប៉មយាមសម្រាប់ត្រួតពិនិត្យភ្លើងឆេះព្រៃ

– បន្តបង្កើត និងពង្រឹងសហគមន៍ស្រះជម្រកត្រីបន្ថែមទៀតឱ្យបានគ្រប់ឃុំ

– បន្តរៀបចំទិវាមច្ឆជាតិ១កក្កដារៀងរាល់ឆ្នាំ សំដៅបង្កើនការយល់ដឹងពីអំពី សារៈសំខាន់នៃធនធានជលផល ដោយលែងកូនបង្កងឱ្យបានច្រើនជាអតិបរិមា (៦-១០លានក្បាល)

**ទី(៥) ទិសដៅផ្នែកសេវាកម្មគាំទ្រ**

– ជំរុញកិច្ចសហការជិតស្និទ្ធជាមួយក្រសួងផែនការ ក្នុងដំណើរការធ្វើជំរឿនកសិកម្មជាតិលើកទី១ក្នុងព្រះរាជាណាចក្រកម្ពុជា

– ជំរុញបន្តអនុវត្តផែនការសកម្មភាព ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) ២០០៩-២០១៣ ភ្ជាប់យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ របស់រាជរដ្ឋាភិបាល គោលនយោបាយជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ និងយុទ្ធសាស្ត្រកសិកម្មនិងទឹក

– ជំរុញរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០១៤-២០១៨ សិក្សាលទ្ធភាពនៃការរៀបចំកសាងផែនការមេសម្រាប់អភិវឌ្ឍន៍វិស័យកសិកម្មរយៈពេលមធ្យមនិងវែង ២០១៤-២០៣៤

– ជំរុញការអនុវត្តប្រព័ន្ធផែនការផ្ទៃក្នុង (Internal Planning) និងការកសាងផែនការថវិកា ដោយផ្អែកតាមកម្មវិធី (Program Budgeting) នៃក្របខណ្ឌផែនការយុទ្ធសាស្ត្រ (BSP) របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីប្រើប្រាស់ទុនវិនិយោគរបស់រដ្ឋ ឱ្យចំទិសដៅអាទិភាព និងមានប្រសិទ្ធភាពខ្ពស់

– បន្តកិច្ចសហការជាមួយស្ថាប័ន និងអង្គភាពពាក់ពន្ធ័ពិនិត្យដោះស្រាយទំនាស់ផ្សេងៗ ក្នុងតំបន់វិនិយោគសម្បទានដីសេដ្ឋកិច្ច ដែលមានគោលការណ៍ និងចុះកិច្ចសន្យាជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងបន្តជំរុញឱ្យក្រុមហ៊ុនវិនិយោគសម្បទានដីសេដ្ឋកិច្ច គោរពតាមកិច្ចសន្យា ផែនការមេ និងការណែនាំរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

– បន្តការសហការជាមួយអង្គភាពជំនាញ ដើម្បីពិនិត្យលើការយកថ្លៃសម្បទានពីក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ចដែលដល់កំណត់ពេលត្រូវយកថ្លៃសម្បទាន

– បន្តជំរុញឱ្យក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច ចុះបញ្ជីដីជាដីឯកជនរបស់រដ្ឋ ចំពោះក្រុមហ៊ុនណាដែលពុំបានធ្វើ

– បន្តធ្វើបច្ចុប្បន្នភាពលើការរៀបចំ ចងក្រង ប្រមូលព័ត៌មាន និងទិន្នន័យគម្រោង ដែលផ្តល់ហិរញ្ញប្បទាន សហប្រតិបត្តិការរបស់ដៃគូអភិវឌ្ឍន៍ និងត្រៀមលក្ខណៈចុះត្រួតពិនិត្យ តាមដាន និងវាយតម្លៃ

- ជំរុញការរៀបចំ និងបន្តយន្តការតាមដានល្បឿនការងារបង្កបង្កើនផលឆ្នាំ២០១៣ នៅតាមបណ្តារាជធានី ខេត្តទូទាំងប្រទេស និងពង្រឹងសមត្ថភាពត្រួតពិនិត្យ លើការងារស្ថិតិកសិកម្មពីថ្នាក់កណ្តាលដល់មូលដ្ឋាន ដើម្បីសម្រួលដល់ការប្រមូល បញ្ចូល វិភាគ និងចងក្រងទិន្នន័យស្ថិតិកសិកម្មប្រចាំឆ្នាំ
- ជំរុញយន្តការការធ្វើអង្កេតស្ទង់ទិន្នផលដំណាំស្រូវ អង្កេតដំណាំផ្សេងៗ ដំណាំអចិន្ត្រៃយ៍ និងការប្រមូលទិន្នន័យប្រព័ន្ធព័ត៌មាន ស្ថិតិកសិកម្ម ដើម្បីឱ្យប្រព័ន្ធស្ថិតិកសិកម្មមានតម្លាភាព និងនិរន្តរភាព
- បង្កើនសមត្ថភាពបច្ចេកទេស ក្នុងការប្រមូល កែច្នៃ និងផ្ទៀងផ្ទាត់ទិន្នន័យ ស្ថិតិឱ្យមានតម្លាភាព និងប្រសិទ្ធភាពល្អប្រសើរ សម្រាប់អ្នកប្រើប្រាស់ស្រាវជ្រាវរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ
- ខិតខំជំរុញនិងកិច្ចសហការជាមួយក្រសួងផែនការ (វិទ្យាស្ថានជាតិស្ថិតិ) និងអង្គការ FAO ជាមួយដៃគូអភិវឌ្ឍនានា ដើម្បីអនុវត្តគម្រោងធ្វើអង្កេត និងដំណើរការជំរឿនកសិកម្មឆ្នាំ២០១៣
- បន្តជំរុញការអនុវត្តសេវាព័ត៌មានទីផ្សារកសិកម្មរាជធានី ខេត្ត ធ្វើការវិភាគកែច្នៃព័ត៌មានទីផ្សារកសិកម្មឱ្យកាន់តែល្អប្រសើរឡើង ដើម្បីចងក្រងព្រឹត្តិប័ត្រប្រចាំខែ ប្រចាំឆ្នាំ ជាមូលដ្ឋានសម្រាប់ផ្សព្វផ្សាយបន្តដល់ប្រជាកសិករនៅតាមជនបទ ពង្រឹងគុណភាពការប្រមូលព័ត៌មានតម្លៃកសិផលនិងធ្វើឱ្យមានភាពជឿជាក់ និងធានាឱ្យបានថាព័ត៌មានទីផ្សារកសិផលនឹងទៅដល់កសិករនៅថ្នាក់ភូមិឃុំ និងបន្តជំរុញការផ្សព្វផ្សាយព័ត៌មានទីផ្សារតាមរយៈគេហទំព័រ ទូរទស្សន៍ វិទ្យុ និងបោះពុម្ពខិត្តប័ណ្ណ និងពិនិត្យតាមដានការប្រមូលព័ត៌មានថ្លៃទីផ្សារនៅតាមរាជធានី ខេត្ត និងសិក្សាបញ្ហាទីផ្សារដែលធ្វើឱ្យមានឥទ្ធិពលដល់ការប្រែប្រួលតម្លៃរបស់ផលិតផល។
- បន្តរៀបចំបទដ្ឋានគតិយុត្តក្រោមច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម សម្រាប់កម្មវិធីនីតិកម្មឆ្នាំ២០១៣ និងត្រៀមដាក់ឆ្លងការពិភាក្សានិងពិនិត្យសម្រេចនូវសេចក្តីព្រាងបទដ្ឋាន គតិយុត្តដែលនាយកដ្ឋាននីតិកម្មកសិកម្មបានសិក្សារៀបចំរួចក្នុងឆ្នាំ២០១២កន្លងមក
- ជំរុញការចូលរួមនិងការអភិវឌ្ឍបទដ្ឋានគតិយុត្តវិស័យកសិកម្ម ជាពិសេសសេចក្តីព្រាងច្បាប់សំខាន់ៗមួយចំនួនក្នុងក្របខណ្ឌសុវត្ថិភាពស្បៀង និងបន្តអនុវត្តនីតិវិធី និងពង្រឹងសមត្ថភាពក្នុងការអនុវត្តអនុសញ្ញារ៉ូថឺដាមស្តីពី នីតិវិធីនៃការយល់ព្រមផ្តល់ព័ត៌មានជាមុន ចំពោះសារធាតុគីមីនិងថ្នាំកសិកម្មគ្រោះថ្នាក់ក្នុងពាណិជ្ជកម្មអន្តរជាតិ
- ពង្រឹងសមត្ថភាពរបស់មន្ត្រីនីតិកម្មកសិកម្ម ក្នុងការបំពេញតួនាទីជាមន្ត្រីអធិការកិច្ចថ្នាំកសិកម្ម និងជីកសិកម្ម លើកកម្ពស់សមត្ថភាពក្នុងការអនុវត្តនីតិវិធីធ្វើអធិការកិច្ច ការត្រួតពិនិត្យបទល្មើសពាក់ព័ន្ធថ្នាំកសិកម្មនិងជីកសិកម្ម និងជំរុញការធ្វើអធិការកិច្ចនិងពង្រឹងការអនុវត្តច្បាប់ ចំពោះសកម្មភាពពាណិជ្ជកម្មគ្រប់រូបភាពនៅរាជធានី ខេត្តទូទាំងប្រទេស
- បន្តអនុវត្តកម្មវិធីផ្សព្វផ្សាយថ្នាក់ក្រោមជាតិនិងថ្នាក់មូលដ្ឋាននូវច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម ដោយយកចិត្តទុកដាក់ចំពោះខេត្តគោលដៅ និងស្រុក ក្រុង ចំណុះខេត្តគោលដៅនិងជំរុញការអនុវត្តនីតិវិធីក្នុងការផ្សាយពាណិជ្ជកម្មគ្រប់រូបភាពអំពី សម្ភារកសិកម្មរបស់ផ្នែកឯកជន ជាពិសេសការផ្សាយពាណិជ្ជកម្មថ្នាំកសិកម្ម និងជីកសិកម្ម
- បន្តពង្រឹងសមត្ថភាពមន្ទីរពិសោធន៍វិភាគគុណភាពជីកសិកម្ម ដើម្បីវិភាគសារធាតុលោហៈធ្ងន់នៅក្នុងជីកសិកម្ម ដែលជាសារធាតុបង្កគ្រោះថ្នាក់សម្រាប់ការស្នើសុំចុះបញ្ជីជីកសិកម្ម
- សម្របសម្រួលក្នុងការបង្កើតសមាគមពាណិជ្ជករសម្ភារកសិកម្មកម្ពុជា (C.A.M.T.A) ដើម្បីលើកកម្ពស់ការសម្របសម្រួល និងកិច្ចសហការរវាងក្រុមហ៊ុនពាណិជ្ជកម្មសម្ភារកសិកម្ម ជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងលើកកម្ពស់ការចូលរួមរបស់សមាជិកសមាគម ក្នុងការអនុវត្តក្រមសីលធម៌ក្នុងពាណិជ្ជកម្មសម្ភារកសិកម្ម
- ពង្រឹងការអនុវត្តភារកិច្ចសវនកម្មតាមច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យលេខ៤០អនក្រ.បក ចុះថ្ងៃទី១៥ខែកុម្ភៈឆ្នាំ២០០៥របស់រាជរដ្ឋាភិបាលកម្ពុជា
- ចុះធ្វើសវនកម្មតាមផែនការសកម្មភាពសវនកម្មប្រចាំឆ្នាំ២០១៣ ដែលបានអនុម័ត និងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរសវនកម្មជាតិនិងសវនកម្មផ្ទៃក្នុងតាមស្ថាប័ននានា

- បន្តរៀបចំលិខិតបទដ្ឋានក្រោមអនុក្រឹត្យ និងផ្សព្វផ្សាយជាសាធារណៈអំពីយន្តការនៃការអនុវត្តអនុក្រឹត្យលេខ៣៦ អនក្រ ស្តីពី “ផលិតកម្មកសិកម្មតាមកិច្ចសន្យា” និងបន្តទំនាក់ទំនងនិងសហការជាមួយដៃគូអភិវឌ្ឍន៍នានា លើការអនុវត្តយន្តការផលិតកម្មកសិកម្មតាមកិច្ចសន្យា និងភាពជាដៃគូ រវាងគ្រួសារកសិករខ្នាតតូច និងក្រុមហ៊ុនវិនិយោគខ្នាតធំលើវិស័យកសិឧស្សាហកម្ម
- បន្តអនុវត្តតាមអនុសាសន៍របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្នុងការផ្សព្វផ្សាយពីអនុសញ្ញាលុបបំបាត់ទម្រង់នៃការរើសអើងប្រឆាំង និងស្ត្រីភេទ និងឯកសារដែលពាក់ព័ន្ធឱ្យបានទូលំទូលាយក្នុងវិស័យកសិកម្ម និងបន្តអនុវត្តទិសដៅទាំង៤នៃគោលនយោបាយនិងយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្ម ឱ្យទទួលបានលទ្ធផលល្អប្រសើរតាមផែនការកំណត់។
- បន្តយកចិត្តទុកដាក់លើការសិក្សាស្រាវជ្រាវ និងកសាងគោលការណ៍ លិខិតបទដ្ឋានណែនាំជាសារាចរ សេចក្តីណែនាំអំពីការងារគ្រប់មន្ត្រីរាជការ និងរៀបចំបែបបទការអនុវត្តជាក់ស្តែង ក្នុងការគ្រប់គ្រងធនធានមនុស្សឱ្យល្អប្រសើរតាមប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យាដោយចងក្រងតាមកំរិតសញ្ញាបត្រ មុខជំនាញ និងតាមមុខតំណែង ដើម្បីជាឯកសារសម្រាប់ក្រសួងប្រើប្រាស់
- បន្តរៀបចំសម្របសម្រួលការងារកសាងគោលការណ៍ លិខិតបទដ្ឋាន សេចក្តីសម្រេចនិងប្រកាសជូនអង្គភាពពាក់ព័ន្ធសម្រាប់ពង្រឹងលើការងារបណ្តុះបណ្តាលធនធានមនុស្ស ដោយលើកគម្រោងបញ្ជូនមន្ត្រីរាជការទៅសិក្សារយៈពេលវែង មធ្យម ខ្លីនៅក្នុងនិងក្រៅប្រទេស តាមជំនាញឱ្យបានច្រើន
- រៀបចំឯកសារដាក់មន្ត្រីឱ្យចូលនិវត្តន៍ឱ្យបានទាន់ពេលវេលា និងបន្តការងារដែលនៅសេសសល់ ពិនិត្យនិងកែលំអលើការងាររៀបចំរចនាសម្ព័ន្ធ សេចក្តីព្រាងប្រកាសស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទក្រសួង និងជំរុញការរៀបចំភារកិច្ចរបស់មណ្ឌលកសិកម្មឃុំ សង្កាត់
- ចុះត្រួតពិនិត្យជាក់ស្តែងការប្រើប្រាស់ក្របខណ្ឌមន្ត្រីរាជការ បុគ្គលិកកិច្ចសន្យា និងពលករអណ្តែតនៅតាមអង្គភាពថ្នាក់កណ្តាលនិងរាជធានី ខេត្ត
- ពង្រឹងការងារបញ្ជិកាគណនេយ្យនៅតាមបណ្តាមន្ទីរកសិកម្មរាជធានី ខេត្ត និងបណ្តាអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចុះត្រួតពិនិត្យ និងបិទបញ្ជីគណនេយ្យការិយបរិច្ឆេទឆ្នាំមុន កំណត់ទុនគ្រាដំបូងនៅតាមគ្រឹះស្ថានសាធារណៈរដ្ឋបាលទាំងបួន ស្ថិតក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ
- សហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីចូលរួមពិនិត្យ និងផ្ទៀងផ្ទាត់តារាងប្រៀបធៀបទ្រព្យសម្បត្តិរដ្ឋ នៅតាមមន្ទីរកសិកម្មរាជធានី-ខេត្ត និងអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បន្តខិតខំប្រឹងប្រែងរៀបចំឯកសារកិច្ចលទ្ធកម្មសាធារណៈឱ្យបានទាន់ពេលវេលា បន្ទាប់ពីទទួលបានលិខិតគោលការណ៍ធានាចំណាយរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរៀបចំកសាងផែនការលទ្ធកម្មប្រចាំឆ្នាំ២០១៣ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរៀបចំនិងអនុវត្តនូវគម្រោងកិច្ចលទ្ធកម្មសម្រាប់ឆ្នាំ២០១៣ នៅពេលទទួលបានគោលការណ៍ធានាចំណាយពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ជួយរៀបចំឱ្យដំណើរការនូវគម្រោងនានាដែលត្រូវការថវិកាបដិភាគ និងបន្តសហការចូលរួមកិច្ចលទ្ធកម្មគម្រោងហិរញ្ញប្បទាន
- បន្តចូលរួមអនុវត្តសកម្មភាពកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ PFM/MAP របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## ៨. ការវាយតម្លៃនិងសន្និដ្ឋាន

លទ្ធផលការងារក្នុងវិស័យកសិកម្មឆ្នាំ២០១២-២០១៣ ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាល ដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាប្រមុខនិងដោយការខិតខំប្រឹងប្រែងយ៉ាងសកម្មរបស់ថ្នាក់ដឹកនាំក្រសួង មន្ត្រី

រាជការ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមានការចូលរួមពីក្រសួង ស្ថាប័នជាតិ អន្តរជាតិ ព្រមទាំងដៃគូអភិវឌ្ឍផង នោះ បានបង្ហាញឱ្យឃើញពីវឌ្ឍនភាពការងារផលិតកម្មអាជីវកម្មនិងសេវាកម្មកសិកម្ម ដោយទទួលបាននូវការរីកចម្រើនលើគ្រប់ផ្នែកជាពិសេសលើការងារផលិតកម្មដំណាំស្រូវ ដែលមានការកើនឡើងខ្ពស់លើសឆ្នាំមុន។ ក្នុងឆ្នាំ២០១២នេះ បើទោះបីជាបានជួបប្រទះនូវគ្រោះធម្មជាតិ ជាពិសេសកង្វះខាតទឹកនៅកណ្តាលរដូវវស្សា បានអូសបន្លាយមានរយៈពេលវែង ចាប់ពីចុងខែមិថុនា រហូតដល់សប្តាហ៍ទី២នៃខែកញ្ញា ឆ្នាំ២០១២ និងមានជំនន់ទឹកភ្លៀងចាប់ពីសប្តាហ៍ទី៣នៃខែកញ្ញា រហូតដល់ដើមសប្តាហ៍ទី១នៃខែវិច្ឆិកាឆ្នាំ២០១២យ៉ាងណាក្តី ប៉ុន្តែជាក់ស្តែងស្ថានភាពផលិតកម្មកដំណាំស្រូវរដូវវស្សាឆ្នាំ២០១២នេះ ជារួមមានកម្រិតល្អទូទាំងប្រទេស។ សរុបការដាំដុះស្រូវទាំងរដូវវស្សានិងរដូវប្រាំង អនុវត្តបានលើផ្ទៃដីសរុបប្រមាណ**៣លានហត** ដោយទទួលបរិមាណផលសរុបប្រមាណ**៩,២៩លានតោន**ស្រូវ ដែលមានទិន្នផលមធ្យមប្រចាំឆ្នាំ**៣,១២ត/ហត**។ ដូច្នេះតុល្យភាពស្បៀងនៅសល់ប្រមាណ**៣លានតោនអង្ករ** គិតជាស្រូវប្រមាណ **៤,៦៩លានតោន** លើសឆ្នាំមុន៣៥.០០០តោនស្រូវ និងខ្ពស់ជាងមធ្យមភាគ១០ឆ្នាំ កន្លងមកប្រមាណ១,២លានតោនអង្ករ ដែលនេះជាជោគជ័យមួយធំធេងណាស់។

តួលេខខាងលើត្រូវបានវាយតម្លៃ ពីភាពជោគជ័យនៃកំណើនផលិតផលស្រូវ ដែលបានកើនលើសក្នុងសូចនាករផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០០៩-២០១៣ ដែលបានកំណត់ថារហូតដល់ឆ្នាំ២០១៣ ទិន្នផលស្រូវនឹងបានកើនឡើងដល់៣,០០ត/ហត។ កំណើនទិន្នផលស្រូវនេះ គឺដោយសារមានការយកចិត្តទុកដាក់យ៉ាងខ្លាំងពីប្រមុខរាជរដ្ឋាភិបាល ថ្នាក់ដឹកនាំក្រសួង មន្ត្រីរាជការក្រោមឱវាទគួបផ្សំនឹងអាកាសធាតុអំណោយផលល្អនាចុងរដូវ ព្រមទាំងប្រជាកសិករមានការយល់ដឹងក្នុងការគ្រប់គ្រងថែរក្សា ស្រែចំការ ការផ្លាស់ប្តូរបច្ចេកទេស និងការផ្លាស់ប្តូរពូជដែលមានបរិមាណទិន្នផលខ្ពស់។

ការនាំចេញអង្ករទៅកាន់ទីផ្សារអន្តរជាតិ ដែលជាលទ្ធផលនៃការអនុវត្តគោលនយោបាយជំរុញផលិតកម្មស្រូវ និងនាំចេញអង្កររបស់រាជរដ្ឋាភិបាលកម្ពុជា ក៏មានវឌ្ឍនភាពគួរជាទីពេញចិត្តជាមួយនិន្នាការកើនឡើងជាលំដាប់។ ជាក់ស្តែងក្នុងនោះនៅឆ្នាំ២០១២កម្ពុជានាំអង្ករចេញប្រមាណ២០ម៉ឺនតោនទៅកាន់ទីផ្សារ៥៧ប្រទេស និងនៅត្រីមានទី១ ឆ្នាំ ២០១៣ នាំចេញអង្ករបានប្រមាណ៩៥ពាន់តោន។

ទន្ទឹមនឹងការកើនឡើងខ្ពស់នូវបរិមាណផលស្រូវលើសពីតម្រូវការ ការចិញ្ចឹមសត្វ ការចិញ្ចឹមត្រី ការគ្រប់គ្រង និងដាំដុះព្រៃឈើ ការអភិវឌ្ឍដំណាំកសិ-ឧស្សាហកម្ម ជាពិសេសដំណាំកៅស៊ូគ្រួសារនិងដំណាំកៅស៊ូឯកជន ត្រូវបានកើនឡើងគួរជាទីមោទនៈ។ កំណែទម្រង់ផ្តាច់ព្រំត្រលើវិស័យជលផល បាននិងកំពុងផ្តល់ផ្លែផ្កាតាមរយៈការចូលរួមចំណែកយ៉ាងសំខាន់ដល់ការកាត់បន្ថយកម្រិតអតិផរណានៅកម្ពុជា ទន្ទឹមនឹងសន្តិសុខនិងសុវត្ថិភាពដីធ្លីត្រូវបានផ្តល់ជូនប្រជាពលរដ្ឋកម្ពុជាទូទាំងប្រទេស ដែលជាបុរេលក្ខខណ្ឌដ៏សំខាន់មួយក្នុងការបង្កើតនូវវឌ្ឍនភាព នៃផលិតកម្មដំណាំនិងការចិញ្ចឹមសត្វនិយាយដោយឡែក និងការអភិវឌ្ឍវិស័យកសិកម្មនិយាយជារួម។ រីឯការងារសេវាកម្មផ្សេងៗរួមមានការងារសេវាកម្មបច្ចេកទេស និងការងារសេវាកម្ម រដ្ឋបាលគ្រប់គ្រងបុគ្គលិក បណ្តុះបណ្តាលអភិវឌ្ឍន៍ធនធានមនុស្ស ការងារគោលនយោបាយផែនការហិរញ្ញវត្ថុ ក៏ត្រូវបានពង្រឹងនិងកែលម្អប្រកបដោយប្រសិទ្ធភាពខ្ពស់ ស្របតាមស្ថានភាពជាក់ស្តែងនៃការអភិវឌ្ឍជាសកល។

រាជធានីភ្នំពេញ, ថ្ងៃទី ខែមេសា ឆ្នាំ២០១៣

**រដ្ឋមន្ត្រី**